# បទបញ្ញាហិរញ្ញវត្ថុនយោបាយៈ
# បទពិសោធន៍នានាលើពិភពលោក



IFES
International Foundation
for Electoral Systems

ការបោះពុម្ពនេះអាចធ្វើទៅបានដោយមានការគាំទ្រផ្នែកថវិកាពីសំណាក់ប្រជាពលរដ្ឋអាមេរិច តាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិចសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID)។ រាល់ខ្លឹមសារដែលមាននៅក្នុងសៀវភៅនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) និងមិនឆ្លុះបញ្ចាំងជាចាំបាច់នូវទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិចសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) និង រដ្ឋាភិបាលសហរដ្ឋអាមេរិចទេ។

USAID
ជំនួយពីពលរដ្ឋអាមេរិក

# បទបញ្ញាហិរញ្ញវត្ថុនយោបាយ៖ បទពិសោធន៍នានាពីជុំវិញពិភពលោក

កែសម្រួលដោយ៖ បណ្ឌិត ម៉ាកណឹស អូមែន និង ហានី ហៃ្យនូហៃ

រក្សាសិទ្ធិគ្រប់យ៉ាងដោយៈ មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES)

ទីស្នាក់ការកណ្តាលៈ 1850 K Street, NW
Fifth Floor
រដ្ឋធានីវ៉ាស៊ីនតោន នៃសហរដ្ឋអាមេរិច

ការិយាល័យប្រចាំប្រទេសកម្ពុជាៈ ផ្ទះលេខ ១៦៦ ផ្លូវ៥១ សង្កាត់បឹងកេងកង១ ភ្នំពេញ

គ្មានផ្នែកណាមួយនៃសៀវភៅនេះអាចត្រូវបានផលិតជាថ្មី ឬ ថតចម្លងបាននោះទេទោះក្នុងរូបភាពណាមួយក៏ដោយ ទោះតាមមធ្យោបាយណាមួយក៏ដោយ ដោយពុំមានការអនុញ្ញាតជាមុនពីមូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) ។

# មាតិកា


អារម្ភកថា

សេចក្តីថ្លែងអំណរគុណ

អំពីអ្នកនិពន្ធ

សេចក្តីផ្តើម

ជំពូក ១

ដំណោះស្រាយជាក់ស្តែងសម្រាប់ការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយសម្រាប់យុទ្ធនាការឃោសនា និង ហិរញ្ញវត្ថុរបស់គណបក្សនយោបាយ

ដោយ៖ ជែក សានទូស៊ី និង បណ្ឌិត ម៉ាកណឹស អូមែន(Jack Santucci & Magnus Ohman)

ជំពូក ២

ដំណោះស្រាយជាក់ស្តែងសម្រាប់ការដាក់ដែនកំណត់ទៅលើចំណាយ

ដោយ៖ ម៉ាកស៊ីន វ៉ាឡេគី (Marcin Walecki)

ជំពូក ៣

ដំណោះស្រាយជាក់ស្តែងសម្រាប់ការធ្វើហិរញ្ញប្បទានសាធារណៈដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោត

ដោយ៖ បណ្ឌិត ម៉ាកណឹស អូមែន (Magnus Ohman)

ជំពូក ៤

ដំណោះស្រាយជាក់ស្តែង សម្រាប់ការអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយ និង ការត្រួតពិនិត្យ

ដោយ៖ ហានី ហៃនូហៃ (Hani Zainulbhai)

សេចក្តីសន្និដ្ឋាន

ដោយបណ្ឌិត៖ ម៉ាកណឹស អូមែន (Magnus Ohman)

សទ្ទានុក្រមហិរញ្ញវត្ថុនយោបាយ

# បញ្ជីតារាងសំខាន់ៗ

*សេចក្ដីផ្ដើម*


តារាង ១៖ បណ្ដុំទស្សនទានសំខាន់ៗស្ដីពីហិរញ្ញវត្ថុនយោបាយ

តារាង ២៖ ការគាំទ្រដល់បណ្ដុំទស្សនទានសំខាន់ៗនៅក្នុងកាតព្វកិច្ចអន្តរជាតិ


*ការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយ*


តារាង ១៖ អនុសាសន៍ដែលបានលើកឡើងដោយអង្គការអន្តរជាតិស្ដីពីការបង្ហាញព័ត៌មាន


*ការដាក់ដែនកំណត់ទៅលើចំណាយ*


តារាង ១៖ ហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតប្រធានាធិបតី៖ ការចំណាយផ្លូវការរបស់បេក្ខជនសំខាន់ៗនៅក្នុងប្រទេសរុស្ស៊ី អ៊ុយក្រែន និង ប៉ូឡូញ

តារាង ២៖ អនុសាសន៍ស្ដីពីការកំណត់ដែនចំណាយដែលបានលើកឡើងដោយអង្គការអន្តរជាតិនានា

តារាង ៣៖ ការកំណត់ដែនចំណាយសម្រាប់យុទ្ធនាការឃោសនា៖ ការយល់ខុស និង ការពិតជាក់ស្ដែង

តារាង ៤៖ ដែនកំណត់ចំណាយសម្រាប់ការបោះឆ្នោតនៅទ្វីបអឺរ៉ុប និង ប្រទេសប្រជាធិបតេយ្យចាស់ទុំដទៃទៀត


*ការផ្ដល់ហិរញ្ញប្បទានសាធារណៈ*


តារាង ១៖ អនុសាសន៍ផ្សេងៗស្ដីអំពីហិរញ្ញប្បទានសាធារណៈ ដែលលើកឡើងដោយអង្គការអន្តរជាតិមួយចំនួន

តារាង ២៖ គោលបំណង និង អត្ថប្រយោជន៍នៃហិរញ្ញប្បទានសាធារណៈ

តារាង ៣៖ ការប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈនៅតាមតំបន់ខុសៗគ្នា

តារាង ៤៖ ប្រភេទនៃស្ថាប័នទទួលបន្ទុកបែងចែកហិរញ្ញប្បទានសាធារណៈ

តារាង ៥៖ ប្រភេទនៃលក្ខណៈវិនិច្ឆ័យដែលកំណត់អំពីលក្ខណៈសម្បត្តិសម្រាប់ទទួលហិរញ្ញប្បទានសាធារណៈ

តារាង ៦៖ លក្ខខណ្ឌអប្បបរមាសម្រាប់ការទទួលបានហិរញ្ញប្បទានសាធារណៈ

តារាង ៧៖ បុរេភេទតួអង្គដែលត្រូវទទួលហិរញ្ញប្បទានសាធារណៈ

តារាង ៨៖ ប្រភេទនៃសកម្មភាពដែលអាចទទួលបានហិរញ្ញប្បទានសាធារណៈ

តារាង ៩៖ ប្រភេទផ្សេងៗនៃហិរញ្ញប្បទានសាធារណៈបែបប្រយោល

តារាង ១០៖ ការគណនាលើការបែងចែកហិរញ្ញប្បទានសាធារណៈនៅក្នុងប្រទេសខុសៗគ្នា

តារាង ១១៖ មូលដ្ឋានគ្រឹះនៃរូបមន្តបែងចែកហិរញ្ញប្បទានសាធារណៈ

តារាង ១២៖ កម្រិតហិរញ្ញប្បទានសាធារណៈដែលប្រើប្រាស់នៅក្នុងប្រទេសខុសៗគ្នា

តារាង ១៣៖ ពេលវេលានៃការបែងចែកហិរញ្ញប្បទាន

តារាង ១៤៖ បញ្ហាជាសក្ដានុពលនានាដែលអាចកើតមាននៅពេលអនុវត្តហិរញ្ញប្បទានសាធារណៈ

តារាង ១៥៖ ការពិចារណាលើទិដ្ឋភាពនីមួយៗនៃហិរញ្ញប្បទានសាធារណៈតាមគោលបំណងដែលគេចង់បាន

## *ការអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយ និង ការត្រួតពិនិត្យ*

តារាង ១៖ តើស្ថាប័នណាជាអ្នកទទួលខុសត្រូវលើការគ្រប់គ្រង និង អនុវត្តបទបញ្ញា?

តារាង ២៖ សិទ្ធិអំណាចរបស់គណៈកម្មការត្រួតពិនិត្យយុទ្ធនាការឃោសនាបោះឆ្នោត

តារាង ៣៖ សិទ្ធិអំណាចរបស់គណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីមហាផ្ទៃ និង រដ្ឋបាលដែនដី

តារាង ៤៖ សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

តារាង ៥៖ ការគាំទ្រជាអន្តរជាតិ និង ជាលក្ខណៈតំបន់ចំពោះការដាក់ទណ្ឌកម្ម

## *ស ចុក៏ស្ពុន្ធិរបន*

តារាង ១៖ រដ្ឋជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ ដែលមានប្រព័ន្ធបង្ហាញព័ត៌មានដូចដែលមានចែងក្នុងមាត្រា៧ (៣) នៃអនុសញ្ញានោះ

# អារម្ភកថា

នៅក្នុងសង្គមនីមួយៗ ចម្ងល់សំខាន់អំពីហិរញ្ញប្បទាននយោបាយសុទ្ធតែសឹងជាចំនុចសំខាន់ៗដែលត្រូវលើកយកមកពិចារណា នៅក្នុងវិស័យនយោបាយ និង អភិបាលកិច្ចា ធនធានទាំងឡាយដែលចាំបាច់ដើម្បីឲ្យការបោះឆ្នោតនានាសម្រេចបានជោគជ័យបានជះឥទ្ធិពលព្រមគ្នាទៅលើសុក្រឹតភាពនៃគោលនយោបាយសាធារណៈ និង ចំណង-ទាក់ទងរវាងអ្នកដឹកនាំនយោបាយ និង ប្រជាពលរដ្ឋរបស់ខ្លួន។ នីតិវិធីតាមផ្លូវច្បាប់និងបទបញ្ញាដែលគ្រប់គ្រងចំណាយសម្រាប់យុទ្ធនាការឃោសនារបស់គណបក្សនយោបាយ និង បេក្ខជនគឺជារបៀបវារៈមួយក្នុងចំណោមរបៀបវារៈសំខាន់ៗនៃគោលនយោបាយសាធារណៈ ដែលអ្នកគ្រប់គ្នាដែលបានចូលរួមនៅក្នុងការធ្វើ "កំណែទម្រង់" ទទួលបានបទពិសោធន៍ពិសេសមួយពីយុទ្ធនាការនយោបាយរបស់ពួកគេផ្ទាល់។

សៀវភៅ "បទបញ្ញាហិរញ្ញប្បទាននយោបាយ៖ បទពិសោធន៍នានាលើពិភពលោក" គឺជាកិច្ចខិតខំប្រឹងប្រែងរបស់អង្គការ*មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (ហៅកាត់ថាអាយហ្វេស)* ដើម្បីរួមចំណែកក្នុងកិច្ចពិភាក្សានានាពាក់ព័ន្ធទៅនឹងហិរញ្ញប្បទាននយោបាយ ដែលជាមូលដ្ឋានគ្រឹះនៃកំណែទម្រង់ច្បាប់បោះឆ្នោតនា តាមរយៈការជួយឧបត្ថម្ភពីសំណាក់*មូលនិធិអង្គការសហប្រជាជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ* អង្គការ*អាយហ្វេស*បានជ្រើសរើសអ្នកជំនាញឆ្នើមៗមួយចំនួនក្នុងវិស័យ "ថវិកា និង នយោបាយ" ដើម្បីប្រមូលចងក្រងបទពិសោធន៍នានា ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឲ្យប្រព័ន្ធហិរញ្ញវត្ថុនយោបាយជាតិ ដែលមានលក្ខណៈប្លែកៗគ្នាកាន់តែមានតម្លាភាពដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។ សៀវភៅនេះ គឺជាលទ្ធផលដែលបានមកពីការធ្វើសិក្ខាសាលា ការសិក្សា និង ការជជែកពិភាក្សាអស់រយៈពេលជាង២ឆ្នាំ ជាមួយអង្គការដៃគូនានាមកពីជុំវិញពិភពលោកដែលបានចូលរួមនៅក្នុងការពិភាក្សាដេញ-ដោលទាំងនេះ។

គោលបំណងរបស់យើងនៅក្នុងសៀវភៅនេះ ពុំមែនចង់ណែនាំឲ្យប្រើប្រាស់អភិក្រម "ពុម្ពមួយត្រូវគ្រប់ទំហំទាំងអស់" ក្នុងវិស័យហិរញ្ញវត្ថុនយោបាយទេ។ អភិក្រមបែបនេះនឹងពុំមានប្រយោជន៍អ្វីឡើយ ហើយក៏ពុំអាចយកមកអនុវត្តបានដែរ។ ច្បាប់ និង បទបញ្ញាហិរញ្ញវត្ថុនយោបាយ សុទ្ធតែសឹងជាលទ្ធផលដែលបានមកពីបទពិសោធន៍ផ្ទៃក្នុងនានានៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត និង អភិបាលកិច្ច ។ ដោយហេតុថាសិទ្ធិរបស់ពលរដ្ឋក្នុងការបោះឆ្នោតនៅក្នុងប្រទេសជាច្រើននាពេលបច្ចុប្បន្ននេះត្រូវបាន "សង្កេត" និង "ឃ្លាំមើល" ដោយសហគមន៍អន្តរជាតិ សព្វថ្ងៃនេះមានកិច្ចខិតខំប្រឹងប្រែងស្របគ្នាជាច្រើនក្នុងការលើកកម្ពស់ និង ស្វែងយល់អំពីបញ្ហាហិរញ្ញ-វត្ថុរបស់បេក្ខជន គណបក្សនយោបាយ និង នយោបាយ ក៏ដូចជាធ្វើឲ្យដំណើរការនោះកាន់តែមានតម្លាភាពសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់។

សូមអរគុណចំពោះចំណាប់អារម្មណ៍របស់អស់លោកអ្នក នៅក្នុងវិស័យដ៏មានសារៈសំខាន់នៃគោលនយោបាយសាធារណៈ និង ការពិភាក្សាដេញដោលនេះ។

**ទីឡេម ស៊ីនេ**
ប្រធាន និងជានាយកប្រតិបត្តិ នៃមូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត

## សេចក្តីថ្លែងអំណរគុណ

មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (អាយហ្វេស) សូមថ្លែងអំណរគុណដល់អស់លោកទាំងអស់ដែលបានចូលរួមក្នុងគម្រោងការងារស្តីពី "បទដ្ឋានសាកលនានាសម្រាប់ហិរញ្ញវត្ថុនយោបាយ" ដែលបានចាប់ផ្តើមតាំងពីឆ្នាំ២០០៧ មក ។ ការបោះពុម្ពផ្សាយ ដែលជាលទ្ធផលមួយក្នុងចំណោមលទ្ធផលចម្បងៗចេញពីគម្រោងនេះច្បាស់ជាពុំអាចកើតមានទេ ប្រសិនបើពុំមានការតាំងចិត្ត ការខិតខំប្រឹងប្រែង និង ការចូលរួមផ្នែកជំនាញពីបុគ្គល និង អង្គការមួយចំនួនទេនោះ។

យើងសូមសំដែងការកោតសរសើរក្រៃលែងចំពោះ *ជេហ្វ្រី ខាលសុន* (Jeffrey Carlson) និង *ម៉ាស៊ីន វ៉ាឡេគី* (Marcin Walecki) សម្រាប់ការដឹកនាំ ដ៏ប៉ិនប្រសប់ និង សម្រាប់អភិក្រមប្រកបដោយគំនិតច្នៃប្រឌិតក្នុងការធ្វើឲ្យសម្រេចបាននូវការសិក្សាអំពីហិរញ្ញវត្ថុនយោបាយនេះ។ យើងក៏សូមសម្តែងនូវការដឹងគុណដោយស្មោះសរផងដែរចំពោះលោក *បណ្ឌិត ម៉ៃឃើល ពីនតូ -ឌូជីនស្គី* (Michael Pinto-Duschinsky) *ម៉ាយ៉ា សឺបាន* (Maya Serban) *ជែក សាន់ទូស៊ី* (Jack Santucci) *ជែមស៍ ទូរីតូ* (James Turitto) និង *យូ ថេរេសា ជេន* (Yu Theresa Chen) ចំពោះការចូលរួមជួយគាំទ្ររបស់ពួកគេនៅក្នុងដំណើរការគម្រោងទាំងមូល។

នៅមានបុគ្គលមួយចំនួនទៀត ដែលបានចូលរួមក្នុងកិច្ចពិភាក្សាជាបន្តបន្ទាប់ស្តីពីបទពិសោធន៍សាកលនានាក្នុងវិស័យបទបញ្ញាហិរញ្ញវត្ថុនយោបាយនេះ។ សម្រាប់ការលះបង់នេះ យើងសូមបង្ហាញការដឹងគុណដោយស្មោះអស់ពីដួងចិត្តជូនចំពោះសមាជិកសមាជិកាទាំងឡាយ នៃ*ក្រុមពិគ្រោះយោបល់របស់មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោតស្តីពីបទដ្ឋានគម្រូនានាក្នុងហិរញ្ញវត្ថុនយោបាយ* សិក្ខាកាមដែលបានចូលរួមនៅក្នុងសន្និសីទអន្តរ-ជាតិកាលពីឆ្នាំ ២០០៧ ស្តីអំពីហិរញ្ញវត្ថុនយោបាយ ដែលបានរៀបចំឡើងដោយអង្គការ *អាយហ្វេស* និង *អេហ្វ.អ៊ី.ស៊ី* (FEC) កិច្ចប្រជុំស្តីពីហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ដែលរៀបចំឡើងដោយអង្គការ *អាយហ្វេស* និង *មជ្ឈមណ្ឌលខាតធ័រ* (Carter Center) កាលពីខែមករា ឆ្នាំ២០០៩ និង កិច្ចប្រជុំដើម្បីរៀបចំឯកសារសម្រាប់បណ្តុះ-បណ្តាលអំពីហិរញ្ញវត្ថុគណបក្សនយោបាយ (BRIDGE) កាលពីខែមីនា ឆ្នាំ២០០៩។ ការរួមចំណែកទាំងនេះបានបង្កើតឲ្យមានអភិក្រមសាកលជាកាលៈទេសៈមួយដើម្បីឆ្លើយតបទៅនឹងសំនួរនានាដែលកំពុងចោទឡើង។

ជាមួយគ្នានេះដែរ យើងក៏សូមថ្លែងអំណរគុណផងដែរដល់អង្គការដៃគូរបស់យើងពលើគឺ *អង្គការក្រុមហោរាពអន្តរជាតិ* សម្រាប់ កិច្ចការទាំងឡាយដែលអង្គការនេះបានបំពេញ ហើយការតាំងចិត្តរបស់អង្គការនេះនៅក្នុងការស្រាវជ្រាវអំពីបញ្ហាហិរញ្ញវត្ថុនយោបាយបានជះឥទ្ធិពលជាពិសេសដល់គម្រោងការងារនេះ។ ជាអវសានក្តី មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (អាយហ្វេស) សូមសំដែងការដឹងគុណក្រៃលែងចំពោះការជួយគាំទ្រប្រកបដោយសប្បុរសធម៌ពីសំណាក់*មូលនិធិអង្គការសហប្រជាជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ* (យូ.អិន.ឌី.អ៊ី.អែហ្វ) សម្រាប់គម្រោងកម្មវិធីដែលមានឈ្មោះថា "ការសម្របចេបានយោបល់រួមៈ បទដ្ឋាននានាលើពិភពលោកសម្រាប់ហិរញ្ញវត្ថុនយោបាយ"។

**ម៉ាឈីស អូមែន** និង **ហានី ហៃហ្សនហៃ**

# អំពីអ្នកនិពន្ធ

## បណ្ឌិត ម៉ាណឹស អូមែន (Dr. Magnus Öhman)

បណ្ឌិត ម៉ាណឹស អូមែន ជាទីប្រឹក្សាជាន់ខ្ពស់ផ្នែកហិរញ្ញប្បទាននយោបាយនៃមូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES)។ គាត់បាននិពន្ធសៀវភៅទាក់ទងនឹងហិរញ្ញវត្ថុនយោបាយចាប់តាំងពីចុងទសវត្សឆ្នាំ ១៩៩០ មក ដោយផ្តោតទៅលើប្រព័ន្ធហិរញ្ញប្បទានសាធារណៈ និង ដំណោះស្រាយដែលមាននិរន្តរភាព។ គាត់បាននិងកំពុងធ្វើការលើគម្រោងនានាទាក់ទងនឹងហិរញ្ញប្បទាននយោបាយក្នុងប្រទេសមួយចំនួនដូចជា អាហ្វហ្គានីស្ថាន ឥណ្ឌូនេស៊ី លីបង់ លីបេរីយ៉ា និង នីហ្សេរីយ៉ា ជាដើម ហើយគាត់ក៏ជា សហអ្នករៀបរៀងឯកសារមេរៀនសម្រាប់បណ្តុះបណ្តាលលើប្រធានបទហិរញ្ញវត្ថុនយោបាយ ( BRIDGE) ក្នុងពេលឆាប់ៗខាងមុខនេះដែរ ។ បណ្ឌិត អូមែន ធ្លាប់បម្រើការជានាយកមូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) ប្រចាំប្រទេសសៀរ៉ាលេអូន ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៨ ជាប្រទេសដែលគាត់បានជួយបង្កើតឲ្យមានប្រព័ន្ធបង្ហាញព័ត៌មានស្តីពីហិរញ្ញវត្ថុនយោបាយលើកដំបូងបង្អស់នៅក្នុងចំណោមកិច្ចការដទៃផ្សេងទៀត។ គាត់បានទទួលសញ្ញាប័ត្របណ្ឌិត ផ្នែកវិទ្យាសាស្ត្រនយោបាយពីសាកលវិទ្យាល័យអ៊ុបសាលា (University of Uppsala) នៅប្រទេសស៊ុយអែត។

## ហានី ហ្សៃនូលបៃ (Hani Zainulbhai)

ហានី ហ្សៃនូលបៃ គឺជាជំនួយការកម្មវិធី ផ្នែកកម្មវិធីផ្នែកហិរញ្ញប្បទាននយោបាយ នៃមូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES)។ នៅក្នុងមុខងារនេះ ហានី បានជួយដល់ការអនុវត្តកម្មវិធីហិរញ្ញប្បទាននយោបាយក្នុងប្រទេសនីការ៉ាហ្គ័រ អាមេនៀ និង ហ្សាម៉ៃកា ក្នុងចំណោមប្រទេសផ្សេងទៀត។ ហានី បានជួយធ្វើការងារជាកម្មសិក្សាការីលើគម្រោងនានារបស់*អង្គការអាយហ្វេស*ចាប់តាំងពីឆ្នាំ២០០៧មក ក៏ដូចជាគម្រោងដទៃទៀតសម្រាប់ទស្សនាវដ្តី "របាយការណ៍រដ្ឋការវ៉ាស៊ីនតោនស្តីពីកិច្ចការនៅតំបន់មជ្ឈិមបូព៌ា" ផងដែរ។ ហានីបានទទួលសញ្ញាប័ត្របរិញ្ញាប័ត្រផ្នែកកិច្ចការអន្តរជាតិនិងសេដ្ឋកិច្ចអន្តរជាតិ ពីសាកលវិទ្យាល័យចចវ៉ាស៊ីនតោន (George Washington University)។

## ជែក សានទូស៊ី (Jack Santucci)

ជែក សានទូស៊ី ជាអ្នកជំនួយការផ្នែកស្រាវជ្រាវរបស់*អង្គការអាយហ្វេស* សម្រាប់មជ្ឈមណ្ឌលស្រាវជ្រាវអនុវត្តន៍អែហ្វ.គ្លីហ្វតុន.វ៉ាយ និង ជាអ្នកផលិតគេហទំព័រ "www.electionguide.org"។ គាត់បានបម្រើការយ៉ាងសកម្មលើគម្រោងនានាស្តីពីហិរញ្ញប្បទាននយោបាយដែលផ្តួចផ្តើមដោយ*អង្គការអាយហ្វេស*។ មុនពេលចូលមកបំរើការងារនៅ*អង្គការអាយហ្វេស* *ជែក*ធ្លាប់បានធ្វើការងារបោះឆ្នោតនៅអង្គការដែលធ្វើការផ្នែកតស៊ូមតិ និង ស្រាវជ្រាវ របស់សហរដ្ឋអាមេរិចចំនួនពីរ គឺៈ វិទ្យាស្ថានហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត (Campaign Finance Institute) និង ការបោះឆ្នោតដោយយុត្តិធម៌ (FairVote)។ ជែក សានទូស៊ី បានទទួលសញ្ញាប័ត្រអនុបណ្ឌិត ផ្នែកលទ្ធិប្រជាធិបតេយ្យនិង អភិបាលកិច្ចសិក្សាពីសាកលវិទ្យាល័យចចថោន (Georgetown University) និង បរិញ្ញាប័ត្រវិទ្យាសាស្ត្រនយោបាយពីសាកលវិទ្យាល័យម៉ាកហ្គៀល (McGill University)។

## បណ្ឌិត ម៉ាស៊ីន វ៉ាឡេគី (Dr. Marcin Walecki)

បណ្ឌិត ម៉ាស៊ីន វ៉ាឡេគី គឺជានាយកប្រតិបត្តិនៃ*អង្គការភាពជាដៃគូអឺរ៉ុបសម្រាប់លទ្ធិប្រជាធិបតេយ្យ* (the European Partnership for Democracy) និងជាអតីតទីប្រឹក្សាជាន់ខ្ពស់ផ្នែកហិរញ្ញប្បទាននយោបាយរបស់*អង្គការអាយហ្វេស*

ផងដែរ។ លោកមានបទពិសោធន៍ការងារជាង ១០ ឆ្នាំ ទាក់ទងនឹងលទ្ធិប្រជាធិបតេយ្យនិង អភិបាលកិច្ចអន្តរជាតិក្នុងប្រទេសចំនួន ២៥ នៅជុំវិញពិភពលោក ដោយផ្តោតទៅលើការប្រឆាំងអំពើពុករលួយ ហិរញ្ញវត្ថុនយោបាយ និងក្រមសីលធម៌សាធារណៈ ព្រមទាំងការអភិវឌ្ឍគណបក្សនយោបាយ។ លោកបានទទួលសញ្ញាប័ត្របណ្ឌិតទស្សនវិជ្ជាផ្នែកនយោបាយ ពីមហាវិទ្យាល័យសាំង អាន់តូនី (St. Antony's College) នៃសាកលវិទ្យាល័យអុកហ្វដ (Oxford University) និង សញ្ញាប័ត្រអនុបណ្ឌិតច្បាប់ (ថ្នាក់លេខ ១) ពីមហាវិទ្យាល័យច្បាប់ និងរដ្ឋបាល នៃសាកលវិទ្យាល័យវ៉ារសាវ (University of Warsaw)។

## ១.១ បញ្ហាប្រឈម

*"ហិរញ្ញវត្ថុនយោបាយ គឺជាបញ្ហាមួយយ៉ាងសំខាន់សម្រាប់លទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ចនិងការអភិវឌ្ឍ បើទោះជាការបោះឆ្នោតមានភាពល្អឥតខ្ចោះ សង្គមស៊ីវិលមានភាពសកម្ម គណបក្សនយោបាយមានការប្រកួតប្រជែងយ៉ាងស្វិតស្វាញ និង អង្គការមូលដ្ឋាននៅប្រទេសនោះមានទំនួលខុសត្រូវយ៉ាងណាក៏ដោយ ក៏តួនាទីហិរញ្ញវត្ថុនៅក្នុងនយោបាយ នៅតែមានឥទ្ធិពលទៅលើគុណភាពនៃលទ្ធិប្រជាធិបតេយ្យ និង អភិបាលកិច្ច ដែលពុំអាចប្រកែកបានឡើយ។ មានតែតាមរយៈតម្លាភាពដែលកាន់តែរីកធំឡើងប៉ុណ្ណោះ ដែលអាចឲ្យគេយល់បានយ៉ាងច្បាស់អំពីទំហំ និង លក្ខណៈនៃឥទ្ធិពលនេះ"*[1]។

ដោយមានការទទួលស្គាល់ទៅលើឥទ្ធិពលរបស់ហិរញ្ញវត្ថុនៅក្នុងនយោបាយ ទើបអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ (UNCAC) បានដាក់បញ្ចូលសេចក្តីអំពាវនាវមួយថា ប្រទេសទាំងឡាយគួរខិតខំពុះពារដើម្បី "ពង្រឹងតម្លាភាពនៅក្នុងការផ្តល់មូលនិធិដល់បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់មុខតំណែងសាធារណៈ ហើយនិងគណបក្សនយោបាយផងដែរ ប្រសិនបើអាចធ្វើទៅបាន" (មាត្រា ៧ (៣))។

បើទោះជាមានសុឆន្ទៈដូចខាងលើក៏ដោយ ក៏នៅមានកិច្ចការជាច្រើនទៀតដែលយើងត្រូវធ្វើ។ ក្នុងចំណោមប្រទេសចំនួន ១៣៦ ដែលជាភាគីនៃអនុសញ្ញានេះ ដោយគិតត្រឹមខែកញ្ញា ឆ្នាំ ២០០៩ មានតែប្រទេសចំនួន ១០៧ ប៉ុណ្ណោះ ដែលគេអាចរកបានព័ត៌មានគ្រប់គ្រាន់សម្រាប់ធ្វើការវិនិច្ឆ័យអំពីការអនុវត្តតាមច្បាប់របស់ពួកគេទាក់ទិនទៅនឹងការបង្ហាញព័ត៌មានហិរញ្ញវត្ថុរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត។ នៅក្នុងចំណោមប្រទេសទាំងនេះ មានប្រទេសចំនួនដល់ទៅ ៦១ ឬ ស្មើនឹង ៥៧% ដែលពុំមានបទប្បញ្ញត្តិតម្រូវឲ្យធ្វើការបង្ហាញចំណូល និង ចំណាយរបស់បេក្ខជនឈរឈ្មោះបោះឆ្នោតនោះទេ[2]។ យើងក៏ចាំបាច់ទទួលស្គាល់ផងដែរអំពីគម្លាតដ៏ធំដែលកើតមានជាញឹកញាប់រវាងវិធានតាមផ្លូវច្បាប់ និង ការអនុវត្តជាក់ស្តែង។ ម្យ៉ាងទៀត ចូរកត់សម្គាល់ផងដែរថា ចំនួនប្រទេសដែលពុំទាន់មានយន្តការខាងផ្លូវច្បាប់សំរាប់ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពលើហិរញ្ញវត្ថុនយោបាយមានចំនួនកាន់តែច្រើន។ តាមពិត គេអាចនិយាយបានថា ពុំទាន់មានប្រទេសណាមួយបានពុះពារអស់រយៈកាលដ៏យូរ ដើម្បីជំនះរាល់ការលំបាកដែលទាក់ទងទៅនឹងការបង្ហាញព័ត៌មានអំពីហិរញ្ញវត្ថុ របស់គណបក្សនយោបាយ និង ហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនោះទេ។

ទោះយ៉ាងណាក៏ដោយ ហិរញ្ញវត្ថុនយោបាយមិនមែនគ្រាន់តែសំដៅត្រឹមតែការបង្ហាញព័ត៌មានប៉ុណ្ណោះទេ។ ជារឿយៗ អត្ថន័យហិរញ្ញវត្ថុនយោបាយក៏បានរួមបញ្ចូលទាំងមូលនិធិរបស់គណបក្សនយោបាយ និង មូលនិធិ

---

[1] *ការិយាល័យលទ្ធិប្រជាធិបតេយ្យ និង អភិបាលកិច្ច (ឆ្នាំ ២០០៣) សៀវភៅណែនាំអំពីហិរញ្ញវត្ថុក្នុងនយោបាយ៖ មគ្គុទេសន៍សម្រាប់លើកកម្ពស់តម្លាភាពក្នុងបណ្តាប្រទេសប្រជាធិបតេយ្យថ្មីថ្មោង ទំព័រ ៥។ ការបោះពុម្ពផ្សាយជាស៊េរីសម្រាប់ជំនួយបច្ចេកទេស របស់ទីភ្នាក់ងារសហរដ្ឋអាមេរិចសម្រាប់ ការអភិវឌ្ឍអន្តរជាតិ (រដ្ឋធានីវ៉ាស៊ីនតោន)។*

[2] *បើប្រៀបធៀបទៅនឹងការបង្ហាញព័ត៌មានអំពីហិរញ្ញវត្ថុរបស់គណបក្សនយោបាយ ស្ថានភាពនេះមានលក្ខណៈប្រសើរជាងខ្លះ។ ព័ត៌មានបែបនេះ អាចរកបានក្នុងប្រទេសចំនួន ១២០ ដែលប្រទេសចំនួន៣៩ ឬ ១ /៣ ក្នុងចំនោមនោះ ពុំមានការតម្រូវឲ្យធ្វើរបាយការណ៍ហិរញ្ញវត្ថុនយោបាយជាផ្លូវការនោះទេ។ ស្ថានភាពសម្រាប់ប្រទេសនីមួយ និង ប្រភពព័ត៌មានទាំងនេះ អាចរកមើលបាននៅក្នុងជំពូកចុងក្រោយ (សេចក្តីសន្និដ្ឋាន) នៃសៀវភៅនេះ។*

សម្រាប់ធ្វើយុទ្ធនាការឃោសនាបោះឆ្នោតផងដែរ។ ដូច្នេះ ហិរញ្ញវត្ថុនយោបាយមានន័យគ្របដណ្តប់លើបញ្ហាជាច្រើន ជាពិសេស ឥរិយាបថរបស់គណបក្សនយោបាយ និង មន្ត្រីសាធារណៈ ព្រមទាំងផលប្រយោជន៍ដែលពួកគេត្រូវយកចិត្តទុកដាក់បន្ទាប់ពីការបោះឆ្នោត (ដែលនេះគឺជាប្រធានបទចម្បងនៃបទប្បញ្ញត្តិមួយចំនួន ដែលមានចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ)។ ក្រៅពីការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយ បទបញ្ញា ការត្រួតពិនិត្យ និង ការតាមដានមូលនិធិនយោបាយ ក៏បានរាប់បញ្ចូលផងដែរនូវការហាមឃាត់ និង ដែនកំណត់ទៅលើការផ្តល់វិភាគទាន និង ចំណាយរបស់គណបក្សនយោបាយឬបេក្ខជន ការធ្វើហិរញ្ញប្បទានសាធារណៈដោយផ្ទាល់ និង ប្រយោលដល់គណបក្សនយោបាយ ឬ បេក្ខជន និងយន្តការទូទៅមួយចំនួនទៀត មានដូចជាការកំណត់រយៈពេលសំរាប់ការឃោសនាបោះឆ្នោតជាដើម។ បទពិសោធន៍សកលនេះ ក៏បានបង្ហាញយ៉ាងច្បាស់ផងដែរថា បទបញ្ញា និង ការត្រួតពិនិត្យធំៗ ដែលធ្វើឡើងដោយស្ថាប័នរបស់រដ្ឋ ក៏បាននៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ ដូច្នេះ ការចូលរួមយ៉ាងសកម្មពីសំណាក់ក្រុមសង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយ មានសារៈសំខាន់យ៉ាងខ្លាំងក្នុងការធ្វើឲ្យការត្រួតពិនិត្យសម្រេចទៅបានដោយប្រសិទ្ធភាព។

ក្នុងទិដ្ឋភាពទូទៅ ហិរញ្ញវត្ថុនយោបាយស្ថិតនៅត្រង់ចំនុចប្រសព្វគ្នានៃបញ្ហាសំខាន់ៗជាច្រើនក្នុងជីវិតនយោបាយ។ ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នយោបាយប្រជាធិបតេយ្យ អភិបាលកិច្ចប្រកបដោយប្រសិទ្ធិភាព និង អំពើពុករលួយ សុទ្ធតែជាប់ទាក់ទិននឹងហិរញ្ញវត្ថុនយោបាយ ចំណែកឯហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និង ហិរញ្ញវត្ថុសម្រាប់ការឃោសនាបោះឆ្នោតអាចជះឥទ្ធិពលជាវិជ្ជមាន និង អវិជ្ជមានលើបញ្ហាទាំងនោះ។ ការមានធនធានគ្រប់គ្រាន់អាចធ្វើឲ្យគណបក្សនយោបាយ ឬ បេក្ខជនទាំងអស់ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតមានលទ្ធភាពបញ្ជូនសារនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោត ប៉ុន្តែវាក៏អាចជះឥទ្ធិពលដល់ការប្រកួតប្រជែងក្នុងការបោះឆ្នោតផងដែរ។ ជាមួយគ្នានេះដែរ បន្ទាប់ពីការបោះឆ្នោត គេក៏ត្រូវការធនធាននានា សម្រាប់ធ្វើការពិភាក្សាឲ្យមានប្រសិទ្ធភាពជាមួយពលរដ្ឋដែរ ក៏ប៉ុន្តែក្រុមមន្ត្រីសាធារណៈអាចនឹងជាប់កាតព្វកិច្ចចំពោះពួកអ្នកធ្វើវិភាគទាននយោបាយដែលមានទ្រព្យធនច្រើន ដែលការនេះអាចធ្វើឲ្យប៉ះពាល់មិនត្រឹមតែទៅលើការឆ្លើយតបរបស់អ្នកនយោបាយទៅនឹងតម្រូវការរបស់សាធារណជនប៉ុណ្ណោះទេ តែថែមទាំងប៉ះពាល់ការគ្រប់គ្រងធនធានសាធារណៈផងដែរ។ សរុបមក អ្នកនយោបាយ និង គណបក្សនយោបាយដែលមានស្ថេរភាពផ្នែកហិរញ្ញវត្ថុ អាចជម្នះបានយ៉ាងងាយស្រួលចំពោះការប៉ុនប៉ងធ្វើវិភាគទាននយោបាយណាមួយដែលពុំស្របច្បាប់ ក៏ប៉ុន្តែឥទ្ធិពលអវិជ្ជមាននៃហិរញ្ញ - វត្ថុនៅក្នុងកិច្ចការនយោបាយ ក៏អាចបង្កើតឲ្យមានផងដែរនូវវដ្តនៃអំពើពុករលួយដ៏សែនធ្ងន់ធ្ងរ ហើយនិងការធ្លាក់ចុះនូវជំនឿទុកចិត្តពីសាធារណៈជននៅក្នុងប្រព័ន្ធនយោបាយទាំងមូល។




ដោយសារតែតួនាទីស្នូលរបស់ហិរញ្ញវត្ថុនយោបាយនៅក្នុងទំនាក់ទំនងជាមួយវិស័យទាំងអស់ខាងលើ ទើបក្នុងអំឡុងពេលមួយទសវត្សចុងក្រោយនេះ *មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត* (IFES) បានអនុវត្តគម្រោងនានាជាច្រើនក្នុងប្រទេសជាង ២០ លើពិភពលោក ដើម្បីពង្រឹងការយល់ដឹង និងតម្លាភាពនៅក្នុងការផ្តល់មូលនិធិដល់គណបក្សនយោបាយ និងយុទ្ធនាការឃោសនាបោះឆ្នោត។ នៅក្នុងកិច្ចការនេះ *អង្គការ*

*អាយហ្វេស* បានក្លាយជាដៃគូជាមួយសមាជិកនៃអង្គការនីតិបញ្ញត្តិ ស្ថាប័នអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយ គណបក្សនយោបាយ ក្រុមសង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយ នៅតាមបណ្តាប្រទេសផ្សេងៗនៅក្នុងទ្វីបអឺរ៉ុប អាស៊ី អាហ្វ្រិក អាមេរិកឡាទីន និង ការ៉ាអ៊ីប។

## *អំពីគម្រោងកម្មវិធីនេះ*

មូលនិធិអង្គការសហប្រជាជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ (យូ.អិន.ឌី.អ៊ី.អែហ្វ) ត្រូវបានបង្កើតឡើងក្នុងរយៈពេលមិនដល់ ២ ឆ្នាំផង បន្ទាប់ពីមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ និង ក្នុងរយៈពេលប្រហែលជាកន្លះឆ្នាំប៉ុណ្ណោះមុននឹងអនុសញ្ញានេះចូលជាធរមាន។ ដោយមានការទទួលស្គាល់ពីភាពចាំបាច់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាហិរញ្ញវត្ថុ និង នយោបាយនៅទូទាំងពិភពលោក ទើបយូ.អិន.ឌី.អ៊ី.អែហ្វ បានដាក់បញ្ចូលក្នុងជុំទីមួយរបស់ខ្លួន ដោយសប្បុរសនូវការគាំទ្រផ្នែកហិរញ្ញវត្ថុដល់គម្រោងកម្មវិធីដែលមានរយៈពេលជាច្រើនឆ្នាំរបស់អង្គការ*អាយហ្វេស* ក្នុងគោលបំណងបង្កើតឲ្យមានការសន្ទនាដ៏ទូលំទូលាយនិងផ្តោតលើលទ្ធផល ស្តីអំពីបទដ្ឋានសកល និង បទពិសោធន៍ល្អៗក្នុងវិស័យហិរញ្ញវត្ថុនយោបាយ[3]។ តាមរយៈគម្រោងកម្មវិធីនេះ អង្គការអាយហ្វេស រួមជាមួយនឹងដៃគូរបស់ខ្លួន បានអនុវត្តសកម្មភាពជាបន្តបន្ទាប់ដើម្បីបង្កើនការយល់ដឹងលើវិធីសាស្ត្រផ្សេងៗក្នុងការពង្រឹងតម្លាភាព នៅក្នុងការផ្តល់ហិរញ្ញវត្ថុដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោត។

ការពិគ្រោះយោបល់មួយចំនួនត្រូវបានធ្វើឡើងជាមួយក្រុមអ្នកស្រាវជ្រាវ អ្នកជំនាញ សកម្មជនប្រឆាំងអំពើពុករលួយ និង ស្ថាប័នអនុវត្តបទបញ្ញា នៅក្នុងវិស័យហិរញ្ញវត្ថុនយោបាយ ដើម្បីរួមគ្នាបញ្ជាក់ និង កំណត់អត្ថន័យមាត្រា ៧ កថាខ័ណ្ឌ៣ នៃអនុសញ្ញាអន្តរជាតិស្តីពីការប្រឆាំងអំពើពុករលួយ អំពីតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុនយោបាយ ទាំងនៅក្នុងបរិបទនៃអនុសញ្ញានេះ និងនៅបណ្តុំបទពិសោធន៍ល្អៗមួយចំនួននៃការអនុវត្តជាក់ស្តែង ។ អង្គការ*អាយហ្វេស*បានរៀបចំឯកសារមួយកាលពីឆ្នាំ ២០០៧ ដើម្បីប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការពិភាក្សានេះ ពោលគឺ ឯកសារ "បទដ្ឋានគម្រូសម្រាប់ហិរញ្ញវត្ថុនយោបាយ" ដែលបច្ចុប្បន្ននេះបានបញ្ចប់រួចរាល់ហើយតាមរយៈការបោះពុម្ពផ្សាយនេះ។ កាលពីឆ្នាំ ២០០៨ ការស្ទង់មតិមួយត្រូវបានធ្វើឡើងក្នុងចំណោមអ្នកជំនាញផ្នែកហិរញ្ញវត្ថុនយោបាយជាច្រើន ដើម្បីស្វែងរកព័ត៌មាន អំពីបញ្ហាចំបងៗមួយចំនួនក្នុងវិស័យហិរញ្ញវត្ថុនយោបាយ និង ដំណោះ-ស្រាយនានាដែលប្រកបដោយប្រសិទ្ធិភាព។ គេហទំព័រ "www.moneyandpolitics.net" ដែលឧទ្ទិសផ្តាច់មុខសម្រាប់វិស័យហិរញ្ញវត្ថុនយោបាយត្រូវបានបង្កើតឡើង។ គេហទំព័រនេះ មិនត្រឹមតែមានឯកសារនានាទាក់ទងនឹងគម្រោងនេះទេ តែថែមទាំងឯកសារសំខាន់ៗជាច្រើនទៀតក្នុងទម្រង់ជាព័ត៌មាន របាយការណ៍ ច្បាប់ និងបទបញ្ញានានា ជាភាសាអង់គ្លេស អារ៉ាប់ អេស្ប៉ាញ និង បារាំង ដែលប្រមូលបានមកពីប្រទេសចំនួន ៩០ ពីជុំវិញពិភពលោក[4]។

ក្នុងក្របខ័ណ្ឌនៃបញ្ហានានាដូចដែលបានពិភាក្សារួចមកហើយនេះ យើងបានធ្វើសកម្មភាពជាច្រើនតាមរយៈភាពជាដៃគូសំខាន់ៗមួយចំនួន។ នៅក្នុងការរៀបចំ "ឯកសារព្រាងគោលស្តីអំពីគណនេយ្យភាព និង តម្លាភាព

---

[3] *សម្រាប់ព័ត៌មានបន្ថែមស្តីអំពី យូ.អិន.ឌី.អ៊ី.អែហ្វ សូមរកមើលនៅក្នុងគេហទំព័រ www.un.org/democracyfund។*

[4] *គេហទំព័រនេះក៏មានផ្ទុកបណ្តាញអ៊ីនធើណែតផ្សេងទៀតសម្រាប់ភ្ជាប់ទៅកាន់ស្ថាប័នអនុវត្តបទបញ្ញាស្តីពីហិរញ្ញវត្ថុនយោបាយនៅក្នុងប្រទេសចំនួន៣៥ ហើយនិងលិខិតុបករណ៍គម្រូៗជាច្រើនទៀត មានដូចជាទម្រង់របាយការណ៍ជាដើម។*

ក្នុងហិរញ្ញវត្ថុនយោបាយ" ឆ្នាំ ២០០៨[5] អង្គការអាយហ្វេសបានធ្វើការរួមគ្នាជាមួយដៃគូគម្រោងកម្មវិធីដ៏សំខាន់របស់ខ្លួនគឺ *អង្គការតម្លាភាពអន្តរជាតិ (Transparency International)* ដែលជាអង្គការឈានមុខគេក្នុងពិភពលោកខាងវិស័យប្រឆាំងអំពើពុករលួយ។ អង្គការទាំងពីរកំពុងរៀបចំផងដែរនូវក្រុមការងារបណ្តោះអាសន្នមួយនៅឯសន្និសីទអន្តរជាតិស្តីពីការប្រឆាំងអំពើពុករលួយកាលពីឆ្នាំ ២០០៨ នៅទីក្រុងអាថែន (ប្រទេសក្រិច) ហើយយើងនឹងបង្កើតឲ្យមានគម្រោងរួមគ្នាមួយដើម្បីលើកឡើងនូវបញ្ហានានា ដែលទាក់ទងទៅនឹងតម្លាភាពហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និង ហិរញ្ញវត្ថុសម្រាប់ការឃោសនាបោះឆ្នោតនៅឯកិច្ចប្រជុំរបស់រដ្ឋជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងដូហា (ប្រទេសកាតា) ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៩។

អង្គការអាយហ្វេស កំពុងធ្វើការងារជាដៃគូជាមួយក្រុមអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិឈានមុខគេមួយចំនួនផងដែរ ដូចជា មជ្ឈមណ្ឌលខាតធ័រ (Carter Center) អង្គការសន្តិសុខ និង សហប្រតិបត្តិការទ្វីបអឺរ៉ុប (OSCE) អង្គការនៃបណ្តារដ្ឋនៅទ្វីបអាមេរិក (Organisation of American States) អគីតិវិទ្យាស្ថានអាហ្វ្រិកភាគខាងត្បូងសម្រាប់ការបោះឆ្នោត ( EISA) លេខាធិការដ្ឋានខំមិនវែល (Commonwealth Secretariat) និង វិទ្យាស្ថានជាតិប្រជាធិបតេយ្យសម្រាប់កិច្ចការអន្តរជាតិ (NDI)។ ការងារនេះផ្តោតជាសំខាន់ទៅលើការពង្រឹងការដាក់បញ្ចូលនូវការត្រួតពិនិត្យហិរញ្ញវត្ថុក្នុងយុទ្ធនាការឃោសនាបោះឆ្នោតទៅក្នុងគម្រោងបេសកកម្ម និង របាយការណ៍របស់ក្រុមអ្នកសង្កេតការណ៍ទាំងនោះ។ កិច្ចប្រជុំចំនួន ៣ លើក នៅក្រុងវ៉ាស៊ីនតោន និង អាត្លង់តា (សហរដ្ឋអាមេរិច) បានចូលរួមចំណែកយ៉ាងសំខាន់ថែមទៀតដល់កិច្ចការនេះ ចំណែកឯបេសកកម្មរួមគ្នាមួយរវាង *អង្គការអាយហ្វេស* និង *មជ្ឈមណ្ឌលខាតធ័រ* ក្នុងប្រទេសលីបង់បានបង្ហាញឲ្យឃើញនូវករណីសិក្សាសាកល្បងដ៏មានប្រយោជន៍មួយ[6]។

ក្រៅពីកិច្ចសហប្រតិបត្តិការជាមួយអង្គការមួយចំនួនដូចបានរៀបរាប់ខាងលើ អង្គការ *អាយហ្វេស* បានធ្វើការជាមួយ *វិទ្យាស្ថានអន្តរជាតិសម្រាប់លទ្ធិប្រជាធិបតេយ្យនិង ជំនួយការបោះឆ្នោត*(IDEA) ក្នុងការលើកកម្ពស់ការយល់ដឹងអំពីហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និង យុទ្ធនាការ ឃោសនាបោះឆ្នោត ហើយនិងសារៈសំខាន់របស់វានៅក្នុងការដឹកនាំតាមបែបប្រជាធិបតេយ្យ និង អភិបាលកិច្ចដែលមានប្រសិទ្ធិភាព ។ ពិសេសជាងនេះទៅទៀត អង្គការទាំងពីរនេះបានរៀបចំឲ្យមានកម្មវិធីបណ្តុះបណ្តាលដាច់ដោយឡែកមួយ ស្តីពីហិរញ្ញវត្ថុនយោបាយ នៅក្នុងឯកសារសំរាប់បណ្តុះបណ្តាលអំពីការកសាងធនធានក្នុងលទ្ធិប្រជាធិបតេយ្យអភិបាលកិច្ចនិងការបោះឆ្នោតដែលហៅកាត់ថា "ប្រ៊ីច" ( BRIDGE) និងបានពង្រីកឲ្យបានកាន់តែទូលាយថែមទៀតនូវព័ត៌មានទាក់ទងនឹងបញ្ហានេះ នៅក្នុងសព្វវចនាធិប្បាយ ស្តីអំពី "ការគ្រប់គ្រង និង ចំណាយសម្រាប់ការបោះឆ្នោត"[7]។

---

[5] *ឯកសារនេះអាចរកបាននៅលើគេហទំព័រ www.moneyandpolitics.net និង គេហទំព័រ www.transparency.org។*

[6] *អ្នកចូលរួមមកពីបណ្តាអង្គការនានា ដូចជាវិទ្យាស្ថានហូឡង់សម្រាប់លទ្ធិប្រជាធិបតេយ្យពហុបក្ស (the Netherlands Institute for Multiparty Democracy) វេទិកាសង្គមសេរី (Open Society Forum) សមាគមតម្លាភាពលីបង់ (the Lebanese Transparency Association) មជ្ឈមណ្ឌលនយោបាយសកម្ម (Center for Responsive Politics) វិទ្យាស្ថានប្រ៊ូកឃីងស៍ (the Brookings Institute) សាកលវិទ្យាល័យចនហបឃីនស៍ (John Hopkins University) និង គណៈកម្មការរៀបចំការបោះឆ្នោតសហព័ន្ធសហរដ្ឋអាមេរិច (the US Federal Election Commission) ក៏បានចូលរួមយ៉ាងសកម្មផងដែរនៅក្នុងកិច្ចប្រជុំទាំងនេះ។ ទាំងកំណត់ហេតុស្តីពីការប្រជុំ ទាំងរបាយការណ៍ស្តីពីហិរញ្ញវត្ថុនយោបាយសម្រាប់ការបោះឆ្នោត ឆ្នាំ ២០០៩ នៅប្រទេសលីបង់ អាចរកមើលបាននៅលើគេហទំព័រ "ហិរញ្ញវត្ថុ និង នយោបាយ"។*

[7] *"ការកសាងធនធាននៅក្នុងលទ្ធិប្រជាធិបតេយ្យ អភិបាលកិច្ច និង ការបោះឆ្នោត" (BRIDGE) ដែលមានគេហទំព័រ www.bridge-project.org បានក្លាយទៅជាបទដ្ឋានការងារ ដែលត្រូវបានយកទៅប្រើប្រាស់ផងដែរ ដោយអង្គការ UNDP UNEAD International IDEA ហើយនិងគណៈកម្មការ*

ដើម្បីធានាឲ្យបានកាន់តែច្រើនតាមដែលអាចធ្វើទៅបាននូវជំនាញសមត្ថភាព សម្រាប់ផ្តល់ជាព័ត៌មានដល់គម្រោងកម្មវិធីនេះ និង សម្រាប់ទាញយកអត្ថប្រយោជន៍ពីបទពិសោធន៍របស់អ្នកជំនាញនានាមកពីជុំវិញពិភពលោក ដែលធ្វើការលើគ្រប់ទិដ្ឋភាពនៃហិរញ្ញវត្ថុនយោបាយ ដូចជា៖ ការធ្វើបទប្បញ្ញត្តិ ការអនុវត្ត ការត្រួតពិនិត្យ និង ការស្រាវជ្រាវជាដើម អង្គការ *អាយហ្វេស*បានបង្កើតក្រុមពិគ្រោះយោបល់ផ្នែកហិរញ្ញវត្ថុនយោបាយ មួយដើម្បីធ្វើការលើគម្រោងកម្មវិធីនេះ។ អ្នកជំនាញការល្បីៗទាំង ៦០ រូប មកពីបណ្តាប្រទេសចំនួន ៣៧ នៅគ្រប់ទ្វីបទាំងអស់បានទទួលយកការអញ្ជើញរបស់អង្គការអាយហ្វេសដើម្បីចែករំលែកចំណេះដឹងរបស់ពួកគេស្តីពីបញ្ហាផ្សេងៗ ដែលទាក់ទងនឹងហិរញ្ញវត្ថុនយោបាយ។ នៅពេលដែលសៀវភៅនេះត្រូវបានចងក្រងឡើង សំនួរជាមូលដ្ឋានជាច្រើនដែលមាននៅគ្រប់ជំពូកនីមួយៗ ត្រូវបានដាក់ជូនក្រុមពិគ្រោះយោបល់ដើម្បីធ្វើការបំភ្លឺ ហើយការឆ្លើយតបរបស់ពួកគេបានជួយកែលម្អអត្ថបទចុងក្រោយនៃសៀវភៅដែលបានបោះពុម្ពផ្សាយនេះ។ កម្រងចម្លើយបំភ្លឺរបស់អ្នកជំនាញទាំងនោះ អាចរកមើលបាននៅលើគេហទំព័រ "www.moneyandpolitics.net"។

សៀវភៅនេះប្រមូលផ្តុំបទពិសោធន៍ទាំងឡាយដែលយើងបានស្រាវជ្រាវតាមរយៈគម្រោងកម្មវិធីនេះ ហើយ និងសកម្មភាពមួយចំនួនផ្សេងទៀត។ បើទោះជា សៀវភៅនេះ ជាក់ស្តែង ពុំអាចគ្របដណ្តប់បានគ្រប់ផ្នែកទាំងអស់ក៏ពិតមែន ក៏ប៉ុន្តែជំពូកនីមួយៗដែលនិយាយអំពីការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយ ការដាក់កម្រិតលើការចំណាយ ការផ្តល់មូលនិធិសាធារណៈ ដល់បេក្ខជន និង គណបក្សនយោបាយ និងការអនុវត្តបទបញ្ជាហិរញ្ញវត្ថុនយោបាយ សុទ្ធតែបានបង្ហាញបទពិសោធន៍ល្អៗនៅក្នុងវិស័យសំខាន់ៗជាច្រើន។ សទ្ទានុក្រមមួយដែលភ្ជាប់មកជាមួយសៀវភៅនេះបានពន្យល់អំពីពាក្យសព្ទសំខាន់ៗនៅក្នុងបច្ចេកសព្ទហិរញ្ញវត្ថុនយោបាយ។ សម្រាប់មិត្តអ្នកអានទាំងឡាយណាដែលចាប់អារម្មណ៍ចង់ស្វែងយល់ឲ្យបានកាន់តែស៊ីជម្រៅថែមទៀតនោះ សូមរកមើលនៅក្នុងបញ្ជីអត្ថបទសម្រាប់ការអានបន្ថែមដែលក្នុងនោះមានឯកសារសំខាន់ៗ និង គេហទំព័រជាច្រើន។

## *បទពិសោធន៍នានាពីជុំវិញពិភពលោក និង ការមិនអនុវត្តទ្រឹស្តី "ពុម្ពមួយត្រូវគ្រប់ទំហំទាំងអស់"*

នៅក្នុងស្នាដៃសំណេរដ៏សំខាន់មួយស្តីពីហិរញ្ញវត្ថុនយោបាយ អ្នកនិពន្ធ *កាល-ហាន ណាស្មាឈ័រ* (Karl-Heinz Nassmacher) បានពន្យល់ថា "ការប៉ុនប៉ងក្នុងការផ្ទេរបទពិសោធន៍ណាមួយ ត្រូវចាប់ផ្តើមចេញពីការទទួលស្គាល់ភាពខុសគ្នា"[8]។ លោក *ម៉ៃខឹល ពីនតូ ឌូឈីនស្គី*(Michael Pinto-Duschinsky) ក៏បានថ្លែងស្រដៀងគ្នានេះដែរថា "ពុំមានច្បាប់រូបមន្តមួយ ឬ វិធីសាស្ត្ររួមណាមួយនៃការធ្វើឧបត្ថម្ភធន ទំនងជាអាចត្រូវបានយកទៅអនុវត្តឲ្យបានសម្រាប់គ្រប់ប្រជាជាតិនោះទេ ជាពិសេសក្នុងខណៈដែលធនធាននានាដែលត្រូវការចាំបាច់សម្រាប់យកទៅអនុវត្តច្បាប់ និង យន្តការឧបត្ថម្ភធនទាំងនោះមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងនោះ"[9]។

---

*រៀបចំការបោះឆ្នោតអូស្ត្រាលី។ កិច្ចប្រជុំមួយសម្រាប់រៀបចំឯកសារបណ្តុះបណ្តាល BRIDGE បានប្រព្រឹត្តទៅនៅទីក្រុងស្តុកខុម (ប្រទេសស៊ុយអែត) កាលពីខែឧសភា ឆ្នាំ២០០៩ ដែលក្នុងនោះមានអ្នកចូលរួមមកពីគណៈកម្មការបោះឆ្នោតចក្រភពអង់គ្លេស និង អង្គការតម្លាភាពអន្តរជាតិអាល្លឺម៉ង់ និង ឡាទ្វី។ ACE ដែលមានគេហទំព័រ www.aceproject.org គឺជាបណ្តាញចែករំលែកចំណេះដឹងអំពីការបោះឆ្នោតតាមគេហទំព័រអាំងទែណែតយ៉ាងទូលំទូលាយ ដែលពុំធ្លាប់មានពីមុនមក។*

8 *ណាស្មាឈ័រ (២០០៣)៖ សញ្ញាណស្តីអំពី៖ "គណបក្សនយោបាយ ការផ្តល់មូលនិធិ និង លទ្ធិប្រជាធិបតេយ្យ" ទំព័រ២ , ការផ្តល់មូលនិធិដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោត, សៀវភៅណែនាំជាស៊េរី, International IDEA, ស្តុកខុម។*

9 *ពីនតូ-ឌូឈីនស្គី ម៉ៃឃើល (២០០២), ហិរញ្ញវត្ថុនយោបាយនៅក្នុងសហគមន៍ខំមិនវែល ទំព័រ ២៥, សៀវភៅបោះពុម្ពផ្សាយជាស៊េរី៖ ការពិចារណាអំពីលទ្ធិប្រជាធិបតេយ្យ ច្បាប់ទី១, លេខាធិការដ្ឋានខំមិនវែលប្រចាំទីក្រុងឡុង។*

ទោះបីជាបែបនេះក៏មានឥទ្ធិពលលើគម្រោងកម្មវិធីនេះដែរ ពោលគឺតាមរយៈការចងក្រងសៀវភៅនេះ។ ដូចគ្រប់សកម្មភាពការងារទាំងអស់របស់អង្គការ*អាយហ្វេស*ដែរ សៀវភៅនេះពុំមានបំណងណែនាំ ឬ ដាក់ចេញនូវអភិក្រម ឬ ដំណោះស្រាយជាក់លាក់ណាមួយនោះទេ ។ ផ្ទុយមកវិញ បំណងរបស់យើងគឺផ្តើមអញ្ជើញអ្នកពាក់ព័ន្ធឲ្យចូលរួមការពិភាក្សាលើបទពិសោធន៍ដែលយើងបានទទួលរហូតមកទល់នឹងពេលនេះ ហើយនិងរបៀបដែលប្រទេសនានានៅជុំវិញពិភពលោកអាចទាញយកអត្ថប្រយោជន៍ពីប្រទេសដទៃទៀត នៅពេលដែលយើងព្យាយាមស្វែងយល់ពីសារសំខាន់ និង ឥទ្ធិពលនៃហិរញ្ញវត្ថុនៅក្នុងនយោបាយ។

ក្នុងខណៈដែលគេអាចបង្កើតសំណុំវិធានរួមមួយ ដែលភាគីពាក់ព័ន្ធភាគច្រើន ឬ ទាំងអស់នឹងយល់ស្រប ការធ្វើបែបនេះអាចធ្វើទៅបានលុះត្រាតែ គេធ្វើឲ្យវិធានទាំងនោះមានលក្ខណៈទូលំទូលាយ គោលៗ ដោយពុំមានអត្ថន័យជាក់លាក់។ ការសន្ទនាដែលមានជាហូរហែអំពីតម្លៃដែលគេត្រូវលើកស្ទួយ និង អំពីប្រសិទ្ធភាពនៃដំណោះស្រាយផ្សេងៗដែលស្ថិតនៅក្នុងស្ថានភាពខុសៗគ្នាគឺជាអ្វីដែលគេចង់បាន។

## *ទស្សនទានសំខាន់ៗនៅក្នុងវិស័យហិរញ្ញវត្ថុនយោបាយ*

ខណៈដែលមានការទទួលស្គាល់ជាយូរមកហើយ អំពីសារសំខាន់នៃហិរញ្ញវត្ថុក្នុងវិស័យនយោបាយ (ដូចជាការទិញសន្លឹកឆ្នោតដែលគេរាយការណ៍មកថាបានកើតមាននៅក្នុងប្រទេសក្រិចសម័យបុរាណ) នៅក្នុងរយៈពេលពីរ ឬ បី ទសវត្សចុងក្រោយនេះ គេសង្កេតឃើញមានការកើនឡើងគួរឲ្យកត់សម្គាល់ចំពោះការខិតខំប្រឹងប្រែងក្នុងការធ្វើបទប្បញ្ញត្តិដើម្បីគ្រប់គ្រងហិរញ្ញវត្ថុក្នុងវិស័យនយោបាយនៅទូទាំងពិភពលោក តាមរយៈការតម្រូវឲ្យមានការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយ ការដាក់បម្រាម និង ដាក់កម្រិតផ្សេងៗលើចំណូល និង ចំណាយរបស់បេក្ខជន និង គណបក្សនយោបាយ និង ការផ្តល់ថវិកាពីរដ្ឋដល់បេក្ខជន និង គណបក្សនយោបាយ ។ ក្រុមអង្គការសង្គមស៊ីវិលនាពេលបច្ចុប្បន្ននេះកាន់តែមានភាពសកម្មជាងពេលមុន នៅក្នុងការត្រួតពិនិត្យតាមដានសកម្មភាពហិរញ្ញវត្ថុរបស់គណបក្សនយោបាយ បេក្ខជនឈរឈ្មោះនិង មន្ត្រីដែលទទួលអាណត្តិតាមរយៈការជាប់ឆ្នោត។

នៅពេលដែលការចោទសួរអំពីតួនាទីហិរញ្ញវត្ថុនៅក្នុងកិច្ចការរបស់គណបក្សនយោបាយ និងការប្រព្រឹត្តទៅនៃយុទ្ធនាការឃោសនាបោះឆ្នោតបានទទួលការចាប់អារម្មណ៍កាន់តែច្រើនឡើងៗនៅពាសពេញពិភពលោក គេបានប្រមូលផ្តុំបទពិសោធន៍ជាច្រើនតាមរយៈការចូលរួមអនុវត្តជាក់ស្តែង ការធ្វើបទបញ្ជាសម្រាប់គ្រប់គ្រង និង ការត្រួតពិនិត្យតាមដានហិរញ្ញវត្ថុនយោបាយ ហើយនិងតាមរយៈការយកចិត្តទុកដាក់សិក្សាស្រាវជ្រាវ ព្រមទាំងការផ្តល់ជំនួយអន្តរជាតិសំរាប់សកម្មភាពទាំងនោះ។

ក្នុងកិច្ចខិតខំប្រឹងប្រែងស្វែងយល់បទពិសោធន៍នានា អង្គការមួយចំនួនបានបង្កើតតារាងមួយដែលនិយាយអំពីការអនុវត្តល្អៗដែលគេបានទទួល និង ទស្សនទានសំខាន់ៗ ពាក់ព័ន្ធទៅនឹងបញ្ហាហិរញ្ញវត្ថុគណបក្សនយោបាយនេះ។ ខណៈដែលតារាងនីមួយៗ មានការឆ្លុះបញ្ចាំងពីបទពិសោធន៍ និង អភិក្រមប្លែកៗគ្នាចំពោះបញ្ហាហិរញ្ញវត្ថុនយោបាយ មានអត្ថន័យសំខាន់ៗលេចឡើងស្ទួនគ្នាជាច្រើន។ នៅក្នុងតារាងខាងក្រោមនេះ ទស្សនទានសំខាន់ៗអំពីហិរញ្ញវត្ថុនយោបាយត្រូវបានធ្វើការបែងចែកជាក្រុមក្រោមប្រធានបទរួមគ្នាមួយ ហើយជាបន្តបន្ទាប់ យើងបានសម្រេចយកទស្សនទានរួមមួយចំនួនដូចខាងក្រោម ដែលបានជះឥទ្ធិពលមកលើគម្រោងកម្មវិធី និង ការពុម្ពផ្សាយសៀវភៅនេះ។

១) ហិរញ្ញវត្ថុមានសារៈសំខាន់ណាស់សម្រាប់នយោបាយប្រជាធិបតេយ្យ ហើយគណបក្សនយោបាយត្រូវតែមានលទ្ធភាពទទួលបានមូលនិធិដើម្បីចូលរួមក្នុងឆាកនយោបាយ។ បទបញ្ញាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុនយោបាយមិនត្រូវរារាំងដល់ការប្រកួតប្រជែងប្រកបដោយភាពស្វិតស្វាញនោះទេ។
២) ហិរញ្ញវត្ថុពុំដែលជាផ្នែកមួយនៃប្រព័ន្ធនយោបាយដែលពុំចេះមានបញ្ហានោះទេ ដូចនេះគេចាំបាច់ត្រូវការបទបញ្ញាដើម្បីគ្រប់គ្រង។
៣) បរិបទ និង វប្បធម៌នយោបាយត្រូវតែយកមកពិចារណា នៅពេលដែលគេបង្កើតយុទ្ធសាស្ត្រដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងនយោបាយ។
៤) បទបញ្ញាដ៏មានប្រសិទ្ធិភាព និង ការបើកចំហរព័ត៌មានអាចជួយដល់ការគ្រប់គ្រងផលប៉ះពាល់អវិជ្ជមាននៃតួនាទីរបស់ហិរញ្ញវត្ថុនៅក្នុងនយោបាយ លុះត្រាតែមានការបង្កើត និង ការអនុវត្តបទបញ្ញានោះឲ្យបានត្រឹមត្រូវ។
៥) ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពអាស្រ័យទៅលើសកម្មភាពនៅក្នុងការប្រាស្រ័យទាក់ទង ដែលធ្វើឡើងដោយភាគីពាក់ព័ន្ធនានា (ដូចជា អ្នកធ្វើបទបញ្ញា ក្រុមសង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយ) និងផ្អែកលើតម្លាភាព។

ការយល់ឃើញទាំងនេះ នឹងមានបញ្ជាក់ជូនថែមទៀតនៅក្នុងតារាង១ និងតារាង២។ តារាង១បង្ហាញអំពីការយល់ឃើញសំខាន់ៗដែលមានលក្ខណៈខុសប្លែកគ្នា ដែលដកស្រង់ចេញពីប្រភពផ្សេងៗ ដូចដែលយើងបានចាត់បញ្ចូលទៅក្នុងក្រុមនីមួយខាងលើ។ ប្រភពព័ត៌មានដទៃទៀត (ដែលក្នុងករណីជាច្រើនគេពុំបានដាក់បញ្ចូលតារាងជាក់លាក់មួយចំនួននៃការយល់ឃើញសំខាន់ៗ ក៏ប៉ុន្តែយ៉ាងហោចណាស់បានបង្ហាញអំពីបទពិសោធន៍នានា ) ក៏ត្រូវបានប្រើប្រាស់នៅក្នុងតារាងទី១ខាងលើនេះដែរ ដើម្បីធ្វើការពិចារណាថែមទៀត និងពង្រីកវិសាលភាពនៃការយល់ឃើញទាំងអស់ខាងលើនេះ។ តារាង២ បង្ហាញអំពីការគាំទ្រដែលមាននៅក្នុងកាតព្វកិច្ចអន្តរជាតិមួយចំនួនដែលចេះតែមានការកើនឡើងជាលំដាប់ចំពោះការយល់ឃើញសំខាន់ៗទាំងនោះ ដែលបានជួយដោះស្រាយបញ្ហាហិរញ្ញវត្ថុនយោបាយ[10]។

ទស្សនទានសំខាន់ៗទាំងនេះ ជាបន្តបន្ទាប់ ប្រមូលផ្ដុំបទពិសោធន៍ និង ចំណេះដឹងពីសំណាក់បណ្ដាអង្គការ និង បុគ្គលជាច្រើនដែលធ្វើការងារក្នុងគ្រប់តំបន់ទាំងអស់នៃពិភពលោក។ យើងសូមសំដែងនូវការដឹងគុណជាពិសេសចំពោះសិក្ខាកាមដែលបានចូលរួមក្នុងសិក្ខាសាលាមួយដែលរៀបចំឡើងដោយអង្គការអាយហ្វេស (IFES) និងអង្គការអាយឌាអន្តរជាតិ (International IDEA) ក្នុងទីក្រុងស្តុកខុម (ប្រទេសស៊ុយអែត) កាលពីខែ ឧសភា ឆ្នាំ ២០០៩ ក៏ដូចជាចំពោះសមាជិកទាំងអស់នៃក្រុមពិគ្រោះយោបល់ដូចបានរៀបរាប់មកខាងលើ។

យើងសូមធ្វើការបញ្ចប់បុព្វកថានេះ ដោយបញ្ជាក់យ៉ាងច្បាស់ថា ក៏ដូចជា ក្រុមប្រឹក្សានៃគណៈកម្មាធិការរដ្ឋមន្ត្រីអឺរ៉ុប យើងមានទំនុកចិត្តថា ការផ្សព្វផ្សាយឲ្យសាធារណជនបានយល់អំពីការបង្ការ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ក្នុងការផ្ដល់ហិរញ្ញវត្ថុដល់គណបក្សនយោបាយ មានសារៈសំខាន់ណាស់សម្រាប់ឲ្យស្ថាប័នប្រជាធិប-តេយ្យមានដំណើរការល្អប្រសើរ[11]។

---

[10] *"កាតព្វកិច្ចអន្តរជាតិ" នៅទីនេះសំដៅទៅលើអត្ថបទដែលមានចែងអំពីកាតព្វកិច្ចនានាតាមរយៈច្បាប់អន្តរជាតិ ឬ ដែលបានផ្ដល់ការបកស្រាយពន្យល់អំពីកាតព្វកិច្ចទាំងនោះ។ តាមធម្មតា ពុំមែនអត្ថបទទាំងអស់សុទ្ធតែភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ឬ សីលធម៌ចំពោះរដ្ឋទាំងអស់នោះទេ។*

[11] *ក្រុមប្រឹក្សាអឺរ៉ុប (២០០៣)៖ អនុសាសន៍របស់គណៈកម្មាធិការរដ្ឋមន្ត្រីនៃរដ្ឋជាសមាជិកស្ដីពីវិធានរួមសម្រាប់ប្រឆាំងអំពើពុករលួយនៅក្នុងការផ្ដល់មូលនិធិដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោត ដែលបានអនុម័តនៅថ្ងៃទី៨ ខែសីហា ឆ្នាំ ២០០៣។*

## *តារាង១៖ បណ្ដុំទស្សនទានសំខាន់ៗស្ដីពីហិរញ្ញវត្ថុនយោបាយ*[12]

| ក្រុមទី ១ | ទស្សនទានសំខាន់ៗ (ប្រភព) |
|---|---|
| ហិរញ្ញវត្ថុមានសារៈសំខាន់ណាស់សម្រាប់នយោបាយប្រជាធិបតេយ្យ ដោយគណបក្សនយោបាយត្រូវតែមានលទ្ធភាពទទួលបានមូលនិធិដើម្បីចូលរួមក្នុងឆាកនយោបាយ។ បទបញ្ញាសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុនយោបាយមិនត្រូវរារាំងដល់ការប្រកួតប្រជែងប្រកបដោយភាពស្មិតស្មាញនោះទេ។ | ▪ ថវិកាគឺជាសមាសភាពដ៏សំខាន់នៃដំណើរការបោះឆ្នោតបែបប្រជាធិបតេយ្យ (IFES)<br>▪ គណបក្សនយោបាយនិងការប្រកួតប្រជែងដើម្បីអំណាចនយោបាយ មានភាពចំបាច់ណាស់ចំពោះចរិតភាពប្រជាធិបតេយ្យនិងអភិបាលកិច្ចល្អ។ (IDEA)<br>▪ ថវិកាគឺជាផ្នែកសំខាន់មួយក្នុងដំណើរការនេះ ហើយគេត្រូវតែចាត់ទុកថវិកាថាជាធនធានយ៉ាងសំខាន់មួយសម្រាប់ការអនុវត្តនយោបាយឲ្យមានលក្ខណៈល្អប្រសើរ។ (IDEA)<br>▪ ការពឹងផ្អែកច្រើនហួសហេតុលើប្រភពមូលនិធិពីវិស័យឯកជននិងសាធារណៈពុំមែនជាភាពឆ្លាតវៃនោះទេ។ (IDEA)<br>▪ គណបក្សនយោបាយត្រូវតែជាផ្នែកមួយនៃដំណោះស្រាយនេះ។ (NDI)<br>▪ គណបក្សនយោបាយត្រូវតែរឹងមាំឡើង ដើម្បីបំពេញតួនាទីឲ្យបានប្រសើរនៅក្នុងសង្គម។ (NDI)<br>▪ ហិរញ្ញប្បទានសាធារណៈគួរត្រូវបានពិចារណា ប៉ុន្តែត្រូវភ្ជាប់ជាមួយកំណែទម្រង់គណបក្សនយោបាយ។ (NDI)<br>▪ យុត្តិធម៌និងភាពសុចរិតក្នុងការទទួលបានព័ត៌មាន។ (TI 2003)<br>▪ ភាពចាំបាច់ក្នុងការបញ្ចៀសពីការបង្កើតបទបញ្ញាច្រើនហួសហេតុនិងត្រូវតាក់តែងតែច្បាប់សម្រាប់គ្រប់គ្រងតែអ្វីដែលអាចអនុវត្តបាននិងដែលជាកម្មវត្ថុនៃការត្រួតពិនិត្យ។ (IDEA/OAS)<br>▪ ការបញ្ញត្តិនៅក្នុងចាប់នូវទណ្ឌកម្មច្បាស់លាស់ ហើយសមស្របជាមួយលក្ខណៈនិង ទំហំនៃការបំពានទៅលើបទដ្ឋានដែលកំពុងមានជាធរមាន។ល។ ការយកចិត្តទុកដាក់តែទៅលើ វិធានការខាងទណ្ឌកម្មពុំបាននាំមកនូវការផ្ដល់មូលនិធិដោយវិតតែមានយុត្តិធម៌ដល់គណបក្សនយោបាយទេ តែផ្ទុយទៅវិញវាបានបង្កឲ្យមានហានិភ័យសម្រាប់ការដាក់ទណ្ឌកម្មដែលគេពុំអាចយកមកអនុវត្តបានសម្រាប់វិធានដែលទទួលរងការបំពាន ដោយហេតុថាទណ្ឌកម្មនោះមានលក្ខណៈស្រាលពេក ឬ ធ្ងន់ធ្ងរពេក។ (PASOS) |

## បទពិសោធន៍ដែលយើងទទួលបាន

- លទ្ធិប្រជាធិបតេយ្យមិនអាចកើតមានឡើងបានឡើយប្រសិនបើពុំមានការរៀបចំ។ (Michels)
- ប្រទេសប្រជាធិបតេយ្យដែលរឹងមាំត្រូវធ្វើឲ្យមានគណបក្សនយោបាយរឹងមាំ។ ដូចគ្នាដែរ គណបក្សនយោបាយត្រូវការធនធាន ដើម្បីទ្រទ្រង់និងដំណើរការហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានរបស់គណបក្សឲ្យបានគ្រប់គ្រាន់ដើម្បីជាតំណាងដល់ប្រជាពលរដ្ឋដើម្បីកសាងសមត្ថភាពដើម្បីប្រកួតប្រជែងក្នុងការបោះឆ្នោតនិងចូលរួមចំណែកក្នុងការជជែកដេញដោលអំពីគោលនយោ-បាយ។ ហេតុដូចនេះហើយ ទើបមានជាគណបក្សទាំងឡាយត្រូវការគៀងគររកមូលនិធិ។ (IDASA)
- ថវិកាមានសារៈសំខាន់ណាស់ ហើយភាពចាំបាច់នៃថវិកាស្ថិតនៅត្រង់ការដែលគេយកវាទៅប្រើប្រាស់ដើម្បីស្វែងរកឥទ្ធិពល ក្នុងការផ្ដល់ឲ្យនៅធនធានមួយផ្សេងទៀត ឬ ត្រូវគេប្រើប្រាស់រួមជាមួយនឹងធនធានផ្សេងៗទៀតដើម្បីទទួលបានអំណាចនយោបាយ។ (Alexander)
- បទបញ្ញាហិរញ្ញវត្ថុនយោបាយប្រាកដជាអាចពង្រឹងការប្រកួតប្រជែងប្រកបដោយភាពស្មិតស្មាញបាន ប្រសិនបើគេអនុវត្តវាបានត្រឹមត្រូវ។ (Loprest)

---

[12] *យោបល់មួយចំនួនបានលើកឡើងថាគណបក្សនយោបាយត្រូវបានគេសន្មត់ថាបានធ្វើសកម្មភាពយ៉ាងលំអៀង។ ទស្សនទានដ៏ចម្បងនេះដែលបានលើកឡើងអង្គការអោយខៀវអន្តរជាតិ ប្រហែលជាត្រូវបកស្រាយថា "ជាអកុសល សកម្មភាពមួយចំនួនរបស់គណបក្សនយោបាយមានចរិតលំអៀងដោយហេតុតែសកម្មភាពទាំងនោះមានផលប៉ះពាល់អវិជ្ជមានដល់ផលប្រយោជន៍ជាតិ។*

| ក្រុមទី ២ | ទស្សនទាន (ប្រភព) |
|---|---|
| ហិរញ្ញវត្ថុពុំដែលជាផ្នែកមួយនៃប្រព័ន្ធនយោបាយដែលមិនមែនចេះតែមិនមានបញ្ហានោះទេ ដូចនេះ គឺចាំបាច់ត្រូវការបទបញ្ញាដើម្បីគ្រប់គ្រងវា។ | ▪ ទប់ស្កាត់ការរីករាលដាលនៃឥទ្ធិពល និង ទំនាស់ផលប្រយោជន៍។(TI 2003)<br>▪ ជាអកុសល សកម្មភាពមួយចំនួនរបស់គណបក្សនយោបាយមានលក្ខណៈលំអៀងសុទ្ធសាធ។ (IDEA)<br>▪ បញ្ហាដែលបានរកឃើញមាន៖<br>✓ ទីលានប្រកួតប្រជែងពុំស្មើភាពគ្នា<br>✓ លទ្ធភាពក្នុងការទទួលបានអំណាចពុំស្មើភាពគ្នា<br>✓ អ្នកនយោបាយទទួលរងការគាបសង្កត់<br>✓ នយោបាយរងការបំផ្លាញ។ (USAID)<br>▪ ចាត់ទុកជាការប្រើប្រាស់ហិរញ្ញវត្ថុនយោបាយពុករលួយ (Pinto-Duschinsky 2005)៖<br>✓ វិភាគទាននយោបាយដែលផ្ទុយពីច្បាប់ហិរញ្ញវត្ថុនយោបាយដែលមានជាធរមាន<br>✓ ការប្រើប្រាស់ថវិការសម្រាប់ធ្វើឃោសនា ឬជាប្រយោជន៍របស់គណបក្សដែលអ្នកនយោបាយក្នុងអណត្តិទទួលបានពីប្រតិបត្តិការពុករលួយ<br>✓ ការប្រើប្រាស់ធនធានរដ្ឋដោយគ្មានការអនុញ្ញាតជាប្រយោជន៍សម្រាប់គណបក្សនយោបាយ<br>✓ ការទទួលហិរញ្ញវត្ថុដែលជាថ្នូរទៅនឹងការផ្តល់ផលប្រយោជន៍ដល់អ្នកធ្វើវិភាគទាន ឬ សន្យាផ្តល់ប្រយោជន៍ឲ្យអ្នកធ្វើវិភាគទាននៅពេលដែលខ្លួនបានជាប់ឆ្នោត។<br>✓ វិភាគទានដែលបានពីប្រភពដែលពុំមានកេរ្តិ៍ឈ្មោះមិនល្អ<br>✓ ការចំណាយថវិការសំរាប់គោលបំណងដែលច្បាប់ហាមឃាត់ ដូចជាការទិញសន្លឹកឆ្នោត ជាដើម។ |

## បទពិសោធន៍ដែលយើងទទួលបាន

- ក្នុងរយៈពេលវែង មូលនិធិមិនស្របច្បាប់ និងមិនសមស្រប ជាពិសេសអាចធ្វើឲ្យគណបក្សនយោបាយបាត់បង់នីត្យានុកូលភាពរបស់ខ្លួន និង ធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យជារួម។ (Nassmacher)
- ហិរញ្ញវត្ថុនយោបាយបានបង្កឲ្យមានការផ្លាស់ប្តូរនៅក្នុងទម្រង់នយោបាយនៅទូទាំងពិភពលោក។ វាក៏បានធ្វើឲ្យមានការផ្លាស់ប្តូរផ្នែកមនោគមវិជ្ជា ការលាលែងពីតំណែងទាំងក្តីអាម៉ាស់ អំពើពុករលួយ បញ្ហាអាស្រូវផ្សេងៗ ហើយរិតតែធ្ងន់ធ្ងរទៅទៀតនោះ គឺភាពអនាធិបតេយ្យ។ (Emelonye)

| ក្រុមទី ៣ | ទស្សនទានសំខាន់ៗ (ប្រភព) |
|---|---|
| បរិបទ និង វប្បធម៌នយោបាយត្រូវតែយកមកពិចារណា នៅពេលដែលគេបង្កើតយុទ្ធសាស្ត្រដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងនយោបាយ។ | ▪ ប្រទេសនីមួយៗត្រូវមានដំណោះស្រាយជាក់លាក់របស់ខ្លួន។(NDI)<br>▪ ពុំមែនមានតែរូបមន្តគោលនយោបាយដែលសមស្របតែមួយគត់សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុនយោបាយនោះទេ។ (IFES)<br>▪ ហិរញ្ញប្បទាននយោបាយ និង ចរិតលក្ខណៈនៃប្រព័ន្ធនយោបាយណាមួយមានទំនាក់ទំនងជាមួយគ្នាជារួម។ ក្នុងលក្ខណៈដោយឡែក ហិរញ្ញប្បទាននយោបាយ និង ប្រព័ន្ធគណបក្សនយោបាយមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ។ (IDEA/OAS) |

| | |
|---|---|
| | ▪ ហិរញ្ញវត្ថុនយោបាយ មានទំនងយ៉ាងរឹងមាំ ជាមួយនឹងគុណភាពនៃប្រជាធិបតេយ្យ។<br>▪ នយោបាយ ដែលមានន័យថា ដំណោះស្រាយមួយអាចសមស្របជាមួយបរិបទរបស់ប្រទេសមួយ តែពុំអាចត្រូវនឹងបរិបទរបស់ប្រទេសមួយទៀតឡើយ។ (IDEA/OAS)<br>▪ ហិរញ្ញប្បទាននយោបាយ  គឺជាបញ្ហាមួយដែលនឹងត្រូវឆ្លងកាត់ការកែទម្រង់ច្បាប់ជាបន្តបន្ទាប់  ដូចនេះ  វាជាការសំខាន់ណាស់ដែលយើងត្រូវយល់អំពីដំណើរការផ្លាស់ប្តូរ និង លក្ខណៈបណ្តោះអាសន្ននៃបញ្ហានេះ។ (IDEA/OAS)<br>▪ ការផ្តល់មូលនិធិដល់គណបក្សនយោបាយ  និង យុទ្ធនាការឃោសនាបោះឆ្នោត គឺជាបញ្ហាដ៏សែនស្មុគស្មាញ និង ចម្រូងចម្រាស់។ វាជាបញ្ហាដែលគេមិនទាន់ដោះស្រាយរួចនៅឡើយ និងដែលក៏ពុំមានដំណោះស្រាយសាកល ឬរូបមន្តសក្តិសិទ្ធណាមួយសម្រាប់បញ្ហានេះដែរ។ (IDEA/OAS) |

## បទពិសោធន៍ដែលយើងទទួលបាន

- បញ្ហានិងដំណោះស្រាយទាំងឡាយមានភាពខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត។ ពុំមានបណ្តុំវិធាន ឬវិធីសាស្ត្រនៃការធ្វើហិរញ្ញប្បទាននយោបាយ រួមមួយដែលទំនងជាយកទៅអនុវត្តបានសំរាប់រាល់ប្រជាជាតិទាំងអស់នោះទេ ដោយហេតុថា ធនធានដែលត្រូវការចាំបាច់សម្រាប់យកទៅអនុវត្តច្បាប់  និងការធ្វើហិរញ្ញប្បទាននយោបាយសំរាប់រដ្ឋនីមួយៗមានការខុសប្លែកគ្នាយ៉ាងខ្លាំង។ (Pinto-Duschinsky 2002)
- បទពិសោធន៍មួយក្នុងចំណោមបទពិសោធន៍សំខាន់ៗដែលយើងបានទទួលគឺថា  ពុំមានវិធានរួមមួយសម្រាប់ការរៀបចំប្រព័ន្ធហិរញ្ញវត្ថុនយោបាយសម្រាប់គ្រប់ស្ថានការណ៍នោះទេ។ នេះមានន័យថា អភិក្រមជាក់លាក់ សម្រាប់ប្រទេសនីមួយៗអាស្រ័យលើកត្តាមិនគិតពីការចូលរួមរបស់សហគមន៍អន្តរជាតិ  បទពិសោធន៍ផ្នែកនយោបាយរបស់ជាតិនីមួយៗ និង ពេលវេលានៃការបោះឆ្នោតជាដើម។ (Carlson, Dahl & Walecki)
- ... ការពិនិត្យមើលឡើងវិញ និង ការផ្លាស់ប្តូរគួរត្រូវបានធ្វើឡើងក្នុងក្របខ័ណ្ឌច្បាប់។ (Loprest)

| ក្រុមទី ៤ | ទស្សនទានសំខាន់ៗ (ប្រភព) |
|---|---|
| បទបញ្ញាដ៏មានប្រសិទ្ធិភាពនិង ការបើកចំហរព័ត៌មាន អាចជួយដល់ការគ្រប់គ្រងផលប៉ះពាល់ជាអវិជ្ជមាននៃតួនាទីរបស់ហិរញ្ញវត្ថុនៅក្នុងនយោបាយ លុះត្រាតែបទបញ្ញាហិរញ្ញវត្ថុនយោបាយត្រូវបានបង្កើតនិង អនុវត្តយ៉ាងត្រឹមត្រូវ។ | ▪ ការអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយប្រកបដោយប្រសិទ្ធិភាព បានផ្តល់ឲ្យយើងនូវតម្លាភាព ការត្រួតពិនិត្យនិង ការដាក់ទណ្ឌកម្មចំពោះអំពើរំលោភបំពានណាមួយ។ (IFES)<br>▪ អ្នកដែលមានភារកិច្ចបង្ខំឲ្យអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយត្រូវតែឯករាជ្យបំផុត។ (IFES)<br>▪ ...កំណែទម្រង់ណាមួយក៏ដោយទៅលើប្រព័ន្ធមូលនិធិនយោបាយ ត្រូវតែជាផ្នែកមួយយ៉ាងសំខាន់នៃការកែទម្រង់ការបោះឆ្នោត ឬ ការកែទម្រង់ផ្នែកនយោបាយទាំងមូល  ដោយហេតុថាកំណែទម្រង់ទាំងនេះនឹងនាំមកនូវកត្តាសំខាន់ៗមួយចំនួន  ដូចជា ការប្រកួតប្រជែងក្នុងចំណោមគណបក្សនយោបាយ លក្ខខណ្ឌនៃការប្រកួតប្រជែង ប្រព័ន្ធគណបក្សនយោបាយ ហើយចុងក្រោយគឺកិត្យានុភាព និង និត្យានុកូលភាពនៃលទ្ធិប្រជាធិបតេយ្យខ្លួនឯងផ្ទាល់។ (OAS/IDEA)<br>▪ ច្បាប់និង បទបញ្ញានានាត្រូវតែលាតសន្ធឹងឲ្យបានលើសពីការគ្រប់គ្រងហិរញ្ញវត្ថុនយោបាយទៅទៀត។ (NDI)<br>▪ ប្រសិទ្ធិភាពក្នុងការអនុវត្តនិង ការគ្រប់គ្រងលើវិធានការនានាដែលបានចែងនៅក្នុងបទបញ្ញា។ (TI 2003)<br>▪ ពហុភាពនៃការកែនត់អំពីចំណូលនិងចំណាយ។ (TI 2003) |

| | |
|---|---|
| | ▪ ... តម្រូវការក្នុងការត្រួតពិនិត្យប្រព័ន្ធមូលនិធិនយោបាយមិនត្រឹមតែនៅក្នុងក្របខ័ណ្ឌនៃបំណងប្រាថ្នារបស់ការកែទម្រង់ និង ការស្វែងរកផលប៉ះពាល់តែប៉ុណ្ណោះទេ ... ប៉ុន្តែថែមទាំងនៅក្នុងក្របខ័ណ្ឌនៃប្រសិទ្ធភាព និង លទ្ធផល ដែលយើងមិនចង់បាន ឬ លទ្ធផលអវិជ្ជមាននៃបទបញ្ញានោះទៀតផង ដោយចៀសវាងនូវកំហុសឆ្គងក្នុងការវាយតំលៃសើៗផ្អែកលើបែបបទដែលមានលក្ខណៈមិនប្រាកដនិយម។ (IDEA/OAS)<br>▪ មូលនិធិនយោបាយជាបញ្ហាមួយដែលនឹងត្រូវឆ្លងកាត់ដំណើរការកែទម្រង់ផ្អែកច្បាប់ជាបន្តបន្ទាប់ ហេតុនេះ វាជាការសំខាន់ដែលយើងត្រូវយល់អំពីដំណើរការប្រវត្តិ និង លក្ខណៈបណ្ដោះអាសន្នរបស់វា។ (PASOS) |

## បទពិសោធន៍ដែលយើងទទួលបាន

- ទោះបីជាពុំបានគ្រប់គ្រាន់ក៏ដោយ ការបើកចំហរព័ត៌មានអំពីគណនីនយោបាយគឺជាលក្ខខណ្ឌចាំបាច់មួយដើម្បីធ្វើឲ្យអ្នកនយោបាយមានការទទួលខុសត្រូវ និង កាត់បន្ថយអំពើពុករលួយផ្នែកនយោបាយ។ (Carlson & Walecki)
- យន្តការនេះគឺដើម្បីស្វែងរកតុល្យភាព ដែលសមស្របបំផុតសម្រាប់គោលបំណងនៃការអនុញ្ញាតឲ្យគណបក្សនីមួយៗទទួលបានឱកាសសមស្របដើម្បីផ្សព្វផ្សាយសារនយោបាយរបស់ខ្លួន។ ការធ្វើបែបនេះអាចធ្វើឲ្យមានការរួមបញ្ចូលគ្នារវាងការធ្វើហិរញ្ញប្បទានសាធារណៈ និង ការត្រួតពិនិត្យការចំណាយសម្រាប់ការបោះឆ្នោត។ (Goodwin-Gill)
- តាមដែលយើងបានដឹង បទប្បញ្ញត្តិដែលមានខ្លឹមសារល្អអាចជួយពីការអនុវត្តជាក់ស្ដែង ឬ អាចមានការឃ្លាំមើល ឬ អនុវត្តមិនបានដល់។ (គម្រោងយុត្តិធម៌សង្គមសេរី (Open Society Justice Initiative))
- ប្រសិនបើពុំមានការការពារខាងផ្លូវច្បាប់ អណ្ណត្តិ និង ធនធានឲ្យបានគ្រប់គ្រាន់ទេនោះ ស្ថាប័នអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយអាចនឹងប្រែក្លាយទៅជាឧបករណ៍ ឬ ជាអាវុធប្រកបដោយគ្រោះថ្នាក់នៅក្រោមការក្ដោបក្ដាប់របស់គណបក្សកាន់អំណាច។ (Vilks)
- ការបង្ហាញអំពីការទទួលខុសត្រូវជាសារវ័ន មានដូចជា៖ ការធ្វើរបាយការណ៍តាមពេលកំណត់ស្ដីអំពីចំណូល និង ចំណាយធ្វើជូនស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ហើយនិងការធ្វើសវនកម្មលើគណនីធនាគារតាមពេលកំណត់ ដោយក្រុមហ៊ុនសវនកម្មដែលមានការទទួលស្គាល់។ (Dundas)

| ក្រុមទី ៥ | ទស្សនទានសំខាន់ៗ (បរភព) |
|---|---|
| ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពអាស្រ័យទៅលើសកម្មភាពទាំងឡាយនៅក្នុងការប្រាស្រ័យទាក់ទងដែលធ្វើឡើងដោយភាគីពាក់ព័ន្ធនានា (ដូចជា ភ្នាក់ងារអនុវត្តបទបញ្ញា ហិរញ្ញវត្ថុនយោបាយ សង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយ) ហើយក៏ត្រូវការកែលម្អសមត្ថភាពផងដែរ។ | ▪ ការផ្តល់ហិរញ្ញប្បទានសម្រាប់ធ្វើសកម្មភាពនយោបាយរបស់គណបក្សនយោបាយ និង បេក្ខជនគួរតែជាបញ្ហាសម្រាប់ការពិភាក្សាដេញដោលជាសាធារណៈ។ (IDEA)<br>▪ ការទទួលបានព័ត៌មានអំពីហិរញ្ញវត្ថុនយោបាយនឹងជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ក្នុងការអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយជាផ្លូវការ។ (IFES)<br>▪ សង្គមស៊ីវិលគួរតែមានតួនាទីជាអ្នកតាមដានឃ្លាំមើល។ (NDI)<br>▪ តម្លាភាពអាចធ្វើឡើងតាមរយៈការបើកចំហរ និង ការបញ្ចេញផ្សព្វផ្សាយព័ត៌មាន។ (TI 2003)<br>▪ ត្រូវមានការចូលរួមពីសំណាក់សង្គមស៊ីវិល។ (TI 2003)<br>▪ ចូរលើកកម្ពស់តម្លាភាពនៅក្នុងទំនាក់ទំនងរវាងគណបក្សនយោបាយជាមួយនឹងពលរដ្ឋដែលខ្លួនតំណាង តាមរយៈការផ្សព្វផ្សាយឯកសារហិរញ្ញវត្ថុរបស់គណបក្សនយោបាយជាសាធារណៈ និង ការធានាឲ្យមានការទទួលបានព័ត៌មានយ៉ាងទូលំទូលាយ។ (PASOS) |

**បទពិសោធន៍ដែលយើងទទួលបាន៖**

- ដើម្បីធានាការអនុវត្តបទបញ្ជាហិរញ្ញប្បទាននយោបាយ ត្រូវមានមធ្យោបាយសម្រាប់ត្រួតពិនិត្យហិរញ្ញប្បទានរបស់បេក្ខជន និង គណបក្សនយោបាយ។ ដូច្នេះ តាមរយៈការបើកចំហរព័ត៌មាន តម្លាភាពហិរញ្ញប្បទាននយោបាយ គឺជាចំនុចចាប់ផ្តើមនៃក្របខណ្ឌបទបញ្ជាហិរញ្ញវត្ថុនយោបាយ។ តម្លាភាពក៏បានជួយពង្រឹងសិទ្ធិអំណាចម្ចាស់ឆ្នោតដើម្បីឲ្យពួកគេធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់នៅថ្ងៃបោះឆ្នោត។ (TI 2005)
- កិច្ចខិតខំប្រឹងប្រែងនានាគួរត្រូវបានធ្វើឡើងដើម្បីផ្តល់ព័ត៌មាន និង អប់រំដល់គ្រប់ភ្នាក់ងារទាំងអស់ដែលពាក់ព័ន្ធនឹងការបង្ហាញព័ត៌មានអំពីហិរញ្ញវត្ថុនយោបាយ មានដូចជា៖ ភ្នាក់ងារអនុវត្តបទបញ្ញត្តិហិរញ្ញវត្ថុនយោបាយ គណបក្សនយោបាយ បេក្ខជនឈរឈ្មោះបោះឆ្នោត សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និង សាធារណជន ជាដើម ស្តីអំពីតួនាទីនៃប្រព័ន្ធហិរញ្ញប្បទាននយោបាយ និង សារៈសំខាន់របស់វាក្នុងការបង្កើតឲ្យមាននូវដំណើរការបែបប្រជាធិបតេយ្យ និង ដំណើរការបោះឆ្នោតដែលអាចជឿទុកចិត្តបាន។ (Boneo & Dahl)

*តារាង២៖ ការផ្តល់ការគាំទ្រសម្រាប់បណ្តុំទស្សនទានសំខាន់ៗនៅក្នុងកាតព្វកិច្ចអន្តរជាតិ*

| បណ្តុំទស្សនទានសំខាន់ៗ | លិខិតុបករណ៍ដែលមានចែងពីកាតព្វកិច្ចអន្តរជាតិ(ប្រភព) |
|---|---|
| ១) ថវិការមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់នយោបាយប្រជាធិបតេយ្យ ហើយគណបក្សនយោបាយទាំងអស់ត្រូវតែមានលទ្ធភាពទទួលបានហិរញ្ញប្បទានដើម្បីចូលរួមក្នុងដំណើរការនយោបាយ។ បទបញ្ញាហិរញ្ញវត្ថុនយោបាយមិនត្រូវបង្កជាឧបសគ្គសម្រាប់ការប្រកួត-ប្រជែងដែលមានភាពស្វិតស្វាញនោះទេ។ | ▪ ការពង្រឹងគណបក្សនយោបាយ និង អង្គការនយោបាយដទៃទៀតគឺជាអាទិភាពសម្រាប់ប្រជាធិបតេយ្យ (អង្គការនៃបណ្តារដ្ឋអាមេរិក (មាត្រា៥))<br>▪ គណបក្សនយោបាយគួរទទួលបាននិរភាគទានហិរញ្ញវត្ថុពីថវិការដ្ឋ ដើម្បីចៀសវាងការពឹងផ្អែកលើជំនួយពីបុគ្គលឯកជន និងដើម្បីធានាបាននូវឱកាសប្រកបដោយសមភាពរវាងគណបក្សនយោបាយ។ (ក្រុមប្រឹក្សាអឺរ៉ុប ២០០១ (កថាខ័ណ្ឌទី ៨-២))<br>▪ គណបក្សនយោបាយ អាចស្វែងរក និង ទទួលមូលនិធិតាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុពីរដ្ឋ ឬ ឯកជន។<br>▪ រដ្ឋគួរជួយគាំទ្រដល់ការបង្កើត និង ការដំណើរការដោយសេរីរបស់គណបក្សនយោបាយ។ រដ្ឋអាចធ្វើបទបញ្ញាសម្រាប់គ្រប់គ្រងការផ្តល់ហិរញ្ញប្បទានដល់គណបក្សនយោបាយ និងយុទ្ធនាការឃោសនាបោះឆ្នោត បែងចែកឲ្យដាច់ពីគ្នារវាងបក្ស និង រដ្ឋ ព្រមទាំងដាក់លក្ខខណ្ឌសម្រាប់ការប្រកួតប្រជែងនៅក្នុងការបោះឆ្នោតឈរលើមូលដ្ឋានសមភាព។ (គណៈកម្មការវេនីស (Venice Commission) (កថាខណ្ឌ 2)) សហភាពអន្តរសភា (IPU (មាត្រា 4(1))) |
| ២) ថវិការពុំមែនជាផ្នែកដែលមិនចេះតែមិនមានបញ្ហានៅក្នុងប្រព័ន្ធនយោបាយទេ ដូច្នេះគេត្រូវការបទបញ្ញាសម្រាប់គ្រប់គ្រងបញ្ហាថវិកាក្នុងនយោបាយ។ | ▪ គួរយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហានានា ដែលជាប់ទាក់ទងទៅនឹងការចំណាយដ៏ច្រើនសន្ធឹកសន្ធាប់ទៅលើយុទ្ធនាការឃោសនាបោះឆ្នោតនិង ការបង្កើតប្រព័ន្ធហិរញ្ញវត្ថុនយោបាយប្រកបដោយតុល្យភាពនិងតម្លាភាព។ (អង្គការនៃបណ្តារដ្ឋអាមេរិក "មាត្រា៥")<br>▪ រដ្ឋជាភាគីនីមួយៗគួរតែអនុម័តបទបញ្ញត្តិនិងវិធានការដទៃទៀតដើម្បីៈ (ក) ហាមឃាត់ការប្រើប្រាស់មូលនិធិដែលគណបក្ស ឬ បេក្ខជននយោបាយបានទទួលដោយខុសច្បាប់ និង តាមរយៈការប្រព្រឹត្តអំពើពុករលួយដើម្បីគាំទ្រធនធានដល់គណបក្សនយោបាយរបស់ខ្លួន។ (សហភាពអាហ្វ្រិក "មាត្រា១០")<br>▪ ច្បាប់បោះឆ្នោតគួរតែហាមប្រាមរដ្ឋាភិបាលក្នុងការផ្តល់ជំនួយ ឬ ជួយដល់គណបក្សនយោបាយណាមួយដើម្បីទទួលបានផលប្រយោជន៍ដោយមិនយុត្តិធម៌។ (SADC (មាត្រា 3(១)) |
| ៣) បរិបទ និង វប្បធម៌នយោបាយត្រូវតែយកមកពិចារណានៅពេលបង្កើតយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងថវិកានៅក្នុងនយោបាយ។ | ▪ (តាមធម្មតា ឯកសារច្បាប់អន្តរជាតិពុំបានទទូចឲ្យមានការអនុវត្តខុសៗគ្នានៅក្នុងក្របខណ្ឌជាតិនោះទេ។ ជាធម្មតា គេបានដឹងយ៉ាងច្បាស់អំពីភាពចាំបាច់សម្រាប់ការកែតម្រូវបទបញ្ញាហិរញ្ញវត្ថុនយោបាយនានាដែលមានលក្ខណៈពិស្តារដើម្បីសម្របទៅនឹងលក្ខខណ្ឌរបស់ប្រទេសនីមួយៗ។ គេអាចធ្វើដូច្នេះបានដរាបណាបទបញ្ញាទាំងនោះគោរពតាមអនុសាសន៍ទូទៅដែលមាននៅក្នុងលិខិតអន្តរជាតិ។ ចូរគួសចំណាំថា មាត្រា៧ (កថាខណ្ឌទី៣) នៃអនុសញ្ញាសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយបានចែងថា រដ្ឋទាំងឡាយគួរអនុវត្តវិធានការក្នុងការលើកកំពស់តម្លាភាពក្នុងវិស័យហិរញ្ញវត្ថុនយោបាយដែលសមស្របទៅនឹងគោល-ការណ៍គ្រឹះនៃច្បាប់ផ្ទៃក្នុង)។ |

| | |
|---|---|
| ៤) បទបញ្ញាប្រកបដោយប្រសិទ្ធិភាព និង ការបើកចំហរព័ត៌មានអាចជួយគ្រប់គ្រងផលប៉ះពាល់អវិជ្ជមានដែលកើតចេញពីតួនាទីរបស់ថវិកានៅក្នុងនយោបាយ ក៏ប៉ុន្តែលុះត្រាតែបទបញ្ញានោះត្រូវបានបង្កើត និង អនុវត្តឲ្យបានត្រឹមត្រូវ។ | ▪ តម្លាភាពនៃការចំណាយលើការបោះឆ្នោតគួរតែសម្រេចបានតាមរយៈការផ្សព្វផ្សាយពីគណនីយុទ្ធនាការឃោសនាបោះឆ្នោត។ (គណៈកម្មការវេនីស កថាខណ្ឌទី ១២)<br>▪ ការដាក់កំហិតក្នុងលក្ខណៈមួយសមស្របលើការចំណាយក្នុងយុទ្ធនាការឃោសនា អាចធ្វើការកែតម្រូវបានប្រសិនបើចាំបាច់ ដើម្បីធានាថា ការសម្រេចចិត្តដោយសេរីរបស់អ្នកបោះឆ្នោតមិនត្រូវបានរំខាន ឬ ដើម្បីធានាថា ដំណើរការប្រជាធិបតេយ្យមិនត្រូវបានប៉ះពាល់ដោយសារការចំណាយមិនសមរម្យរបស់បេក្ខជន ឬគណបក្សនយោបាយ។ (UNHRC (កថាខណ្ឌ ១៩))<br>▪ រដ្ឋនានាគួរគាំទ្រឲ្យមានការត្រួតពិនិត្យឯករាជ្យចំពោះការធ្វើ ហិរញ្ញប្បទានដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោត... ការត្រួតពិនិត្យដោយឯករាជ្យគួរដាក់បញ្ចូលទាំងការត្រួតពិនិត្យទៅលើគណនីរបស់គណបក្សនយោបាយ និងចំណាយផ្សេងៗដែលទាក់ទងនឹងការឃោសនា ក៏ដូចជាការបង្ហាញព័ត៌មាន និង ការផ្សព្វផ្សាយរបស់គណបក្សនយោបាយ។ (ក្រុមប្រឹក្សាអឺរ៉ុប ២០០៣ "មាត្រា១៤") |
| ៥) ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពអាស្រ័យលើសកម្មភាពនៅក្នុងការប្រាស្រ័យទាក់ទងគ្នាដែលត្រូវបានធ្វើឡើងដោយភាគីពាក់ព័ន្ធនានា មានដូចជា បញ្ញត្តិករហិរញ្ញវត្ថុនយោបាយ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ ហើយត្រូវផ្អែកលើតម្លាភាពទៀតផង។ | ▪ រដ្ឋជាភាគីនីមួយៗត្រូវអនុម័តច្បាប់និងវិធានការដទៃទៀតដើម្បីៈ (ខ) បញ្ចូលគោលការណ៍តម្លាភាពទៅក្នុងការធ្វើហិរញ្ញប្បទានទៅគណបក្សនយោបាយ។ (សហភាពអាហ្វ្រិក "មាត្រា១០")<br>▪ រដ្ឋជាភាគីនីមួយៗក៏ត្រូវពិចារណាផងដែរអំពីការចាត់វិធានការផ្នែកច្បាប់ និងរដ្ឋបាលឲ្យបានសមរម្យស្របទៅនឹងគោលបំណងនៃអនុសញ្ញានិង គោលការជាមូលដ្ឋានទាំងឡាយនៃច្បាប់ក្នុងស្រុក ដើម្បីលើកកម្ពស់ តម្លាភាពនៅក្នុងការផ្តល់មូលនិធិដល់បេក្ខជនសម្រាប់អណត្តិជ្រើសតាំង ដោយការបោះឆ្នោត និង គណបក្សនយោបាយ ប្រសិនបើអាចធ្វើទៅ បាន។ (អង្គការសហប្រជាជាតិ "មាត្រា៧ កថាខណ្ឌ៣") |

# ជំពូក ១

# ដំណោះស្រាយដ៏ស័ក្តិសមសម្រាប់ការបង្ហាញព័ត៌មានអំពីហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនា និង គណបក្សនយោបាយ

ដោយ៖ ជែក សានទូស៊ី និង បណ្ឌិត ម៉ាកណឺស អូមែន

## ស ចក្ខុវិស័យថ្មី

រឿងអាស្រូវថ្មីៗមួយចំនួនពាក់ព័ន្ធនឹងអ្នកនយោបាយ និងការចាត់ចែងហិរញ្ញវត្ថុមិនបានត្រឹមត្រូវបានបង្ហាញឲ្យឃើញពីតម្រូវការសម្រាប់ការដឹងលឺជាសាធារណៈក្នុងកិច្ចការនានានៃវិស័យនយោបាយ។ នៅចក្រភពអង់គ្លេស រឿងអាស្រូវទាក់ទងនឹងការចំណាយរបស់សភាបានបង្ខំឲ្យសមាជិកសភាប្រមាណ២០រូបលាលែងពីមុខតំណែង ស្របពេលដែលការចោទប្រកាន់របស់តុលាការទៅលើអតីតនាយករដ្ឋមន្ត្រីអ៊ីស្រាអែល អ៊ីហ៊ូដ អូលមើត និង ការចោទប្រកាន់របស់តុលាការសហរដ្ឋអាមេរិចប្រឆាំងនឹងអភិបាលរដ្ឋ រ៉ូដ ប្លាហ្គូចេវិច បានបង្ហាញថាអំពើពុករលួយផ្នែកនយោបាយនៅបន្តកើតមានក្នុងពេលបច្ចុប្បន្ននេះ ដូចដែលវាធ្លាប់កើតឡើងជាយូរណាស់មកហើយ។

ជំពូក ២ មាត្រា ៧ កថាខណ្ឌ ៣ នៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ (UNCAC) តម្រូវឲ្យរដ្ឋជាភាគីទាំងអស់ខិតខំប្រឹងប្រែងប្រកបដោយសុច្ឆន្ទៈ ដើម្បីលើកកម្ពស់តម្លាភាពនៅក្នុងវិស័យហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និង បេក្ខជនឈរឈ្មោះបោះឆ្នោត ។ ការបើកចំហរព័ត៌មានអំពីហិរញ្ញវត្ថុនយោបាយ គឺជាឧបករណ៍គោលនយោបាយដ៏ចម្បងដើម្បីឲ្យតម្លាភាពនេះសម្រេចទៅបាន។ ការបើកចំហរព័ត៌មានសំដៅលើការផ្សព្វផ្សាយឲ្យបានទាន់ពេលវេលានូវព័ត៌មានស្តីពីចំណូល និង ចំណាយរបស់បេក្ខជន និង គណបក្សនយោបាយ។ ខណៈដែលទម្រង់ផ្សេងៗនៃបទបញ្ញាស្តីពីហិរញ្ញវត្ថុនយោបាយត្រូវបានគេបង្កើតឡើង ដើម្បីគ្រប់គ្រងតួនាទីរបស់ថវិកាក្នុងកិច្ចការនយោបាយ ដូចជា ការកំណត់ពិដានចំណាយ ការហាមឃាត់ក្នុងការទទួលយកមូលនិធិពីប្រភពមួយចំនួន និង ការផ្តល់ហិរញ្ញប្បទានសាធារណៈ ការបង្ហាញព័ត៌មានប្រកបដោយប្រសិទ្ធភាពក៏មានភាពចាំបាច់ដែរសម្រាប់ឲ្យបទបញ្ញាផ្សេងៗទៀតអនុវត្តបានល្អប្រសើរ។ បញ្ហានេះត្រូវបានទទួលស្គាល់ដោយអង្គការអន្តរជាតិមួយចំនួន ដូចមានបង្ហាញយ៉ាងច្បាស់ក្នុងតារាងទី ១ ខាងក្រោមនេះ

*តារាង១៖ អនុសាសន៍ដែលបានលើកឡើងដោយអង្គការអន្តរជាតិស្តីពីការបង្ហាញព័ត៌មាន*

| ឈ្មោះអង្គការ | អនុសាសន៍ |
|---|---|
| គណៈកម្មការវេនីស៖ គោលការណ៍ស្តីពីហិរញ្ញវត្ថុនយោបាយ (អនុម័តនៅថ្ងៃទី ៩-១០ ខែមីនា ឆ្នាំ ២០០១) កថាខណ្ឌ១២) | “តម្លាភាពនៃការចំណាយសម្រាប់ការបោះឆ្នោតត្រូវតែអាចសម្រេចបានតាមរយៈការផ្សព្វផ្សាយគណនីធនាគារសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត”។ |
| គណៈកម្មាធិការនៃរដ្ឋមន្ត្រីសហភាពអឺរ៉ុប (អនុសាសន៍ឆ្នាំ២០០៣ មាត្រា ១៣ ចំនុច“ក”) | “ក. រដ្ឋនានាគួរតម្រូវឲ្យគណបក្សនយោបាយទាំងអស់ធ្វើការបង្ហាញគណនីធនាគាររបស់ពួកគេ ដូចមានចែងក្នុងមាត្រា ១១ (ស្តីពីគណនីរួមដែលមានរួមបញ្ចូលរាល់សកម្មភាពហិរញ្ញវត្ថុទាំងអស់ដែលជាប់ទាក់ទងដោយផ្ទាល់ ឬ ដោយប្រយោលទៅនឹងគណបក្សនយោបាយទាំងនោះ)។ ការបង្ហាញគួរតែធ្វើឡើងជាទៀងទាត់ ហើយយ៉ាងហោចណាស់១ដងក្នុងមួយឆ្នាំ ជូនអាជ្ញាធរឯករាជ្យមួយ ដូចបានចែងក្នុងមាត្រា ១៤ (ស្តីពីការត្រួតពិនិត្យឯករាជ្យ រួមមានការពិនិត្យមើលគណនីរបស់គណបក្សនយោបាយ និង ចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត)”។ |
| អង្គការតម្លាភាពអន្តរជាតិ៖ មុខនាទីរបស់គោល-នយោបាយ (មករា ឆ្នាំ ២០០៥ ទំព័រ២) | “គណបក្សនយោបាយ បេក្ខជន និងអ្នកនយោបាយ គួរតែប្រកាសទ្រព្យសម្បត្តិ ចំណូល និងចំណាយរបស់ខ្លួន ជូនទីភ្នាក់ងារឯករាជ្យណាមួយដើម្បីធ្វើការត្រួតពិនិត្យ” ។ |

| | |
|---|---|
| សភាក្រុមប្រឹក្សាអឺរ៉ុប៖ អនុសាសន៍លេខ ១៥១៦ ឆ្នាំ២០០១ កថាខ័ណ្ឌ៨ ចំនុច គ(១) | “...ដើម្បីរក្សាទុកឲ្យបានខ្ជាប់ខ្ជួននូវគណនីចំនូល និង ចំណាយ ដែលគណនីនេះនឹងត្រូវដាក់ជូនអ្នកជំនាញសវនកម្មឯករាជ្យយ៉ាងហោចណាស់ ១ឆ្នាំម្តង ហើយត្រូវផ្សព្វផ្សាយជាសាធារណៈ”។ |
| អង្គការ SADC៖ បទដ្ឋាន និងគម្រូស្តង់ដារសម្រាប់ការបោះឆ្នោតក្នុងតំបន់ SADC មាត្រា ៦ | “គណៈកម្មការរៀបចំការបោះឆ្នោតគួរមានអំណាចពេញលេញដើម្បីធានាថា ព័ត៌មានសមស្របស្តីការចំណាយ ត្រូវបានផ្ញើទាន់ពេលវេលា ដើម្បីផ្តល់ការពិនិត្យគណនីរបស់គណបក្សនយោបាយ និង ដើម្បីឲ្យមានការធ្វើវិសោធនកម្ម និង ការផ្ទៀងផ្ទាត់គណនីសម្រាប់គណបក្សនយោបាយ”។ |

ជំពូកនេះចាប់ផ្តើមឡើងដោយមានការពិភាក្សាអំពីសមាសភាពខុសៗគ្នា និង បញ្ហាផ្សេងៗនៅក្នុងប្រព័ន្ធគម្រូនៃការបើកចំហរព័ត៌មាន។ ត្រូវមានភាពអនុញ្ញាតឲ្យមានការអនុវត្តឧបករណ៍គោលនយោបាយដទៃទៀត ហើយវាអាចជាមធ្យោបាយមួយដែលនាំឲ្យមានការសម្រេចគោលដៅខុសៗគ្នាក្នុងផ្នែកបទដ្ឋាន។ យើងសូមធ្វើការបង្ហាញអំពីគុណតម្លៃទាំងនោះ និង ការយកចិត្តទុកដាក់ទៅលើទិដ្ឋភាពប្លែកៗគ្នានៃប្រព័ន្ធបើកចំហរព័ត៌មានស្តីពីហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនា។ ជាចុងក្រោយ ដោយមានការទទួលស្គាល់ថា ក្នុងចំណោមប្រទេសនានា ភាពខុសប្លែកគ្នាស្ថិតនៅត្រង់វិធីសាស្រ្តដែលគេយកមកអនុវត្តពុំមែនស្ថិតនៅត្រង់គុណតម្លៃដែលពួកគេព្យាយាមពង្រីកឲ្យបានជាអតិបរិមាទេនោះ យើងបានធ្វើការពិចារណាអំពីវិធីសាស្រ្តក្នុងការបង្កើតប្រព័ន្ធបើកចំហរព័ត៌មានហិរញ្ញវត្ថុនយោបាយដែលមានប្រសិទ្ធិភាពក្រោយពីយើងបានពិនិត្យទៅលើស្ថានភាពនយោបាយជាក់លាក់នានា។

ដូចមានបរិយាយនៅក្នុងសៀវភៅនេះ ជំពូកនេះកំនត់អត្ថន័យហិរញ្ញវត្ថុនយោបាយ ដែលរួមបញ្ចូលទាំងហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនា (ដែលជាធម្មតា ធ្វើឡើងដោយបេក្ខជន និង គណបក្សនយោបាយ) ហើយនិង ហិរញ្ញវត្ថុសម្រាប់សកម្មភាពផ្សេងទៀតរបស់គណបក្សនយោបាយក្រៅពីការឃោសនាបោះឆ្នោត។ ការត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយទាំងពីរប្រភេទនេះ អាចធ្វើឡើងតាមរយៈបទបញ្ជាសម្រាប់តម្រូវឲ្យមានការបង្ហាញព័ត៌មានអំពីហិរញ្ញវត្ថុនយោបាយ បើទោះបីជាទិដ្ឋភាពមួយចំនួនផ្សេងទៀត ដូចជាការកំណត់រយៈពេលសម្រាប់បង្ហាញព័ត៌មាននឹងពិតជាមានភាពខុសគ្នាក៏ដោយ។

## ប្រព័ន្ធសម្រាប់បង្ហាញការព័ត៌មាន៖ ការបង្កើតប្លុក

សំនួរចម្បងៗនៅក្នុងប្រព័ន្ធបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយនោះគឺ៖ នរណាបង្ហាញអ្វីទៅកាន់អ្នកណា និង នៅពេលណា? នៅពេលដែលគេមានច្បាប់សម្រាប់ដោះស្រាយបញ្ហាទាំងនេះ គេត្រូវការចាំបាច់អង្គភាពអនុវត្តច្បាប់មួយ (ដែលនៅក្នុងនេះ យើងហៅថា “ភ្នាក់ងារអនុវត្តបទបញ្ជាហិរញ្ញវត្ថុនយោបាយ”) ដែលជាទូទៅ វាជាផ្នែកមួយរបស់រដ្ឋាភិបាល។ គណៈកម្មាធិការរៀបចំការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ និង បេក្ខជន (ប្រសិនបើអាចធ្វើបាន) គួរមានអ្នកឯកទេសទទួលបន្ទុកផ្ទៃក្នុងរបស់ខ្លួនផងដែរដើម្បីជួយសម្រួលអង្គការទាំងនោះបំពេញតាមតម្រូវការផ្នែកច្បាប់នៃការបង្ហាញព័ត៌មានអំពីហិរញ្ញវត្ថុនយោបាយ។ ដូច្នេះ បទប្បញ្ញត្តិសម្រាប់ការបង្ហាញព័ត៌មានអំពីហិរញ្ញវត្ថុនយោបាយពុំអាចមានប្រសិទ្ធិភាពទេ លុះត្រាតែបទប្បញ្ញត្តិនោះមានលក្ខណៈសមស្រប និង អាចយកមកអនុវត្តបាន ដូចដែលយើងនឹងធ្វើការពិភាក្សាខាងក្រោមនេះ។

## *នរណា ត្រូវបង្ហាញព័ត៌មាន?*

អង្គភាព ដែលត្រូវទទួលខុសត្រូវនៅក្រោមច្បាប់សម្រាប់ការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយ អាស្រ័យទៅលើស្ថាប័ននយោបាយ និង បរិបទនយោបាយរបស់ប្រទេសនីមួយ ឧទាហរណ៍៖ ប្រព័ន្ធបោះឆ្នោត កម្រិតនៃការធ្វើវិមជ្ឈការ និង អង្គភាពដែលមានអំណាចធម្មនុញ្ញ។ ជាទូទៅគណបក្សនយោបាយដែលបានចុះបញ្ជី និង អង្គភាពរៀបចំការឃោសនាបោះឆ្នោត មានការទទួលខុសត្រូវដោយឯករាជ្យក្នុងការដាក់បង្ហាញធនធានហិរញ្ញវត្ថុរបស់ពួកគេ។ ប្រសិនបើអាចធ្វើទៅបាន អង្គភាពនីមួយៗគួរមានមន្ត្រីម្នាក់ ឬ ច្រើននាក់ ដើម្បីទុកដាក់កំណត់ត្រាលំអិតស្តីពីហិរញ្ញវត្ថុរបស់គណបក្សនិង ដើម្បីទទួលខុសត្រូវក្នុងការរៀបចំបង្ហាញព័ត៌មានតាមការតម្រូវរបស់ច្បាប់។




ដូចបានរៀបរាប់ខាងលើ ជាបឋមយើងត្រូវធ្វើការបែងចែករបាយការណ៍ដែលទាក់ទងនឹងសកម្មភាពជាធម្មតារបស់គណបក្សនយោបាយចេញពីរបាយការណ៍ដែលទាក់ទងនឹងសកម្មភាពឃោសនាបោះឆ្នោត។

ចំពោះរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការឃោសនាបោះឆ្នោត ប្រព័ន្ធនៃការបង្ហាញព័ត៌មានផ្តោតទៅលើគណបក្ស ឬ បេក្ខជនដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ឬទាំងពីរ។ ប្រសិនបើអាចធ្វើបាន ការទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មានគួរធ្លាក់ទៅលើភ្នាក់ងារណាក៏ដោយដែលផ្តើសកម្មភាពឃោសនា។ ជាឧទាហរណ៍ នៅក្នុងប្រព័ន្ធបោះឆ្នោតឯកត្តនាម បេក្ខជនដែលប្រកួតប្រជែងក្នុងការបោះឆ្នោតគួរតែជាអ្នកដែលត្រូវបង្ហាញព័ត៌មាន ចំណែកឯនៅក្នុងប្រព័ន្ធបោះឆ្នោតសមាមាត្រវិញ ការបង្ហាញព័ត៌មានគួរតែជាការទទួលខុសត្រូវរបស់គណបក្សនយោបាយ ព្រោះពួកគេជាអ្នកធ្វើសកម្មភាពឃោសនាបោះឆ្នោត។ នៅក្នុងប្រព័ន្ធបោះឆ្នោតជ្រើសតាំងប្រធានាធិបតី បេក្ខជនឈរឈ្មោះគួរតែជាអ្នកទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មាន[13]។ ដោយអាស្រ័យទៅលើការរៀបចំយុទ្ធនាការឃោសនា ភ្នាក់ងារដែលទទួលខុសត្រូវក្នុងការបង្ហាញព័ត៌មានអាចជាគណៈកម្មាធិការរៀបចំការឃោសនា ជាបេក្ខជន

---

[13] *ពុំមែនគ្រប់ករណីសុទ្ធតែអញ្ចឹងទាំងអស់នោះទេ។ នៅក្នុងប្រទេសស៊ៀរ៉ាលេអូន បើទោះបីជាគេប្រើប្រាស់ប្រព័ន្ធបោះឆ្នោតឯកត្តនាមដោយផ្តោតទៅលើបេក្ខជនឈរឈ្មោះជាជាងគណបក្សនយោបាយក៏ដោយ មានតែគណបក្សនយោបាយប៉ុណ្ណោះដែលគេតម្រូវឲ្យផ្ញើរបាយការណ៍។ ចំណែកនៅក្នុងប្រទេសលីបង់វិញ មានតែបេក្ខជនឈរឈ្មោះប៉ុណ្ណោះដែលត្រូវបង្ហាញរបាយការណ៍ បើទោះបីជាគណបក្សនយោបាយ និង សម្ព័ន្ធគណបក្សនយោបាយដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធបោះឆ្នោតក៏ដោយ។*

ឈរឈ្មោះ ឬ ជាគណបក្សនយោបាយ។ គេក៏អាចធ្វើដូចគ្នាដែរ ចំពោះការបោះឆ្នោតជ្រើសរើសអាជ្ញាធរតំបន់ បើទោះជាការបោះឆ្នោតប្រភេទនេះមានបេក្ខជនចូលរួមប្រកួតប្រជែងដ៏ច្រើនលើសលុបក៏ដោយ។ លើសពីនេះទៅទៀត ការដែលអាចមានបេក្ខជនជាច្រើនខ្វះការយល់ដឹងជាមូលដ្ឋានអំពីកិច្ចការគណនេយ្យក៏ចាំបាច់ត្រូវយកមកពិចារណា ផងដែរនៅពេលគេរៀបចំបង្កើតប្រព័ន្ធបង្ហាញព័ត៌មាន។

ជាគោលការណ៍ទូទៅ ភ្នាក់ងារដែលចាំបាច់បំផុតក្នុងការធ្វើរបាយការណ៍ជូនអ្នកអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយអាចនឹងអាស្រ័យទៅលើប្រព័ន្ធបោះឆ្នោតដែលគេយកមកប្រើប្រាស់[14]។ ប្រព័ន្ធបោះឆ្នោតដែលផ្តោតទៅលើគណបក្សនយោបាយជាសំខាន់ វាជាការសមស្របដែលមន្ត្រីណាម្នាក់របស់គណបក្សនយោបាយត្រូវរៀបចំធ្វើរបាយការណ៍។ ប្រព័ន្ធបោះឆ្នោតដែលផ្តោតជាសំខាន់ទៅលើបេក្ខជន ការទទួលខុសត្រូវគួរធ្លាក់ទៅលើគណៈកម្មាធិការរៀបចំយុទ្ធនាការឃោសនាបោះឆ្នោតរបស់បេក្ខជននោះ។ នៅក្នុងប្រព័ន្ធបោះឆ្នោតចម្រុះដែលចំហរបញ្ជីឈ្មោះបេក្ខជន ការកំណត់ថាអ្នកណាជាអ្នកធ្វើរបាយការណ៍ អាស្រ័យទៅលើកម្រិតត្រឹមណាដែលបេក្ខជនធ្វើការរៃអង្គាសមូលនិធិ និង ធ្វើការចំណាយដោយឯករាជ្យពីគណបក្សរបស់ពួកគេ។ នៅក្នុងករណីជាច្រើនទៀត បេក្ខជនដែលឈរឈ្មោះក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង រដ្ឋបាលមូលដ្ឋាន មានការទទួលខុសត្រូវក្នុងការប្រើប្រាស់មូលនិធិសម្រាប់យុទ្ធនាការឃោសនាច្រើនជាងបេក្ខជន ដែលឈរឈ្មោះក្នុងការបោះឆ្នោតជ្រើសតាំងប្រធានាធិបតី ដែលជាទូទៅគណបក្សនយោបាយចាត់ទុកជាអាទិភាព។

ទោះជាយ៉ាងណាក៏ដោយ ថវិការដែលពុំមានច្បាប់គ្រប់គ្រងតែងមានទំនោររកច្រកជ្រៀតចូលទៅក្នុងនយោបាយ ដូច្នេះទាំងអង្គភាពរៀបចំការឃោសនារបស់បេក្ខជន និង គណបក្សនយោបាយគួរតម្រូវឲ្យធ្វើរបាយការណ៍នៅពេលណាពួកគេបានទទួលថវិកានិងចំណាយថវិកាសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។ ប្រព័ន្ធបង្ហាញព័ត៌មានទាំងឡាយណា ដែលគ្រាន់តែតម្រូវឲ្យបេក្ខជន ឬគណបក្សនយោបាយធ្វើរបាយការណ៍ ជារឿយៗតែងតែប្រឈមនឹងហានិភ័យផ្សេងៗដែលអាចបង្កឲ្យមានចន្លោះប្រហោង ដែលអនុញ្ញាតឲ្យប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានធ្វើឡើងតាមរយៈក្រុមណាមួយដែលមិនចាំបាច់ត្រូវបង្ហាញរបាយការណ៍។

មិនថាការទទួលខុសត្រូវធ្លាក់ទៅលើគណបក្សនយោបាយ ឬ បេក្ខជននោះទេ អង្គភាពនីមួយៗគួរតែងតាំងហិរញ្ញិកម្នាក់ និង បុគ្គលិកក្រោមឱវាទមួយចំនួន (ប្រសិនបើអាចធ្វើបាន) ដើម្បីគ្រប់គ្រងរាល់មូលនិធិទាំងអស់ដែលគណបក្សនយោបាយ ឬ បេក្ខជនបានទទួល រាល់ការប្រើប្រាស់មូលនិធិទាំងនោះ ការធ្វើកំណត់ត្រាអំពីចំណូល និង ចំណាយ និង ការធ្វើរបាយការណ៍ ។ មានហេតុផលពីរយ៉ាង ដែលគណបក្សនយោបាយឬបេក្ខជនត្រូវមានភ្នាក់ងារតែម្នាក់យ៉ាងដូច្នេះសម្រាប់ចាត់ចែងកិច្ចការទាំងនោះ។ ទីមួយ ការតាមដាន និងការផ្តល់របាយការណ៍ហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនា ទាមទារឲ្យមានការធ្វើការងារពេញម៉ោង ហើយត្រូវការការបណ្តុះបណ្តាលមួយសមស្របអំពីជំនាញគណនេយ្យនិងអ្វីដែលច្បាប់ត្រូវការ។ ទីពីរ ការមានមន្ត្រីចាត់ចែងធ្វើរបាយការណ៍ និង កិច្ចការហិរញ្ញវត្ថុ ដែលប្រកបដោយជំនាញវិជ្ជាជីវៈ នឹងជួយសម្រាលបន្ទុកដល់រដ្ឋាភិបាល និង អ្នកចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត

[14] *សម្រាប់សេចក្តីរាយការណ៍ស្តីពីការត្រួតពិនិត្យថ្មីៗទៅលើកម្រិត ដែលកំណត់ថា "អ្នកណាជាអ្នកបង្ហាញព័ត៌មាន" អាស្រ័យទៅលើតួនាទីរបស់បេក្ខជនឈរឈ្មោះនៅក្នុងប្រព័ន្ធបោះឆ្នោត សូមមើលអត្ថបទស្តីអំពី "ប្រជាធិបតេយ្យ និង ការបង្ហាញព័ត៌មាន៖ ប្រព័ន្ធបោះឆ្នោត និង បទបញ្ញាហិរញ្ញវត្ថុនយោបាយ" និពន្ធដោយ ចូអែល ចនសុន* (Johnson, Joel) *(ឆ្នាំ ២០០៨) នៅក្នុងព្រឹត្តិប័ត្រច្បាប់បោះឆ្នោត លេខ ៧(៤) ខែ តុលា ២០០៨។*

ដូចគ្នាដែរ។ អ្នកត្រួតពិនិត្យផ្ទៃក្នុងអាចជួយត្រួតពិនិត្យមើលគណបក្សនយោបាយ និង គណៈកម្មការរៀបចំយុទ្ធនាការឃោសនាបោះឆ្នោតមុនពេលពួកគេធ្វើការសម្រេចចិត្តណាមួយដែលអាចនាំឲ្យមានទណ្ឌកម្ម។ បទបញ្ជាផ្ទៃក្នុងរបស់គណបក្សនយោបាយក៏អាចជួយកាត់បន្ថយបន្ទុករបស់រដ្ឋាភិបាលក្នុងការធ្វើបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុនយោបាយផងដែរ[15]។ បទប្បញ្ញត្តិដែលទាក់ទងនឹងការបើកចំហរព័ត៌មានហិរញ្ញវត្ថុនយោបាយ គួរបញ្ជាក់ឲ្យបានច្បាស់ ថាតើហិរញ្ញឹក ឬ មន្ត្រីត្រួតពិនិត្យផ្ទៃក្នុងមានការទទួលខុសត្រូវតាមផ្លូវច្បាប់ក្នុងការបំពេញតាមតម្រូវការនៃការផ្សព្វផ្សាយការណ៍ឬទេ ឬមួយថាតើការទទួលខុសត្រូវទាំងនោះត្រូវធ្លាក់ទៅលើបេក្ខជន ឬ អ្នកដឹកនាំរបស់គណបក្សនយោបាយ។

បន្ថែមពីលើនេះ សវនករគណបក្សនយោបាយ និង យុទ្ធនាការឃោសនា គួរតែជាអ្នកប្រឹក្សាយោបល់ឯករាជ្យ ដែលត្រូវបានជ្រើសរើសចេញពីផ្នែកឯកជន ហើយដែលការងាររបស់ពួកគេដាច់ចេញពីការងារបោះឆ្នោតរបស់គណបក្សនយោបាយ។ ការធ្វើបែបនេះ គឺដើម្បីកាត់បន្ថយឲ្យបានជាអតិបរមាចំពោះការធ្វើរបាយការណ៍ភូតកុហករបស់ក្រុមសវនករ។ នៅក្នុងប្រទេសមួយចំនួនដូចជា កាណាដា និង ស៊ៀរ៉ាលេអូនជាដើម បទប្បញ្ញត្តិស្តីពីហិរញ្ញវត្ថុនយោបាយរបស់ប្រទេសទាំងនេះបានកំនត់យ៉ាងច្បាស់ថា សវនករណាមួយដែលប្រើប្រាស់ដោយគណបក្សនយោបាយ មិនអាចជាសមាជិក ឬ មន្ត្រីរបស់គណបក្សនយោបាយនោះបានទេ។ ក្នុងការអនុវត្តជាក់ស្តែង គេពិបាកធានាឲ្យមានឯករាជ្យភាពបែបនេះណាស់ ប៉ុន្តែ យ៉ាងហោចណាស់ គេអាច ប្រើគោលការណ៍មុខទស្សន៍មួយសម្រាប់បង្កើតស្ថាប័នត្រួតពិនិត្យណាមួយ។ បើទោះបីជាអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយមានភាពឯករាជ្យក៏ដោយ ក៏ការបង្កើតឲ្យមានអ្នកត្រួតពិនិត្យផ្ទៃក្នុងនឹងជួយសម្រួលដល់ការបំពេញតាមតម្រូវការ និង ការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយសម្រាប់រាល់តួអង្គទាំងអស់ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។

នៅក្នុងប្រទេសមួយចំនួនដែលមានប្រព័ន្ធធនាគារ ហើយដែលត្រូវបានគេប្រើជាទូទៅ ហិរញ្ញឹករបស់គណបក្សនយោបាយ ឬ បេក្ខជនឈរឈ្មោះគួរធ្វើប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់តាមរយៈគណនីតែមួយគត់។ ការធ្វើបែបនេះ បានជួយធ្វើឲ្យកាន់តែមានភាពងាយស្រួលសម្រាប់អ្នកត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយក្នុងការផ្ទៀងផ្ទាត់មើលការបំពេញតាមអ្វីដែលច្បាប់បានតម្រូវ។ ជាឧទាហរណ៍ ប្រព័ន្ធបែបនេះត្រូវបានប្រើប្រាស់នៅក្នុងប្រទេសមួយចំនួនដូចជា អាហ្វហ្កានីស្ថាន លីបង់ និង ការបោះឆ្នោតជាច្រើននៅសហរដ្ឋអាមេរិចជាដើម។

នៅតាមបណ្តាប្រទេសមួយចំនួន អ្នកធ្វើវិភាគទាន ដល់គណបក្សនយោបាយ ឬ យុទ្ធនាការឃោសនាបោះឆ្នោតក៏ត្រូវរាយការណ៍អំពីវិភាគទានរបស់ខ្លួនផងដែរ។ អភិក្រមប្រភេទនេះ មិនសូវមានការប្រើប្រាស់ច្រើននោះទេ (មានប្រហែលជា ១៥ ប្រទេសប៉ុណ្ណោះនៅលើពិភពលោក ដូចជាប្រទេសអេក្វាឌ័រ ឥណ្ឌូនេស៊ី ប៉ាពួញូហ្គីនេ និង សិង្ហបុរីជាដើម ហើយអភិក្រមនេះទៀតសោតក៏មានការលំបាកក្នុងការអនុវត្តដែរ។ យ៉ាងណាក៏ដោយ ការផ្តល់ការអនុគ្រោះពន្ធចំពោះការធ្វើវិភាគទាននយោបាយបានបង្កើតឲ្យមានការលើកទឹកចិត្តបន្ថែមទៀតដល់ការផ្សព្វផ្សាយការណ៍ ចំណែកឯការបង្ហាញព័ត៌មាន ដែលទាក់ទងនឹងការធ្វើវិភាគទាននយោបាយនេះ អាចជាគុណសម្បត្តិដ៏មានសារៈ

[15] *ម៉ាស៊ីន វ៉ាលេគី (២០០៧) ភាពប្រឈមសម្រាប់បទដ្ឋាន និង ស្តង់ដារនៃការគ្រប់គ្រងការបោះឆ្នោត៖ ស្តង់ដារនានាស្តីពីហិរញ្ញវត្ថុនយោបាយ (វ៉ាស៊ីនតោន អាយហ្វេស)*

ប្រយោជន៍ថែមទៀតទៅលើរបាយការណ៍ដែលអ្នកចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតបានធ្វើដោយខ្លួនពួកគេផ្ទាល់[16]។

ដោយឡែក ការបង្ហាញព័ត៌មានអំពីហិរញ្ញវត្ថុរបស់គណបក្សនយោបាយក្រៅពីហិរញ្ញវត្ថុដែលប្រើប្រាស់សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតបម្រើឲ្យគោលបំណងផ្សេងទៀត ក្រៅពីការបើកចំហរព័ត៌មានដែលទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោត។ គោលបំណងនោះមិនសូវផ្តល់ប្រយោជន៍សម្រាប់អ្នកបោះឆ្នោតទេ ក្នុងការជ្រើសរើសចុះសម្រេចចិត្តនៅថ្ងៃបោះឆ្នោត ប៉ុន្តែវាបានផ្តល់ប្រយោជន៍ខ្លាំងក្នុងការធានាថា គណបក្សនយោបាយនានាអនុវត្តតាមគោលការណ៍តម្លាភាពហិរញ្ញវត្ថុ និង គណនេយ្យភាពដែលអាចជឿទុកចិត្តបាន។ ប្រសិនបើមានការអនុវត្តត្រឹមត្រូវ តម្រូវការនៃការបង្ហាញព័ត៌មានក៏អាចជួយទប់ស្កាត់ការធ្វើវិភាគទានដល់យុទ្ធនាការឃោសនា នៅមុនពេលធ្វើរបាយការណ៍ហិរញ្ញវត្ថុនយោបាយជាផ្លូវការ។ ករណីនេះកើតមានជាពិសេសនៅក្នុងបណ្តាប្រទេសមួយចំនួនដែលគណបក្សនយោបាយចាំបាច់ត្រូវរាយការណ៍អំពីហិរញ្ញវត្ថុរបស់ខ្លួនក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោត រយៈពេលមួយ ឬ ពីរខែមុនពេលបោះឆ្នោត។ ជាធម្មតា ទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយត្រូវដាក់របាយការណ៍ជាទៀងទាត់អំពីសកម្មភាពជាបន្តបន្ទាប់របស់គណបក្សខ្លួនមកទីភ្នាក់ងារដែលត្រូវទទួលរបាយការណ៍ បើទោះជាប្រព័ន្ធមជ្ឈការអាចមានតិចតួចក៏ដោយ។

## *ព័ត៌មានអ្វីខ្លះដែលត្រូវបង្ហាញ?*

ក្នុងកាលៈទេសៈមួយសមស្រប ច្បាប់នឹងតម្រូវឲ្យមានការបង្ហាញព័ត៌មានដ៏ទូលំទូលាយស្តីពីសកម្មភាពហិរញ្ញវត្ថុទាំងអស់ ដោយមានបញ្ជាក់ពីប្រភេទនៃប្រតិបត្តិការហិរញ្ញវត្ថុដែលនឹងត្រូវរាយការណ៍។ បន្ទាប់មក អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយអាចផ្តល់ការណែនាំលំអិតទាក់ទងនឹងអ្វីដែលនឹងត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ ដោយរួមបញ្ចូលទាំងកម្រិតអប្បរមាដែលត្រូវរាយការណ៍ និងករណីលើកលែងមួយចំនួន។ មានការចាត់ជាប្រភេទព័ត៌មានសំខាន់ៗចំនួនបួន។ ជាធម្មតា ប្រភេទព័ត៌មានបឋមៗចំនួនពីរសំដៅទៅលើលំហូរហិរញ្ញវត្ថុក្នុងអំឡុងពេលជាក់លាក់ណាមួយ រីឯប្រភេទព័ត៌មានទីបី និង ទីបួន គឺសំដៅលើ "ការត្រួតពិនិត្យតាមដាន" ដើម្បីបង្ហាញពីស្ថានភាពនៅក្នុងអំឡុងពេលជាក់លាក់ណាមួយ។

1. **ចំណូល៖** ប្រសិនបើអាចធ្វើបាន អ្នករាយការណ៍គួរបង្ហាញព័ត៌មានអំពីចំនួន និង ប្រភេទនៃរាល់វិភាគទានទាំងអស់។ វិភាគទានទាំងនោះអាចជាសាច់ប្រាក់សុទ្ធ

**របៀបដែលប្លែកពីគេមួយក្នុងការរាយការណ៍អំពីការចំណាយសម្រាប់ការបោះឆ្នោតនៅក្នុងប្រទេសលីបង់**

ក្នុងករណីជាច្រើន គណបក្សនយោបាយ និង បេក្ខជននានាត្រូវធ្វើរបាយការណ៍រៀងៗខ្លួនអំពីចំណាយរបស់ខ្លួន។ ចំណែកឯក្នុងករណីមួយចំនួនទៀត គណបក្សនយោបាយក៏ត្រូវរាយការណ៍ផងដែរអំពីចំណាយរបស់បេក្ខជនរបស់ខ្លួន។ អភិក្រមប្លែកពីគេមួយត្រូវបានគេជ្រើសរើស យកទៅប្រើប្រាស់ក្នុងប្រទេសលីបង់ ជាទីដែលលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាតើការចំណាយណាមួយត្រូវធ្វើរបាយការណ៍ឬអត់ នោះពុំមែនអាស្រ័យទៅលើអ្នកណាជាអ្នកធ្វើការចំណាយទេ តែវាអាស្រ័យទៅលើថាតើការ ចំណាយនោះបានផ្តល់ផលប្រយោជន៍ដល់យុទ្ធនាការឃោសនា ឬអត់។ គេអាចនិយាយម្យ៉ាងទៀតថា ប្រសិនបើការផលិត ផ្ទាំងរូបភាព ឬ ឈុតខ្សែភាពយន្តទូរទស្សន៍បានផ្តល់ប្រយោជន៍ដល់បេក្ខជនណាម្នាក់ បេក្ខជននោះត្រូវតែបញ្ចូលការចំណាយនោះទៅក្នុងរបាយការណ៍របស់ខ្លួនបើទោះជាអ្នកណាជាអ្នកចំណាយក៏ដោយ។ ដោយហេតុថា នេះគឺជាអភិក្រមថ្មីមួយ ដែលបង្កើតឡើងដើម្បីទទួលព័ត៌មានស្តីអំពីការចំណាយរបស់ភាគីទីបី វាបានបង្ហាញពីការលំបាកសម្រាប់បេក្ខជននយោបាយក្នុងការគណនាឲ្យបានច្បាស់លាស់នូវចំនួនទឹកប្រាក់ដែលពួកគេចូលរួមនៅក្នុងចំណាយដែលធ្វើឡើងដោយគណបក្សនយោបាយ និង ក្រុមដទៃទៀត។ ប្រព័ន្ធនេះត្រូវបានប្រើប្រាស់ជាលើកដំបូងនៅក្នុងការបោះឆ្នោតសភាកាលពីឆ្នាំ២០០៨។

---

16 *បណ្តាប្រទេសដែលប្រើប្រាស់ប្រព័ន្ធបង្ហាញព័ត៌មានដោយអ្នកធ្វើវិភាគទាននយោបាយរួមមាន៖ អាហ្សង់ទីន ថៃ និង ចក្រភពអង់គ្លេស។ ប្រទេសមួយចំនួនទៀតដូចជា អៀឡង់ និង រុស្ស៊ី ជាដើមតម្រូវឲ្យអ្នកធ្វើវិភាគទាននយោបាយធ្វើការបង្ហាញព័ត៌មានលុះត្រាតែការធ្វើវិភាគទានរបស់ពួកគេលើសពីចំនួនជាក់លាក់ណាមួយដែលច្បាប់កំណត់។*

មូលប្បទានប័ត្រ ប័ណ្ណឥណទាន ឬ ការធ្វើវិភាគទាន ដែលមិនមែនជាលុយ ។ វិភាគទានដែលមិនមែនជាលុយរួមមានទំនិញ និង សេវាជាដើម។ ប្រសិនបើអាចធ្វើបាន តម្លៃជាប្រាក់នៃវិភាគទានទាំងនោះគួរត្រូវបានរាយការណ៍ទៅតាមតម្លៃទីផ្សារ។ ជាងនេះទៅទៀត ការបង្ហាញឲ្យបានគ្រប់ជ្រុងជ្រោយគួរបញ្ចូលអត្តសញ្ញាណ អាសយដ្ឋាន មុខរបរ និង និយោជករបស់អ្នកធ្វើវិភាគទានម្នាក់ៗ (ប្រសិនបើអាចធ្វើទៅបាន។ ប្រសិនបើមានការធ្វើវិភាគទានពីក្រុមហ៊ុន សាជីវកម្មណាមួយ ការបង្ហាញព័ត៌មានអំពីអត្តសញ្ញាណ អាសយដ្ឋាន និង សកម្មភាពឧស្សាហកម្មរបស់សាជីវកម្មនោះគឺមានលក្ខណៈគ្រប់គ្រាន់ហើយ។

ចំពោះការបង្ហាញព័ត៌មានដែលពាក់ព័ន្ធទៅនឹងចំណូល គេអាចអនុវត្ត "តេស្តសាកល្បងអំពីតម្លាភាព" ដូចខាងក្រោមដើម្បីពិនិត្យមើលថាតើមានការផ្តល់ព័ត៌មានគ្រប់គ្រាន់ដែរឬយ៉ាងណា[17]។

- នរណាជាអ្នកផ្តល់វិភាគទាន?
- ផ្តល់ប្រាក់ចំនួនទឹកប្រាក់ប៉ុន្មាន?
- ផ្តល់នៅពេលណា ?
- ផ្តល់ទៅនរណា ?
- ផ្តល់ដើម្បីអ្វី?

ប្រភពទិន្នន័យស្តីអំពីបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយរបស់អង្គការអាយឌៀ (IDEA) បង្ហាញថា ៥៣% ក្នុងចំនោមប្រទេសទាំងអស់ដែលមានទិន្នន័យអំពីហិរញ្ញវត្ថុនយោបាយ បានតម្រូវឲ្យគណបក្សនយោបាយបញ្ជូនរបាយការណ៍ស្តីពីចំណូលរបស់ពួកគេ[18]។

2. **ចំណាយ៖** អ្នកផ្តល់របាយការណ៍គួរបង្ហាញព័ត៌មានរាល់ចំណាយទាំងអស់ កាលបរិច្ឆេទ និង ចំនួននៃចំណាយមួយលើកៗ និង អ្នកទទួលចំណាយទាំងនោះ។ ចំណាយត្រូវរួមបញ្ចូលទាំង៖ បំណុល និង ការទទួលខុសត្រូវលើសំណង ដែលគណបក្សនយោបាយ ឬ បេក្ខជនជាប់ជំពាក់នៅក្នុងអំឡុងពេលដែលត្រូវដាក់របាយការណ៍ ។

3. **បំណុល៖** អ្នកផ្តល់របាយការណ៍គួរបង្ហាញរាល់ប្រាក់កម្ចី និង បុរេប្រទាន (ប្រាក់បើកឲ្យមុនការបំពេញការងារ) ទាំងអស់ដែលបានផ្តល់ជូនសាមីគណបក្សនយោបាយ ឬ គណៈកម្មាធិការរៀបចំយុទ្ធនាការឃោសនា មុខរបររបស់អ្នកផ្តល់ឥណទាន និង និយោជក (ប្រសិនបើអាចធ្វើបាន)។ របាយករណ៍ក៏គួរបញ្ចូលផងដែរនូវ ចំនួនប្រាក់កម្ចី ឬ បុរេប្រទាន កាលបរិច្ឆេទដែលបានខ្ចី និង កាលបរិច្ឆេទដែលត្រូវសងបំណុល។

4. **ទ្រព្យសម្បត្តិ៖** ជាចុងក្រោយ អ្នកផ្តល់របាយការណ៍គួរបង្ហាញព័ត៌មានអំពីទ្រព្យសម្បត្តិរបស់គណបក្សនយោបាយ ឬ បេក្ខជន។ ទ្រព្យសម្បត្តិទាំងនោះរាប់បញ្ចូលទាំងបញ្ជីគណនីធនាគារ ទំហំឥណទាន ហើយនិងតម្លៃជាមូលធន

[17] *ហេន្រី រ៉ដ (២០០២)៖ ទិដ្ឋភាពរួមនៃការបង្ហាញព័ត៌មាន និង តម្លាភាពនៅក្នុងការធ្វើហិរញ្ញប្បទាននយោបាយនៅទ្វីបអាមេរិចឡាទីន (កិច្ចប្រជុំរបស់អង្គការនៃបណ្តារដ្ឋនៅទ្វីបអាមេរិច នៅវែនឃូវ័រ ប្រទេសកាណាដា)។*

[18] *អាយឌៀ (២០០៨)៖ ប្រភពទិន្នន័យហិរញ្ញវត្ថុនយោបាយ (វិទ្យាស្ថានអន្តរជាតិសម្រាប់លទ្ធិប្រជាធិបតេយ្យ និង ជំនួយបោះឆ្នោត ទីក្រុងស្តុកខុម ប្រទេសស៊ុយអែត)។ គេហទំព័រ៖ http://www.idea.int/parties/finance/db/*

មានដូចជា អចលនទ្រព្យ និង យានយន្តជាដើម។ ការបង្ហាញអំពីទ្រព្យសម្បត្តិមានសារៈសំខាន់ជាពិសេស សម្រាប់បរដ្ឋទាំងឡាយណា ដែលពុំមានកំណត់ត្រាបញ្ជាក់កម្មសិទ្ធិករ និង ប្រភពនៃទ្រព្យសម្បត្តិទាំងនោះ។

ប្រព័ន្ធមួយចំនួនក៏បានតម្រូវឲ្យមានការបង្ហាញព័ត៌មានបន្ថែមទៀតដែរ ដូចជា អត្តសញ្ញាណអ្នកគ្រប់គ្រងយុទ្ធនាការឃោសនា ឬសវនករ ព័ត៌មានលំអិតអំពីគណនីធនាគារប្រើសម្រាប់យុទ្ធនាការឃោសនា ហើយក្នុងករណីខ្លះទៀត ត្រូវបង្ហាញព័ត៌មានអំពីការចាត់ចែងមូលនិធិយុទ្ធនាការឃោសនាដែលអាចនឹងលើស។

ជាការចាំបាច់ណាស់ដែលគេត្រូវកត់សម្គាល់ថា ប្រភេទព័ត៌មានទាំងនេះត្រូវរាប់បញ្ចូលទាំងហិរញ្ញវត្ថុដែលទាក់ទងទៅនឹងប្រតិបត្តិការរបស់គណបក្សនយោបាយ ហើយនិងគណៈកម្មាធិការរៀបចំយុទ្ធនាការឃោសនា នៅចន្លោះការបោះឆ្នោតនីមួយៗ ក៏ដូចជាចំនូល ចំណាយ និងបំណុលដែលគណបក្សនយោបាយ និង បេក្ខជនបានជំពាក់នៅក្នុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត។

បទប្បញ្ញត្តិស្តីអំពីការបើកចំហរព័ត៌មានក៏គួរបញ្ជាក់ផងដែរអំពីកំឡុងពេលសម្រាប់ធ្វើរបាយការណ៍ចំនួល និង ចំណាយ។ របាយការណ៍ស្តីពីសកម្មភាពជាប្រក្រតីរបស់គណបក្សនយោបាយ ជាទូទៅត្រូវធ្វើប្រចាំឆ្នាំ ហើយជាបន្តបន្ទាប់ របាយការណ៍នោះត្រូវគ្របដណ្តប់សកម្មភាពដែលគណបក្សនយោបាយបានធ្វើកន្លងមក។ សម្រាប់ការបង្ហាញព័ត៌មានដែលទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោត ភាគច្រើនបំផុត តម្រូវការក្នុងការធ្វើរបាយការណ៍បានដាក់កាតព្វកិច្ចដល់គណបក្សនយោបាយឲ្យរាយការណ៍អំពីចំណូល និង ចំណាយរបស់ពួកគេក្នុងអំឡុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត បើទោះជាកំឡុងពេលនៃការធ្វើរបាយការណ៍ជួនកាលចប់ក្នុងរយៈពេលមួយយ៉ាងខ្លីបន្ទាប់ពីការបោះឆ្នោតក៏ដោយ។ ធ្វើដូច្នេះ គណបក្ស និងបេក្ខជននយោបាយមិនអាចលាក់បាំងវិភាគទាន និង ចំណាយរបស់ពួកគេដោយការពន្យារពេលដំណើរការហិរញ្ញវត្ថុនានារហូតដល់ថ្ងៃបន្ទាប់ពីការបោះឆ្នោតបានឡើយ។

សម្រាប់ការបោះឆ្នោតប្រធានាធិបតីនៅប្រទេសអាហ្វហ្គានីស្ថាន កាលពីឆ្នាំ២០០៩ រយៈពេលធ្វើរបាយ-ការណ៍យុទ្ធនាការឃោសនាមានចំណុចបញ្ចប់ ប៉ុន្តែពុំមានចំណុចចាប់ផ្តើមនោះទេ ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺថា វិភាគទានដែលបេក្ខជននយោបាយបានទទួល និងថវិការដែលបានប្រើប្រាស់ទាក់ទងនឹងការបោះឆ្នោតគួរត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍ បើទោះជាការចំណាយនោះត្រូវបានធ្វើឡើងនៅពេលណាក៏ដោយ[19]។

## *ការផ្តើនត់ត្រា*

បន្ថែមលើការបង្ហាញព័ត៌មានដែលត្រូវធ្វើឡើងតាមពេលកំណត់ គណបក្ស និង បេក្ខជននយោបាយគួរត្រូវបានតម្រូវឲ្យថែរក្សាទុកកំណត់ត្រាសកម្មភាពហិរញ្ញវត្ថុរបស់ពួកគេឲ្យបានត្រឹមត្រូវ។ កំណត់ត្រាហិរញ្ញវត្ថុទាំងនោះត្រូវមានលក្ខណៈបន្តឥតដាច់ និង ត្រូវធ្វើបច្ចុប្បន្នភាព។ កំណត់ត្រាទាំងនោះគួរអនុវត្តតាមវិធាននៃប្រព័ន្ធគណ -នេយ្យទ្វេ[20]។ កំណត់ត្រារបៀបនេះ បានជួយសម្រួលដល់ស្ថាប័នពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយ

[19] *គណៈកម្មការរៀបចំការបោះឆ្នោតឯករាជ្យអាហ្វហ្គានីស្ថានៈ មគ្គុទេសន៍របាយការណ៍សម្រាប់បេក្ខជន ឆ្នាំ២០០៩។*

[20] *ការអនុវត្តវិធានគណនេយ្យទ្វេជាទូទៅនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុរបស់រដ្ឋបានជួយសម្របសម្រួលការបង្ហាញព័ត៌មាន និង ការចូលរួម។ នៅផ្នែកម្ខាង មន្ត្រីទទួលបន្ទុកអនុវត្តវិធានបង្ហាញព័ត៌មាននឹងទំនងជាទទួលបានការបណ្តុះបណ្តាលក្នុងការអនុវត្តកិច្ចការនេះប្រសិនបើគេត្រូវបានជ្រើសរើសពីវិស័យឯកជន។*

ក្នុងការធ្វើសវនកម្មដល់ទីកន្លែងដោយពុំចាំបាច់ផ្តល់ដំណឹងជាមុន ហើយដែលការធ្វើបែបនេះអាចមានសារៈសំខាន់ ដើម្បីធានាការអនុវត្តច្បាប់ហិរញ្ញវត្ថុនយោបាយឲ្យបានខ្ជាប់ខ្ជួន ហើយអាចជាការបំពេញបន្ថែមយ៉ាងសំខាន់មួយ ទៅលើការវិភាគ និង របាយការណ៍ដែលស្ថាប័ននោះបានទទួល ។ ចូរគូសចំណាំថា ស្ថាប័នពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយត្រូវមានសមត្ថភាពគ្រប់គ្រាន់ រាប់បញ្ចូលទាំងបុគ្គលិកសវនករដែលមានចំណេះដឹងយ៉ាងទូលំទូលាយ ដើម្បីអនុវត្តកិច្ចការនានាប្រកបដោយប្រសិទ្ធភាព។ ការធ្វើសវនកម្មដោយផ្ទាល់ដល់ទីកន្លែងមានន័យថា អជ្ញាធរនៃស្ថាប័នពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយអាចចូលទៅក្នុងទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ ហើយពិនិត្យមើលកំណត់ត្រាសកម្មភាពហិរញ្ញវត្ថុទាំងឡាយរបស់ពួកគេដោយការផ្តល់ដំណឹងជាមុនក្នុងរយៈពេលខ្លី ឬដោយពុំចាំបាច់ជូនដំណឹងជាមុន[21]។

ប្រសិនបើមាន គណបក្សនយោបាយ និង បេក្ខជន ដែលត្រូវរៀបចំកំណត់ត្រាសកម្មភាពហិរញ្ញវត្ថុគួរដាក់បញ្ចូល៖

១. សេចក្តីចម្លងមូលប្បទានប័ត្រ សេចក្តីបញ្ជាចំណាយ កំណត់ត្រាប័ណ្ណឥណទាន និង ទម្រង់លិខិតបញ្ជាក់[22]ផ្សេងៗទៀតដែលចុះហត្ថលេខាដោយអ្នកធ្វើវិភាគទាននយោបាយ

២. កិច្ចសន្យាកម្ចីជាលាយលក្ខណ៍អក្សរ និង សេចក្តីចម្លង មូលប្បទានប័ត្រ សេចក្តីបញ្ជាចំណាយ កំណត់ត្រាប័ណ្ណឥណទាន ឬ បង្កាន់ដៃទទួលប្រាក់ និង បង្កាន់ដៃបញ្ជាក់អំពីការសងកម្ចី

៣. សេចក្តីចម្លងបង្កាន់ដៃបង់ប្រាក់វិក័យប័ត្រ និង បង្កាន់ដៃទទួលទំនិញ និង សេវាដែលបានជាវ

៤. សេចក្តីចម្លងមូលប្បទានប័ត្រ សេចក្តីបញ្ជាចំណាយ ឬ បង្កាន់ដៃប័ណ្ណឥណទានដែលប្រើប្រាស់ដើម្បីចំណាយសម្រាប់ទំនិញ និង សេវា

៥. ឯកសារទាក់ទងទៅនឹងសេវាដែលត្រូវបានផ្តល់ដល់បេក្ខជន ឬ គណបក្សនយោបាយ ដោយមានភ្ជាប់ជាមួយការចំណាយលើប្រាក់ឈ្នួល និង បៀវត្ស។

៦. ឯកសារបញ្ជាក់អះអាងអំពីបង្កាន់ដៃបង់ប្រាក់សម្រាប់ប័ណ្ណឥណទាន ឬ ប័ណ្ណបំណុលណាមួយដែលត្រូវបានប្រើប្រាស់ ហើយនិងបង្កាន់ដៃទទួលទំនិញដែលបញ្ជាក់អំពីទំនាក់ និង សេវាដែលបានជាវ។

ចូរកត់សម្គាល់ថា គេមិនអាចរំពឹងទុកជាមុនថាគណបក្សនយោបាយ និង បេក្ខជន នឹងផ្សព្វផ្សាយការណ៍អំពីប្រតិបត្តិការហិរញ្ញវត្ថុណា ដែលពួកគេមិនបានកត់ត្រាទុកនោះទេ។ ជាក់ស្តែង ប្រសិនបើអង្គភាពពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយមានចេតនាចង់ឲ្យគណបក្សនយោបាយ ឬ បេក្ខជនផ្ញើររបាយការណ៍ស្តីពីព័ត៌មានហិរញ្ញវត្ថុនយោបាយជាក់លាក់ណាមួយ គេត្រូវជូនដំណឹងជាមុនដល់បេក្ខជន ឬ គណបក្សនយោបាយ ។ ឧទាហរណ៍ ប្រសិនបើគេគិតថា គណបក្សនយោបាយត្រូវរាយការណ៍អំពីប្រតិបត្តិការហិរញ្ញវត្ថុរបស់ពួកគេក្នុងពេលឃោសនាបោះឆ្នោត អង្គភាពពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយចាំបាច់ត្រូវជូនដំណឹងអំពីករណីនេះ(ដោយរាប់បញ្ចូលទាំងព័ត៌មានលំអិតដែលត្រូវផ្ញើរ)ដល់ពួកគេ ក្នុងរយៈពេលមួយសមរម្យមុននឹងយុទ្ធនាការឃោសនាចាប់ផ្តើម។

---

[21] *នៅក្នុងស្ថាប័នមួយចំនួនដែលស្ថាប័នពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយអាចរងឥទ្ធិពលពីរបបដឹកនាំផុតអណត្តិ អំណាចរបស់ស្ថាប័ននោះអាចត្រូវបានប្រើប្រាស់ដើម្បីធ្វើទុកបុកម្នេញក្រុមគណបក្ស ឬ បេក្ខជននយោបាយដែលមាននិន្នាការប្រឆាំង។*

[22] *ទម្រង់លិខិតបញ្ជាក់នេះគឺជាទម្រង់បែបបទខ្លីមួយដែលអ្នកផ្តល់អំណោយត្រូវបំពេញនៅពេលគេបរិច្ចាគដល់គណបក្សនយោបាយ ឬ បេក្ខជន។ ជាធម្មតាទម្រង់លិខិតនេះមានរួមបញ្ចូលការធានាអះអាងអំពីអត្តសញ្ញាណរបស់អ្នកធ្វើអំណោយទាន និងព័ត៌មានមូលដ្ឋានដទៃទៀតសម្រាប់ធ្វើទំនាក់ទំនង។*

ឧទាហរណ៍ដ៏ល្អមួយដែលបង្ហាញពីអ្វីដែលមិនគួរធ្វើនោះ ត្រូវបានគេទាញចេញពីការបោះឆ្នោតឆ្នាំ ២០០៩ នៅក្នុងប្រទេសឥណ្ឌូនេស៊ី ដែលអ្នកពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយ ពោលគឺគណៈកម្មការជាតិរៀបចំការបោះឆ្នោត(KPU) បានដាក់ចេញបទបញ្ជាហិរញ្ញវត្ថុនយោបាយ ក្នុងរយៈពេល ១០ ថ្ងៃបន្ទាប់ពីការធ្វើមីទីងឃោសនាបោះឆ្នោតជាផ្លូវការមក។

## ត្រូវបង្ហាញទៅនរណា ?

ជាបឋមបំផុត ព័ត៌មានស្តីពីហិរញ្ញវត្ថុនយោបាយ ត្រូវតែបង្ហាញជូនអង្គភាពពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយរបស់រដ្ឋាភិបាល។ ការបង្ហាញព័ត៌មានដល់អង្គភាពខាងលើនេះមិនត្រូវមានលក្ខណៈស្មុគស្មាញពេកទេ ពោលគឺមន្ត្រីទទួលបន្ទុករៀបចំរបាយការណ៍ត្រូវតែបញ្ជូនរបាយការណ៍ទៅតាមទម្រង់ណាក៏ដោយដែលច្បាប់បានតម្រូវ។ ស្ថាប័នដែលត្រូវទទួលរបាយការណ៍នេះ អាចជាអង្គភាពគ្រប់គ្រងការបោះឆ្នោត (ដូចករណីនៅចក្រភពអង់គ្លេស) អាចជាស្ថាប័នដែលគេបង្កើតឡើងជាពិសេសសម្រាប់តែត្រួតពិនិត្យសកម្មភាពគណបក្សរបស់គណបក្សនយោបាយ (ដូចនៅប្រទេសសៀរ៉ាលេអូន) ឬមួយជាស្ថាប័នដែលធ្វើការងារទូទៅលើការត្រួតពិនិត្យហិរញ្ញវត្ថុ (ដូចជារបបត្រួតពិនិត្យនៅប្រទេសប៊ុលហ្គារីជាដើម)[23]។

ជាទូទៅអង្គភាពខាងលើនេះត្រូវមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញអណត្តិការងាររបស់ខ្លួន ហើយត្រូវតែជាស្ថាប័នមួយឯករាជ្យពីឥទ្ធិពលនយោបាយរបស់ក្រុមណាមួយ។ សមត្ថភាពដែលអង្គភាពនេះត្រូវការអាស្រ័យទៅលើកិច្ចការដែលគេត្រូវធ្វើជាមួយនឹងរបាយការណ៍ដែលគេបានទទួល ដែលការងារនោះមានភាពប្លែកគ្នាពីការរក្សាទុកឯកសារជាធម្មតា ទៅនឹងការត្រួតពិនិត្យមើលរបាយការណ៍យ៉ាងហ្មត់ចត់។

ទោះជាយ៉ាងណាក៏ដោយ រាល់ព័ត៌មានដែលបង្ហាញនៅក្នុងរបាយការណ៍ត្រូវតែធានាឲ្យបានថានឹងត្រូវបានចែករំលែកដល់សាធារណជន។ ការបង្ហាញព័ត៌មានជាសាធារណៈមានសភាពស្មុគស្មាញជាង ហើយការទទួលខុសត្រូវជាច្រើននឹងត្រូវធ្លាក់ទៅលើអង្គភាពពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយ។ ស្ថាប័នមានសមត្ថកិច្ចក្នុងការផ្សព្វផ្សាយរបាយការណ៍នេះ រាប់តាំងពីប្រទេសបូស្នៀ(Bosnia Herzegovina) រហូតដល់សហរដ្ឋអាមេរិក បានបោះពុម្ពផ្សាយតាមរយៈគេហទំព័ររបស់ខ្លួននូវរបាយការណ៍ដែលពួកគេបានទទួល។ ហិរញ្ញិករបស់គណបក្សនយោបាយក៏អាចនឹងស្ម័គ្រចិត្តបង្ហាញព័ត៌មានអំពីហិរញ្ញវត្ថុរបស់គណបក្សខ្លួនដោយផ្ទាល់ដល់សាធារណជនផងដែរ។ ជាឧទាហរណ៍ ការអនុវត្តខាងលើនេះបាននិងកំពុងធ្វើនៅក្នុងប្រទេសកូស្តារីកា (Costa Rica) ដែលរឹងរិតតែធ្វើឲ្យមានតម្លាភាពច្រើនជាងអ្វីដែលគេរំពឹងទុកពីក្របខណ្ឌច្បាប់តែឯកឯង[24]។

ដើម្បីឲ្យការបង្ហាញព័ត៌មានមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង ផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត របាយការណ៍ទាំងឡាយត្រូវតែចែករំលែកដល់ប្រព័ន្ធផ្សព្វផ្សាយ ក្រុមអ្នកនយោបាយដែលមានទំនោរធ្វើកំណែទម្រង់ ក្រុមអ្នក

---

[23] *របាយការណ៍ហិរញ្ញវត្ថុទាំងនោះត្រូវបានទទួលនៅក្នុងចក្រភពអង់គ្លេសដោយគណៈកម្មការបោះឆ្នោត ក្នុងប្រទេសសៀរ៉ាលេអូនដោយគណៈកម្មការចុះបញ្ជីគណបក្សនយោបាយ និង នៅក្នុងប្រទេសប៊ុលហ្គារីដោយការិយាល័យសវនកម្មជាតិ។*

[24] *នីនូអា ទីណាទីន (២០០៩) ចំណាប់អារម្មណ៍នៅឯសន្និសីទដែលរៀបចំឡើងដោយអង្គការអាយហ្វេស និង មូលស្ថាបនាខាតផ័រ ស្តីអំពីបទដ្ឋានសាកលក្នុងហិរញ្ញវត្ថុនយោបាយ កាលពីថ្ងៃទី ២២ ដល់ ២៣ ខែមករា។*

សិក្សាស្រាវជ្រាវ ក្រុមអ្នកឃ្លាំមើល និង អ្នកបោះឆ្នោត[25]។ ការផ្សព្វផ្សាយរបាយការណ៍ទាំងនោះអាចធ្វើឡើងតាមរយៈច្បាប់ស្តីពីសេរីភាពក្នុងការទទួលបានព័ត៌មាន ទស្សនាវដ្តីសាធារណៈ និង អាំងទែណែត ដែលគេឃើញមានការប្រើប្រាស់កាន់តែច្រើនឡើងៗ។ ច្បាប់មួយចំនួនអាចតម្រូវឲ្យមានការផ្សព្វផ្សាយនៅមណ្ឌលបណ្ណាល័យសាធារណៈ ឬ ប្រព័ន្ធផ្សព្វផ្សាយជាក់លាក់មួយចំនួន (ដូចជា ទស្សនាវដ្តីរបស់រដ្ឋាភិបាល ឬ ទស្សនាវដ្តីផ្លូវការជាដើម) ក៏ប៉ុន្តែការផ្សព្វផ្សាយរបាយការណ៍តាមប្រព័ន្ធអាំងទែណែតនៅជាមធ្យោបាយដែលត្រូវការចំណាយតិចតួច និងមានប្រសិទ្ធិភាពបំផុតក្នុងការចែករំលែកព័ត៌មានដល់បណ្តាក្រុមគោលដៅនានាដូចដែលបានអនុវត្តនៅក្នុងប្រទេសជាច្រើន។

ព័ត៌មានដែលអាចឲ្យសាធារណជនទទួលយកបានគួរតែសមស្របទៅតាមសមត្ថភាពយល់ដឹងរបស់ពួក-គេ។ ក្រុមអង្គការសង្គមស៊ីវិលដែលឃ្លាំមើលកិច្ចការនេះ អាចប្រើប្រាស់ព័ត៌មានដើមដែលពួកគេទទួលបាន ចំណែកឯប្រព័ន្ធផ្សព្វផ្សាយ និង ជាពិសេសក្រុមអ្នកបោះឆ្នោតនឹងទទួលបានប្រយោជន៍កាន់តែច្រើនថែមទៀតពីព័ត៌មានដែលមានលក្ខណៈសង្ខេបស្តីអំពីនិន្នាការទូទៅ និង តួអង្គពាក់ព័ន្ធសំខាន់ៗ ។ ប្រសិនបើអាចធ្វើទៅបាន ព័ត៌មានដើមនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនយោបាយ អាចនឹងកាន់តែមានសារៈប្រយោជន៍ប្រសិនបើវាត្រូវបានរៀបចំនៅក្នុងទម្រង់ដែលងាយស្រួលអាន ដូចជាតារាងទិន្នន័យ ឬ ឯកសារព័ត៌មានមូលដ្ឋានដែលយើងអាចយកមកប្រើប្រាស់បាន ។ ទម្រង់ព័ត៌មានបែបនេះពុំសូវចាំបាច់ប៉ុន្មានទេចំពោះប្រព័ន្ធផ្សព្វផ្សាយ ដែលធ្វើការងារលើការបោះពុម្ពផ្សាយព័ត៌មាន ឬ ពុំសូវមានប្រយោជន៍ទេសម្រាប់សាធារណជន ដែលនឹងត្រូវការព័ត៌មានសង្ខេបៗតែប៉ុណ្ណោះ។ សម្រាប់អង្គការក្រៅរដ្ឋាភិបាល ព័ត៌មានបែបនេះអាចនឹងមានភាពចាំបាច់ក្នុងការវិភាគទិន្នន័យ ហើយរៀបចំទិន្នន័យទាំងនោះក្នុងទម្រង់មួយដែលងាយស្រួលយល់។ ដោយប្រើប្រាស់ដំណើរការបែបនេះ អង្គការក្រៅរដ្ឋាភិបាលអាចជួយផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតនិងប្រព័ន្ធផ្សព្វផ្សាយ ហើយនឹងអាចជួយសម្រាលបន្ទុកការងារពីភ្នាក់ងារត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុនយោបាយបានមួយកម្រិតទៀត[26]។

ប្រសិនបើគេពុំអាចប្រើប្រាស់ប្រព័ន្ធអាំងទែណែតបានយ៉ាងទូលំទូលាយ ឬ ពុំមានដំណោះស្រាយជាក់ស្តែងណាមួយដែលអង្គភាពពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយអាចធ្វើទៅបាននោះទេ អង្គភាពដែលមានសមត្ថកិច្ចនោះអាចផ្សព្វផ្សាយព័ត៌មានហិរញ្ញវត្ថុនយោបាយយ៉ាងទូលំទូលាយបាន ដោយការថតចម្លងមូលប្បទានបត្រ វិក័យបត្រផ្សេងៗដែលបញ្ជាក់ពីការចំណាយ។ល។ ដែលសាធារណជនអាចចូលទៅមើលបាននៅការិយាល័យរបស់អង្គភាពនោះនៅក្នុងម៉ោងធ្វើការ។ ការនេះអាចធ្វើឲ្យក្រុមអ្នកឃ្លាំមើល និង អ្នកសិក្សាស្រាវជ្រាវអាចផ្តើមស៊ើបអង្កេតបានដោយឯករាជ្យ និង ទទួលបានព័ត៌មានដើមពីរបាយការណ៍នេះសម្រាប់ធ្វើការវិភាគ។

---

*[25] ហ្សាវ៉ាតូ ដានីញែល (២០០៣) "ចរិតលក្ខណៈខាងផ្លូវច្បាប់ និង ការអនុវត្តជាក់ស្តែងនៃការផ្តល់មូលនិធិដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោតក្នុងទ្វីបអាមេរិចឡាទីន" នៅក្នុងសៀវភៅណែនាំស្តីអំពីការផ្តល់មូលនិធិដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោត ទំព័រ១១២ របស់អង្គការអាយឌៀអន្តរជាតិ ប្រចាំទីក្រុងស្តុកខុម។*

*[26] គណៈកម្មការរៀបចំការបោះឆ្នោតសហព័ន្ធសហរដ្ឋអាមេរិចអនុញ្ញាតឲ្យអ្នកប្រើប្រាស់គេហទំព័ររបស់គណៈកម្មការនេះដឹងអំពីហិរញ្ញវត្ថុរបស់បេក្ខជនម្នាក់ៗ ដោយបង្ហាញអំពីឈ្មោះអ្នកផ្តល់អំណោយ ឈ្មោះរបស់ក្រុមហ៊ុន និង អាសយដ្ឋាន។ល។ គណៈកម្មការរៀបចំការបោះឆ្នោតនៅកាណាដា ក៏បានផ្តល់ទិន្នន័យដែលអាចស្រាវជ្រាវបានស្រដៀងគ្នានេះដែរ។ អង្គការក្រៅរដ្ឋាភិបាលសហរដ្ឋអាមេរិចមួយឈ្មោះមជ្ឈមណ្ឌលសម្រាប់នយោបាយឆ្លើយតបប្រើប្រាស់ប្រភពទិន្នន័យអេឡិចត្រូនិចដែលបោះពុម្ពដោយគណៈកម្មការបោះឆ្នោតសហរដ្ឋអាមេរិច ដើម្បីផលិតជារបាយការណ៍ដែលមានសារប្រយោជន៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ និង សាធារណជន ដូចជា អត្ថបទសង្ខេបអំពីការធ្វើវិភាគទាននយោបាយដោយក្រុមហ៊ុនឧស្សាហកម្មសំខាន់ៗមួយចំនួន។ សម្រាប់ការអានបន្ថែម សូមរកមើលក្នុងគេហទំព័រwww.fec.gov និង www.opensecrets.org។*

### *តើត្រូវធ្វើការបង្ហាញព័ត៌មាននៅពេលណា ?*

ពេលវេលាដែលការបង្ហាញព័ត៌មានអំពីហិរញ្ញវត្ថុនយោបាយគួរធ្វើឡើងនឹងអាស្រ័យទៅលើបរិការណ៍នៃសកម្មភាពដែលការបង្ហាញព័ត៌មានត្រូវគ្រប់ដណ្តប់ និង ការប្រើប្រាស់ព័ត៌មានទាំងនោះសម្រាប់គោលបំណងណាមួយ (ដូចជា ការផ្សព្វផ្សាយនូវកម្មវិធីជាយលំអិត ឬ ការផ្សព្វផ្សាយដល់សាធារណជនជាដើម)។

ដូចដែលយើងបានពិភាក្សារួចមកហើយ ទាំងគណបក្សនយោបាយ និង បេក្ខជន គួរផ្សព្វផ្សាយដោយស្ម័គ្រចិត្តនូវហិរញ្ញវត្ថុរបស់ពួកគេដែលទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោត។ ព័ត៌មានអំពីហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោតដែលអ្នកបោះឆ្នោតត្រូវដឹងត្រូវតែបង្ហាញក្នុងរយៈពេលមួយសមស្របមុនថ្ងៃបោះឆ្នោត។ ប្រសិនបើអាចធ្វើបាន គណបក្សនយោបាយ និង បេក្ខជនដែលឈរឈ្មោះទាំងអស់គួរបង្ហាញរាល់សកម្មភាពហិរញ្ញវត្ថុរបស់ខ្លួនយ៉ាងទៀងទាត់នៅគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោតដោយមិនគិតថា គណនីរបស់ពួកគេមានការផ្លាស់ប្តូរឬយ៉ាងណា នោះទេ[27]។ គណៈកម្មការយុទ្ធនាការឃោសនាបោះឆ្នោតគួរបង្ហាញព័ត៌មានហិរញ្ញវត្ថុទាំងមូលរបស់ពួកគេនៅពេលបានទទួលមូលនិធិ នៅក្នុងអំឡុងពេលបោះឆ្នោត នៅក្រោយការបោះឆ្នោត និង នៅពេលបិទបញ្ជីគណនី។

ប្រព័ន្ធធ្វើរបាយការណ៍ហិរញ្ញវត្ថុមួយទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោតនោះអាចដាក់បញ្ចូលនូវកាតព្វកិច្ចមួយចំនួនដូចខាងក្រោមសម្រាប់ធ្វើរបាយការណ៍។

វិធានការផ្សេងៗគ្នាអាចជួលស្ថាប័នត្រួតពិនិត្យរបាយការណ៍ធ្វើការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុរបស់បេក្ខជននយោបាយដល់សាធារណជន ដូចជា៖ ការបង្ហាញរបាយការណ៍តាមប្រព័ន្ធអេឡិចត្រូនិចដោយគណបក្សនយោបាយនិងបេក្ខជន ការប្រើប្រាស់ទម្រង់បទដ្ឋាននានា ការប្រើប្រាស់បច្ចេកវិទ្យាស្កេនអុបទិច និង ការប្រើប្រាស់ប្រព័ន្ធទិន្នន័យ ដែលគេអាចបើកមើលព័ត៌មានហិរញ្ញវត្ថុនយោបាយដោយផ្ទាល់បាន។

## វិធីសាស្រ្តអនុវត្តសម្រាប់ក្របខ័ណ្ឌច្បាប់ដែលសមហេតុផល និង អាចប្រព្រឹត្តទៅបាន

| | |
|---|---|
| របាយការណ៍មុនពេលឃោសនា | អ្នកចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតរាយការណ៍ពីទ្រព្យនិងបំណុលរបស់ខ្លួន មុននឹងផ្តើមយុទ្ធនាការឃោសនាបោះឆ្នោត។ |
| របាយការណ៍ក្នុងពេលឃោសនា | អ្នកចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតរាយការណ៍ជាប្រចាំពីចំណូល និង ចំណាយរបស់ខ្លួន។ |
| របាយការណ៍ក្រោយបោះឆ្នោត | អ្នកចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតរាយការណ៍ពីចំណូល និង ចំណាយក្នុងអំឡុងពេលឃោសនាទាំងមូល។ របាយការណ៍នេះក៏អាចបញ្ចូលទាំងព័ត៌មានអំពីទ្រព្យនិង បំណុលរបស់ពួកគេក្រោយការបោះឆ្នោតផងដែរ។ |

[27] *គណបក្សនយោបាយនៅចក្រភពអង់គ្លេស និង គណៈកម្មការយុទ្ធនាការឃោសនានៅសហរដ្ឋអាមេរិចធ្វើរបាយការណ៍ហិរញ្ញវត្ថុរបស់គេ ក្នុងរយៈពេលបីខែម្តង។ សូមអាន GRECO (2008) ការវាយតម្លៃលើកទីបី៖ របាយការណ៍វាយតម្លៃស្តីអំពីតម្លាភាពមូលនិធិគណបក្សនយោបាយនៅចក្រភពអង់គ្លេស (ទីក្រុងស្ត្រាសប៊ួរ៖GRECO ទំព័រ១៨។*

គ្មានប្រព័ន្ធនៃការបង្ហាញព័ត៌មានណាមួយអាចអនុវត្តបានឡើយ ប្រសិនបើមានការដាក់បន្ទុកច្រើនពេកដល់គណបក្ស និង បេក្ខជននយោបាយ ។ ច្បាប់បទដ្ឋានត្រូវតែមានតុល្យភាពរវាងសមហេតុផល និងអាចឲ្យបញ្ញត្តិករហិរញ្ញវត្ថុនយោបាយ និង ហិរញ្ញប្បទានរបស់បេក្ខជន និង គណបក្សនយោបាយអនុវត្តបាន ។ តម្រូវការដែលគេអាចបំពេញបានត្រូវមានភាពស៊ីសង្វាក់គ្នាទៅនឹងវិស័យ បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធ និង សេដ្ឋកិច្ចរបស់រដ្ឋនីមួយៗ។ ឧទាហរណ៍ជាក់ស្តែង ការបង្ហាញព័ត៌មានតាមប្រព័ន្ធអ៊ីនធឺណិត នឹងមិនមែនជាមធ្យោបាយមួយដ៏ប្រពៃឡើយ ប្រសិនបើអ៊ីនធឺណែតមិនត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយក្នុងប្រទេសណាមួយទេនោះ។ កំណត់ទម្រង់ដែលអាចសម្រេចទៅបាន គឺតម្រូវការដែលគណបក្សនយោបាយ បេក្ខជន និងបញ្ញត្តិករហិរញ្ញវត្ថុនយោបាយមានសមត្ថភាពពិតប្រាកដក្នុងការគោរពតាមនិងអនុវត្តបានយ៉ាងត្រឹមត្រូវតាមច្បាប់ដែលបានបញ្ញត្តិ។ ការតម្រូវឲ្យមានការបង្ហាញព័ត៌មានរាល់ការធ្វើវិភាគទាននយោបាយដែលមានតម្លៃចាប់ពី ១ អឺរ៉ូឡើងទៅនឹងបង្កើតជាបន្ទុកថែមទៀតដល់គណបក្សនយោបាយពិបាកអនុវត្តតាម និង ដែលបញ្ញត្តិករហិរញ្ញវត្ថុនយោបាយមានការលំបាកក្នុងការតាមដានរបាយការណ៍។ ដោយហេតុថា បទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយអាចប្រែក្លាយទៅជាគ្មានខ្លឹមសារដោយសារគេពុំអាចអនុវត្តបាន គេត្រូវតែបង្កើតប្រព័ន្ធហិរញ្ញប្បទាននយោបាយ ដោយគិតគូរអំពីបញ្ហាប្រឈមទាំងឡាយទៅតាមបរិបទរបស់រដ្ឋនីមួយៗ។

## ការកំណត់កម្រិតអប្បបរមាជាទូទៅនិង ករណីលើកលែងសម្រាប់ការបង្ហាញព័ត៌មាន

ទោះបីតម្លាភាពជាគោលបំណងសម្រាប់ការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយក៏ពិតមែន ប៉ុន្តែមានករណីលើកលែងមួយចំនួនដែលគណបក្សនយោបាយ និង បេក្ខជនពុំចាំបាច់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ទេ។ ជាងនេះទៅទៀត បញ្ញត្តិករហិរញ្ញប្បទាននយោបាយដែលព្យាយាមឲ្យសាធារណជនទទួលបានព័ត៌មានអំពីហិរញ្ញវត្ថុនយោបាយតែងតែកំណត់នូវការលើកលែងមួយចំនួន។

ហេតុផលយ៉ាងសាមញ្ញបំផុតសម្រាប់ការកំណត់ប្រភេទព័ត៌មាន ដែលគណបក្សនិង បេក្ខជននយោបាយត្រូវរាយការណ៍គឺដើម្បីធ្វើឲ្យកាន់តែងាយស្រួលសម្រាប់ការអនុវត្ត។ ក្នុងករណីជាច្រើនទៀត គេមិនអាចធ្វើបានឡើយចំពោះការទាមទារឲ្យមានការធ្វើរបាយការណ៍ដាច់ដោយឡែកៗលើការចំណាយនីមួយៗ ដោយមានភ្ជាប់ជាមួយនូវឯកសារសំអាង។ នៅក្នុងប្រទេសជាច្រើន គេបានកំណត់កម្រិតអប្បបរមាមួយ ដែលការចំណាយណាមួយតិចជាងកម្រិតកំណត់នេះគេគ្រាន់តែតម្រូវឲ្យធ្វើរបាយការណ៍រួមគ្នាក្នុងទម្រង់មួយ ឬមិនតម្រូវឲ្យមានការរាយការណ៍តែម្តង។

ករណីលើកលែងស្រដៀងគ្នានេះក៏កើតមានច្រើនដែរចំពោះការធ្វើវិភាគទានដែលមានកម្រិតតិចតួច។ ការលំបាកក្នុងករណីនេះគឺថា អ្នកធ្វើវិភាគទាននយោបាយ គណបក្សនយោបាយ និង បេក្ខជនអាចនឹងមានចេតនាលាក់កំបាំងនូវរាល់វិភាគទាននានាដែលពួកគេមិនចង់ឲ្យសាធារណៈជនបានដឹង តាមរយៈការបំបែកវិភាគទានទាំងនោះទៅជាចំណែកតូចៗដែលនឹងធ្លាក់នៅក្រោមកម្រិតអប្បរមាដែលត្រូវរាយការណ៍ ។ ជាជំហានដំបូងដើម្បីទប់ស្កាត់ករណីនេះ កម្រិតអប្បបរមាដែលត្រូវធ្វើរបាយការណ៍ត្រូវតែផ្អែកលើចំនួនទឹកប្រាក់សរុបដែលបានផ្តល់ឲ្យដោយអ្នកធ្វើវិភាគទាននយោបាយក្នុងកំឡុងពេលដែលត្រូវធ្វើរបាយការណ៍ ដោយមិនត្រូវគិតអំពីទំហំនៃការធ្វើវិភាគទានមួយលើកៗនោះទេ។ កម្រិតអប្បបរមាចំពោះការធ្វើវិភាគទានដែលត្រូវធ្វើរបាយការណ៍មានសភាពផ្សេងៗគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ដូចជា៖ ចាប់ពី ១០០ ដុល្លារឡើងទៅនៅប្រទេសអាហ្វហ្គានីស្ថាន និង ៨០០០ ដុល្លារឡើងទៅនៅចក្រភពអង់គ្លេស។

ករណីដោយឡែកមួយទៀតគឺថា តើបញ្ញត្តិការហិរញ្ញវត្ថុនយោបាយគួរបោះពុម្ពផ្សាយរាល់ព័ត៌មានទាំងអស់ដែលខ្លួនទទួលបានពីបេក្ខជនដែលចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតឬយ៉ាងណា ។ ចំពោះករណីនេះ ការលើកលែងដែលកើតមានច្រើនបំផុតនៅក្នុងការធ្វើរបាយការណ៍ជាប់ទាក់ទងទៅនឹងអត្តសញ្ញាណរបស់ម្ចាស់ជំនួយ។ ជារឿយៗ គេបានរៀបចំឲ្យមានអតិក្រមបរិមាណណាមួយ តាមកម្រិតដែលទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកធ្វើវិភាគទាននយោបាយ ដែលការធ្វើវិភាគទានក្នុងកម្រិតតិចតួចមិនត្រូវបានរាយការណ៍នោះទេ សូម្បីតែការធ្វើរបាយការណ៍ទៅឲ្យបញ្ញត្តិករហិរញ្ញវត្ថុនយោបាយក៏ដោយ។ ជាលទ្ធផល អតិក្រមនេះបានដកចេញនូវព័ត៌មានស្តីអំពីការធ្វើវិភាគទានដែលមានកម្រិតតិចតួចពីសាធារណជន។ សូម្បីតែនៅសហរដ្ឋអាមេរិក ប្រទេសដែលគេចាត់ទុកតម្លាភាពពេញលេញជាអតិក្រមទូទៅឆ្ពោះទៅរកបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយ ព័ត៌មានអាសយដ្ឋានរបស់អ្នកធ្វើអំណោយដល់បេក្ខជនឬ គណបក្សនយោបាយត្រូវបានគេដកចេញ (សូម្បីតែឈ្មោះ និង និយោជករបស់អ្នកធ្វើអំណោយនោះ)។

## ការតាក់តែងច្បាប់ស្តីអំពីការបង្ហាញព័ត៌មានឆ្ពោះទៅរកគោលដៅជាបទដ្ឋាន

គេអាចតាក់តែងច្បាប់សម្រាប់បញ្ញត្តិអំពីការធ្វើរបាយការណ៍ហិរញ្ញវត្ថុនយោបាយដោយពិស្តារបាន ទៅតាមគោលដៅជាបទដ្ឋានដែលគេប្រាថ្នាចង់បាន។ ក្នុងការសិក្សានេះ យើងនឹងផ្តើមបង្ហាញជូននូវគោលដៅជាបទដ្ឋានចំនួន ៣ គឺ៖ ភាពប្រកួតប្រជែង តម្លាភាព និងការទប់ស្កាត់ឥទ្ធិពលអវិជ្ជមាននៃហិរញ្ញវត្ថុនយោបាយ។ ក្នុងជំពូកនេះ យើងនឹងបញ្ជាក់គោលដៅនីមួយៗ និងពិភាក្សាដោយសង្ខេបអំពីទំនាក់ទំនងរវាងគោលដៅទាំងនោះជាមួយការរៀបចំប្រព័ន្ធនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុនយោបាយ។

### *តម្លាភាព*

តម្លាភាពហិរញ្ញវត្ថុនយោបាយសំដៅលើការប្រាថ្នាចង់បានការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ស្តីពីប្រភពធនធានរបស់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះ ហើយការធ្វើដូច្នេះ សាធារណជនអាចដឹងអំពីមូលដ្ឋាននៃការជួយឧបត្ថម្ភ និង អាកប្បកិរិយារបស់អ្នកនយោបាយ ។ គោលដៅសំខាន់គឺសម្រាប់ឲ្យអ្នកបោះឆ្នោតទាំងឡាយបានដឹងកាន់តែស៊ីជម្រៅពីគោលនយោបាយរបស់គណបក្សនយោបាយ និង បេក្ខជន ដែលអ្នកបោះឆ្នោតចង់បានដែលនាំឲ្យអ្នកបោះឆ្នោតមានជម្រើសជាក់ច្បាស់កាន់តែច្រើននៅពេលពួកគេទៅបោះឆ្នោត ។

ការកំនត់ពេលវេលា សម្រាប់បង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយ កម្រិតនៃព័ត៌មានលំអិតដែលត្រូវបង្ហាញ និង កិច្ចខិតខំប្រឹងប្រែងរបស់បញ្ញត្តិករហិរញ្ញវត្ថុនយោបាយក្នុងការផ្សព្វផ្សាយព័ត៌មានបន្តសុទ្ធសឹងជារឿងសំខាន់ៗ ដែលគេត្រូវយកចិត្តទុកដាក់ដើម្បីធានាឲ្យមាននូវតម្លាភាព។ ដូចសុភាសិតមួយបានពោលថា "ការពន្យារពេលក្នុងការផ្តល់ព័ត៌មាន គឺជាការបំផ្លាញក្នុងផ្តល់ព័ត៌មាន"។

ដោយហេតុថាអ្នកបោះឆ្នោតត្រូវគេគិតថាពុំមានពេលវេលា និង ធនធានគ្រប់គ្រាន់ក្នុងការសំយោគគំនិតរបស់ខ្លួនគេផ្ទាល់ចេញពីព័ត៌មានដែលគេបានដាក់បង្ហាញ វាជាការចាំបាច់ណាស់ដែលបញ្ញត្តិករហិរញ្ញវត្ថុនយោបាយត្រូវខិតខំផ្សព្វផ្សាយព័ត៌មានទាំងនោះជាផ្នែកផ្សេងៗដែលអ្នកបោះឆ្នោតងាយយល់ ។ នេះមានន័យថា ត្រូវសង្ខេបព័ត៌មានទិន្នន័យទាំងនោះតាមមធ្យោបាយសមស្របមួយ និង ធ្វើការផ្សព្វផ្សាយតាមរយៈបណ្តាញផ្សព្វផ្សាយនានាឲ្យបានច្រើន។ ការរក្សាទុករបាយការណ៍ហិរញ្ញវត្ថុនយោបាយនៅក្នុងការិយាល័យដែលបើកចំហរសម្រាប់សាធា-រណជនក៏អាចជាវិធីសាស្ត្រមួយល្អដែរ។ ការបង្ហោះព័ត៌មានតាមប្រព័ន្ធអ៊ីនធ័រណែត ការចែកចាយព័ត៌មានតាមរយ

បណ្ដាញបោះពុម្ពផ្សាយនិងទូរទស្សន៍ និងការបង្ហាញព័ត៌មាននៅក្នុងរបាយការណ៍ សុទ្ធសឹងតែជាមធ្យោបាយផងៗ ក្នុងការពង្រីកឲ្យបានជាអតិបរមានូវការទទួលបានព័ត៌មានជាសាធារណៈស្ដីពីហិរញ្ញវត្ថុនយោបាយ ។

អង្គការក្រៅរដ្ឋាភិបាល និង ស្ថាប័នសិក្សាស្រាវជ្រាវអាចមានសារៈសំខាន់នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។ ក្នុងកាលទេសៈខ្លះ ប្រព័ន្ធផ្សព្វផ្សាយអាចគ្រាន់បើជាងអ្នកបោះឆ្នោតតិចតួចប៉ុណ្ណោះក្នុងការរៀបចំទិន្នន័យឲ្យទៅជាក្រាហ្វិកព័ត៌មានប្រកបដោយខ្លឹមសារ។ សម្រាប់ហេតុផលនេះ បញ្ញត្តិករហិរញ្ញវត្ថុនយោបាយគួរបោះពុម្ពផ្សាយព័ត៌មានក្នុងទម្រង់ដែលសាធារណជនងាយអានបាន ឧទាហរណ៍ដូចជា៖ អត្ថបទព័ត៌មាន តារាងព័ត៌មានសង្ខេប ឬ តារាងទិន្នន័យមូលដ្ឋានជាដើម។ មធ្យោបាយទាំងនេះនឹងជួយឲ្យអ្នកស្រាវជ្រាវឯករាជ្យអាចប្រើប្រាស់ប្រភពទិន្នន័យទាំងនោះបានយ៉ាងរហ័សក្នុងការវិភាគព័ត៌មាន។ អ្វីទៅដែលសាធារណជនអាចទទួលបានពីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះក៏អាចបម្រើជាប្រយោជន៍សម្រាប់អ្នកសារព័ត៌មាននានា ក្នុងការតាមដានសកម្មភាពហិរញ្ញវត្ថុរបស់ក្រុមអ្នកនយោបាយឲ្យបានកាន់តែជិតស្និទ្ធ។ ព័ត៌មានដែលបេក្ខជននយោបាយ អាចនឹងជ្រើសរើសមិនយកមកបង្ហាញជូនសាធារណជនទៅ ជារឿយៗជាព័ត៌មានដែលគួរឲ្យចាប់អារម្មណ៍ជាងព័ត៌មានដែលគេបានដាក់បង្ហាញហើយ ជាទូទៅក្រុមអ្នកសារព័ត៌មានតែងចង់ស្វែងរកប្រភេទព័ត៌មានទាំងបន្ថែមទៀត។

ដើម្បីធ្វើឲ្យព័ត៌មានទាំងនោះជាព័ត៌មានដែលមានសារប្រយោជន៍ វាជាការចាំបាច់ណាស់សម្រាប់បញ្ញត្តិករហិរញ្ញវត្ថុនយោបាយធ្វើការផ្សព្វផ្សាយព័ត៌មានអំពីម្ចាស់ជំនួយរបស់គណបក្សនយោបាយ និង បេក្ខជន ដូចដែលបានបង្ហាញលំអិតក្នុងផ្នែកខាងលើរួចមកហើយអំពីប្រភេទព័ត៌មានដែលត្រូវរាយការណ៍នៅក្នុងរបាយការណ៍។ យោងតាមប្រភេទនីមួយ តម្លាភាពអាចអាស្រ័យទៅលើការទទួលព័ត៌មានអំពីអត្តសញ្ញាណ អាសយដ្ឋាន មុខរបរ និង និយោជករបស់អ្នកផ្ដល់វិភាគទាន ឬ ទទួលវិភាគទានហិរញ្ញវត្ថុនយោបាយ ។ ប្រសិនបើ នីតិបុគ្គលសាជីវកម្មទទួលបានការអនុញ្ញាតឲ្យផ្ដល់វិភាគទាននយោបាយ នោះព័ត៌មានស្ដីពីអត្តសញ្ញាណ អាសយដ្ឋាន និងឧស្សាហកម្មរបស់សាជីវកម្មទាំងនោះនឹងមានលក្ខណៈគ្រប់គ្រាន់អាចទទួលយកបាន។ ពាក់ព័ន្ធនឹងគោលបំណងនៃតម្លាភាពវិញ ព័ត៌មានដែលទាក់ទងនឹងម្ចាស់ជំនួយនឹងធ្វើឲ្យអ្នកបោះឆ្នោតបានដឹងអំពីទំនាក់ទំនងរបស់គណបក្សនយោបាយ និងបេក្ខជនជាមួយក្រុមហ៊ុនពាណិជ្ជកម្ម និង ក្រុមដែលមានឥទ្ធិពល។

នៅចុងបញ្ចប់ ការកំណត់ពេលវេលាក្នុងការបង្ហាញព័ត៌មានមានសារសំខាន់ណាស់សម្រាប់តម្លាភាព។ ប្រសិនបើអ្នកបោះឆ្នោតបានទទួលព័ត៌មានសំខាន់ៗនៅក្រោយថ្ងៃបោះឆ្នោត នៅថ្ងៃបោះឆ្នោត ឬ ជៀកនឹងថ្ងៃបោះឆ្នោត ព័ត៌មានទាំងនោះទំនងជាមិនមានប្រយោជន៍ចំពោះពួកគេឡើយ។ យើងអាចទាញការសន្និដ្ឋានថា បញ្ញត្តិករហិរញ្ញវត្ថុនយោបាយគួរតែចែកចាយព័ត៌មានដំបូងដើមទៅដល់ក្រុមសង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយយ៉ាងហោចណាស់ឲ្យបាន ២ ទៅ៣សប្ដាហ៍មុនថ្ងៃបោះឆ្នោតដើម្បីជាប្រយោជន៍ដល់អ្នកបោះឆ្នោត។

## ការទប់ស្កាត់ឥទ្ធិពលអវិជ្ជមានរបស់ហិរញ្ញវត្ថុនៅក្នុងនយោបាយ

តួអង្គមួយបង្កឲ្យមានឥទ្ធិពលអវិជ្ជមាននៅពេលដែលការបែងចែកធនធានធ្វើឡើងក្រៅសមភាព ដែលតួអង្គមួយទៀតគ្មានតុល្យភាពអំណាចក្នុងការតតាំង។ ឥទ្ធិពលនេះកើតឡើងនៅពេលដែល “ជនណាម្នាក់ប្រើប្រាស់អំណាចច្រើនលើសលប់ និងនៅពេលដែលជននោះត្រូវបានជំរុញឲ្យធ្វើអំពើណាមួយ ឬ ហាមប្រាមមិនឲ្យអ្នកដទៃធ្វើ

សកម្មភាពណាមួយដែលជននោះមិនចង់ឲ្យធ្វើ ឬជននោះនឹងធ្វើប្រសិនបើខ្លួនអាចធ្វើបានដោយសេរី"[28]។ អ្នកនយោបាយមួយក្រុមអាចនឹងបង្កើនឥទ្ធិពលបែបនេះ ប្រសិនបើសិនពួកគេអាចកាន់កាប់បានដោយឯកតោភាគីទៅលើខដែលមានចែងនៅក្នុងគោលនយោបាយ ឬ ការធ្វើកំណែទម្រង់។ ក្រុមខាងលើនេះ អាចនឹងបង្កើនឥទ្ធិពលដដែលនេះ តាមរយៈការបោះឆ្នោត ក្រុមឡោបភាពជួយទំនុកបំរុងដល់បេក្ខជន និងគណបក្សនយោបាយឲ្យបានឈ្នះក្នុងការបោះឆ្នោត ឬដោយផ្តល់សំណូកក្នុងចន្លោះពេលបោះឆ្នោតដល់អ្នកធ្វើគោលនយោបាយដែលបានជ្រើសតាំងដោយការបោះឆ្នោត។ ម្យ៉ាងវិញទៀត ក្រុមណាមួយដែលបានគ្រប់គ្រងស្ថាប័ន និង ធនធានរបស់ រដ្ឋក៏អាចនឹងបង្កើនឥទ្ធិពលបែបនេះដែរតាមរយៈការធ្វើឲ្យល្អក់កករដល់ដំណើរការបោះឆ្នោត ឬការប្រើប្រាស់ទ្រព្យសម្បត្តិ និងសេវាសាធារណៈដោយផ្តាច់មុខសម្រាប់ជាប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងពេលបោះឆ្នោត។ ករណីនេះជូនកាលសំដៅលើការរំលោភអំណាច ឬ សំដៅទៅលើបច្ចេកស័ព្ទដែលគេឃើញកើតមានជារឿយៗនៅក្នុងអតីតប្លុកកុម្មុយនីស្ត ពោលគឺការរំលោភបំពានធនធានរដ្ឋបាល។

ឥទ្ធិពលអវិជ្ជមាននេះអាចលេចរូបរាងច្បាស់លាស់នៅក្នុងការគន់គិតរបស់រដ្ឋាភិបាល ដើម្បីទទួលបានទ្រព្យសម្បត្តិដ៏ច្រើនមហិមា ឬអត្ថប្រយោជន៍ពិសេសនានាហួសពីអ្វីដែលបានកំណត់ដោយអណ្តត្តិបោះឆ្នោតរបស់ខ្លួន។ និយាយឲ្យចំទៅ ការបញ្ចុះបញ្ចូលរបស់ពួកក្រុមដែលទទួលបានប្រយោជន៍ពីឥទ្ធិពលរបស់ខ្លួនអាចនឹងពេញចិត្តពេញថ្លើមជាមួយនឹងលទ្ធភាពពិសេសដែលពួកគេទទួលបានក្នុងការទាក់ទងជាមួយនឹងសមាជិកសភាតំណាងរាស្ត្រដោយសារឥទ្ធិពលនៃការជួយឧបត្ថម្ភជាធនធាន ឬ សម្ភារៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ។ ជាលទ្ធផលគោលនយោបាយសាធារណៈមានភាពលំអៀងទៅរកផលប្រយោជន៍របស់ក្រុមជនទាំងនោះ ជាជាងបម្រើឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត។

ខណៈដែលឥទ្ធិពលអវិជ្ជមានខាងលើនេះមានការលំបាកនៅក្នុងការអង្កេតរកការពិត ហើយថែមទាំងពិបាកក្នុងការបង្ការមិនឲ្យកើតមានឡើង ការលើកកម្ពស់តម្លាភាពអាចជាមធ្យោបាយដ៏មានប្រយោជន៍ដើម្បីកាត់បន្ថយបញ្ហានានាដែលកើតចេញពីឥទ្ធិពលនេះ។ ច្បាប់នានាដែលបញ្ញត្តិអំពីការបើកចំហរព័ត៌មាន អាចនឹងជួយកាត់បន្ថយបញ្ហាទាំងនោះជាអតិបរមាតាមរយៈការផ្តល់ព័ត៌មានឲ្យអ្នកបោះឆ្នោតបានដឹងថា អ្នកណាជាអ្នកជួយឧបត្ថម្ភដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោតរបស់ពួកគេ ដូចដែលយើងបានរៀបរាប់ខាងលើរួចមកហើយ ឬតាមរយៈការជំរុញឲ្យអជ្ញាធរដែលទទួលខុសត្រូវធ្វើការពិនិត្យ និង ចាត់ការទៅការរំលោភបំពានក្រមសីលធម៌ និង វិធាននានាដែលបានចែងអំពីការឃោសនា។ នៅមុនការបោះឆ្នោត ការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយប្រកបដោយប្រសិទ្ធិភាពបានលើកទឹកចិត្តឲ្យមានការប្រកួតប្រជែងដោយយុត្តិធម៌ពីសំណាក់គណបក្សនយោបាយ និង បេក្ខជន ដោយចៀសវាងពីការដាក់ទណ្ឌកម្ម (ទោះជាផ្នែកហិរញ្ញវត្ថុ រដ្ឋបាល ឬនយោបាយក៏ដោយ)។ ក្រោយពីការបោះឆ្នោត ការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយបានជម្រុញឲ្យមានគណនេយ្យភាពតាមរយៈការអនុញ្ញាតឲ្យក្រុមអ្នកយកព័ត៌មាន ក្រុមសង្គមស៊ីវិល និងអ្នកបោះឆ្នោតផ្សារភ្ជាប់គោលនយោបាយ ទៅនឹងទម្រង់ចម្បងៗនានានៃជំនួយហិរញ្ញវត្ថុ។ ឧបករណ៍គោលនយោបាយដ៏សំខាន់នៅទីនេះគឺការពង្រីកវិសាលភាព និង និងភាពពិស្តារនៃការបង្ហាញព័ត៌មាន។ ការតម្រូវឲ្យមានការបង្ហាញព័ត៌មាននៅចន្លោះពេលបោះឆ្នោតក៏អាចជួយទប់ស្កាត់ការធ្វើវិភាគទាននយោបាយជាថ្នូរនឹងការតបស្នង ដែលការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុទាំងនោះត្រូវបានគេដឹងយ៉ាង

[28] *វចនានុក្រមប្លាកឡូ បោះពុម្ពលើកទី៥ ឆ្នាំ១៩៧៩*

ច្បាស់ថាអ្នកនយោបាយនឹងផ្តល់អត្ថប្រយោជន៍ដល់ពួកគេវិញតាមរយៈការផ្តល់កិច្ចសន្យា ការលើកលែងពន្ធ។ល។ ដល់អ្នកធ្វើវិភាគទានទាំងនោះ។

ទំរង់មួយផ្សេងទៀតនៃឥទ្ធិពលអវិជ្ជមាននេះកើតចេញពីសកម្មភាពដោយផ្ទាល់របស់រដ្ឋ នៅពេលដែលបុគ្គលមានអំណាចមានលទ្ធភាពកាន់កាប់ធនធានរបស់រដ្ឋ ជនទាំងនោះនឹងប្រើប្រាស់ធនធានទាំងនោះដើម្បីធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត។ ការប្រើយានយន្តរបស់រដ្ឋ និងប្រព័ន្ធឃោសនារបស់រដ្ឋដើម្បីប្រយោជន៍ផ្ទាល់របស់គណបក្សនយោបាយក្នុងពេលយុទ្ធនាការឃោសនាគឺជាឧទាហរណ៍ពីរដែលបង្ហាញអំពីឥទ្ធិពលអវិជ្ជមាននោះ។ ឧបករណ៍ដ៏សំខាន់ក្នុងការអង្កេតរកការពិតចំពោះសកម្មភាពរំលោភបំពានខាងលើនេះគឺការបង្ហាញពីប្រភេទ និង ប្រភពនៃកម្ចី និង ការធ្វើវិភាគទាននយោបាយ ជាពិសេសក្នុងចន្លោះពេលបោះឆ្នោត។ អ្វីដែលពិបាកជាងនេះទៅទៀតក្នុងការរកឲ្យឃើញការពិត គឺថាគណបក្សកាន់អំណាចអាចសន្យាថានឹងផ្តល់ការងារ កិច្ចសន្យា និង ជួយការពារក្រុមជនដែលបានឧបត្ថម្ភដល់គណបក្សកាន់អំណាចជាថ្នូរនឹងការខិតខំប្រឹងប្រែងរបស់ជនទាំងនោះ ដែលបានធ្វើឲ្យគណបក្សគេឈ្នះឆ្នោត។ ការបង្ហាញព័ត៌មានលំអិតអាចជួយក្រុមសកម្មជន និងបញ្ញត្តិករហិរញ្ញវត្ថុ-នយោបាយរកឃើញទម្រង់នៃឥទ្ធិពលអវិជ្ជមាននេះ។ ជាឧទាហរណ៍ ប្រសិនបើអ្នកទទួលផលពីការសម្រេចនានារបស់រដ្ឋាភិបាលតាមដានមើលយ៉ាងជិតដល់ទៅលើព័ត៌មានអំពីអាសយដ្ឋាន និយោជក និង សកម្មភាពពាណិជ្ជកម្មរបស់អ្នកផ្តល់អំណោយដល់គណបក្សនយោបាយ នោះគេនឹងអាចរកឃើញភស្តុតាងដែលបង្ហាញពីការប្រព្រឹត្តមិនត្រឹមត្រូវទាំងនោះ។ ក្នុងប្រទេសមួយចំនួន ដែលរដ្ឋាភិបាលប្រើមធ្យោបាយមិនស្របច្បាប់ដើម្បីយកជ័យជំនះលើការបោះឆ្នោត វាគឺជាការចាំបាច់ណាស់ (បើទោះជាមិនទំនងថានឹងអាចធ្វើបានក៏ដោយ) ដែលស្ថាប័នទទួលបន្ទុកផ្នែកទទួល និងវិភាគរបាយការណ៍ពីគណបក្សនយោបាយ និង បេក្ខជនត្រូវមានឯករាជភាព និង មានធនធានគ្រប់គ្រាន់។

ការទិញសន្លឹកឆ្នោតក៏ជាធាតុផ្សំមួយនៃឥទ្ធិពលអវិជ្ជមាននៃហិរញ្ញវត្ថុនយោបាយដែរ ព្រោះវាបានធ្វើឲ្យអ្នកបោះឆ្នោតខុសពីចំណូលចិត្តនយោបាយរបស់ខ្លួន ដែលអាចបណ្តាលឲ្យមានឥទ្ធិពលមិនល្អរយៈពេលវែងសម្រាប់ពួកគេ ជាថ្នូរទៅនឹងការទទួលយកអំណោយលួងចិត្តរយៈពេលខ្លីពីអ្នកនយោបាយ។ ការទិញសន្លឹកឆ្នោតគឺជាបាតុភាពមួយក្នុងបណ្តាបាតុភាពនានាដែលគេពិបាកនឹងរកឲ្យឃើញ។ ការពិនិត្យពិច័យឲ្យបានច្បាស់លាស់ទៅលើការចំណាយរបស់គណបក្សនយោបាយ និង បេក្ខជន ប្រៀបធៀបនឹងអ្វីជាក់ស្តែងដែលគេបានទិញអាចនឹងបង្ហាញឲ្យយើងឃើញការពិត។ ដូច្នេះដែរ ភាពចាំបាច់ក្នុងការគ្រប់គ្រងការទិញសន្លឹកឆ្នោតនោះ បញ្ជាក់ពីសារសំខាន់នៃការបង្ហាញព័ត៌មានអំពីការចំណាយរបស់គណបក្សនយោបាយ និង បេក្ខជន។

## *ការប្រកួតប្រជែង*

គោលបំណងទីបីដែលជាគោលបំណងទូលំទូលាយ គឺពាក់ព័ន្ធទៅនឹងការពង្រឹងការប្រកួតប្រជែងគ្នារវាងគណបក្សនយោបាយ និង បេក្ខជន ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលនៃការរៀបចំបង្កើតប្រព័ន្ធហិរញ្ញវត្ថុនយោបាយមានការប្រែប្រួល អាស្រ័យទៅតាមរបៀបដែលគេកំនត់សម្រាប់ការចូលរួមប្រកួតប្រជែង ។ ទោះជាបែបនេះក្តី អ្វីដែលទស្សនទាននីមួយៗចែករំលែកជាមួយទស្សនទានដទៃទៀតគឺការទទួលស្គាល់ថា រាល់យុទ្ធនាការឃោសនាទាំងអស់អាស្រ័យទៅលើសម្ភារៈនានាដែលមានតម្លៃជាសាច់ប្រាក់។

បើតាមទស្សនៈមួយ ភាពប្រកួតប្រជែងគ្នាបង្កប់នូវអត្ថន័យមួយសំដៅទៅលើ "ទីលានប្រកួតប្រជែងស្មើភាព" លទ្ធភាពជាមូលដ្ឋានសម្រាប់គ្រប់គណបក្សនយោបាយ និង បេក្ខជនទាំងអស់ផ្សព្វផ្សាយសារនយោបាយរបស់ខ្លួន[29]។ តាមលក្ខណៈបច្ចេកទេស លទ្ធភាពក្នុងការផ្សព្វផ្សាយសារនយោបាយសំដៅទៅលើការប្រើប្រាស់បណ្ដាញទូរទស្សន៍ ប្រព័ន្ធបំពងសម្លេង ផ្ទាំងប៉ាណូធំៗ ទីលានប្រមូលផ្ដុំ និង មធ្យោបាយឃោសនាផ្សេងទៀត ។ បញ្ហាប្រឈមចំនួន ២ ដែលកើតមានឡើងពីទីលានប្រកួតប្រជែងមិនស្មើភាព គឺថា យុទ្ធនាការឃោសនាមួយអាចនឹងមិនមានថវិកាគ្រប់គ្រាន់ដើម្បីទទួលបានធនធានទាំងនោះយកមកប្រើប្រាស់សម្រាប់ឃោសនា ឬ ធនធានសម្រាប់យុទ្ធនាការឃោសនារបស់គូប្រជែងរបស់គេអាចមានចំនួនច្រើនលើសលុបជាង ដែលជាហេតុធ្វើឲ្យសារនយោបាយក្នុងយុទ្ធនាការឃោសនារបស់ភាគីម្ខាងទៀតមិនបានជ្រួតជ្រាបដល់អ្នកបោះឆ្នោត។ គេបានធ្វើការវិនិច្ឆ័យផ្អែកតាមការយល់ឃើញមួយនៅក្នុងការកំនត់ថា "សមភាពកម្រិតណា" ដែលហៅថាទីលានប្រកួតប្រជែងស្មើភាព ។ សម្រាប់គោលបំណងពិតប្រាកដ "សមភាព" នៅក្នុងការប្រកួតប្រជែងសំដៅដល់ការលុបបំបាត់គម្លាតខុសគ្នារវាងអ្នកប្រកួតប្រជែងទាំងអស់នៅក្នុងការបោះឆ្នោត ចំណែកឯការពន្យល់បែបសាមញ្ញវិញ "សមភាព" ផ្ដោតទៅលើការដែលថា អ្នកដែលចូលរួមប្រកួតប្រជែងទាំងអស់មានលទ្ធភាពទទួលបានធនធានគ្រប់គ្រាន់ដើម្បីធ្វើឲ្យសម្លេងរបស់ពួកគេបានលឺទៅដល់អ្នកបោះឆ្នោត។

គោលបំណងនៃការធ្វើឲ្យមានភាពប្រកួតប្រជែងបង្កប់បទបញ្ញត្តិហិរញ្ញវត្ថុនយោបាយមួយចំនួន ដែលត្រូវបានបង្កើតឡើងដើម្បីផ្ដល់ឱកាសប្រកួតប្រជែងគ្រប់រូបទទួលបាន និង ប្រើប្រាស់ ធនធានស្មើគ្នា។ បទបញ្ញត្តិទាំងនោះកំណត់អំពី ដែនកំនត់លើការធ្វើវិភាគទាន និងការចំណាយ រយៈពេលផ្សព្វផ្សាយការឃោសនា ដែលមានថេរវេលាកំណត់ និងការផ្ដល់មូលនិធិរបស់រដ្ឋសម្រាប់សកម្មភាពរបស់គណបក្សនយោបាយ និងយុទ្ធនាការឃោសនា។ បទប្បញ្ញត្តិទាំងនេះគូសបញ្ជាក់ពីភាពចាំបាច់ចំពោះការបង្ហាញឲ្យបានលំអិត និង ទៀងទាត់ ទៅតាមពេលវេលាដែលបានកំណត់។ ប្រសិនបើគេពុំបានបង្ហាញលំអិតអំពី អត្តសញ្ញាណ មុខរបរ និងកន្លែងធ្វើការរបស់អ្នកធ្វើអំណោយដល់គណបក្សនយោបាយ និង បេក្ខជននោះទេ នោះគេក៏ពុំអាចអនុវត្តការកំណត់ព្រំដែនចំពោះការធ្វើវិភាគទានបានដែរ។ អ្នកធ្វើអំណោយម្នាក់អាចនឹងធ្វើការផ្ដល់អំណោយជាច្រើនដងដល់គណបក្សនយោបាយ ឬ បេក្ខជន ដោយប្រើឈ្មោះផ្សេងៗដែលខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះ តាមរយៈប្ដីឬប្រពន្ធ ឬកូនចៅរបស់គេ ឬតាមរយៈនិយោជកណាម្នាក់។ ដូចគ្នានេះដែរ និយោជកមួយអាចនឹងផ្ដល់អំណោយជាច្រើនលើកតាមរយៈនិយោជិតរបស់ខ្លួន[30]។

ក្រៅពីការធ្វើវិភាគទាននយោបាយ ការដាក់ដែនកំណត់លើការចំណាយសម្រាប់ការឃោសនាបោះឆ្នោត និងការផ្ដល់មូលនិធិរបស់រដ្ឋដល់គណបក្សនយោបាយឬបេក្ខជន តម្រូវឲ្យមានការបង្ហាញព័ត៌មានយ៉ាងទៀងទាត់ និងគ្រប់គ្រាន់ក្នុងរយៈពេលទាំងមូលនៃការបោះឆ្នោតនីមួយៗ។ ដោយអាស្រ័យទៅលើប្រព័ន្ធដែលគេប្រើប្រាស់សម្រាប់ការផ្ដល់មូលនិធិសាធារណៈ បញ្ញត្តិការហិរញ្ញវត្ថុនយោបាយត្រូវការព័ត៌មានជាទៀងទាត់អំពីទ្រព្យសម្បត្តិដែលមានសម្រាប់ការឃោសនាបោះឆ្នោតដើម្បីធានាថាគណនាបានយ៉ាងសុក្រឹតអំពីភាពសមស្របក្នុងការទទួលយកមូលនិធិនេះ

[29] *ចំណាប់អារម្មណ៍របស់ ខាសាស ហ្សាម៉ូរ៉ា ខេវិន (២០០៩) ក្នុងសន្និសីទស្ដីអំពីបទដ្ឋានសាកលក្នុងហិរញ្ញវត្ថុនយោបាយ ដែលរៀបចំឡើងដោយអង្គការអាយហ្វេស និង មូលស្ថាបនាខាផ័រ កាលពីថ្ងៃទី ២២ ដល់ ២៣ មករា។*

[30] *គណៈកម្មការបោះឆ្នោតសហព័ន្ធដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិច និង មជ្ឈមណ្ឌលសម្រាប់នយោបាយដែលមានការឆ្លើយតប ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយធ្វើការងារផ្ដោតទៅលើតម្លាភាពហិរញ្ញវត្ថុ បានធ្វើការចំណាយធនធានជាច្រើនដើម្បីកំណត់អំពីចំនួនសរុបនៃថវិការដែលបុគ្គលម្នាក់ធ្វើអំណោយដល់បេក្ខជន ឬ គណបក្សនយោបាយ។*

របស់អង្គភាពដែលរៀបចំយុទ្ធនាការឃោសនា។ នៅក្នុងករណីជាច្រើន ព័ត៌មានទាំងនោះបានមកពីការបង្ហាញគណនីរបស់គណបក្សនយោបាយ។ ដូច្នេះ ដើម្បីធានាឲ្យបាននូវលទ្ធភាពប្រកួតប្រជែងមួយស្មើភាពក្នុងក្របខ័ណ្ឌនៃការចំណាយ បញ្ញត្តិការហិរញ្ញវត្ថុនយោបាយពិតណាស់ចាំបាច់ត្រូវតែដឹងពីអ្វីដែលគណបក្សនយោបាយ និង បេក្ខជនបានចំណាយ។

## ដំណោះស្រាយសម្រាប់ឧបសគ្គនានាចំពោះការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយ

ផ្នែកផ្សេងៗដែលបានលើកឡើងខាងដើមបានធ្វើការសន្និដ្ឋានលក្ខខណ្ឌនយោបាយនានា ដែលជារឿយៗពុំសូវកើតមានឡើងឡើយ។ លក្ខខណ្ឌទាំងនោះរួមបញ្ចូលទាំង អង្គភាពពង្រឹងការអនុវត្តហិរញ្ញវត្ថុនយោបាយដែលមានភាពឯករាជ្យនិងមានធនធានគ្រប់គ្រាន់ ឆន្ទៈនយោបាយក្នុងការអនុវត្តនិង/ឬគោរពច្បាប់ដែលបញ្ញត្តិអំពីការបង្ហាញព័ត៌មាន និង ដំណើរការបោះឆ្នោតប្រកបដោយសេរី និង យុត្តិធម៌ជាទូទៅ។ នៅក្នុងផ្នែកនេះ យើងនឹងបង្ហាញពីទស្សនៈបឋមៗមួយចំនួនស្ដីពីវិធីសាស្ត្រក្នុងការលើកកម្ពស់ការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយ ក្នុងបរិបទមួយចំនួនដែលពុំមានលក្ខខណ្ឌអនុគ្រោះដូចបានរៀបរាប់ខាងលើ។

### *កង្វះឆន្ទៈនយោបាយធ្វើឲ្យស្ថាប័នពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយមានភាពទន់ខ្សោយ*

ប្រសិនបើអ្នកនយោបាយមកពីគណបក្សទាំងអស់ មានទិន្នន័យការយល់ព្រមលើបញ្ហាណាមួយ នោះវានឹងមិនរិតបន្តឹងការអនុវត្តនានាដែលគេមើលឃើញថានឹងជួយពួកគេឲ្យបានឈ្នះឆ្នោតនោះទេ។ ដោយសារមូលហេតុនេះហើយ ទើបបណ្ដាប្រទេសប្រជាធិបតេយ្យមួយចំនួនដែលមានរចនាសម្ព័ន្ធនយោបាយរឹងមាំ កម្រនឹងផ្ដល់សិទ្ធិប្រព័ន្ធបោះឆ្នោតរបស់ខ្លួនណាស់។ ដូចគ្នានេះដែរ ចេតនាក្នុងការបង្កើតឲ្យមាននីតិវិធីចំកន់ត្រូវដែលឯករាជ្យជារឿយៗមានសភាពដូចជាសមរភូមិដ៏ក្ដៅគគុកដូច្នេះដែរ។ ការកែទម្រង់ទៅលើការបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយក៏មានលក្ខណៈដូចគ្នាដែរ។ នៅក្នុងការអង្កេតថ្មីមួយរបស់អង្គការអាយហ្វេសដែលធ្វើជាមួយនឹងអ្នកជំនាញការ និងស្ថាប័នពង្រឹងការអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយ អ្នកផ្ដល់សម្ភាសន៍ជាច្រើនគិតថា ការជំទាស់យ៉ាងដាច់ខាតប្រឆាំងទៅនឹងការបង្ហាញព័ត៌មានគឺថា "បទប្បញ្ញត្តិដែលតម្រូវឲ្យបង្ហាញព័ត៌មានមិនអាចអនុវត្តបានឡើយ ដោយហេតុថា វាតែងតែមានកត្តាជាច្រើននៅជុំវិញការអនុវត្តនោះ"[31]។ សូម្បីតែនៅសហរដ្ឋអាមេរិកក៏ដោយ ក៏ច្បាប់ដែលបញ្ញត្តិអំពីការបើកចំហរព័ត៌មានដែលមានតាំងតែពីឆ្នាំ ១៩១០ មក មិនត្រូវបានយកមកអនុវត្តឡើយរហូតដល់ឆ្នាំ ១៩៧៥ ពេលគឺនៅពេលដែលសភាសហរដ្ឋអាមេរិកបង្កើតឲ្យមានទីភ្នាក់ងារឯករាជ្យមួយសម្រាប់អនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយ ដោយសារមានរឿងអាស្រូវដ៏ចម្រូងចម្រាស់មួយ។ នៅក្នុងកាលៈទេសៈនេះ សំនួរបិតនៅត្រង់ថា តើគេត្រូវរៀបចំ និង អនុវត្តការកែទម្រង់យ៉ាងដូចម្ដេចឲ្យមានប្រសិទ្ធភាព ប្រសិនបើគណបក្សនិងអ្នកនយោបាយមិនអនុវត្តតាមច្បាប់ដែលបញ្ញត្តិអំពីការបើកចំហរព័ត៌មានហិរញ្ញវត្ថុនយោបាយ។

ជាជំហានដំបូង អង្គការទទួលបន្ទុកត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយអាចត្រូវបានផ្ដល់អំណាចជាស្ថាប័នមួយឯករាជ្យ តែគណបក្សកាន់អំណាចអាចនឹងប្រើប្រាស់អំណាចគ្រប់គ្រងរដ្ឋរបស់ខ្លួនដើម្បីទប់ស្កាត់មិនឲ្យមានការ

---

[31] *របាយការណ៍អង្កេតស្ដីពីហិរញ្ញវត្ថុនយោបាយ ឆ្នាំ២០០៨ របស់អង្គការអាយហ្វេស។ ការអង្កេតនោះមានការចូលរួមពីអ្នកសិក្សាស្រាវជ្រាវ អ្នកធ្វើកំណែទម្រង់ និង ភាគីពាក់ព័ន្ធនឹងការបោះឆ្នោតមួយចំនួន។*

អនុវត្តច្បាប់បាន។ ក្នុងស្ថានភាពនេះ ភាពឯករាជ្យនៃស្ថាប័នអាចនឹងកាត់បន្ថយប្រសិទ្ធិភាពនៃយុទ្ធសាស្ត្រទាំងនេះ ។ តាមរយៈការផ្តល់ថវិកាគ្រប់គ្រាន់ដល់ស្ថាប័នពង្រឹងការអនុវត្តច្បាប់ហិរញ្ញវត្ថុនយោបាយ ការមានបុគ្គលិកធ្វើការគ្រប់គ្រាន់ និងការបន្តស្ថិតនៅក្នុងមុខតំណែងពីអំណាចរបស់ស្ថាប័នដែលកើតពីការបោះឆ្នោតជ្រើសតាំង គម្រូឯករាជ្យនេះអាចផ្តល់ឲ្យបញ្ញត្តិករហិរញ្ញវត្ថុនយោបាយនូវលំហផ្ទៃកនយោបាយ និង ធនធានដើម្បីពង្រឹងការអនុវត្តច្បាប់បើកចំហរព័ត៌មានដោយគ្មានការភ័យខ្លាច ការបណ្តេញចេញ ឬការសងសឹកជាដើម។ ជាគោលការណ៍ បញ្ញត្តិករហិរញ្ញវត្ថុនយោបាយត្រូវបែរការទន្ទឹមនឹងការរក្សាលក្ខណៈវិនិច្ឆ័យដូចគ្នាទៅនឹងអង្គភាពគ្រប់គ្រងការបោះឆ្នោតដែលឯករាជ្យជាពន្ធច្នោះដែរ។ នៅតាមបណ្តាប្រទេសជាច្រើន ការធ្វើបទបញ្ញាហិរញ្ញវត្ថុនយោបាយតាមពិតជាការទទួលខុសត្រូវរបស់អង្គភាពគ្រប់គ្រងការបោះឆ្នោត[32]។ ទោះជាយ៉ាងណាក៏ដោយ ភាពឯករាជ្យនៃស្ថាប័នដែលបង្កើតជាផ្លូវការតែឯកឯងនោះអាចនឹងមិនទាន់គ្រប់គ្រាន់សម្រាប់ធានាការអនុវត្តបទបញ្ញានោះទេ។ ដោយសារតែបញ្ញត្តិករហិរញ្ញវត្ថុនយោបាយភាគច្រើនពឹងផ្អែកលើមន្ត្រីជាប់ឆ្នោតក្នុងការតែងតាំងពួកគេ បញ្ញត្តិករហិរញ្ញវត្ថុនយោបាយទាំងនោះទំនងជាអាចនឹងត្រូវគេរៀបចំចាត់តាំងទៅតាមបំណងរបស់អ្នកនយោបាយ ស្របគ្នាទៅនឹងបេសកកម្មរបស់ទីភ្នាក់ងារពង្រឹងការអនុវត្តហិរញ្ញវត្ថុនយោបាយដែរ។ បន្ទាប់មកទៀត បើទោះបីជាបញ្ញត្តិករហិរញ្ញវត្ថុនយោបាយប្រើប្រាស់ឯករាជ្យភាព និង អណ្តត្តិរបស់ខ្លួនធ្វើការត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយយ៉ាងម៉ត់ចត់ក៏ដោយ ក៏ធនធានរបស់គេអាចនឹងនៅមានកម្រិត ដែលនាំឲ្យគេមិនអាចធ្វើការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពបាននោះទេ។ ប្រសិនបើស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយពុំមានភាពឯករាជ្យគ្រប់គ្រាន់ក្នុងការធានាឲ្យមានការអនុវត្តច្បាប់បានទេនោះ នោះការកែទម្រង់ចាំបាច់ត្រូវធ្វើឲ្យបានកាន់តែស៊ីជម្រៅ។ ការធ្វើកំណែទម្រង់ជារឿយៗត្រូវការការគាំទ្រពីសម្លេងភាគច្រើន តែគួរឲ្យសោកស្តាយដែលការគាំទ្របែបនេះជារឿយៗអាចគៀងគរបានតែនៅក្រោយពេលកើតមានរឿងអាស្រូវពុករលួយពាក់ព័ន្ធនឹងហិរញ្ញវត្ថុនយោបាយប៉ុណ្ណោះ។

## *ការរំលោភបំពានវិធានបើកចំហរព័ត៌មានដោយគណបក្សកាន់អំណាច*

ការបង្ហាញព័ត៌មានឲ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយជាប់ពាក់ព័ន្ធយ៉ាងសំខាន់ជាមួយការបង្ហាញឲ្យដឹងអំពីអ្នកធ្វើអំណោយ និង អ្នកទទួលហិរញ្ញវត្ថុនយោបាយ។ ដោយអាស្រ័យទៅលើកម្រិតនៃសុចរិតភាព និងស្ថាប័នីយកម្មនៃបទដ្ឋានប្រជាធិបតេយ្យនៅក្នុងសង្គមមួយ របៀបបង្ហាញព័ត៌មានខាងលើនេះអាចនឹងបង្កឲ្យមានហានិភ័យផ្សេងៗ។ ករណីប្រទេសអ៊ុយក្រែនជាឧទាហរណ៍មួយចំពោះករណីខាងលើនេះ ដែលអតីតប្រធានាធិបតីលោក *ឡេអូនីដ គូចម៉ា* កាលពីឆ្នាំ ២០០២ បានក្តាប់បានព័ត៌មានយ៉ាងច្រើនតាមរយៈការតម្រូវយ៉ាងតឹងរឹងនៅក្នុងការបង្ហាញព័ត៌មាន ហើយដែលព័ត៌មានទាំងនោះត្រូវបានប្រើប្រាស់ជាបន្តបន្ទាប់ដើម្បីធ្វើទុកបុកម្នេញគណបក្សប្រឆាំង តាមរយៈអជ្ញាធរពន្ធដារដែលនៅក្រោមបង្គាប់លោកប្រធានាធិបតីនោះ ក្រុមសមត្ថកិច្ចពន្ធគយអគ្គីភ័យ និងប៉ូលីសរបស់រដ្ឋជាដើម[33]។ ហានិភ័យនៃការធ្វើទុកបុកម្នេញដែលជាលទ្ធផលនៃការបង្ហាញព័ត៌មានមានលក្ខណៈកាន់តែធ្ងន់ធ្ងរនៅក្នុងបណ្តាប្រទេសដែលសង្គ្រាមទើបតែបានបញ្ចប់

---

[32] *សម្រាប់ការពិភាក្សាដោយសង្ខេបអំពីគម្រូនៃការគ្រប់គ្រងការបោះឆ្នោតដោយឯករាជ្យ សូមអានសៀវភៅណែនាំអំពីការគ្រប់គ្រងការបោះឆ្នោតរបស់អង្គការអាយឌាអ៊ីនធ័រណេស្សូណាល (ឆ្នាំ ២០០៦) ទំព័រ ៧ដល់១១។*

[33] *វ៉ាឡេតី ម៉ាស៊ីន (២០០៤)៖ "អ៊ុយក្រែន៖ ការរំលោភបំពានបញ្ញត្តិបើកចំហរព័ត៌មានដោយអំណាចផ្តាច់ការ" របាយការណ៍ស្តីពីអំពើពុករលួយសាកល បោះពុម្ពឆ្នាំ ២០០៤ ដោយអង្គការតម្លាភាពអន្តរជាតិ ទំព័រ ៤១ (២)។*

ដែលជាទូទៅភាពតានតឹង និង ការគម្រាមកំហែងប្រើអំពើហិង្សា គឺជាកត្តាមួយដែលធ្វើឲ្យពិបាកក្នុងការទទួលបានតម្លាភាពស្របតាមបទដ្ឋានអន្តរជាតិ"[34] ។

យើងអាចរំពឹងទុកថា ការបើកចំហរព័ត៌មានអាចជាឧបករណ៍មួយសម្រាប់ការធ្វើទុកបុកម្នេញនៅក្នុងបណ្តាប្រទេសដែលមិនសូវមានលក្ខណៈសេរី ដែលទោះជាយ៉ាងណាក៏ដោយ ការបោះឆ្នោតជាបញ្ហាចោទ។ បញ្ហានោះគឺថា គណបក្សកាន់អំណាចនៅក្នុងប្រទេសដែលលទ្ធិប្រជាធិបតេយ្យមានភាពទន់ខ្សោយទទួលមានការជំរុញឲ្យរំលោភបំពានការបើកចំហរព័ត៌មាន នៅពេលណាដែលគណបក្សកាន់អំណាចត្រូវប្រឈមមុខនឹងការប្រកួតប្រជែងយ៉ាងស្វិតស្វាញដើម្បីដណ្តើមយកតំណែងដឹកនាំរដ្ឋ។ ក្នុងបរិបទទាំងនេះ គេគួរធ្វើការថ្លឹងថ្លែងរវាងកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ចុះបញ្ចូលឲ្យមានការកែទម្រង់លើតម្លាភាពហិរញ្ញវត្ថុនយោបាយ និង លទ្ធភាពដែលគ្រោះថ្នាក់អាចនឹងកើតមានសម្រាប់គណបក្សប្រឆាំង ។ ផ្ទុយទៅវិញ ភាពចាំបាច់ក្នុងការការពារអ្នកផ្តល់ជំនួយដល់គណបក្សនយោបាយ ឬ បេក្ខជន ពីការធ្វើទុកបុកម្នេញ គឺជាហេតុផលមួយ ដែលអ្នកនយោបាយតែងតែប្រើប្រាស់ក្នុងការទាញយកប្រយោជន៍ដើម្បីកុំឲ្យបាត់បង់ជំនួយពីអ្នកផ្តល់ជំនួយដែលចង់លាក់កំបាំងពីសាធារណជន ជាជាងសុវត្ថិភាពរបស់ក្រុមអ្នកធ្វើជំនួយទាំងនោះ។

លទ្ធភាពដែលការធ្វើទុកបុកម្នេញអាចនឹងកើតមានឡើង អាចជម្រុញឲ្យមានការដោះដូរគ្នារវាងតម្លាភាព និង សន្តិសុខផ្ទាល់ខ្លួន ។ ជាមូលដ្ឋាន គេអាចសម្រួលចំនួនអប្បបរមាដែលតម្រូវឲ្យបង្ហាញឲ្យដឹង និងព័ត៌មានដែលនឹងបង្ហាញដោយយោងទៅតាមនោះ។ តាមរយៈការកំណត់ចំនួនអប្បបរមាលើវិភាគទាន និងចំណាយឲ្យបានខ្ពស់ដែលត្រូវបង្ហាញព័ត៌មាន នោះការធ្វើវិភាគទានដោយ "បុគ្គលទូទៅ" នឹងទទួលបានការការពារ។ យ៉ាងណាក្តី ការកំណត់កម្រិតអប្បបរមាឲ្យកាន់តែខ្ពស់ដែលត្រូវបង្ហាញព័ត៌មាននឹងមិនអាចការពារអ្នកផ្តល់ជំនួយសំខាន់ៗសម្រាប់យុទ្ធនាការរបស់គណបក្សប្រឆាំងបានឡើយ។

ជម្រើសមួយទៀត គឺការលុបចេញនូវព័ត៌មានអំពីអត្តសញ្ញាណជាក់លាក់មួយចំនួននៅពេលបង្ហាញព័ត៌មាន ឧទាហរណ៍ដូចជា៖ ឈ្មោះអ្នកផ្តល់ជំនួយ បុគ្គលអ្នកទទួលជំនួយ និងនិយោជករបស់ពួកគេជាដើម។ អាស្រ័យទៅលើកម្រិតដែលការបៀតបៀននយោបាយអាចកើតមានឡើង គេអាចនឹងណែនាំឲ្យលុបចោល ឬ រក្សាទុកការបង្ហាញព័ត៌មានអំពីសកម្មភាពឧស្សាហកម្មរបស់អ្នកផ្តល់ជំនួយផងដែរ ។ ប្រសិនបើចំនួនអ្នកពាក់ព័ន្ធនៅក្នុងឧស្សាហកម្មជាក់លាក់ណាមួយមានតិចតួច នោះបុគ្គលម្នាក់ៗទំនងជាត្រូវលាតត្រដាងអត្តសញ្ញាណនៅពេលធ្វើរបាយការណ៍។ ជាធម្មតា មានចំណុចសំខាន់មួយប្រសិនបើគេដកចេញព័ត៌មានមួយចំនួនធំអំពីចំណូលដែលគណបក្សនយោបាយ និង បេក្ខជនបានទទួល របាយការណ៍នោះនឹងពុំមានខ្លឹមសារនោះទេ។

គេអាចលើកហេតុផលថា តម្លាភាពអាចនឹងមិនមែនជាចំនុចអាទិភាពបំផុតឡើយនៅក្នុងបណ្តាប្រទេសដែលមានការរិតត្បិតសេរីភាព។ ប្រសិនបើការបៀតបៀនផ្នែកនយោបាយទៅលើគណបក្សប្រឆាំងទំនងជាកើតមានឡើង វាជាការចាំបាច់ជាងដែលគេត្រូវផ្តល់អាទិភាពទៅលើការប្រកួតប្រជែងច្រើនជាងតម្លាភាព និងយុត្តិធម៌ ព្រោះឧបករណ៍គោលនយោបាយដែលពាក់ព័ន្ធពុំតម្រូវជាចាំបាច់ឲ្យមានការបង្ហាញអត្តសញ្ញាណរបស់

[34] បូណោអូ ហូរ៉ាស្យូ និង ដាល បប (២០០៦) "បទពិសោធន៍ស្តីអំពីហិរញ្ញវត្ថុនយោបាយនៅក្នុងប្រទេសដែលទើបចប់ពីសង្គ្រាម" (វ៉ាស៊ីនតោនៈ អាយហ្វេស យូអេសអេអាយឌី) ទំព័រ ១៣

បុគ្គលណាម្នាក់ឡើយ។ សារៈសំខាន់របស់ក្រុមអង្គការសង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយ (ថែមទាំងសហគមន៍អន្តរជាតិផងដែរ) ដែលប្រឈមខ្លួននឹងការគម្រាមកំហែងធ្ងន់ធ្ងរពាក់ព័ន្ធនឹងសុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកផ្ដល់វិភាគទាននយោបាយមិនគួរត្រូវបានគេបំភ្លេចឡើយ។ អន្តរាគមន៍ទាំងនេះអាចជាអន្តរាគមន៍មើលដ៏មានប្រសិទ្ធភាពបំផុតទៅលើប្រតិបត្តិការហិរញ្ញវត្ថុនយោបាយ ដោយហេតុថា នៅក្នុងបណ្ដាប្រទេសមួយចំនួនស្ថាប័នទទួលបន្ទុកត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយឯករាជ្យ និង ការមានធនធានគ្រប់គ្រាន់មិនទំនងជាមានដំណើរការនោះទេ។

## អនុសាសន៍

ខណៈដែលប្រទេសនីមួយៗត្រូវតែបង្កើតប្រព័ន្ធបើកចំហរព័ត៌មានដោយផ្ទាល់របស់ខ្លួន គេគួរសិក្សាបទពិសោធន៍មួយចំនួនក្នុងរយៈកាលប្រមាណពីរឬបីទសវត្សចុងក្រោយនេះទាក់ទងទៅនឹងបទប្បញ្ញត្តិអំពីការធ្វើរបាយការណ៍ហិរញ្ញវត្ថុនយោបាយនៅជុំវិញពិភពលោក។

១. ការបង្ហាញព័ត៌មានគឺជាសសរទ្រូងនៃការត្រួតពិនិត្យលើមូលនិធិហិរញ្ញវត្ថុនយោបាយ។ ប្រសិនបើគ្មានការបង្ហាញព័ត៌មានប្រកបដោយប្រសិទ្ធភាពនោះទេ បទបញ្ញត្តិដទៃទៀតដូចជា ការដាក់ដែនកំណត់លើចំណាយ ឬការហាមឃាត់ប្រភេទនៃការធ្វើវិភាគទានជាក់លាក់មួយចំនួនអាចនឹងមិនអាចអនុវត្តបាននោះទេ។ ដូច្នេះ ការបង្កើតប្រព័ន្ធបើកចំហរព័ត៌មានបានត្រឹមត្រូវមានសារសំខាន់យ៉ាងខ្លាំងក្នុងការដោះស្រាយបញ្ហាផ្សេងៗដែលជាគោលដៅនៃបទបញ្ញត្តិហិរញ្ញវត្ថុនយោបាយ។

២. ការត្រួតពិនិត្យលើមូលនិធិហិរញ្ញវត្ថុគណបក្សនយោបាយប្រកបដោយប្រសិទ្ធិភាព ជាធម្មតាវាស្ថិតនៅហួសពីសមត្ថភាពរបស់តួអង្គតែមួយឯកឯង។ តាមរយៈការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ បញ្ញត្តិករហិរញ្ញវត្ថុនយោបាយអាចទទួលបានការជួយជ្រោមជ្រែងពីប្រព័ន្ធផ្សព្វផ្សាយ និង ក្រុមសង្គមស៊ីវិលនានា (ថែមទាំងពីសំណាក់គណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត) នៅក្នុងត្រួតពិនិត្យហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និង បេក្ខជន។

៣. ការបង្កើតប្រព័ន្ធបង្ហាញព័ត៌មានមួយដែលល្អឥតខ្ចោះទំនងជាមិនអាចទៅរួចឡើយ។ ការយកចិត្តទុកដាក់ដែលត្រូវផ្ដោតទៅលើនោះគឺការធានាឲ្យបានថាគ្មានការខ្វះចន្លោះដែលគេងាយនឹងមើលឃើញណាមួយមាននៅក្នុងការតម្រូវឲ្យធ្វើរបាយការណ៍ (ដូចជា ការគ្រាន់តែទាមទាររបាយការណ៍ក្នុងអំឡុងពេលធ្វើយុទ្ធនាការឃោសនាក្នុងពេលមួយយ៉ាងខ្លី ឬ ការផាត់គណបក្សនយោបាយ និង បេក្ខជនចេញពីកាតព្វកិច្ចដែលពួកគេត្រូវរាយការណ៍)។

៤. ក្នុងពេលជាមួយគ្នានេះ គេចាំបាច់ត្រូវធានាឲ្យបានថា តម្រូវការក្នុងការបង្ហាញព័ត៌មានមិនត្រូវដាក់បន្ទុកច្រើនពេកដល់អ្នកចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឡើយ។ តម្រូវការធ្វើរបាយការណ៍ដែលមានភាពស្មុគស្មាញពេកនឹងបង្អាក់ការអនុវត្តបទប្បញ្ញត្តិ ហើយជារឿយៗមានព័ត៌មានដែលមានតម្លៃតិចតួចបណ្ដោះត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍។ ជាការពិតដែលបរិមាណព័ត៌មានច្រើនលើសលប់ហួសហេតុ សន្ធាប់ពេកទំនងជាធ្វើឲ្យមានការលំបាកសម្រាប់ស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយ ប្រព័ន្ធផ្សព្វផ្សាយ និង អង្គការសង្គមស៊ីវិលនៅក្នុងការស្វែងរកទិន្នន័យណាដែលមានប្រយោជន៍។

៥. ស្របទៅនឹងចំនុចខាងលើដែរ គេត្រូវធានាថាប្រព័ន្ធបង្ហាញព័ត៌មានគួរមានការពិចារណា ផងដែរលើកត្តាក្នុងស្រុកមួយចំនួន ដូចជា បន្ទុកទៅលើបញ្ញត្តិករហិរញ្ញវត្ថុនយោបាយនិងអង្គភាពដែលត្រូវធ្វើរបាយ-

ការណ៍ កម្រិតជំនាញបច្ចេកទេស និង ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់បក្ខជន បច្ចេកវិទ្យាដែលគេអាចប្រើប្រាស់បានសម្រាប់ធ្វើរបាយការណ៍និងការផ្សព្វផ្សាយព័ត៌មាន និង ក្របខ័ណ្ឌពេលវេលា សម្រាប់ការធ្វើរបាយការណ៍ ការផ្ទៀងផ្ទាត់និង ការបោះពុម្ពផ្សាយរបាយការណ៍ហិរញ្ញវត្ថុជាដើម។

៦. ការដាក់ចេញនូវតម្រូវការនៃការបង្ហាញព័ត៌មានមានសារសំខាន់សម្រាប់ការពិភាក្សាដោយចំហរួមជាមួយអ្នកដែលមានកាតព្វកិច្ចត្រូវធ្វើរបាយការណ៍ រួមមានកិច្ចពិភាក្សាស្ដីអំពីប្រព័ន្ធរបាយការណ៍ដោយលំអិត និង ក្រុមស្នូលដែលត្រូវធ្វើជាមួយតំណាងគណបក្សនយោបាយ និងបេក្ខជន។

៧. ត្រូវមានការត្រៀមរៀបចំក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធបង្ហាញព័ត៌មានណាមួយក្នុងរយៈពេលណាមួយ។ ប្រព័ន្ធថ្មីតែងតែត្រូវការការកែសម្រួល ដែលសូម្បីតែប្រព័ន្ធដែលមានស្រាប់ហើយនៅតែទាមទារឲ្យធ្វើការពិនិត្យមើលឡើងវិញឲ្យបានទៀងទាត់ ដើម្បីសម្របទៅតាមការផ្លាស់ប្ដូរនៅក្នុងដំណើរការរបស់ហិរញ្ញវត្ថុនយោបាយទាំងមូលនៅក្នុងប្រទេស។

## ៥ សេចក្ដីសន្និដ្ឋាន

ជំពូកនេះបានផ្ដល់ការយកចិត្តទុកដាក់ទៅលើបញ្ហាជាមូលដ្ឋានមួយចំនួន នៅក្នុងប្រព័ន្ធបង្ហាញព័ត៌មានហិរញ្ញវត្ថុនយោបាយ។ ខណៈដែលប្រធានបទនេះអាចមានលក្ខណៈស្មុគស្មាញពិបាកនឹងយល់ ការបង្កើតប្រព័ន្ធណាមួយគួរមានលក្ខណៈងាយៗបន្តិច។ ជាបឋម អ្នកធ្វើកំណែទម្រង់គួរកំណត់ថាអ្វីជាគោលដៅជាបទដ្ឋានដែលគេចង់បាន ដូចជា៖ ធ្វើឲ្យអ្នកបោះឆ្នោតមានព័ត៌មានកាន់តែច្រើន ការប្រកួតប្រជែងដោយស្មើភាពគ្នារបស់គណបក្សនយោបាយនិងបេក្ខជន ឬលទ្ធភាពស្មើៗគ្នាក្នុងការចូលរួមកិច្ចការនយោបាយក្នុងចំណោមក្រុមសង្គមសេដ្ឋកិច្ច។ តាមរយៈការសម្រេចចិត្តនេះ អ្នកធ្វើកំណែទម្រង់អាចប្រមើលមើលឃើញប្រព័ន្ធបង្ហាញព័ត៌មានដ៏ប្រសើរមួយក្នុងបរិបទនៃសមាសធាតុបទបញ្ញត្តិចំនួនបី ដូចជា៖ ព័ត៌មានអ្វីខ្លះដែលត្រូវដាក់បង្ហាញ នរណាជាអ្នកបង្ហាញព័ត៌មានទាំងនោះ រយៈពេលប៉ុន្មានត្រូវបង្ហាញម្ដង និង បង្ហាញទៅកាន់ស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយប្រភេទណាជាដើម។ ចុងក្រោយ គេត្រូវតែពិចារណាថាតើលក្ខខណ្ឌតម្រូវការអ្វីខ្លះដែលសមស្របទៅនឹងបរិបទរបស់ប្រទេស និងអ្វីខ្លះដែលគេអាចសម្រេចបានសម្រាប់បញ្ញត្តិករហិរញ្ញវត្ថុនយោបាយ គណបក្សនយោបាយ និងតួអង្គនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតក្នុងការគៀងគរធនធានដែលពួកគេអាចរកបាន។ ដំណើរការនៃការបង្កើតនីតិវិធីទាំងនេះ គួរធ្វើឲ្យបានច្រើនតាមដែលអាចធ្វើទៅបានតាមរយៈការពិភាក្សាជាមួយអ្នកដែលត្រូវធ្វើរបាយការណ៍ និង អ្នកដែលត្រូវប្រើប្រាស់របាយការណ៍ទាំងនោះ (ដូចជា ស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយ ប្រព័ន្ធផ្សព្វផ្សាយ ក្រុមសង្គមស៊ីវិល ហើយចុងក្រោយគេបំផុតគឺអ្នកបោះឆ្នោត)។

ដោយហេតុថាក្របខ័ណ្ឌបទបញ្ញត្តិខុសៗគ្នាអាចផ្ដល់លទ្ធផលជាបទដ្ឋានផ្សេងៗគ្នា គេពុំមានគម្រូប្រព័ន្ធបើកចំហរព័ត៌មានហិរញ្ញវត្ថុនយោបាយរួមគ្នាមួយនោះទេ។ ស្ថាប័ននយោបាយផ្លូវការនានាមានការសន្និដ្ឋានបន្ថែមទៀតសម្រាប់ភាពខុសប្លែកគ្នាចម្បងៗនៃប្រព័ន្ធនីមួយៗ ដូចជាភាពខុសគ្នានៅក្នុងការតាក់តែងរដ្ឋធម្មនុញ្ញ និង ចរិតលក្ខណៈនៃប្រព័ន្ធបោះឆ្នោត ។ លើសពីនោះទៅទៀត កម្រិតនៃបច្ចេកវិទ្យា ចំណេះដឹង ស្ថេរភាពសង្គម និង ការអភិវឌ្ឍផ្នែកសង្គមស៊ីវិលនឹងមានលក្ខណៈខុសគ្នា។ បរិបទនីមួយៗមានការអនុវត្តល្អៗរបស់វាផ្ទាល់។

វត្ថុបំណងក្នុងជំពូកនេះបានចាប់ផ្តើមដោយការពិចារណាអំពីដំណើរការស្រាយជាក់ស្តែងមួយចំនួន ចំនុចដែលត្រូវធ្វើកំណែទម្រង់ហិរញ្ញវត្ថុនយោបាយ ដោយផ្អែកលើភាពចាំបាច់ ហើយនិងកត្តាពាក់ព័ន្ធនានាសម្រាប់អាទិភាពនៃការធ្វើកំណែទម្រង់។ ប្រទេសមួយចំនួនអាចត្រូវការប្រព័ន្ធបង្ហាញព័ត៌មានតាមប្រព័ន្ធអេឡិចត្រូនិច រីឯប្រទេសខ្លះទៀតត្រូវការធ្វើកំណែទម្រង់ឲ្យបានកាន់តែទូលំទូលាយថែមទៀតសម្រាប់ប្រព័ន្ធគណនេយ្យរបស់ពួកគេ។ តាមរយៈការពិនិត្យទៅលើភាពខុសគ្នានៅក្នុងប្រព័ន្ធបង្ហាញព័ត៌មាន និង តើគេអនុវត្តយ៉ាងដូចម្តេចនៅក្នុងប្រទេសនីមួយៗ យើងឃើញថាបញ្ជីដែលបង្ហាញអំពីការអនុវត្តល្អៗដែលត្រូវរៀនសូត្រតាមដូចជានៅខ្វះខាតនៅឡើយ។ ការអនុម័តច្បាប់ទូទៅមួយសម្រាប់កំនត់អំពីការបើកចំហរព័ត៌មានគឺជារឿងមួយយ៉ាងសាមញ្ញ។ ទោះជាយ៉ាងណាក្តី ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយប្រកបដោយខ្លឹមសារ ត្រូវឲ្យមានការកំណត់គោលបំណង និង បញ្ហាឲ្យបានជាក់លាក់។ នៅពេលដែលគេយល់ស្របជាមួយគោលបំណង និង បញ្ហាទាំងនោះហើយ អ្នកធ្វើកំណែទម្រង់អាចតាក់តែងប្រព័ន្ធបង្ហាញព័ត៌មានដែលនឹងសម្រេចគោលបំណងរបស់គេបានជាអតិបរមា និង កាត់បន្ថយឧបសគ្គឲ្យនៅតិចតួចបំផុត។

# ជំពូក ២៖

# ដំណោះស្រាយជាក់ស្តែងសម្រាប់ការកំណត់នៅលើចំណាយ

ដោយ៖ បណ្ឌិត ម៉ាកស៊ីន វ៉ាឡេគី (Marcin Walecki)

## សេចក្តីផ្តើម

“ប្រសិនបើគ្មានដែនកំណត់លើចំណាយសរុបនោះទេ ចំណាយនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតនឹងកើនឡើងឥតឈប់ឈរ និង ពុំអាចជៀសរួចឡើយ ...។ ក្រៅពីការផ្តល់ប្រយោជន៍សម្រាប់ការផ្តល់វិភាគទាន ដែនកំណត់លើការចំណាយក៏មានសក្តានុពលផ្ទាល់របស់ខ្លួនដែរ ក្នុងការទប់ស្កាត់អំពើពុករលួយដែលកើតមាននៅពេលបោះឆ្នោតសហព័ន្ធ”។ *(ចៅក្រមតុលាការកំពូល លោកវ៉ាយថ៍ (White) ដែលបានថ្លែងនៅក្នុងរឿងក្តីប័កគ្លី និង វ៉ាលេអូ (Buckley v. Valeo court case)* ។

ដើម្បីសម្រេចបានប្រព័ន្ធមួយមានភាពយុត្តិធម៌និងធានាបាននូវការប្រកួតប្រជែង ប្រទេសមួយគួរផ្តល់ឲ្យមានទីលានប្រកួតប្រជែងដោយស្មើភាពមួយដែលគ្រប់តួអង្គនយោបាយអាចចូលរួមបាន។ ក្នុងចំណោមបញ្ញត្តិចំបងៗនៅក្នុងច្បាប់ហិរញ្ញវត្ថុនយោបាយដែលបម្រើឲ្យគោលបំណងខាងលើនេះ នោះគឺការដាក់ដែនកំណត់លើចំណាយ ។ ដែនកំណត់លើចំណាយជួយធានាឲ្យមានសមភាពផ្នែកមធ្យោបាយក្នុងចំណោមបេក្ខជនទាំងអស់ ដែលជាគោលការណ៍មួយយ៉ាងសំខាន់នៅក្នុងសង្គមប្រកាន់លទ្ធិប្រជាធិបតេយ្យ និង នៅក្នុងដំណើរការបោះឆ្នោត។

ក្នុងរយៈពេលពីរឬបីទសវត្សចុងក្រោយនេះ ការយកចិត្តទុកដាក់កាន់តែខ្លាំងចំពោះចំណាយដែលចេះតែមានការកើនឡើងនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតបានជំរុញឲ្យមានការលើកសំណើនានា ក្នុងគោលដៅដាក់ដែនកំណត់លើចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។ ក្នុងបណ្តាប្រទេសជាច្រើន អ្នកនយោបាយដែលមាននិន្នាការទៅរកការកែទម្រង់បានលើកហេតុផលថា ជនណាដែលមានលទ្ធភាពធ្វើការចំណាយក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់អាចប្រជែងក្នុងយុទ្ធនាការឃោសនាបោះឆ្នោតបានយ៉ាងស្រួល ដោយហេតុថាគេមានថវិកាគ្រប់គ្រាន់ដើម្បីក្តោបក្តាប់មធ្យោបាយដែលប្រើប្រាស់សម្រាប់ផ្សព្វផ្សាយសារនយោបាយ (ឧទាហរណ៍៖ ប្រព័ន្ធផ្សព្វផ្សាយផ្ទាំងប៉ាណូធំៗ និង ការរៀបចំព្រឹត្តិការណ៍នៅតាមទីសាធារណៈជាដើម ) ការធ្វើបែបនេះបានធ្វើឲ្យប៉ះពាល់ដល់ភាពយុត្តិធម៌នៃដំណើរការបោះឆ្នោត។ ភាពសមហេតុសមផលនៃទស្សនៈនេះគឺផ្អែកទៅលើការសន្មត់មួយដែលថាហិរញ្ញវត្ថុនយោបាយដែលគ្មានច្បាប់គ្រប់គ្រង មានភាពបរាជ័យក្នុងការធានាឲ្យមានទីលានប្រកួតប្រជែងស្មើភាពគ្នាមួយក្នុងការឈោងចាប់យកអំណាចដឹកនាំរដ្ឋ។

ជាការពិតណាស់ ទំនាក់ទំនងនយោបាយដែលមានប្រសិទ្ធិភាពគឺជាកត្តាចម្បងមួយ នៅពេលដែលការប្រកួតប្រជែងដើម្បីទាញការគាំទ្រពីអ្នកបោះឆ្នោត ហើយដែលការចំណាយពុំមានការរិតត្បិតអាចនាំឲ្យការប្រាស្រ័យទាក់ទងនយោបាយទៅកាន់អ្នកបោះឆ្នោតរបស់អ្នកនយោបាយមួយចំនួនមានសភាពខ្លាំងក្លាលើសលុបច្រើនជាងអ្នកនយោបាយមួយចំនួនទៀត ដែលជាហេតុបង្កឲ្យមានការទាញយកប្រយោជន៍មិនស្មើគ្នានៅក្នុងប្រព័ន្ធបោះឆ្នោត ។ នៅក្នុងបរិបទនៃការបោះឆ្នោត *ការទទួលបានលទ្ធភាពនៃការចូលរួមប្រកួតប្រជែង*ត្រូវបានគេយល់ថា ជាការដកចេញនូវរបាំងនានាក្នុងការចូលរួមប្រកួតប្រជែងការបោះឆ្នោត រីឯ *យុត្តិធម៌*វិញត្រូវបានគេយល់ថាជាការសម្រេចបាននូវទីលានប្រកួតប្រជែងដោយស្មើភាពគ្នាមួយសម្រាប់តួអង្គនយោបាយទាំងអស់ និង ការបន្ថយលទ្ធភាពដែលនាំឲ្យ

មានការទាញយកប្រយោជន៍មិនស្មើគ្នាសម្រាប់អ្នកនយោបាយមួយលើអ្នកនយោបាយមួយទៀត ដោយសារតែហេតុផលធនធាន[35]។

តាមប្រវត្តិសាស្ត្រ បទបញ្ញាដែលបញ្ញត្តិអំពីចំណាយក្នុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោតគឺជាការឆ្លើយតបទៅនឹងការរំលោភបំពាននានានៅក្នុងការបោះឆ្នោត។ ការដាក់ចេញនូវច្បាប់ស្តីពីអំពើពុករលួយនិងអនីត្យានុកូលនៅឆ្នាំ១៨៨៣ (Corrupt and Illegal Practices Act of 1883) នៅចក្រភពអង់គ្លេសត្រូវបាន *ឆាល សាយម័រ* (Charles Seymour) ពិពណ៌នា ថា "ជាចំណុចដ៏សំខាន់មួយនៅក្នុងការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៃប្រទេសអង់គ្លេស"[36]។ លក្ខណៈពិសេសរបស់ច្បាប់ខាងលើនេះ គឺជាការបញ្ញត្តិអំពីដែនកំណត់លើចំណាយដែលច្បាប់អនុញ្ញាតពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោតនៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ដោយមានការគាំទ្រដោយបទបញ្ញត្តិរឹងមាំមួយចំនួនដើម្បីធានាការអនុវត្តច្បាប់នោះ។ ដែនកំណត់នៃចំណាយត្រូវបានគេកម្រិតត្រឹម៧១០ផោនសម្រាប់អ្នកបោះឆ្នោត២០០០នាក់ដំបូងក្នុងមណ្ឌលនីមួយៗ និងបន្ទាប់មកទៀតគឺ៤០ផោនៗ សម្រាប់អ្នកបោះឆ្នោត១០០០នាក់បន្ថែមលើចំនួនអ្នកបោះឆ្នោតខាងលើនេះ។ ការរក្សាទុករបាយការណ៍ចំណាយឲ្យបានហ្មត់ចត់ត្រូវបានតម្រូវឲ្យធ្វើដើម្បីបញ្ជាក់អះអាងថាមិនមានការចំណាយណាលើសពីចំនួនដែលបានកំនត់ខាងលើនេះទេ។

នៅសហរដ្ឋអាមេរិក ច្បាប់សហព័ន្ធស្តីពីអំពើពុករលួយឆ្នាំ១៩១០ (The 1910 Federal Corrupt Practices Act) បានចែងអំពីដែនកំណត់លើចំណាយក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ទោះជាយ៉ាងនេះក្តី ច្បាប់នេះគ្របដណ្តប់ត្រឹមតែគណបក្សនយោបាយ និង គណៈកម្មការយុទ្ធនាការបោះឆ្នោតរបស់ពួកគេតែប៉ុណ្ណោះ មានការដាក់ពិន័យតិចតួច ហើយមិនសូវបានយកទៅអនុវត្តនោះទេ។ មកដល់ឆ្នាំ១៩១១ ច្បាប់ខាងលើនេះត្រូវបានធ្វើវិសោធនកម្មដើម្បីពង្រីកលក្ខខណ្ឌតម្រូវរបស់ច្បាប់នេះដល់បេក្ខជនសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតសំខាន់ៗខ្លះទៀតរបស់សហរដ្ឋអាមេរិក។ វិសោធនកម្មឆ្នាំ១៩១១ក៏បានតម្រូវជាលើកទី១ឲ្យបេក្ខជនបង្ហាញព័ត៌មានពីហិរញ្ញវត្ថុរបស់ខ្លួនផងដែរ ហើយ ថែមទាំងបានបញ្ញត្តិដែនកំនត់លើចំនួនទឹកប្រាក់ដែលអនុញ្ញាតឲ្យបេក្ខជនអាចធ្វើការចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនីមួយៗ។ ការចំណាយលើយុទ្ធនាការឃោសនាបោះឆ្នោតអ្នកតំណាងរាស្ត្រត្រូវបានកំនត់ត្រឹម៥០០០ដុល្លារ រីឯសម្រាប់ការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភាវិញត្រូវបានកំនត់ត្រឹម១០០០០ដុល្លារ ឬត្រឹមចំនួនដែលកំណត់ដោយច្បាប់របស់រដ្ឋនីមួយៗ (ដែលជាទូទៅមានចំនួនតិចជាង)។

នៅក្នុងប្រទេសប្រជាធិបតេយ្យបែបទំនើបជាច្រើន ដែនកំនត់លើចំណាយរបស់គណបក្សនយោបាយ និងយុទ្ធនាការឃោសនាត្រូវបានគេប្រើប្រាស់ ដើម្បីបញ្ចៀសកុំឲ្យមានការកើនឡើងចំនួនដ៏លើសលុបក្នុងការចំណាយ

---

[35] *ដាយអានេ ដាវីដសុន (Diane R. Davidson) ហិរញ្ញវត្ថុនយោបាយនៅប្រទេសកាណាដា៖ ការធ្វើឲ្យមានតុល្យភាព ឯកសារផ្អែកច្បាប់ដែលបានធ្វើការបង្ហាញនៅឯកិច្ចប្រជុំប្រចាំឆ្នាំរបស់សមាគមច្បាប់និងសង្គម(Law and Society Association) ស្តីអំពី "ច្បាប់ និង សង្គម នៅសតវត្សទី២១៖ ការផ្លាស់ប្តូរ ការតស៊ូ និង អនាគត" សាកលវិទ្យាល័យហាំបល(Humbolt Univerity) ទីក្រុងប៊ែឡាំង ប្រទេសអាល្លឺម៉ង់ ចាប់ពីថ្ងៃទី២៥-២៨ កក្កដា ឆ្នាំ ២០០៧។*

[36] *គាត់ក៏បានអះអាងដែរថា ច្បាប់ស្តីពីអំពើពុករលួយស្វះស្វែងដើម្បីទប់ស្កាត់ការចំណាយមិនប្រក្រតី និង ការចំណាយមិនស្របច្បាប់ដែលបានរីកដុះដាលនៅក្នុងទម្រង់ជាការសូកប៉ាន់តាមរបៀបដែលមានជាយូរមកហើយ។ សូមមើលបន្ថែមនៅក្នុង "ការកែទម្រង់ការបោះឆ្នោតនៅក្នុងប្រទេសអង់គ្លេសនិងវេលស៍" របស់ឆាល សៃម័រ (បោះពុម្ពឡើងវិញដោយដាវីដ និង ឆាល ឆ្នាំ១៩៧០) ទំព័រ ៤៥៤ដល់៤៥៥។*

ផ្នែកនយោបាយរបស់គណបក្ស ដើម្បីគ្រប់គ្រងវិសមភាពរវាងគណបក្សនីមួយៗ និង ដើម្បីទប់ស្កាត់អំពើពុករលួយ និង ឥទ្ធិពលមិនសមស្របនានា។ *អាឡែន វែរ* (Allan Ware) សាស្ត្រាចារ្យផ្នែកនយោបាយនៅសាកលវិទ្យាល័យ អុកហ្វដ (Oxford University) បានស្នើយោបល់ថា "មធ្យោបាយមួយក្នុងការប៉ុនប៉ងបញ្ឈប់*ការប្រជែងគ្នាដោយបំពាន* ក្នុងចំណោមគណបក្សក្នុងការស្វែងរកមូលនិធិ គឺត្រូវរិតត្បិតលើចំនួនដែលបក្សនីមួយធ្វើការចំណាយលើសកម្មភាព ដែលត្រូវប្រើថវិកាអស់ច្រើន ពោលគឺយុទ្ធនាការឃោសនាបោះឆ្នោតតែម្តង"[37]។ នៅមានការអះអាងមួយចំនួនទៀត ដែលគាំទ្រការដាក់ដែនកំណត់លើការចំណាយ។ ជាដំបូង ការចំណាយដែលគ្មានការរិតត្បិតអាចផ្តល់អត្ថប្រយោជន៍ ដោយមិនយុត្តិធម៌ចំពោះបេក្ខជន ឬ គណបក្សនយោបាយដែលមានលទ្ធភាពក្នុងការទទួលបានថវិកា ហើយថែមទាំង អាចធ្វើឲ្យអ្នកនយោបាយពឹងផ្អែកយ៉ាងខ្លាំងទៅលើម្ចាស់មូលនិធិធំៗទាំងនោះ។ ទី២ ដែនកំណត់លើចំណាយក៏ជា មធ្យោបាយមួយផងដែរក្នុងការបង្កាបេក្ខជន និង គណបក្សនយោបាយពីការទិញសន្លឹកឆ្នោតដោយផ្ទាល់(ឧទាហរណ៍ តាមរយៈការអញ្ជើញអ្នកបោះឆ្នោតដែលមានសក្តានុពលឲ្យចូលរួមក្នុងពិធីធំៗ ដោយមានការផ្តល់ជូននូវការប្រគុំ តន្ត្រី អំណោយ ការទទួលទានអាហារនិងភេសជ្ជៈដោយឥតគិតថ្លៃជាដើម)។ ទី៣ ដែនកំណត់លើចំណាយអាចបង្កាការ ពិភាក្សាដេញដោលផ្នែកនយោបាយក្នុងពេលបោះឆ្នោតពីការកេងយកចំណេញតាមរយៈការបង្វៀងការជជែកដេញ ដោលអំពីបញ្ហាទូទៅទៅផ្តោតលើបញ្ហាមួយចំនួនដែលនឹងទទួលបានការគាំទ្រហិរញ្ញវត្ថុយ៉ាងច្រើនសន្ធឹកសន្ធាប់។

ជាទូទៅ បញ្ញត្តិស្តីអំពីដែនកំណត់លើចំណាយជាធម្មតាតែងត្រូវបានចែងនៅក្នុងច្បាប់បោះឆ្នោត ឬ ច្បាប់ ដទៃទៀតដែលពាក់ព័ន្ធយ៉ាងជាក់លាក់ជាមួយនឹងហិរញ្ញវត្ថុរបស់គណបក្សនយោបាយ ឬ ហិរញ្ញវត្ថុសម្រាប់ការ បោះឆ្នោត។ ក្នុងចំណោមប្រទេសចំនួន១០៤ដែលបណ្ឌិត *ម៉ៃឃើល ពីនតូ ឌូសឈីនស្គី* (Michael Pinto- Duschinsky) បានធ្វើការសិក្សា ៤១%នៃប្រទេសទាំងនោះមានបទបញ្ញត្តិដែលចែងអំពីដែនកំណត់ចំណាយ[38]។ ការកំណត់ចំនួន អតិបរមាក្នុងការធ្វើការចំណាយសម្រាប់ការបោះឆ្នោតជារឿយៗត្រូវបានកំណត់ដោយច្បាប់ អង្គភាពគ្រប់គ្រងនិង ចាត់ចែងការបោះឆ្នោត ឬអជ្ញាធរដទៃទៀតដែលមានភារកិច្ចអនុវត្តបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយ។ ក្នុងករណីដែល កម្រិតអតិបរមានៃចំណាយត្រូវបានចែងនៅក្នុងច្បាប់ ដែនកំណត់នៃការចំណាយទាំងនេះត្រូវបានកំណត់ដោយការ ចង្អុលបង្ហាញពីកម្រិតអតិបរមា ឬ ដោយការយករូបមន្តមកអនុវត្ត (ឧទាហរណ៍៖ ផលគុណនៃប្រាក់ឈ្នួលប្រចាំខែ គិតជាមធ្យម)[39] ដោយមានបញ្ញត្តិអំពីការកែសម្រួលចំនួននោះដោយយោងទៅតាមអត្រាអតិផរណា។

ស្ថិតិមួយចំនួនបង្ហាញថាដែនកំណត់លើចំណាយក្នុងទ្វីបអឺរ៉ុប បានក្លាយជាកម្មវត្ថុនៃការធ្វើ បទប្បញ្ញត្តិឲ្យកាន់ តែទូលំទូលាយនៅក្នុងប្រទេសដែលមានប្រជាធិបតេយ្យក្មេងខ្ចី ជាជាងប្រទេសដែលលទ្ធិប្រជាធិបតេយ្យមានភាព ចាស់ទុំ។ លើសពីនេះទៅទៀត ការដាក់ដែនកំណត់យ៉ាងតឹងរ៉ឹងទៅលើចំណាយរបស់បេក្ខជនឈរឈ្មោះជាតំណាង រាស្ត្រគឺជាលក្ខណៈពិសេសមួយនៃគម្រូបទបញ្ញត្តិហិរញ្ញវត្ថុនយោបាយរបស់ពួកបស្ចឹមប្រទេស។ ដែនកំណត់ដែល ត្រឹមតែផ្តោតទៅលើបេក្ខជនតំណាងរាស្ត្រនៅតែធ្វើឡើងបានតិចតួចនៅឡើយនៅក្រោមលក្ខខណ្ឌទំនើបនានាដើម្បី

---

[37] *មូលនិធិប្រជាធិបតេយ្យភាវូបនីយកម្ម ដោយភីតធ័រ ប៉រណែល (Petter Burnell) និង អាឡែន វែរ (Allen Ware) (មែនឆេសស្ទ័រ៖ រោងពុម្ពសាកល វិទ្យាល័យមែនឆេសស្ទ័រ ឆ្នាំ១៩៩៨) ទំព័រ ២៥០។*

[38] *ម៉ៃឃើល ពីនតូ ឌូសឈីនស្គី៖ ព្រឹត្តិប័ត្រប្រជាធិបតេយ្យ ភាគ១៣ ថ្ងៃទី៤ តុលា ២០០២*

[39] *ក្នុងករណីនៃការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ប្រទេសប៊ុលហ្គារី ប៉ូឡូញ និង ស្លូវ៉ាក បានកំណត់យកដែនកំណត់បែបកូតាជាក់លាក់មួយ រីឯនៅប្រទេសរុស្ស៊ី និង អ៊ុយក្រែន គេប្រើប្រាស់រូបមន្តជាក់លាក់(ដោយយកប្រាក់ឈ្នួលអប្បបរមាគុណនឹង៣០០០០០ និង ១០០០០០ ទៅតាម លំដាប់លំដោយ)។*

គ្រប់គ្រងចំណាយផ្នែកនយោបាយទាំងមូល[40] ដោយហេតុថាការចំណាយទៅលើយុទ្ធនាការឃោសនាបោះឆ្នោតគឺស្ថិតនៅកម្រិតថ្នាក់ជាតិ[41]។ ដោយសារការរីកចម្រើននៃមធ្យោបាយផ្សព្វផ្សាយ ដូចជាលិខិត ប្រព័ន្ធទូរស័ព្ទ ផ្ទាំងរូបភាព និង ផ្ទាំងប៉ាណូធំៗដែលធ្វើចេញដោយផ្ទាល់ពីថ្នាក់ជាតិ នោះអវត្តមាននៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុនយោបាយដ៏ទូលំទូលាយមួយ រួមមានទាំងការកំណត់ដែនចំណាយនៅថ្នាក់ជាតិ ធ្វើឲ្យការកំណត់ដែនចំណាយនៅថ្នាក់មូលដ្ឋានមិនសូវមានសារសំខាន់ប៉ុន្មានទេ។ នៅប្រទេសកាណាដា ការកំណត់ដែនចំណាយសម្រាប់គណបក្សនយោបាយ និងបេក្ខជនត្រូវបានអនុវត្តជាលើកដំបូងក្នុងឆ្នាំ១៩៧៤ និងត្រូវបានពង្រីកបន្ថែមទៀតនៅឆ្នាំ២០០៣។ គេយល់ឃើញថាច្បាប់ទាំងនោះគឺជាមូលដ្ឋានប្រជាធិបតេយ្យដ៏សំខាន់របស់ប្រទេសកាណាដា។ នៅឆ្នាំ២០០៣ ដែនកំណត់ចំណាយត្រូវបានលើកយកមកពិភាក្សា ហើយការកំណត់អត្ថន័យដ៏ទូលំទូលាយមួយសម្រាប់ចំណាយក្នុងពេលបោះឆ្នោតត្រូវបានគេដាក់បញ្ចូលនៅក្នុងច្បាប់។ ចំណាយដែលជាកម្មវត្ថុនៅក្រោមការគ្រប់គ្រងរបស់ច្បាប់បច្ចុប្បន្ននេះ រួមបញ្ចូលទាំងការស្ទង់មតិជាសាធារណៈ ទស្សនកិច្ចរបស់ថ្នាក់ដឹកនាំគណបក្ស និងបៀវត្សបុគ្គលិកជាដើម។ ការកំណត់ដែនចំណាយក៏គ្របដណ្តប់ទាំងភាគីទី៣ផងដែរ។ យោងតាមច្បាប់កាណាដា "ភាគីទី៣" គឺជាបុគ្គល ឬក្រុមបុគ្គលដែលមិនមែនជាបេក្ខជន គណបក្សនយោបាយដែលបានចុះបញ្ជី ឬ មិនមែនជាសមាគមអ្នកបោះឆ្នោតនៅតាមមណ្ឌលរបស់គណបក្សនយោបាយដែលបានចុះបញ្ជី។

គួរបញ្ជាក់ផងដែរថា នៅពេលណាដែលប្រព័ន្ធហិរញ្ញវត្ថុនយោបាយបានកំណត់ដែនចំណាយរបស់បេក្ខជន និងគណបក្សនយោបាយដើម្បីបង្កាកុំឲ្យមានការកេងយកប្រយោជន៍ដោយមិនយុត្តិធម៌ គេក៏ត្រូវតែកំណត់ដែនចំណាយសម្រាប់ភាគីដទៃទៀតដែរ ដូចជា "ភាគីទី៣" ជាដើម ។ ប្រសិនបើគេមិនបានធ្វើដូច្នេះទេ ក្រុម អ្នកអ្នកមានធនធានដែលគាំទ្រអ្នកនយោបាយ ឬក្រុមសកម្មជននយោបាយ អាចធ្វើការចំណាយថវិការបស់ខ្លួនដោយផ្ទាល់ដើម្បីជាប្រយោជន៍របស់បេក្ខជនណាមួយ ឬដើម្បីរាំងការបោះឆ្នោតរបស់បេក្ខជនមួយផ្សេងទៀត។ ប្រសិនបើគេគ្រាន់តែអនុវត្តដែនចំណាយទៅលើតែបេក្ខជនឬគណបក្សនយោបាយ នោះវិធានការប្រឆាំងនឹងបេក្ខជនអាចនឹងមិនមានប្រយោជន៍ទេពាក់ព័ន្ធទៅនឹងការកំណត់ចំនួនទឹកប្រាក់ដែលច្បាប់អនុញ្ញាតឲ្យបេក្ខជនម្នាក់ៗធ្វើការចំណាយ ។ ដើម្បីអោយមានប្រសិទ្ធិភាព ការកំណត់ដែនចំណាយខាងលើនេះចាំបាច់ត្រូវយកមកអនុវត្តផងដែរចំពោះក្រុមផ្សេងទៀតដែលពាក់ព័ន្ធ។ ជាឧទាហរណ៍ នៅចក្រភពអង់គ្លេស ចំណាយរបស់គណៈកម្មការយុទ្ធនាការឃោសនារបស់គណ - បក្សនយោបាយសម្រាប់ការបោះឆ្នោតគឺកំណត់ត្រឹម៣០លានដុល្លារ (ឬ២០លានផោន) សម្រាប់គណបក្សនីមួយៗ រីឯការចំណាយរបស់ក្រុមដែលជួយឃោសនាឲ្យគណបក្សនយោបាយគឺកំណត់ត្រឹម១លានប្រាំសែនដុល្លារ (ស្មើនឹង១លានផោន)សម្រាប់ក្រុមនីមួយៗ។ ទោះជាបែបនេះក្តី កិច្ចខិតខំប្រឹងប្រែងនេះនៅមិនទាន់ដោះស្រាយបញ្ហានៃការគេចវេសបាននៅឡើយទេ។ ប្រសិនបើមានដែនកំណត់លើចំណាយរបស់សហជីពមួយ ចំនួន១លាន៥សែនដុល្លារ ដែលជាអ្វីដើម្បីបញ្ឈប់ក្រុមសហជីពពីការបំបែកជាក្រុមតូចៗ ដែលក្រុមនីមួយៗមិនចំណុះឲ្យគ្នា ហើយអាចធ្វើការចំណាយរហូតដល់១លាន៥សែនដុល្លារ។ លទ្ធភាពដែលអាចឲ្យគេពង្រីកគណៈកម្មការ"មិនចំណុះគ្នា"និងក្រុមអ្នកក្រុមផ្សេងៗជាច្រើនដែលជួយឃោសនាគាំទ្រគណបក្សនយោបាយធ្វើឲ្យមានការរំខានដល់ប្រសិទ្ធិភាពនៃការ

[40] *ពីនតូ ឌូសឈីនស្គី (១៩៨១) ទំព័រ ២៦៨។*

[41] *ការចំណាយសរុបរបស់គណបក្សពលករ និង គណបក្សអភិរក្ស នៅថ្នាក់មូលដ្ឋាន និង ថ្នាក់ជាតិក្នុងកំឡុងការបោះឆ្នោតសកលឆ្នាំ១៩៩៧គឺប្រហែលជា៦០លានផោន ដែលជិត៩០%នៃការចំណាយនោះធ្វើឡើងនៅថ្នាក់ជាតិ។ យ៉ាងណាក៏ដោយ កាលពីឆ្នាំ១៨៨០ ការចំណាយនៅថ្នាក់ជាតិដោយគណបក្សនយោបាយធំៗទាំងពីរនេះគឺប្រហែលជា២%នៃចំណាយសរុប។*

កំណត់ដែនចំណាយ។ អ្នកជំនាញខ្លះបានលើកហេតុផលថា ការរឹតបន្តឹងលទ្ធភាពចំណាយរបស់ភាគីទី៣ អាចជួយធានាថាបេក្ខជនឈរឈ្មោះទាំងអស់អាចស្ថិតនៅឯករាជ្យដាច់ចេញពីការទទួលរងសម្ពាធរបស់ក្រុមដែលមានផលប្រយោជន៍ពាក់ព័ន្ធដ៏មានឥទ្ធិពល។

## *បញ្ហានានាដែលកើតមានពេលដាក់ដែនកំណត់លើចំណាយ*

គេគួរយល់ថា ដែនកំណត់លើចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតមិនមែនជាយន្តការដ៏ល្អឥតខ្ចោះដែលគ្រប់រដ្ឋទាំងអស់គួរប្រើប្រាស់ដើម្បីកាត់បន្ថយការចំណាយសម្រាប់នយោបាយនោះទេ។ ដែនកំណត់លើចំណាយអាចរួមចំណែកធ្វើឲ្យមានវិវាទរវាងគោលការណ៍ជាមូលដ្ឋានគ្រឹះចំនួនពីរនៃរបបលទ្ធិប្រជាធិបតេយ្យសេរីបែបទំនើប ពោលគឺភាពចាំបាច់នៃការធានាសមភាពនយោបាយ និង ភាពចាំបាច់ក្នុងការធានាសេរីភាពផ្នែកនយោបាយ។ បញ្ហានេះបានកើតឡើងនៅក្នុងរឿងក្តីក្តាំដ៏គួរឲ្យចាប់អារម្មណ៍ចំនួន២។ រឿងទី១កើតមាននៅសហរដ្ឋអាមេរិចនៅក្នុងករណីវិវាទរវាង *បាក់គ្លេ* (Buckley) និង *វ៉ាលេអូ* (Valeo) នៅពេលដែលតុលាការកំពូលសម្រេចថាបញ្ញត្តិស្តីពីដែនកំណត់ចំណាយសំខាន់ៗចំនួន៣មិនស្របនឹងរដ្ឋធម្មនុញ្ញ។ បញ្ញត្តិទាំង នោះរួមមាន ការដាក់ដែនកំណត់លើការចំណាយឯករាជ្យ ការរិតត្បិតលើចំនួនធនធានឯកជនដែលបេក្ខជនឈរឈ្មោះអាចប្រើប្រាស់បាន និងដែនកំណត់ចំណាយសរុបទៅលើបេក្ខជនដែលប្រកួតប្រជែងសម្រាប់មុខតំណែងសហព័ន្ធ[42]។ នៅក្នុងសេចក្តីសម្រេចជាប្រវត្តិសាស្ត្រនៅក្នុងរឿងក្តី *បាក់គ្លេ និង វ៉ាលេអូ* តុលាការកំពូលសហរដ្ឋអាមេរិក ដែលបាន ទទួលឥទ្ធិពលពីការធ្វើវិសោធនកម្មលើកទី១និងការពិចារណាទៅលើសេរីភាពបញ្ចេញមតិ បានធ្វើមោឃភាពបទប្បញ្ញត្តិដ៏ទូលំទូលាយនោះដែលបានអនុម័តក្រោយពីមានរឿងអាស្រូវ *វ៉ាត់ធ័រហ្គេត* (Watergate)។ រឿងទី២កើតមាននៅចក្រភពអង់គ្លេសក្នុងករណីរឿងក្តីរបស់អ្នកស្រី *បូមែន* (Bowman) ដែលតុលាការរកឃើញថា ការរិតត្បិតយ៉ាងតឹងរ៉ឹងទៅលើការចំណាយដែលធ្វើឡើងដោយបុគ្គលឯកជនទាក់ទងទៅនឹងការបោះឆ្នោត គឺជាការរិតត្បិតដោយមិនសមហេតុផលទៅលើសេរីភាពនៃការបញ្ចេញមតិ។ តុលាការបានលើកឡើងថាជំពូក៧៥នៃច្បាប់ដែលបានអនុម័តនៅឆ្នាំ១៩៨៣ គឺជាការរារាំងបោះពុម្ពផ្សាយព័ត៌មានរបស់អ្នកស្រី *បូមែន*សម្រាប់រាល់គោលបំណងទាំងអស់។ តុលាការក៏បានចោទសួរផងដែរថា តើវាអាចចាំបាច់ឬទេក្នុងការដាក់ដែនកំណត់ចំណាយមកលើអ្នកស្រី *បូមែន*ចំនួន៥ផោនដើម្បីធ្វើឲ្យសម្រេចបានគោលបំណងនៃការធានាឲ្យមានសមភាពរវាងបេក្ខជន។ តុលាការទាញសេចក្តីសន្និដ្ឋានថាការរិតត្បិតដែលតុលាការបានចោទសួរនោះពុំសមស្របតាមគោលបំណងដែលគេចង់បាននោះទេ។ តុលាការរបស់សហភាពអឺរ៉ុបបានក្រើនរំលឹកថា ការបោះឆ្នោតដោយសេរី និងសេរីភាពក្នុងការបញ្ចេញមតិ ជាពិសេសសេរីភាពដេញដោលផ្នែកនយោបាយរួមគ្នាបង្កើតបានជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធប្រជាធិបតេយ្យ។

លើសពីនេះទៅទៀត នៅក្នុងប្រទេសមួយចំនួន ការដាក់ដែនកំណត់ឲ្យនៅទាបទៅលើការចំណាយក្នុងយុទ្ធនាការឃោសនាដែលច្បាប់បានអនុញ្ញាត បានធ្វើឲ្យការរាយការណ៍អំពីការចំណាយរបស់គណបក្សនយោបាយមានភាពមិនស៊ីសង្វាក់គ្នា ដូចយ៉ាងករណីនៅប្រទេសឥណ្ឌា និង អ៊ីស្រាអែលជាដើម ។ បន្ថែមលើនេះទៀត ការស្រាវជ្រាវ

---

[42] *តាមទស្សនៈរបស់របស់តុលាការកំពូលសហរដ្ឋអាមេរិច "ទស្សនៈទានដែលថារដ្ឋាភិបាលអាចរិតត្បិតការនិយាយស្តីរបស់ធាតុផ្សំមួយចំនួនរបស់សង្គមក្នុងគោលបំណងលើកកម្ពស់សម្លេងរបស់អ្នកម្ខាងទៀតមានលក្ខណៈខុសស្រឡះទាំងស្រុងទៅនឹងការធ្វើវិសោធនកម្មលើកទី១។ កិច្ចការពារដែលមាននៅក្នុងវិសោធនកម្មលើកទី១ប្រឆាំងនឹងការធ្វើឲ្យរួមតូចនូវការសម្តែងមតិដោយសេរីមិនមែនកើតមានឡើងដោយអាស្រ័យទៅលើលទ្ធភាពផ្នែកហិរញ្ញវត្ថុរបស់បុគ្គលក្នុងការពាក់ព័ន្ធទៅក្នុងការពិភាក្សាជាសាធារណៈនោះទេ"។ សូមមើល ករណីវិវាទរវាងបាក់ឃ្លេ និង វ៉ាលេអូ (១៩៧៦) ទំព័រ៤៨-៤៩។*

ដែលធ្វើឡើងដោយអ្នកនិពន្ធបានចង្អុលបង្ហាញថា ដែនកំណត់ចំណាយធ្វើឲ្យបញ្ញត្តិនៃការបង្ហាញព័ត៌មានកាន់តែមានការលំបាកនៅក្នុងការអនុវត្ត។ ករណីប្រទេស ប៉ូឡូញ រុស្ស៊ី និង អ៊ុយក្រែន (ក្នុងតារាង១ខាងក្រោម) បានបង្ហាញថាដែនកំណត់ចំណាយបង្ហាញឲ្យយើងឃើញជាក់ស្តែងអំពីភាពមិនស៊ីសង្វាក់គ្នា ដោយសារដែនកំណត់ចំណាយទាំងនោះត្រូវបានគេដាក់ចេញក្នុងកំរិតមួយដ៏ទាបដែលគ្មានលក្ខណៈប្រាកដនិយមទាល់តែសោះ។ ការធ្វើបែបនេះមិនត្រឹមតែបរាជ័យក្នុងការទប់ស្កាត់"ការប្រកួតប្រជែងដោយមិនស្មើភាព"ដោយហិរញ្ញវត្ថុនយោបាយប៉ុណ្ណោះទេ តែការបរាជ័យថែមទាំងធ្វើឲ្យប៉ះពាល់ជំនឿទុកចិត្តនៅក្នុងប្រព័ន្ធបទបញ្ញត្តិហិរញ្ញវត្ថុនយោបាយទាំងមូលទៀតផង។ វិធានទាំងនេះក៏បានបង្កការលំបាកក្នុងការប៉ាន់ប្រមាណកម្រិតពិតប្រាកដនៃការចំណាយទៀតផង។ ដោយហេតុថាគ្មានគណបក្សនយោបាយណាមួយចង់ទទួលទណ្ឌកម្មដោយសារការបំពានច្បាប់ស្តីពីដែនកំណត់លើចំណាយ ពួកគេនឹងធ្វើរបាយការណ៍ចំណាយរបស់ខ្លួនទាបជាងកម្រិតច្បាប់កំណត់។ លើសពីនេះទៀត ប្រសិនបើគណបក្សនយោបាយដែលប្រឆាំងមិនព្រមអនុវត្តតាមច្បាប់ដែលពាក់ព័ន្ធទៅនឹងដែនកំណត់លើចំណាយ និង ការបង្ហាញព័ត៌មាន ពេលនោះ "កិច្ចព្រមព្រៀងស្តីពីការមិនបំពាន" អាចនឹងកើតមានឡើង ។ ជាលទ្ធផល ទាំងអ្នកបោះឆ្នោត សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយនឹងមិនអាចទទួលបាននូវដែលគួរឲ្យទុកចិត្តបានដើម្បីជាប្រយោជន៍ក្នុងការត្រួតពិនិត្យហិរញ្ញវត្ថុយុទ្ធនាការឃោសនាបោះឆ្នោតបានឡើយ។

***តារាង១: ហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតប្រធានាធិបតី៖ ចំណាយផ្លូវការរបស់បេក្ខជនសំខាន់ៗនៅប្រទេសរុស្ស៊ីអ៊ុយក្រែន និង ប៉ូឡូញ***

| | | | | |
|---|---|---|---|---|
| **រុស្ស៊ី** | | | | |
| បេក្ខជនឈរឈ្មោះបោះឆ្នោតប្រធានាធិបតីឆ្នាំ ១៩៩៦* | ឡេបែដ (Lebed) | ហ្ស៊ីរីនូវស្គី (Zhirinovskiy) | យ៉ាវលីនស្គី (Yavlinskiy) | យែលស៊ីន (Yeltsin) |
| ចំណាយ (គិតជាលានដុល្លារអាមេរិក | 2.83 | 2.72 | 2.72 | 2.42 |
| បេក្ខជនឈរឈ្មោះបោះឆ្នោតប្រធានាធិបតីឆ្នាំ ២០០០** | ហ្ស៊ីរីនូវស្គី (Zhirinovskiy) | ទីតូវ (Titow) | យ៉ាវលីនស្គី (Yavlinskiy) | ពូទីន (Putin) |
| ខ្ទង់ចំណាយ (គិតជាលានដុល្លារអាមេរិក | 0.869 | 0.866 | 0.840 | 0.451 |
| **អ៊ុយក្រែន** | | | | |
| បេក្ខជនឈរឈ្មោះបោះឆ្នោតប្រធានាធិបតីឆ្នាំ ១៩៩៩*** | ម៉ូរ៉ូស្ស (Moroz) | កាឆេនកូ (Tkachenko) | គូចម៉ា (Kuchma) | វីត្រែនកូ (Vitrenko) |
| ចំណាយ (គិតជាលានដុល្លារអាមេរិក | 0.214 | 0.195 | 0.154 | 0.125 |
| **ប៉ូឡូញ** | | | | |
| បេក្ខជនឈរឈ្មោះបោះឆ្នោតប្រធានាធិបតីឆ្នាំ ១៩៩០ | ម៉ាហ្សូវីគី (Mazowiecki) | វ៉ាឡេសា (Walesa) | ទីមីនស្គី (Tyminski) | ស៊ីម៉ូស្សេវីក (Cimoszewicz) |
| ចំណាយ (គិតជាលានដុល្លារអាមេរិក | 0.597 | 0.581 | 0.351 | 0.192 |
| បេក្ខជនឈរឈ្មោះបោះឆ្នោតប្រធានាធិបតីឆ្នាំ ១៩៩៥ | កាវ៉ាស្នៀស្គី (Kwasniewski) | វ៉ាឡេសា (Walesa) | ប៉ៅឡាក (Pawlak) | គូរ៉ុន (Kuron) |
| ចំណាយ (គិតជាលានដុល្លារអាមេរិក | 1.373 | 1.121 | 0.544 | 0.535 |
| បេក្ខជនបោះឆ្នោតប្រធានាធិបតីឆ្នាំ ២០០០**** | កាវ៉ាស្នៀស្គី (Kwasniewski) | ក្រាហ្សាក្លេវស្គី (Krzaklewski) | អូឡិចឆូស្គី (Olechowski) | កាលីណូស្គី (Kalinowski) |

| | | | | |
|---|---|---|---|---|
| **ចំណាយ (គិតជាលានដុល្លារអាមេរិក)** | 2.29 | 2.31 | 0.42 | 0.46 |

**សំគាល់៖** *ដែនកំណត់ចំណាយជាផ្លូវការ 2,850,000 ដុល្លារសហរដ្ឋអាមេរិច

** ដែនកំណត់ចំណាយជាផ្លូវការ 920,000 ដុល្លារសហរដ្ឋអាមេរិច

*** ដែនកំណត់ចំណាយជាផ្លូវការ 385,000 ដុល្លារសហរដ្ឋអាមេរិច

**** ដែនកំណត់ចំណាយជាផ្លូវការក្នុងឆ្នាំ2000គឺ 2,600,000 ដុល្លារសហរដ្ឋអាមេរិច។ សម្រាប់ដែនកំណត់ចំណាយជាផ្លូវការក្នុងឆ្នាំ 1990 និង 1995 មិនមានព័ត៌មាន។

នៅមានការប្រឈមមួយចំនួនតូចទៀតចំពោះការកំណត់ដែនចំណាយដែលយើងគួរពិចារណា ។ សំខាន់ជាងគេបំផុតនោះ ការកំណត់ដែនចំណាយមានការលំបាកក្នុងការធ្វើបទបញ្ញាសម្រាប់គ្រប់គ្រងនិងពិបាកនៅក្នុងការអនុវត្ត។ ការដាក់ចេញឲ្យមានការអនុវត្តការកំណត់ដែនចំណាយអាចនាំឲ្យមានការសម្រេចចិត្តលើគោលនយោបាយសំខាន់ៗមួយចំនួនដូចជា អំឡុងដែលគេត្រូវយកដែនកំណត់លើការចំណាយមកអនុវត្ត ប្រភេទនៃការចំណាយដែលគេត្រូវរាប់បញ្ចូលនៅក្នុងការចំណាយសម្រាប់ "យុទ្ធនាការឃោសនា" និងការរៀបចំនានាដែលត្រូវរាប់បញ្ចូលនៅក្នុងការកំណត់ដែនចំណាយជាដើម។ បើតាមលោក *ហ៊ើប៊ើត អាឡិចសាន់ឌ័រ* (Herbert E.Alexander)៖ ដែនកំណត់លើចំណាយគឺជាការបំភ័ន្តភ្នែកម៉្យាងនៅក្នុងប្រព័ន្ធបោះឆ្នោតពហុបក្ស ដែល មានភាពចន្លោះប្រហោងយ៉ាងច្រើនចំពោះការទូទាត់ថវិកា...។ នៅពេលដែលសេរីភាពក្នុងការនិយាយស្តី និង ការបង្កើតសមាគមត្រូវបានធានា ការរិតត្បិតថវិកានៅកម្រិតណាមួយនៅក្នុងដំណើរការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតនឹងបង្កើតឲ្យមានច្រកថ្មីៗទៀត ដែលតាមរយៈនេះ បុគ្គលនិងក្រុមដែលមានធនធានអាចនាំយកឥទ្ធិពលរបស់ពួកគេទៅភ្ជាប់នឹងយុទ្ធនាការឃោសនានិងអ្នកកាន់អំណាច[43]។ ជាឧទាហរណ៍ ប្រ សិនបើដែនកំណត់សម្រាប់ចំណាយត្រូវបានគេកំណត់អត្ថន័យត្រឹមតែ "ជាការចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត" (សម្រាប់អនុវត្តក្នុងពេលកំណត់ណាមួយមុនពេលបោះឆ្នោត) វាធ្វើឲ្យគណបក្សនយោបាយអាចនឹងបោះពុម្ពខិតប័ណ្ណឃោសនា លើកផ្ទាំងប៉ាណូឃោសនា ចាក់ផ្សាយសារនយោបាយ និង ផ្ញើរសារនយោបាយដោយផ្ទាល់ទៅកាន់អ្នកបោះឆ្នោតនៅមុនពេលការធ្វើយុទ្ធនាការឃោសនា ។ មានកត្តាចម្បងមួយដែលគេត្រូវយកមកពិចារណាប្រសិនបើការអនុវត្តដែនកំណត់សម្រាប់ចំណាយនៅក្នុងបណ្តាប្រទេសអន្តរកាលមានការជាប់ពាក់ព័ន្ធ នោះគឺអតិផរណា ឬ អតិផរណាក្នុងកម្រិតខ្ពស់ដែលប្រទេសមួយចំនួនក្នុងចំណោមប្រទេសទាំងនោះបានឆ្លងកាត់រួចហើយ[44]។ រាល់បញ្ហាទាំងអស់ដែលគេបានលើកយកមកពិចារណាត្រូវបានអ្នកជំនាញការមួយចំនួនអះអាងថា "ការហាមប្រាមលើការផ្សព្វផ្សាយសារនយោបាយតាមកញ្ចក់ទូរទស្សន៍ដោយមានការចំណាយមានប្រសិទ្ធិភាពច្រើនជាងឆ្ងាយណាស់បើធៀបទៅនឹងការកំណត់ដែនចំណាយផ្លូវការទៅលើចំណាយរបស់គណបក្សនយោបាយនៅក្នុងការដាក់ដែនកំណត់លើការចំណាយនៃការបោះឆ្នោត" ។

---

[43] *ហ៊ើប៊ើត អាឡិចសាន់ឌ័រ "អភិក្រមសម្រាប់បញ្ហាហិរញ្ញវត្ថុយុទ្ធនាការឃោសនា និង គណបក្សនយោបាយ" បោះពុម្ពផ្សាយនៅក្នុង "មូលនិធិសម្រាប់លទ្ធិប្រជាធិបតេយ្យ៖ អភិក្រមសម្រាប់ហិរញ្ញវត្ថុនយោបាយប្រៀបធៀប" របស់ ខាល ហេនស៍ ណាស់ស្មាឈ័រ ឆ្នាំ២០០១ ទំព័រ១៩៨។*

[44] *នៅក្នុងប្រទេសប៊ុលហ្គារី ការកំណត់ដែនចំណាយកាលពីឆ្នាំ១៩៩១ ត្រូវបានយកទៅអនុវត្តនៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៧ ក៏ប៉ុន្តែអតិផរណានៅឆ្នាំ១៩៩៧បានកាត់បន្ថយតម្លៃរូបិយប័ណ្ណរបស់ប៊ុលហ្គារីមួយចំនួនតូចបើធៀបទៅនឹងតម្លៃរបស់រូបិយប័ណ្ណនេះកាលពីឆ្នាំ១៩៩១។ ចំណាយជាអតិបរមាដែលច្បាប់អនុញ្ញាតរបស់បេក្ខជនម្នាក់សម្រាប់យុទ្ធនាការឃោសនាគិតជាទឹកប្រាក់ចំនួន ៣០ពាន់ (រូបិយប័ណ្ណប៊ុលហ្គារី) ត្រូវបានកាត់បន្ថយអស់ប្រហែល២០ដុល្លារសហរដ្ឋអាមេរិច។*

## ដែនកំណត់សម្រាប់ចំណាយ និង ទស្សនៈរបស់អង្គការអន្តរជាតិ/អង្គការប្រចាំតំបន់

អង្គការអន្តររដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន (ដូចជា អង្គការនៃបណ្តារដ្ឋនៅទ្វីបអាមេរិច ក្រុមប្រឹក្សាអឺរ៉ុប ធនាគារពិភពលោក អង្គការអេស៊ីអ៊ីអ៊ីអ៊ីអូ(ACEEEO) និងអង្គការតម្លាភាពអន្តរជាតិជាដើម) បានធ្វើការតស៊ូមតិឲ្យបង្កើតបទដ្ឋាននានា និង ការអនុវត្តល្អៗពាក់ព័ន្ធនឹងការកំណត់ដែនចំណាយនេះ ។ បញ្ហាដែលទាក់ទងទៅនឹងការចំណាយដ៏ខ្ពស់នៃយុទ្ធនាការឃោសនាបោះឆ្នោតក៏ត្រូវបានទទួលស្គាល់ផងដែរដោយលិខិតុ-បករណ៍អន្តរជាតិសំខាន់ៗមួយចំនួន ដូចជាធម្មនុញ្ញប្រជាធិបតេយ្យសម្រាប់បណ្តារដ្ឋនៅទ្វីបអាមេរិច (Inter American Democractic Charter) ដែលបានអនុម័តកាលពីឆ្នាំ២០០១ និង យោបល់ទូទៅលេខ២៥ (General Comment No.25) ដែលអនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិកាលពីឆ្នាំ១៩៩៦ ។

អង្គការអន្តររដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលភាគច្រើន បានស្នើរយោបល់ថា រដ្ឋនានាគួរតែកំណត់ការចំណាយដើម្បីធ្វើឲ្យការចំណាយផ្នែកនយោបាយរបស់គណបក្សនយោបាយមានកម្រិតមួយទាបបំផុតតាមដែលអាចធ្វើទៅបាន។ អនុសាសន៍មួយចំនួនទៀតថែមទាំងបានស្នើយោបល់បន្ថែមទៀតដូចជា "បង្រួមរយៈពេលធ្វើយុទ្ធនាការឃោសនាឲ្យកាន់តែខ្លី ផ្តល់លទ្ធភាពឲ្យបានស្មើៗគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដោយរួមបញ្ចូលទាំងការទទួលបានម៉ោងផ្សាយដោយឥតគិតថ្លៃសម្រាប់បេក្ខជនទាំងអស់នៅក្នុងរយៈពេលសំខាន់ៗនៃយុទ្ធនាការឃោសនា ហាមប្រាមឬដាក់ដែនកំណត់ទៅលើការផ្សព្វផ្សាយសារនយោបាយដោយមានការចំណាយ ហើយនិងឧបត្ថម្ភធនទៅលើលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ" ជាដើម ។

*តារាង២៖ អនុសាសន៍ស្ដីពីការកំណត់ចំណាយ ដែលបានលើកឡើងដោយអង្គការអន្តរជាតិនានា*

**អង្គការ**

- ក្រុមប្រឹក្សាអឺរ៉ុប
- គណៈកម្មការអឺរ៉ុបសម្រាប់លទ្ធិប្រជាធិបតេយ្យតាមរយៈច្បាប់ (គណៈកម្មការវេនីស)
- (សេចក្ដីព្រាង) អនុសញ្ញាស្ដីពីបទដ្ឋានបោះឆ្នោត សិទ្ធិបោះឆ្នោត និង សេរីភាព

**អនុសាសន៍**

ដើម្បីបង្កើតឲ្យមានលក្ខខណ្ឌស្មើភាពគ្នាសម្រាប់គ្រប់បេក្ខជនទាំងអស់ និង គណបក្សនយោបាយទាំងអស់ (រួមទាំងសម្ព័ន្ធភាពគណបក្សនយោបាយ) រដ្ឋជាភាគីទាំងអស់ ត្រូវរៀបចំឲ្យមានទំហំអតិបរមាសមស្របមួយសម្រាប់មូលនិធិបោះឆ្នោតរបស់បេក្ខជន ឬ គណ បក្សនយោបាយ (រួមទាំងសម្ព័ន្ធភាពគណបក្សនយោបាយ) ដែលពួកគេអាចប្រើមូលនិធិនេះបានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់ពួកគេ។

**អង្គការ**

- អង្គការសហប្រជាជាតិ
- យោបល់ទូទៅលេខ២៥ ស្ដីពីសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការសាធារណៈ សិទ្ធិបោះឆ្នោត និងសិទ្ធិទទួលបានសេវាសាធារណៈដោយស្មើភាពគ្នា (ប្រការ២៥)៖ 12/07/96 CCPR/21/Rev.1/Add.7។

**អនុសាសន៍**

ការកំណត់ដែនចំណាយសមស្របសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត អាចត្រូវបានកែតម្រូវប្រសិនបើចាំបាច់ ដើម្បីធានាថា ជម្រើសនយោបាយដោយសេរីរបស់អ្នក បោះឆ្នោតមិនទទួលរងការប៉ះពាល់ ឬដើម្បីធានាថា ដំណើរការប្រជាធិបតេយ្យមិនត្រូវបានបំផ្លាញដោយសារចំណាយមិនសមស្របក្នុងនាមគណបក្សនយោបាយ និង បេក្ខជន។

**អង្គការ**

- ធម្មនុញ្ញលទ្ធិប្រជាធិបតេយ្យសម្រាប់បណ្ដារដ្ឋនៅទ្វីបអាមេរិច
  (អនុម័តដោយមហាសន្និបាតនៅឯកិច្ចប្រជុំពេញអង្គពិសេសមួយក្នុងទីក្រុងលីម៉ា (ប្រទេសប៉េរូ) កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ (មាត្រា៥)

**អនុសាសន៍**

ការពង្រឹងគណបក្សនយោបាយនិងស្ថាប័ននយោបាយផ្សេងៗទៀត គឺជាអាទិភាពសម្រាប់លទ្ធិប្រជាធិបតេយ្យ។ ការយកចិត្តទុកដាក់ជាពិសេសមួយនឹងត្រូវផ្ដោតទៅលើបញ្ហានានាពាក់ព័ន្ធនឹងចំណាយដ៏ខ្ពស់ក្នុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត និង ការ បង្កើតប្រព័ន្ធហិរញ្ញវត្ថុមួយដែលមានតុល្យភាព និង តម្លាភាពសម្រាប់ហិរញ្ញវត្ថុរបស់ពួកគេ។

**អង្គការ**

- បទដ្ឋាន និង ស្តង់ដារវេទិកាសភារបស់សហគមន៍អេសអេឌីស៊ី (SADC) សម្រាប់ការបោះឆ្នោតនៅក្នុងតំបន់
  អនុម័តដោយសន្និបាតពេញអង្គ កាលពីថ្ងៃទី ២៥ មីនា ឆ្នាំ ២០០១ នៅទីក្រុងវីនហ្វុក (Windhoek)។

**អនុសាសន៍**

ការផ្តល់មូលនិធិសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត គឺជាករណីមួយដែលការប្រើប្រាស់មូលនិធិមិនត្រឹមត្រូវតែងតែកើតមាន ហើយដែលការប្រកួតប្រជែងពុំមានលក្ខណៈស្មើភាពគ្នា។ បទពិសោធន៍ទទួលបានពីប្រទេសភាគច្រើនបង្ហាញថាគណបក្សគ្រប់គ្រងអំណាចមានធនធានយ៉ាងច្រើនលើសលុប (ទាំងថវិកា និង ទ្រព្យសម្បត្តិ) ខណៈដែលគណបក្សប្រឆាំងមានធនធានយ៉ាងខ្សត់ខ្សោយ។ ការកំណត់ដែនចំណាយនយោបាយពុំមានវត្តមានក្នុងប្រទេសទាំងនោះឡើយ ហើយក៏ពុំត្រូវបានគេយកចិត្តទុកដាក់ដែរ ។ ពួកអ្នកមានទ្រព្យតែងតែជាប់ពាក់ព័ន្ធនឹងការចំណាយដ៏ខ្ជះខ្ជាយនេះដើម្បីឈ្នះឆ្នោត។

ដូច្នេះគណៈកម្មការបោះឆ្នោតគួរតែមានអំណាចពេញលេញតាមផ្លូវច្បាប់ដើម្បីហាមឃាត់លើប្រភេទចំណាយជាក់លាក់មួយចំនួន ក៏ដូចជាដើម្បីទប់ស្កាត់ឥទ្ធិពលអវិជ្ជមានដែលកើតមានទៅលើដំណើរការប្រជាធិបតេយ្យ និងលទ្ធផលនៃការបោះឆ្នោត។ គណៈកម្មការបោះឆ្នោតគួរមានអំណាចពេញលេញដើម្បីធានាឲ្យបានថារបាយការណ៍សមស្របមួយស្តីអំពីការចំណាយលើការបោះឆ្នោតត្រូវបានធ្វើយ៉ាងទាន់ពេលវេលា ពោលគឺដើម្បីតាមដានលើគណនីរបស់គណបក្សនយោបាយ និងសម្រាប់គណបក្សនយោបាយធ្វើសវនកម្ម និង ផ្ទៀងផ្ទាត់គណនី។

**អង្គការ**

- តម្លាភាពអន្តរជាតិ
  ឯកសារគោលនយោបាយរបស់អង្គការតម្លាភាពអន្តរជាតិ លេខ1/2005

**អនុសាសន៍**

ដើម្បីត្រួតពិនិត្យតម្រូវការហិរញ្ញវត្ថុនយោបាយ យន្តការមួយចំនួនដូចជា ការកំណត់ដែនចំណាយ និង ការឧបត្ថម្ភធនក្នុងការទទួលបានព័ត៌មានគួរត្រូវបានយកមកពិចារណា។

**អង្គការ**

- ក្រុមប្រឹក្សាអឺរ៉ុប
- គណៈកម្មាធិការរដ្ឋមន្ត្រី
- អនុសាសន៍ (លេខ៤ ឆ្នាំ២០០៣) របស់គណៈកម្មាធិការរដ្ឋមន្ត្រី ធ្វើទៅកាន់រដ្ឋជាសមាជិកស្តីអំពីវិធានទូទៅប្រឆាំងនឹងអំពើពុករលួយនៅក្នុងការផ្តល់មូលនិធិដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនា។

**អនុសាសន៍**

រដ្ឋជាសមាជិកគួរពិចារណាក្នុងការអនុម័តវិធានការណ៍ផ្សេងៗដើម្បីបង្ការសេចក្តីត្រូវការថវិកាហួសប្រមាណរបស់គណបក្សនយោបាយ ដូចជាតាមរយៈការបង្កើតដែនកំណត់នានាស្តីអំពីចំណាយទៅលើយុទ្ធនាការឃោសនាបោះឆ្នោត។

**អង្គការ**

- សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាប្រធានាធិបតី និង នាយករដ្ឋមន្ត្រីនៃបណ្តារដ្ឋនៅទ្វីបអាមេរិច
  "ហិរញ្ញវត្ថុប្រជាធិបតេយ្យ៖ គណបក្សនយោបាយ យុទ្ធនាការឃោសនា និង ការបោះឆ្នោត"
- មូលស្ថាបនាខាធ័រ (The Carter Center) ទីក្រុងអាត្លង់តា រដ្ឋហ្សកហ្ស៊ី (Georgia) ថ្ងៃទី19 ខែមិនា ឆ្នាំ2003

**អនុសាសន៍**

គេគួរធ្វើការវិនិយោគនៅក្នុងឥរិយាបថបែបប្រជាធិបតេយ្យរបស់គណបក្សនយោបាយ ជាជាងនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតរយៈពេលយូរនិងអវិជ្ជមាន។ ឥទ្ធិពលនៃការប្រមូលគៀងគរមូលនិធិនយោបាយគួរត្រូវបានកាត់បន្ថយតាមរយៈការគ្រប់គ្រងកត្តានានាដែលនាំឲ្យមានការចំណាយសម្រាប់យុទ្ធនាការឃោសនាកើនឡើងខ្ពស់។ វិធានការណ៍ផ្សេងៗអាចរួមបញ្ចូលទាំងការដាក់ដែនកំណត់ចំណាយ ការបង្រួមយុទ្ធនាការឃោសនា ការផ្តល់លទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ (រួមមានការផ្តល់ម៉ោងផ្សាយដោយឥតគិតថ្លៃដល់បេក្ខជនក្នុងរយៈពេលសំខាន់ៗ) និងការហាមប្រាម ឬ ការដាក់កម្រិតការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងសកម្មភាពនយោបាយ។

**អង្គការ**

- អង្គការអេស៊ីអ៊ីអ៊ីអ៊ីអូ (ACEEEO)
  អនុសាសន៍ស្តីពីវិធានគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ... (ខែតុលា ឆ្នាំ2001)

**អនុសាសន៍**

ការចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់បេក្ខជន និង គណបក្សគួរត្រូវបានកំណត់ព្រំដែន។

*តារាង 3 ការកំណត់ដែនចំណាយសម្រាប់យុទ្ធនាការឃោសនា៖ ការយល់ខុស និង ភាពពិតជាក់ស្តែង*

| ការយល់ខុស | ភាពពិតជាក់ស្តែង |
|---|---|
| 1. ការដាក់ដែនកំណត់លើការចំណាយគឺជាការបំពានទៅនឹងសេរីភាពក្នុងការនិយាយស្តីរបស់បេក្ខជន។ | មតិខ្លះបានអះអាងថា "លុយគឺជាការបញ្ចេញមតិ" ដូច្នេះហើយការដែលរិតត្បិតទៅលើការចំណាយនោះ គឺជាបន្ទុកមួយដែលពុំអាចទទួលយកបានឡើយដែលដាក់ទៅលើសេរីក្នុងការនិយាយស្តី។ ការលើកឡើងដូច្នេះគឺផ្អែកលើមូលដ្ឋានមួយដែលមិនអាចទទួលយកបាន ដែលថាក្នុងរបបប្រជាធិបតេយ្យ អ្នកដែលមានលុយច្រើននឹងទទួលបានសិទ្ធិនយាយស្តីច្រើនជាងគេ ដែលជាហេតុធ្វើឲ្យគេមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការបោះឆ្នោត និងកិច្ចការសាធារណៈ។ ក៏ប៉ុន្តែការអះអាងបែបនេះមានភាពផ្ទុយគ្នាស្រឡះទៅនឹងគោលការណ៍គ្រឹះនៃសមភាពប្រជាធិបតេយ្យដែលចែងថា "មនុស្សម្នាក់មានសិទ្ធិបោះឆ្នោតតែមួយសម្លេងគត់"។ លើសពីនេះទៅទៀត ការអនុញ្ញាតឲ្យមានការចំណាយដោយគ្មានដែនកំណត់បានជួយឲ្យបេក្ខជនដែលមានធនធានច្រើនអាចលុបបំបាត់សម្លេងរបស់គូប្រជែងខ្លួន ដែលជាហេតុធ្វើឲ្យថយចុះនូវគុណភាពជារួម និង ពហុភាពនៃការពិភាក្សាដេញដោលជាសាធារណៈ។ |
| 2.ការដាក់ដែនកំណត់លើការចំណាយបានជួយដល់បេក្ខជនផុតអណត្តិ និង បានធ្វើឲ្យប៉ះពាល់ដល់គូប្រជែងរបស់គេ។ | ជាដំបូង គេហាក់ដូចជាគិតថា ការកំណត់ដែនចំណាយអាចនឹងមានន័យស្មើនឹង "ការការពារអ្នកនយោបាយផុតអណត្តិ" ដោយហេតុថាបេក្ខជនផុតអណត្តិទំនងជាបានទទួលផលប្រយោជន៍ពីភាពល្បីល្បាញរបស់គេ រីឯគូប្រឆាំងរបស់គេជារឿយៗតែងត្រូវការចំណាយក្នុងបរិមាណដ៏ច្រើន ដើម្បី |

| | |
|---|---|
| | ទទួលបានការគាំទ្រ និង ឈ្នះឆ្នោត។ តែការពិតវាមិនមែនដូចជាការសន្មត់នោះទេ។ បេក្ខជនផុតអណត្តិតែងតែគៀងគរប្រមូលហិរញ្ញវត្ថុច្រើនជាងឆ្ងាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតបើប្រៀបធៀបទៅនឹងគូប្រជែងរបស់ពួកគេ ដែលនេះគឺជាអ្វីដែលការកំណត់ដែនចំណាយពិតជាចង់ឲ្យមានទីលានប្រកួតប្រជែងស្មើភាពគ្នាមួយ និង ជួយឲ្យបេក្ខជនប្រឆាំងអាចប្រកួតប្រជែងបាន។ ឧទាហរណ៍៖ បេក្ខជនផុតអណត្តិសម្រាប់ការបោះឆ្នោតតំណាងរាស្ត្រនៅសហរដ្ឋអាមេរិចគៀងគរធនធានជិត៧ដងច្រើនជាងគូប្រជែងរបស់ពួកគេកាលពីការបោះឆ្នោតឆ្នាំ២០០២។ ជាលទ្ធផលដែលគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើល បេក្ខជនផុតអណត្តិទាំងនោះឈ្នះបាន៩០%នៅពេលនោះ។ |
| 3. ការកំណត់ដែនចំណាយបានរារាំងបេក្ខជននានាមិនឲ្យធ្វើយុទ្ធនាការឃោសនាបានដោយប្រសិទ្ធិភាព បានកម្រិតព័ត៌មានដែលអ្នកបោះឆ្នោតត្រូវទទួលបាន ដែលជាហេតុធ្វើឲ្យការចូលរួមមានការថយចុះ។ | សញ្ញាណដែលថាបេក្ខជនទាំងឡាយ ត្រូវការប្រមូលគៀងគរថវិកាដ៏ច្រើនសន្ធឹកសន្ធាប់ និង យកទៅចំណាយលើការផ្សព្វផ្សាយតាមរលកធាតុអាកាសដែលមានរយៈពេលត្រឹមតែ30វិនាទី ដើម្បីធ្វើយុទ្ធនាការឃោសនា "ដ៏មានប្រសិទ្ធិភាព" នោះ គឺជារឿងថ្មីមួយ។ តាមការពិត មានមនុស្សមួយចំនួនតូចប៉ុណ្ណោះដែលនឹងតវ៉ាថា ការផ្សព្វផ្សាយបែបបរិហារ ឬ ការចាក់ផ្សាយឈុតឆាកបែបគាំទ្រគឺជាមធ្យោបាយដ៏ប្រសើរបំផុតដើម្បីឲ្យអ្នកបោះឆ្នោតបានដឹងអំពីរឿងសំខាន់ៗនៃយុទ្ធនាការឃោសនាបោះឆ្នោត។ ការកំណត់ដែនចំណាយសមស្របនឹងអនុញ្ញាតឲ្យបេក្ខជនអាចផ្សព្វផ្សាយសារនយោបាយរបស់ខ្លួនទៅកាន់អ្នកបោះឆ្នោតប្រកបដោយខ្លឹមសារ និង ជក់ជាប់ក្នុងអារម្មណ៍អ្នកបោះឆ្នោតបានយូរ។ ដោយមិនចាំបាច់ពឹងផ្អែកទៅលើថវិកាជាច្រើនលានដុល្លារជាប្រចាំនោះ អ្នកធ្វើយុទ្ធនាការឃោសនាប្រើប្រាស់ឱកាសរបស់ខ្លួនដើម្បីទាក់ទាញអ្នកបោះឆ្នោតតាមរយៈមធ្យោបាយនានាដែលត្រូវការចំណាយពេលវេលាជាជាងចំណាយលុយ (ឧទាហរណ៍៖ វេទិកាសាធារណៈ ការធ្វើយុទ្ធនាការដោយផ្ទាល់ពីផ្ទះមួយទៅផ្ទះមួយជាដើម)។ |
| 4. ការកំណត់ដែនចំណាយមិនត្រូវបានគេយកមកសាកល្បងជាមុនទេ នេះគឺជាគំនិតដ៏គ្រោះថ្នាក់មួយ។ | ច្បាប់ស្តីពីដែនកំណត់ចំណាយសម្រាប់បេក្ខជនសភាជាលើកដំបូងត្រូវបានអនុម័តក្នុងឆ្នាំ1911 ហើយត្រូវបានធ្វើបច្ចុប្បន្នកម្មម្តងទៀតនៅក្នុងច្បាប់មួយ (The Hatch Act) កាលពីឆ្នាំ1939។ ជាអកុសល ច្បាប់ទាំងនេះពុំបានបញ្ញត្តិអំពីយន្តការសម្រាប់អនុវត្តនោះទេ ដែលជាហេតុធ្វើឲ្យគេមិនបានយកចិត្តទុកដាក់ទៅលើដែនកំណត់ចំណាយដែលមានចែងនៅក្នុងច្បាប់នោះទេ។ ទោះជាយ៉ាងនេះក្តី ក៏ក្រុងអែលប៊ូគ្យូគ្យ (Albuquerque) នៃរដ្ឋញូម៉ិចស៊ិចកូ (New Mexico) បានអនុវត្តបញ្ញត្តិស្តីអំពីដែនចំណាយស្ទើរតែបន្តឥតដាច់ចាប់តាំងពីឆ្នាំ១៩៧៤មក។ ទីក្រុងនេះ បានបង្ហាញពីគុណប្រយោជន៍ជាច្រើនពីគោលនយោបាយខាងលើនេះ ដូចជា ចំនួនអ្នកចេញទៅបោះឆ្នោតលើស |

| | |
|---|---|
| | ពីមធ្យមភាគ ភាពជឿជាក់របស់អ្នកបោះឆ្នោតទៅលើការបោះឆ្នោតមូលដ្ឋានមានកម្រិតខ្ពស់ការបោះឆ្នោតសហព័ន្ធ ហើយនិងការបង្កើនឲ្យមានការប្រកួតប្រជែង។ កត្តានេះហើយដែលនាំឲ្យមានការគាំទ្រពីសាធារណជនដ៏ច្រើនលើសលុបទៅលើការកំណត់ដែនចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។ |

*តារាង4៖ ដែនកំណត់ចំណាយសម្រាប់ការបោះឆ្នោតនៅក្នុងទ្វីបអឺរ៉ុប និង ប្រជាធិបតេយ្យចាស់ទុំដទៃទៀត*[45]

| ប្រទេស | ដែនកំណត់លើការចំណាយរបស់គណបក្សនយោបាយ | កម្រិតនៃដែនកំណត់លើការចំណាយ |
|---|---|---|
| **បែលហ្ស៊ិក** | មាន (សម្រាប់ការបោះឆ្នោតមួយលើកៗ) | ១លានអឺរ៉ូ |
| **ប៊ុលហ្គារី** | មាន (សម្រាប់ការបោះឆ្នោតមួយលើកៗ) | ជាង១លាន៥សែនអឺរ៉ូ |
| **កាណាដា** | មាន | គណបក្សនយោបាយដែលបានចុះបញ្ជី និង បេក្ខជនមិនត្រូវធ្វើការចំណាយសម្រាប់ការបោះឆ្នោតឲ្យលើសពីការកំណត់ដែលត្រូវបានគណនាដោយស្នងការទទួលបន្ទុកកិច្ចការបោះឆ្នោតទៅតាមរូបមន្តដែលបញ្ញត្តិដោយច្បាប់បោះឆ្នោតកាណាដាឡើយ។ |
| **បារាំង** | មាន | នៅក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតី គណបក្សមួយនិង បេក្ខជនរបស់គណបក្សនោះត្រូវបានអនុញ្ញាតឲ្យធ្វើការចំណាយជាង១៦លានអឺរ៉ូសម្រាប់ជុំទី១ និងជាង២០លានអឺរ៉ូសម្រាប់ការបោះឆ្នោតនៅជុំទី២។ ចំណែកឯការបោះឆ្នោតសភា ទាំងបេក្ខជននិងគណបក្សនយោបាយមិនត្រូវចំណាយឲ្យលើសពី៤ម៉ឺនអឺរ៉ូ បូកជាមួយនឹងជាង០,២ អឺរ៉ូទៀតគិតក្នុងប្រជាពលរដ្ឋម្នាក់។ |
| **ហុងហ្គារី** | មាន | ដែនកំណត់ចំណាយគិតក្នុងបេក្ខជនម្នាក់ ក្នុងការបោះឆ្នោតមួយលើក។ |
| **អៀឡង់** | មាន | ដែនកំណត់ចំណាយគិតក្នុងបេក្ខជនម្នាក់ ក្នុងការបោះឆ្នោតមួយលើក។ |
| **អ៊ីតាលី** | មាន | ដែនកំណត់ចំណាយគិតក្នុងបេក្ខជនម្នាក់ ក្នុងការបោះឆ្នោតមួយលើក។ គេបានកំណត់ដែនចំណាយផងដែរសម្រាប់គណបក្សនយោបាយដែលបានដាក់បេក្ខជនគេឲ្យឈរឈ្មោះនៅ |

---

[45] *ប្រភព៖ គេហទំព័រអង្គការអោយខាអន្តរជាតិ (International IDEA) (www.idea.int) ការស្រាវជ្រាវផ្ទាល់របស់អ្នកនិពន្ធ។*

| | | |
|---|---|---|
| | | គ្រប់មណ្ឌលបោះឆ្នោតទាំងអស់។ |
| **ឡាតវី** | មាន | សម្រាប់ការបោះឆ្នោតសភា៖ ០,២០ សេនតា សម្រាប់អ្នកបោះឆ្នោតម្នាក់។ |
| **លីទុយអានី** | មាន | ១ពាន់ដងនៃប្រាក់ឈ្នួលអប្បបរមាគិតជាមធ្យមសម្រាប់បញ្ជីបេក្ខជនដែលឈរឈ្មោះនៅក្នុងមណ្ឌលបោះឆ្នោតមួយដែលបេក្ខជនច្រើន។ |
| **ប៉ូឡូញ** | មាន | ជាង៣លាន៥សែនអឺរ៉ូ (សម្រាប់ការបោះឆ្នោតជ្រើសរើសប្រធានាធិបតី) |
| **ព័រទុយហ្គាល់** | មាន | ៣លាន៨ពាន់៦រយអឺរ៉ូ |
| **អេស្ប៉ាញ** | មាន | ដែលកំណត់ចំណាយសម្រាប់ការបោះឆ្នោតមួយលើកត្រូវបានកំណត់ដោយតុលាការគណនេយ្យ។ |
| **ចក្រភពអង់គ្លេស** | មាន | ១៨លាន៨សែន៨ម៉ឺនផោន (សម្រាប់គណបក្សនយោបាយតែប៉ុណ្ណោះ មិនរាប់បញ្ចូលការចំណាយរបស់បេក្ខជនឡើយ)។ |
| **សហរដ្ឋអាមេរិច** | មាន / គ្មាន | ជាទូទៅគេពុំបានកំណត់ដែនចំណាយតែ ក៏ប៉ុន្តែគេមានការកំណត់ដែនចំណាយសម្រាប់ការបោះឆ្នោតមូលដ្ឋានជាក់លាក់មួយចំនួន និង មានការកំណត់ដោយស្ម័គ្រចិត្តសម្រាប់ការបោះឆ្នោតប្រធានាធិបតី។ |

## សេចក្តីសន្និដ្ឋាន

ដោយសារគេមានជំនឿតាមបែបប្រជាធិបតេយ្យថារាល់អ្នកប្រកួតប្រជែងនៅក្នុងការបោះឆ្នោតទាំងអស់គួរតែមានសមភាពក្នុងការប្រកួតប្រជែងដើម្បីការគ្រប់គ្រងអំណាច ជាទូទៅ បណ្តាប្រទេសប្រជាធិបតេយ្យមួយចំនួនបានគ្រប់គ្រងលំហូរហិរញ្ញវត្ថុនៅក្នុងវិស័យនយោបាយ ដោយបង្កើតបានជាក្របខ័ណ្ឌច្បាប់ដែលបញ្ញត្តិអំពីដែនកំណត់លើការចំណាយ ដែលនៅក្នុងនោះ គណបក្សនយោបាយ បេក្ខជនឈរឈ្មោះ និង ភាគីទីបីគួរអនុវត្ត ។ ដែនកំណត់ចំណាយដែលមានភាពប្រាកដប្រជា និង ត្រូវបានតាក់តែងយ៉ាងល្អ អាចជួយពង្រឹងបន្ថែមនូវការប្រកួតប្រជែងផ្នែកនយោបាយប្រកបដោយយុត្តិធម៌។ *ខេត អេវីង* (Keith Ewing) សាស្ត្រាចារ្យច្បាប់នៅ*មហាវិទ្យាល័យឃីង* (The King's College) បានពិពណ៌នាថាការប្រកួតប្រជែងក្រោមមជ្ឈដ្ឋានមួយដែលគ្មានដែនកំណត់លើការចំណាយ គឺជា "ការអញ្ជើញមនុស្សពីរនាក់ឲ្យចូលរួមក្នុងការប្រកួតប្រជែងមួយ ដែលអ្នកប្រកួតម្នាក់ប្រើប្រាស់កង់ជាមធ្យោបាយ ខណៈដែលបុគ្គលម្នាក់ទៀតប្រើប្រាស់រថយន្តប្រណាំងដើម្បីប្រកួត"[46]។ លើសពីនេះទៅទៀត ការកំណត់ដែនចំណាយសម្រាប់ក្នុងវិស័យនយោបាយ ក៏អាចជួយបន្ថយការលើកទឹកចិត្តក្នុងការទទួលយកការធ្វើអំណោយក្នុងទ្រង់ទ្រាយធំដែលមានលក្ខណៈពុករលួយផងដែរ។

[46] *ខេត អេវីង, លុយ នយោបាយ និង ច្បាប់ (អុកស្វដ៖ រោងពុម្ពសាកលវិទ្យាល័យអុកស្វដ ឆ្នាំ១៩៩២) ទំព័រ១៥។*

មិនតែប៉ុណ្ណោះ នៅពេលគេតវ៉ាឲ្យមានដែនកំណត់លើការចំណាយ ការពិភាក្សាជាសាធារណៈអំពីការចំណាយនៃលទ្ធិប្រជាធិបតេយ្យជារឿយៗគេតែងតែផ្អែកលើការសន្មត់ចំនួនពីរគឺ៖ (ទី១) អ្នកនយោបាយ និងក្រុមអ្នកស្រាវជ្រាវជាច្រើនជឿជាក់ថា ក្នុងប្រទេសរបស់ពួកគេចំណាយលើការបោះឆ្នោតមានកម្រិតខ្ពស់ជាងការចំណាយនៅក្នុងប្រទេសប្រជាធិបតេយ្យដទៃទៀត[47] (ទី២) ការចំណាយទៅលើការបោះឆ្នោតកំពុងមានការកើនឡើងយ៉ាងឆាប់រហ័ស[48]។ នៅក្នុងប្រទេសជាច្រើន ការ ពិភាក្សាបែបនេះគឺផ្អែកទៅលើការសន្មត់មិនត្រឹមត្រូវដោយពុំបានធ្វើការស្រាវជ្រាវប្រៀបធៀប ឬពិចារណាឲ្យបានគ្រប់គ្រាន់អំពីអ្វីជាចំនាយពិតប្រាកដក្នុងផ្នែកនយោបាយ ហើយគេត្រូវការចំណាយអស់ប៉ុន្មានដើម្បីឲ្យមានការទាក់ទងប្រកបដោយប្រសិទ្ធភាព។

លទ្ធផលនៃការស្រាវជ្រាវប្រៀបធៀបនាពេលថ្មីៗនេះទៅលើការចំណាយផ្នែកនយោបាយ ក៏បានចោទជាសំនួរផងដែរចំពោះហេតុផលមួយចំនួនដែលត្រូវបានយកទៅប្រើប្រាស់ដោយអ្នកគាំទ្រការកំណត់ដែនចំណាយ ។ លោក*ណាស់ម៉ាឈ័រ* (Nassmacher) បានលើកឡើងថា លទ្ធភាពនៃចំណូលកំណត់អំពី "ចំណាយនៃលទ្ធិប្រជាធិប-តេយ្យ"នាពេលបច្ចុប្បន្ននេះ។ មានន័យថា ឧបត្ថម្ភធន សាធារណៈមានចំណែកទទួលខុសត្រូវចំពោះការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតដែលមានការចំណាយក្នុងកម្រិតមួយខ្ពស់។ ប្រសិនករណីនេះកើតមានឡើង នោះការផ្តល់មូលនិធិសាធារណៈក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតដែលគេបានអនុវត្តនៅក្នុងប្រទេសប្រជាធិបតេយ្យមួយចំនួនអាចនឹងធ្វើឲ្យប៉ះពាល់ដល់សារៈសំខាន់ដទៃទៀតនៃបទប្បញ្ញត្តិហិរញ្ញវត្ថុនយោ - បាយ។ ការលើកឡើងថា សេចក្តីត្រូវការមានច្រើនជា ការផ្គត់ផ្គង់ (ដែលជាបុព្វហេតុនាំឲ្យមានការស្វែងរកមូលនិធិពុករលួយ) ប្រហែលជាមិនត្រឹមត្រូវទាំងស្រុងនោះទេ។ តាមការពិត យើងប្រហែលជាកំពុងព្យាយាមដាក់ដែនកំណត់ទៅលើការចំណាយផ្នែកនយោបាយ ក៏ប៉ុន្តែយើងបែជាផ្តល់មូលនិធិបន្ថែមទៀតដើម្បីធ្វើឲ្យការចំណាយក្នុងវិស័យនយោបាយមានការកើនឡើងទៅវិញ។

ជាចុងក្រោយ នៅក្នុងរបបដែលពុំមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ការកំណត់ដែនចំណាយយ៉ាងតឹងរឹងនិងក្នុងកម្រិតមួយទាបអាចនឹងធ្វើឲ្យមានគ្រោះថ្នាក់ដល់គណបក្សប្រឆាំង ហើយជាលទ្ធផល ការធ្វើបែបនេះរិតតែផ្តល់ផលប្រយោជន៍ដល់របបនេះថែមទៀត តាមរយៈការអនុញ្ញាតឲ្យពួកគេកេងចំណេញទៅលើធនធានដទៃទៀតដូចជាស្ថានីយទូរទស្សន៍ដែលគ្រប់គ្រងដោយរដ្ឋ រដ្ឋបាលសាធារណៈ។ល។ នៅក្នុងការអនុវត្តជាក់ស្តែង ការកំណត់ដែនចំណាយមាននិន្នាការធ្វើឲ្យជីវិតនយោបាយរបស់គណបក្សនិងបេក្ខជនប្រឆាំងកាន់តែមានការលំបាក ព្រោះថាគណបក្សកាន់អំណាចអាចអនុវត្តបទប្បញ្ញត្តិទាំងនោះដោយមានការរើសអើង ដូចដែលយើងបានឃើញរួចមកហើយនៅក្នុងប្រទេសមួយចំនួននៃអតីតសហភាពសូវៀត។ ក្នុងករណីធ្ងន់ធ្ងរភាគច្រើន ដែនកំណត់ចំណាយដែលមានភាពមិនប្រាកដនិយម អាចរិតត្បិតយ៉ាងធ្ងន់ធ្ងរទៅដល់សេរីភាពក្នុងការនិយាយស្តី។ យុទ្ធនាការឃោសនាបោះឆ្នោតដែល

---

[47] *គេនៅតែជឿជាក់ជាទូទៅថា អ៊ីស្រាអែល គឺជា "រដ្ឋប្រជាធិបតេយ្យដែលការចំណាយសម្រាប់អ្នកបោះឆ្នោតម្នាក់មានកម្រិតខ្ពស់ជាងគេបំផុតនៅក្នុងពិភពលោក"។ សូមអាន សៀវភៅ "របបសាធារណរដ្ឋទី២" និពន្ធដោយអារៀន អាហ៊្សេរ (Arian Asher)។ នយោបាយនៅប្រទេសអ៊ីស្រាអែល (Chatham:N.J: Chatham House, 1998) ទំព័រ១៥៥។ សូមអានផងដែរ "ហិរញ្ញវត្ថុសាធារណៈ: សមាជិកភាពរបស់គណបក្សនយោបាយ និង ការប្រកួតប្រជែងផ្ទៃក្នុងរបស់គណបក្សនយោបាយ" នៅក្នុងទស្សនាវដ្តីអឺរ៉ុបស្តីពីការស្រាវជ្រាវនយោបាយ និពន្ធដោយមេណាឆេម ហាហ្វនុង (Menachem Hoffnung) លេខ២៩/១ ឆ្នាំ១៩៩៦ ទំព័រ៧៣ដល់៨៦។*

[48] *ឧទាហរណ៍មួយពីប្រទេសអាល្លឺម៉ង់បង្ហាញថា ការចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតនៅចន្លោះពីឆ្នាំ១៩៥៣ដល់១៩៦៥មានការកើនឡើង៣០០% ចំណែកឯកម្រិតតម្លៃទូទៅកើនឡើងពី១០០ក្នុងឆ្នាំ១៩៥០ ទៅដល់១៣៧ ក្នុងឆ្នាំ១៩៦៥។ សូមរកមើល "ហេតុអ្វីបានជាឧបត្ថម្ភធនសាធារណៈបានប្រែក្លាយទៅប្រភពចម្បងនៃមូលនិធិរបស់គណបក្សនយោបាយនៅអាល្លឺម៉ង់ខាងលិច ប៉ុន្តែមិនបានកើតឡើងនៅក្នុងប្រទេសអង់គ្លេស" និពន្ធដោយ អ៊ូវ៉េ ស្លេត (Uvwe Schleth) និង ម៉ៃឃើល ពីនតូ ឌូសឈីនស្គី (Michael Pinto-Duschinsky) នៅក្នុង Arnold J. Heidenheimer ស្តីអំពីហិរញ្ញវត្ថុនយោបាយប្រៀបធៀប ទំព័រ២៧។*

ត្រូវបានធ្វើឲ្យរាំងស្ទះដោយការដាក់ដែនកំណត់ចំណាយឲ្យនៅទាបបែបនេះ មិនគ្រប់គ្រាន់ឡើយក្នុងការផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់អ្នកបោះឆ្នោតអំពីគោលនយោបាយនិងផែនការនយោបាយរបស់បេក្ខជន ។ ដូច្នេះ ស្ថិតក្នុងកាលៈទេសៈបែបនេះ អវត្តមាននៃដែនកំណត់ចំណាយ អាចនឹងចូលរួមចំនែកធ្វើឲ្យមានវេទិកាពិភាក្សានយោបាយកាន់តែមានភាពបើកចំហរ និងរស់រវើក។

## ជំពូក ៣៖

# ដំណោះស្រាយជាក់ស្តែងសម្រាប់ការធ្វើហិរញ្ញប្បទានសាធារណៈដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោត

ដោយ៖ បណ្ឌិត ម៉ាកណឹស អូម៉ែន

(Magnus Ohman)

## សេចក្ដីផ្ដើម និង សាវតា

កិច្ចខិតខំប្រឹងប្រែងណាមួយក៏ដោយក្នុងការបញ្ញត្តិហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និង បេក្ខជនគួរទទួលស្គាល់ថាហិរញ្ញវត្ថុមានផលប៉ះពាល់ទាំងផលវិជ្ជមាន និង អវិជ្ជមានលើនយោបាយប្រជាធិបតេយ្យ។ វិស័យមួយដែលនៅក្នុងនោះការទទួលស្គាល់បែបនេះបង្កើតបានជាផ្នែកយ៉ាងសំខាន់មួយនៅក្នុងហិរញ្ញវត្ថុនយោបាយ គឺការធ្វើហិរញ្ញប្បទានសាធារណៈ។ នៅក្នុងករណីភាគច្រើនដែលគេបង្កើតឲ្យមានហិរញ្ញប្បទានសាធារណៈ គឺដើម្បីពង្រឹងតួនាទីជាវិជ្ជមានរបស់គណបក្សនយោបាយ និង ដើម្បីជួយទប់ស្កាត់ការប្រើប្រាស់ថវិកាច្រើនហួសហេតុនៅក្នុងវិស័យនយោបាយ។

ជំពូកនេះនឹងធ្វើការពន្យល់អំពីចំនុចប្លែកៗគ្នាមួយចំនួននៅក្នុងការធ្វើហិរញ្ញប្បទានសាធារណៈនៅក្នុងប្រព័ន្ធនយោបាយពហុបក្ស ហើយនិងបង្ហាញឲ្យឃើញនូវ អនុសាសន៍មួយចំនួនទាក់ទងទៅនឹងអ្វីដែលគេត្រូវពិចារណានៅពេលដែលគេប៉ុនប៉ងធ្វើការកែទម្រង់ហិរញ្ញប្បទានសាធារណៈ។ ការស្រាវជ្រាវនៅក្នុងជំពូកនេះទទួលស្គាល់គម្លាតដ៏ធំក្នុងចំណោមតំបន់ និង ប្រទេសនានា ហើយការស្រាវជ្រាវនេះទៀតសោតក៏គ្មានចេតនាធ្វើការណែនាំឲ្យមានការប្រើប្រាស់ដំណោះស្រាយទោលតែមួយនោះដែរ។ ផ្ទុយមកវិញ ការសិក្សាស្រាវជ្រាវនេះលើកទឹកចិត្តអ្នកធ្វើច្បាប់ និងអ្នកអនុវត្តច្បាប់ទាំងអស់ ឲ្យផ្ដោតការយកចិត្តទុកដាក់លើគោលបំណងទាំងប៉ុន្មានដែលគេចង់ធ្វើឲ្យបានសម្រេចនៅក្នុងប្រព័ន្ធហិរញ្ញប្បទានសាធារណៈនេះ និងប្រើប្រាស់គោលបំនងទាំងនោះជាមគ្គុទេសន៍សម្រាប់ប្រព័ន្ធដែលពួកគេកំពុងតែអនុវត្ត។ ការសិក្សាស្រាវជ្រាវនានាលើការធ្វើហិរញ្ញប្បទានសាធារណៈដល់គណបក្សនយោបាយ និងយុទ្ធនាការឃោសនាបោះឆ្នោតរួមបញ្ចូលតែបណ្ដាប្រទេសជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ហើយជារឿយៗគឺជាប្រទេសដែលប្រជាធិបតេយ្យមានភាពចាស់ទុំ ដោយហេតុថាយើងខ្វះប្រភពព័ត៌មានពីប្រទេសដែលទើបនឹងមានលទ្ធិប្រជាធិបតេយ្យថ្មីថ្មោង និងប្រទេសដែលមិនទទួលស្គាល់របបប្រជាធិបតេយ្យ ។ ទោះជាយ៉ាងណាក៏ដោយ អភិក្រមនេះអាចប្រឈមទៅនឹងការខកខានក្នុងការរួមបញ្ចូលចំនុចសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងបញ្ហានេះ។ ការសិក្សាដដែលខាងលើនេះ ក៏នឹងពិភាក្សាផងដែរអំពីមធ្យោបាយនានា ដែលតាមរយៈមធ្យោបាយទាំងនោះរបបដឹកនាំមួយចំនួនបានព្យាយាមប្រើប្រាស់មូលនិធិសាធារណៈដើម្បីពង្រឹងរបបរបស់ពួកគេ ជាជាងលើកកម្ពស់ប្រព័ន្ធពហុភាពនយោបាយ។

ជាញឹកញាប់ ហិរញ្ញប្បទានសាធារណៈត្រូវបានគេប្រើប្រាស់នៅក្នុងទម្រង់ ផ្សេងៗគ្នាជាច្រើន។ នៅសហរដ្ឋអាមេរិក ទម្រង់"*ប្រហ្វងក៍*" អាចត្រូវបានចាត់ទុកថាជាទម្រង់ដើមមួយនៃការធ្វើហិរញ្ញប្បទានសាធារណៈដែលគេបានដាក់ចេញនៅឆ្នាំ១៧៧៥។ ទោះយ៉ាងណាក៏ដោយ គេគួរតែបញ្ជាក់ថា ការធ្វើហិរញ្ញប្បទានសាធារណៈដល់គណបក្សនយោបាយ និង យុទ្ធនាកាឃោសនាបោះឆ្នោតមិនមែនជាការច្នៃប្រឌិតរបស់ពួកអឺរ៉ុប ឬ អង់គ្លូសាក់សុងនោះទេ ។ ករណីដំបូងៗមួយចំនួនទៀត ពាក់ព័ន្ធនឹងហិរញ្ញប្បទានសាធារណៈសម្រាប់គណបក្សនយោបាយ គឺមាននៅប្រទេសអ៊ុយរុយហ្គាយ កូស្តារីការ និង អាហ្សង់ទីន ក្នុងឆ្នាំ 1928 1954 និង 1959 បន្តបន្ទាប់គ្នា ខណៈដែលអភិក្រមនេះត្រូវបានគេអនុវត្តជាលើកដំបូងនៅទ្វីបអឺរ៉ុប (អាល្លឺម៉ង់ខាងលិច) ក្នុងឆ្នាំ១៩៥៩ ។ ជារួម ហិរញ្ញប្បទានសាធារណៈត្រូវបានគេយកមកប្រើប្រាស់នៅក្នុងប្រទេសភាគច្រើន ជា"ការវិវត្តបែបទំនើបមួយ" បើតាមការបញ្ជាក់អះអាងរបស់ *ណាស្មាឈើរ* (*Nassmacher*) ចំណែកឯប្រទេសមួយចំនួនដែលលទ្ធិប្រជាធិបតេយ្យកំពុងលូតលាស់បានអនុម័តឲ្យមានការ

ប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈតាមបែបណាមួយ ចាប់តាំងពីពេលដែលពួកគេបានចាប់ផ្តើមប្រកាន់យកនយោបាយពហុបក្សមក។ ដោយហេតុថាឥទ្ធិពលនៃកំណែទម្រង់ទាំងនេះមានលក្ខណៈខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត *កាសា ហ្សាម៉ូរា* (Casas-Zamora) យល់ថាការរីករាលដាលនៃប្រព័ន្ធហិរញ្ញប្បទានសាធារណៈជា"និន្នាការដ៏មានសារសំខាន់បំផុតនៅក្នុងវិស័យហិរញ្ញវត្ថុនយោបាយនាពេលបច្ចុប្បន្ននេះ"។

បញ្ហាហិរញ្ញវត្ថុសាធារណៈក៏បានទាក់ទាញចំណាប់អារម្មណ៍កាន់តែច្រើនផងដែរពីអង្គការអន្តរជាតិមួយចំនួន។ តារាង១ខាងក្រោមនេះទាញយកព័ត៌មានពីឯកសារមួយដែលនិយាយអំពី "ដំណោះស្រាយហិរញ្ញប្បទានសាធារណៈសម្រាប់គណបក្សនយោបាយនៅក្នុងបណ្តាប្រទេសដែលមានប្រជាជនមូស្លីមភាគច្រើន" ហើយតារាងនេះក៏បង្ហាញផងដែរអំពីចំណាប់អារម្មណ៍របស់ស្ថាប័នខុសៗគ្នាមួយចំនួនទៅលើតួនាទីនៃហិរញ្ញប្បទានសាធារណៈ។

*តារាង ១៖ អនុសាសន៍ផ្សេងៗស្តីអំពីហិរញ្ញប្បទានសាធារណៈដែលលើកឡើងដោយអង្គការអន្តរជាតិមួយចំនួន*

| អង្គការ (កាលបរិច្ឆេទ) | អនុសាសន៍ |
|---|---|
| ធនាគារពិភពលោក (ឆ្នាំ២០០១) | • ចូរធ្វើការពិចារណាអំពីមូលនិធិសាធារណៈ។ ប្រទេសជាច្រើនបានបង្កើតឲ្យមានផ្នែកខ្លះនៃមូលនិធិសាធារណៈ ដោយពួកគេទទួលស្គាល់ថាគណបក្សនយោបាយដើរតួនាទីយ៉ាងសំខាន់នៅក្នុងផលប្រយោជន៍សាធារណៈ៖ ពោលគឺគណបក្សរួមចំណែកយ៉ាងសំខាន់ក្នុងការប្រកួតប្រជែងផ្នែកនយោបាយ និងការសម្តែងចេញតាមបែបវិមជ្ឈការនូវគុណតម្លៃ និង អត្ថប្រយោជន៍ដែលមានលក្ខណៈចម្រុះ។ ហិរញ្ញប្បទានសាធារណៈកាត់បន្ថយអានុភាពចំពោះផលប្រយោជន៍ឯកជនដែលគេយកទៅប្រើប្រាស់ដើម្បីការ "ទិញឥទ្ធិពល" ហើយក៏អាចជួយជ្រោមជ្រែងថែមទៀតដល់ការអនុវត្តដែនកំណត់ចំណាយ ដោយហេតុថាអ្នកបោះឆ្នោតមិនចង់ឲ្យមានការចំណាយសាធារណៈច្រើនលើសលុបពេកទេ។ |
| ក្រុមប្រឹក្សាអឺរ៉ុប (គណៈកម្មការវេនីស) (ឆ្នាំ២០០២) | • ក្នុងវិស័យហិរញ្ញប្បទានសាធារណៈសម្រាប់គណបក្សនយោបាយ ឬ យុទ្ធនាការឃោសនាបោះឆ្នោត គោលការណ៍សមភាពនៃកាលានុវត្តភាព គឺការអនុវត្តសមភាព "ដោយម៉ត់ចត់" ឬ "សមាមាត្រ"។<br>• គ្រប់គណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភាត្រូវតែមានលក្ខណៈសម្បត្តិក្នុងការទទួលបានហិរញ្ញប្បទានសាធារណៈ។<br>• ហិរញ្ញប្បទានសាធារណៈអាចនឹងលាតសន្ធឹងរហូតដល់ក្រុមនយោបាយនានាដែលមានភាពជាតំណាងមួយភាគធំនៅក្នុងចំណោមអ្នកបោះឆ្នោត ហើយនិងពង្រីករហូតដល់បេក្ខជនឈរឈ្មោះបោះឆ្នោតផងដែរ។<br>• ការផ្តល់ហិរញ្ញវត្ថុពីមូលនិធិសាធារណៈទៅឲ្យគណបក្សនយោបាយត្រូវតែមានការត្រួតពិនិត្យយ៉ាងត្រឹមត្រូវទៅលើគណនីរបស់គណបក្សនយោបាយពីសំណាក់អង្គភាពសាធារណៈជាក់លាក់ណាមួយ។ |
| មូលស្ថាបនាខាតផរ និង អង្គការនៃបណ្តារដ្ឋនៅទ្វីបអាមេរិច (២០០៣) | • គួរតែមានការប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានចម្រុះដែលមានរួមបញ្ចូលទាំងចំណែកសាធារណៈមួយផ្នែកធំ។ មូលនិធិសាធារណៈគួរត្រូវបានផ្តល់សម្រាប់ជំនួសការបំពេញបន្ថែមទៅលើទៅលើមូលនិធិឯកជននៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការបោះឆ្នោត និង នយោបាយ។ ការផ្តល់ហិរញ្ញប្បទានសាធារណៈសម្រាប់ |

| | |
|---|---|
| | សកម្មភាពជាបន្តរបស់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាគួរត្រូវបាន បែងចែកតាមរយៈការរួមបញ្ចូលគ្នារវាងវិធានសមាមាត្រ និង ការឧបត្ថម្ភធនស្មើៗ គ្នាដល់គណបក្សនយោបាយទាំងអស់ដែលបំពេញបានតាមលក្ខខណ្ឌអប្បបរមា សមស្រប។ |
| អង្គការតម្លាភាពអន្តរជាតិ (២០០៥) | • ការពិចារណាដោយម៉ត់ចត់គួរផ្តោតទៅលើអត្ថប្រយោជន៍នៃការធ្វើហិរញ្ញប្បទាន របស់រដ្ឋដល់គណបក្សនយោបាយនិងបេក្ខជន ហើយក៏គួរផ្តោតផងដែរទៅលើ ការជំរុញឲ្យមានការចូលរួមពីប្រជាពលរដ្ឋតាមរយៈការឧបត្ថម្ភតូចៗ និង វិភាគទាន សមាជិកភាព។<br>• ដើម្បីគ្រប់គ្រងតម្រូវការហិរញ្ញវត្ថុនយោបាយ យន្តការមួយចំនួនដូចជាការកំណត់ ដែនចំណាយ និង ការឧបត្ថម្ភធនក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយគួរត្រូវបានគេ ពិចារណា។ |
| ក្រុមប្រឹក្សាអឺរ៉ុប (គណៈកម្មាធិការរដ្ឋមន្ត្រី) (២០០៣) | • រដ្ឋគួរផ្តល់ការឧបត្ថម្ភដល់គណបក្សនយោបាយ។ ការឧបត្ថម្ភរបស់រដ្ឋគួរត្រូវបាន កម្រិតក្នុងបរិមាណមួយសមរម្យ។ ការឧបត្ថម្ភរបស់រដ្ឋអាចជាហិរញ្ញវត្ថុ។<br>• លក្ខណៈវិនិច្ឆ័យដែលមិនទទួលរងឥទ្ធិពលពីខាងក្រៅ មានភាពយុត្តិធម៌ និង សមហេតុផលគួរត្រូវបានយកទៅអនុវត្តនៅពេលធ្វើការបែងចែកជំនួយឧបត្ថម្ភ របស់រដ្ឋ។<br>• រដ្ឋនានាគួរតែធានាឲ្យបានថា ការជួយឧបត្ថម្ភណាមួយក៏ដោយពីរដ្ឋ និង/ឬ ពីពលរដ្ឋនឹងមិនជ្រៀតជ្រែកឯករាជ្យភាពរបស់គណបក្សនយោបាយទេ។ |

## គោលបំណងរបស់ហិរញ្ញប្បទានសាធារណៈ

គ្មានប្រព័ន្ធហិរញ្ញប្បទានសាធារណៈតែមួយរួមគ្នានោះទេ ។ ជារឿយៗគេទទួលស្គាល់ថា ដោយហេតុថា ប្រទេសនីមួយៗមានភាពខុសប្លែកគ្នា ប្រព័ន្ធហិរញ្ញប្បទានសាធារណៈណាមួយក៏ដោយត្រូវតែមានភាពបត់បែនដើម្បី សម្របទៅតាមស្ថានភាពរបស់ប្រទេសនីមួយៗ។ ដោយសារនេះជារឿងពិត វាជាការចាំបាច់ណាស់ដែលហិរញ្ញ - ប្បទានសាធារណៈអាចត្រូវបានដាក់ឲ្យអនុវត្តសម្រាប់ហេតុផលនានាដែលមានលក្ខណៈខុសៗគ្នាយ៉ាងខ្លាំង ហើយ ជាប្រការសំខាន់ ដែលប្រទេសពីរមានស្ថានភាពប្រហាក់ប្រហែលគ្នាត្រូវការប្រព័ន្ធហិរញ្ញប្បទានខុសៗគ្នា ប្រសិន បើប្រទេសទាំងនោះព្យាយាមសម្រេចគោលបំណងខុសគ្នា។ ឧទាហរណ៍៖ នៅក្នុងបណ្តាប្រទេសដែលស្ថិតក្នុងតំបន់ ស្កង់ឌីណាវ (អឺរ៉ុបខាងជើង) សារៈសំខាន់នៃហិរញ្ញប្បទានសាធារណៈដែលគេផ្តោតទៅលើការជួយឧបត្ថម្ភសកម្មភាព របស់គណបក្សនយោបាយក្រៅពីការបោះឆ្នោតនឹងមានភាពផ្ទុយគ្នាស្រឡះនៅក្នុងសហរដ្ឋអាមេរិច ដែលនៅទីនោះ មុខងារសំខាន់របស់គណបក្សនយោបាយគឺការបោះឆ្នោត។ ជាបន្តបន្ទាប់ ប្រទេសនីមួយៗត្រូវតែសម្របការផ្តល់ មូលនិធិណាមួយដល់គណបក្សនយោបាយ ឬ យុទ្ធនាការឃោសនាបោះឆ្នោតទៅតាមធនធានរបស់រដ្ឋដែលរដ្ឋអាច ផ្តល់សម្រាប់ប្រព័ន្ធនយោបាយនិងគណបក្ស ទៅតាមទំហំសេដ្ឋកិច្ចនិងទំនៀមទម្លាប់របស់រដ្ឋនោះ ។ គេក៏ត្រូវតែ ពិចារណាផងដែរទៅលើគោលបំណងនានាដែលគេចង់សម្រេចឲ្យបាន ដោយប្រើប្រាស់ប្រព័ន្ធសមស្របណាមួយ។

ដូច្នេះ គេអាចចោទសួរថា តើអ្វីជាគោលបំនងដែលប្រព័ន្ធហិរញ្ញប្បទានសាធារណៈត្រូវគេរំពឹងជាទូទៅដើម្បីសម្រេចឲ្យបាន? វាអាចនឹងមានប្រយោជន៍ក្នុងការសិក្សាអំពីគោលបំណង និង អត្ថប្រយោជន៍ដែលគេបានពណ៌នានៅក្នុងអត្ថបទថ្មីៗមួយចំនួនដែលពិភាក្សាអំពីហិរញ្ញប្បទានសាធារណៈនៅក្នុងបរិបទភូមិសាស្ត្រខុសៗគ្នា ។

*តារាង ២៖ គោលបំណង និង អត្ថប្រយោជន៍នៃហិរញ្ញប្បទានសាធារណៈ*

| | |
|---|---|
| ណាសស្មាឈ័រ (Nassmacher) | • ជាដំបូង គឺដើម្បីផ្តល់ជូនគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះ នូវធនធានចាំបាច់មួយចំនួនសម្រាប់ការបំពេញមុខងាររបស់ពួកគេ ដើម្បីលើកកម្ពស់សមភាពរបស់គណបក្សនិងបេក្ខជនទាំងនោះក្នុងការទទួលបាន និង ប្រើប្រាស់ធនធាន និងដើម្បីធ្វើការកែតម្រូវសិទ្ធិពិសេសណាមួយដែលអាចនាំឲ្យប៉ះពាល់ដល់សមភាពនោះ។<br>• បន្ទាប់មក គឺដើម្បីលើកកម្ពស់ និងជំរុញឲ្យមានការចូលរួម និង ការជាប់ពាក់ព័ន្ធរបស់ពលរដ្ឋ តាមរយៈការផ្តល់មូលនិធិឯកជន និងការសម្រេចឲ្យបានជាអតិបរមានូវឥទ្ធិពលរបស់សង្គមស៊ីវិលក្នុងវិស័យនយោបាយ។ វត្ថុបំណងនេះ ក៏បានដាក់ដែនកំណត់ផងដែរទៅលើចំនួនទឹកប្រាក់ និង ទម្រង់នៃការផ្តល់វិភាគទានពីសំណាក់បុគ្គលឯកជន។ |
| ភីលដាត (Pildat) | • ដោយសារតែគណបក្សនយោបាយត្រូវបានគេមើលឃើញថាជាស្ថាប័ននយោបាយដ៏សំខាន់នៅក្នុងលទ្ធិប្រជាធិបតេយ្យសម័យទំនើប [រដ្ឋគួរផ្តល់ការគាំទ្រដល់ពួកគេ] ក្នុងគោលបំណងសម្របសម្រួល ឬ ធានាអត្ថិភាពរបស់គណបក្សនយោបាយ។<br>• [ដូចគ្នានេះផងដែរ] រដ្ឋគួរតែផ្តល់ឱកាសស្មើភាពគ្នា យុត្តិធម៌ និងសមភាពសម្រាប់ការប្រកួតប្រជែងនយោបាយប្រកបដោយភាពស្វិតស្វាញ...។<br>• ... ដើម្បីឲ្យមានបរិយាកាសនយោបាយមួយរឹងមាំ ... ធនធានមួយចំនួនត្រូវបានផ្តល់ដល់គណបក្សនយោបាយ... ដើម្បីសម្របសម្រួលឲ្យទីលានប្រកួតប្រជែងកាន់តែមានលក្ខណៈស្មើភាពគ្នា តាមរយៈការជំរុញឲ្យគណបក្សដែលទើបបង្កើតថ្មី គណបក្សតូចៗ ... ចូលរួមប្រកួតប្រជែង ជាមួយគណបក្សធំៗ ឬ គណបក្សដែលមានធនធានច្រើន។<br>• [លើសពីនេះទៅទៀត] គឺជាបំណងក្នុងការទប់ស្កាត់ឥទ្ធិពលនៃហិរញ្ញវត្ថុឯកជន និង និងរិតត្បិតទៅលើសក្តានុពលរបស់ហិរញ្ញវត្ថុឯកជននោះ ដែលនាំឲ្យប្រាស់ចាកដំណើរការនយោបាយបែបប្រជាធិបតេយ្យ។ |
| អង្គការអាយហ្វេស (IFES) | • ហិរញ្ញប្បទានសាធារណៈ អាចជួយពង្រឹងស្វ័យភាពរបស់អ្នកនយោបាយ ជួយទប់ស្កាត់អំពើពុករលួយដែលទាក់ទងនឹងហិរញ្ញវត្ថុនយោបាយ និងជួយពង្រឹងឲ្យមានតម្លាភាពហិរញ្ញវត្ថុ។<br>• ហិរញ្ញប្បទានសាធារណៈអាចជួយការពារសមភាពផ្នែកនយោបាយនៃឱកាស និងការប្រកួតប្រជែងក្នុងការបោះឆ្នោត។<br>• ហិរញ្ញប្បទានសាធារណៈ អាចផ្តល់ឲ្យតួអង្គនយោបាយនូវធនធានគ្រប់គ្រាន់សម្រាប់សកម្មភាពប្រជាធិបតេយ្យសំខាន់ៗមួយចំនួន ដោយបានជួយបង្កើនស្ថាប័នភាវូបនីយកម្ម និង ស្ថេរភាពរបស់គណបក្សនយោបាយ។ |

| | |
|---|---|
| | • ហិរញ្ញប្បទានសាធារណៈ អាចជាឧបករណ៍ដ៏មានអំណាចមួយក្នុងការធានាឲ្យមានការគោរពបទប្បញ្ញត្តិផ្សេងៗទៀតស្តីអំពីហិរញ្ញវត្ថុនយោបាយ។ |
| កាសា-ហ្សាម៉ូរ៉ា (Casas-Zamora) | • [ហិរញ្ញប្បទានសាធារណៈ] ជួយពង្រឹងស្វ័យភាពរបស់អ្នកនយោបាយ បង្ការអំពើពុករលួយទាក់ទងនឹងហិរញ្ញវត្ថុនយោបាយ និងលើកកម្ពស់តម្លាភាពហិរញ្ញវត្ថុ។<br>• [ហិរញ្ញប្បទានសាធារណៈ]ជួយការពារឲ្យមានសមភាពនៃឱកាស និង ការប្រកួតប្រជែងនៅក្នុងការបោះឆ្នោត។<br>• [ហិរញ្ញប្បទានសាធារណៈ]ផ្តល់ឲ្យតួអង្គនយោបាយនូវធនធានគ្រប់គ្រាន់សម្រាប់សកម្មភាពប្រជាធិបតេយ្យសំខាន់ៗមួយចំនួន ដែលនឹងបង្កើនស្ថាប័នភាវូបនីយកម្ម និង ស្ថេរភាពរបស់គណបក្សនយោបាយ។ |
| គណៈកម្មាធិការចម្រុះនៃសភាប្រទេសអូស្ត្រាលី | • ហិរញ្ញប្បទានសាធារណៈលុបបំបាត់ភាពចាំបាច់ ឬ ការប៉ុនប៉ងក្នុងការស្វែងរកប្រភពមូលនិធិដែលអាចភ្ជាប់ទៅដោយលក្ខខណ្ឌ។<br>• ហិរញ្ញប្បទានសាធារណៈជួយគណបក្សនយោបាយឆ្លើយតបទៅនឹងការចំណាយក្នុងយុទ្ធនាការឃោសនាដែលចេះតែមានការកើនឡើង។<br>• ហិរញ្ញប្បទានសាធារណៈជួយគណបក្សដែលទើបនឹងបង្កើតថ្មី និងក្រុមដែលមានផលប្រយោជន៍ពាក់ព័ន្ធចូលរួមប្រកួតប្រជែងប្រកបដោយប្រសិទ្ធិភាពនៅក្នុងការបោះឆ្នោត។<br>• ហិរញ្ញប្បទានសាធារណៈអាចនឹងជួយសម្រួលគណបក្សនយោបាយពី "ការរៃអង្គាសថវិកាជាប្រចាំ" សម្រាប់ការឃោសនា។ ដូច្នេះគណបក្សទាំងនោះអាចផ្តោតការយកចិត្តទុកដាក់របស់ខ្លួនទៅលើបញ្ហាគោលនយោបាយ និង ដំណោះស្រាយ។<br>• ហិរញ្ញប្បទានសាធារណៈជួយធានាឲ្យបានថាគ្មានអ្នកចូលរួមប្រកួតប្រជែងណាម្នាក់ ... ជួបឧបសគ្គនៅក្នុងការអំពាវនាវទៅកាន់អ្នកបោះឆ្នោតឲ្យគាំទ្រខ្លួន ឬ សកម្មភាពរបស់ខ្លួនដោយហេតុតែកង្វះលទ្ធភាពក្នុងការទទួលបានមូលនិធិគ្រប់គ្រាន់នោះឡើយ។ |
| សហគមន៍អភិវឌ្ឍន៍ទ្វីបអាហ្វ្រិកភាគខាងត្បូង (SADC) | • [ការផ្តល់ហិរញ្ញប្បទានមានសារៈសំខាន់ណាស់ដោយសារតែ] គណបក្សនយោបាយភាគច្រើនមិនសូវមានធនធាន។<br>• ការផ្តល់ហិរញ្ញប្បទានគួរត្រូវបានដាក់ឲ្យអនុវត្តដើម្បីលើកកម្ពស់សមភាព និងធ្វើឲ្យទីលានប្រកួតប្រជែងមានលក្ខណៈស្មើភាពគ្នា។ |

ការពិភាក្សាខាងលើ និង ការពិភាក្សាដទៃៗទៀតស្តីអំពីហិរញ្ញប្បទានសាធារណៈ អនុញ្ញាតឲ្យយើងកំនត់បាននូវគោលបំណងធំៗនៃប្រព័ន្ធហិរញ្ញប្បទានសាធារណៈ (ដោយមិនរៀបតាមលំដាប់) ដូចខាងក្រោម៖

- បង្កើនសមត្ថភាពគណបក្សនយោបាយ និង បេក្ខជនក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកបោះឆ្នោត ដែលអនុញ្ញាតឲ្យអ្នកបោះឆ្នោតធ្វើការជ្រើសរើសប្រកបដោយព័ត៌មានគ្រប់គ្រាន់ (គោលបំណងរយៈពេលខ្លី)។
- ធ្វើឲ្យទីលានប្រកួតប្រជែងមានសមភាពរវាងគណបក្សនយោបាយ និង រវាងបេក្ខជនដែលធនធានរបស់ពួកគេមានកម្រិតខុសៗគ្នា (គោលបំណងសម្រាប់ការបោះឆ្នោត)។
- បង្កើនស្ថាប័នភាវូបនីយកម្មរបស់គណបក្សនយោបាយ (គោលបំណងរយៈពេលវែង)។
- កាត់បន្ថយអំពើពុករលួយនយោបាយ (ជាពិសេសគឺកាត់បន្ថយការពឹងផ្អែករបស់អ្នកនយោបាយទៅលើអ្នកផ្តល់ជំនួយដែលមានឥទ្ធិពល)។

- កាត់បន្ថយតួនាទីរបស់ហិរញ្ញវត្ថុនៅក្នុងនយោបាយ (ទោះជាលុយពុករលួយ ឬយ៉ាងណានោះទេ)
- ប្រើប្រាស់ហិរញ្ញប្បទានសាធារណៈដើម្បីបង្កើតឥទ្ធិពលទៅលើឥរិយាបថរបស់គណបក្សនយោបាយ (ដែលពាក់ព័ន្ធទៅនឹងតម្លាភាពហិរញ្ញវត្ថុ សមភាពយេនឌ័រ និង ក្រុមដែលមានសម្លេងភាគតិច។ល។)

គោលបំណងជា ច្រើន នៅក្នុងគោលបំណងទាំងប៉ុន្មានខាងលើនេះ មានការជាប់ពាក់ព័ន្ធគ្នាទៅវិញទៅមក ក៏ប៉ុន្តែកិច្ចខំប្រឹងប្រែងដើម្បីធ្វើឲ្យសម្រេចគោលបំណងទាំងនោះ អាចនឹងមានភាពប្រទាំងប្រទើសគ្នា។ ឧទាហរណ៍៖ ការផ្តល់ថវិការយ៉ាងច្រើនដល់អ្នកចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតទាំងអស់ អាចនឹងផ្តល់ឱកាសបន្ថែមដល់អ្នកទាំងនោះក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកបោះឆ្នោត ក៏ប៉ុន្តែការធ្វើបែបនេះក៏អាចធ្វើឲ្យប្រេះស្រាំដល់ប្រព័ន្ធគណបក្សផងដែរ ដែលជាហេតុធ្វើឲ្យមានការរអាក់រអួលដល់ដំណើរការស្ថាប័នភាវូបនីយកម្មរបស់គណបក្សនយោ-បាយ។ ក្នុងការធ្វើសេចក្តីសន្និដ្ឋានលើកិច្ចពិភាក្សាស្តីពីគោលបំណងនៃប្រព័ន្ធហិរញ្ញប្បទានសាធារណៈដូចខាងលើ យើងអាចធ្វើការកត់សម្គាល់ថា គេអាចមានលទ្ធភាពក្នុងការបង្កើតរចនាសម្ព័ន្ធនានាដែលអាចដោះស្រាយភាពចន្លោះប្រហោងដែលគេអាចមើលឃើញជាមុន នៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនយោបាយដែលមានស្រាប់ ក៏ប៉ុន្តែគេមិនគួរប៉ុនប៉ងធ្វើអ្វីៗគ្រប់បែបយ៉ាងនៅពេលតែមួយនោះទេ។

## តើមានប្រទេសណាខ្លះដែលប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈ?

សំនួរដំបូងបំផុតដែលនឹងត្រូវឆ្លើយនោះគឺថា តើយន្តការហិរញ្ញប្បទានសាធារណៈមានការប្រើប្រាស់ទូលំទូលាយប៉ុនណា? ក្នុងចំណោមសមាជិកអង្គការសហប្រជាជាតិចំនួន 183 ប្រទេស ដែលតាមផ្លូវច្បាប់ប្រកាន់យកប្រព័ន្ធនយោបាយពហុបក្ស មានប្រទេសចំនួន 174 ដែលមានព័ត៌មានទាក់ទងទៅនឹងហិរញ្ញប្បទានសាធារណៈដោយផ្ទាល់។ 58% នៃប្រទេសទាំងនេះបានបង្កើតឲ្យមានបទប្បញ្ញត្តិដែលបានចែងអំពីហិរញ្ញប្បទានសាធារណៈដោយផ្ទាល់ទៅឲ្យគណបក្សនយោបាយ ក្នុងទម្រង់ណាមួយ។

សំនួរបន្ទាប់គឺ ហេតុអ្វីបានជាមានប្រទេសខ្លះប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈ ហើយប្រទេសខ្លះទៀតមិនប្រើប្រាស់? គេមិនដែលបង្កើតគោលនយោបាយដាច់ដោយឡែកៗពីគ្នានោះទេ ហើយករណីនេះគឺជាការពិតចំពោះអ្វីដែលពាក់ព័ន្ធទៅនឹងវិធាននានាដែលកំណត់អំពីការប្រកួតប្រជែងនយោបាយ។ មានការប៉ុនប៉ងតិចតួចប៉ុណ្ណោះក្នុងការស្វែងយល់អំពីកត្តានានាដែលពន្យល់អំពីមូលហេតុដែលប្រទេសខ្លះប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈ រីឯប្រទេសខ្លះទៀតមិនប្រើប្រាស់ ។ លោក *ពីនតូ-ឌូសឈីនស្គី* (Pinto-Duschinsky) បានធ្វើការកត់សម្គាល់ថាបណ្តាប្រទេសនៅក្នុងសហគមន៍ខំមិនវែល និងរដ្ឋតូចៗ ហាក់ដូចជាមិនសូវប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈទេ ខណៈដែលមានប្រទេសមួយចំនួនទៀតដែលប្រើប្រាស់ប្រព័ន្ធបោះឆ្នោតបែបសមាមាត្រ ទំនងជាប្រើប្រាស់ប្រព័ន្ធនេះច្រើន។ *អ៊ីកស្វែន អេ អាល់* (Iksens et al) បានអះអាងថា ដំណើរការភាវូបនីយកម្មរបស់រដ្ឋអាចជាការអស់ឯកក្នុងការដាក់ចេញឲ្យមានការប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈនៅអឺរ៉ុបកណ្តាល និង អឺរ៉ុបខាងកើត ចំណែកឯលោក *ណាស្មាឈ័រ* វិញយល់ថា ភាពស្ទាក់ស្ទើរនេះគឺដោយសារតែការប្រកាន់យករបបកុម្មុយនីស្តរបស់ប្រទេសទាំងនោះកាលពីអតីតកាល។

មានការលើកឡើង នៅក្នុងបុព្វកថានៃការសិក្សាស្រាវជ្រាវនេះថា ការស្វែងយល់ឲ្យបានគ្រប់ជ្រុងជ្រោយទៅលើបញ្ហាហិរញ្ញប្បទានសាធារណៈតម្រូវឲ្យមានការសិក្សាស្រាវជ្រាវទៅលើគ្រប់ប្រទេសទាំងអស់ ពោលគឺមិនមែនសិក្សាត្រឹមតែទៅលើប្រទេសប្រជាធិបតេយ្យប៉ុណ្ណោះទេ។ ពិតណាស់ ការប្រើប្រាស់ជំនួយឧបត្ថម្ភពីរដ្ឋសម្រាប់គណបក្សនយោបាយមិនមែនជារឿងផ្តាច់មុខរបស់ប្រទេសប្រជាធិបតេយ្យនោះទេ។ ដោយសារតែក្រុមប្រទេសដែលប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈរួមមានទាំងប្រទេសសេរីជាងនិងទាំងប្រទេសមិនសូវសេរី ជាងក្រុមប្រទេសដែលមិនប្រើប្រាស់ប្រព័ន្ធនេះ (បើយោងតាមការដាក់ពិន្ទុរបស់អង្គការ *ហ្វ្រីដឹម ហៅស៍* (*Freedom House*)) គំលាតផ្នែកស្ថិតិមានភាពខុសគ្នាតែបន្តិចបន្តួចប៉ុណ្ណោះ។

វាជាការសមហេតុផលក្នុងការសន្មត់ថាហិរញ្ញប្បទានសាធារណៈអាចនឹងមានការជាប់ពាក់ព័ន្ធទៅនឹងកម្រិតទូទៅនៃអំពើពុករលួយ។ អ្នកនយោបាយពុករលួយប្រហែលជាចង់ចៀសវាងប្រព័ន្ធហិរញ្ញប្បទានសាធារណៈ ដូចដែល*អ៊ីកស្វែន អេ អាល់* បានលើកឡើងដូចខាងលើ ឬពួកគេអាចនឹងប្រើប្រាស់ហិរញ្ញប្បទានសាធារណៈដើម្បីឧបត្ថម្ភគណបក្សនយោបាយ ឬ យុទ្ធនាការឃោសនារបស់ពួកគេ ។ ជាអកុសល គេមានការលំបាកក្រៃលែងក្នុងការវាស់វែងអំពើពុករលួយ ក៏ប៉ុន្តែយើងអាចកត់ចំណាំបានថា ពុំមានការជាប់ពាក់ព័ន្ធគ្នាគួរឲ្យកត់សម្គាល់ជាលក្ខណៈស្ថិតិរវាងការផ្តល់ហិរញ្ញប្បទានសាធារណៈដោយផ្ទាល់ដល់គណបក្សនយោបាយ និង ពិន្ទុរបស់ប្រទេសនីមួយៗកាលពីឆ្នាំ២០០៨ ដែលមានបង្ហាញនៅក្នុងតារាងសន្ទស្សន៍របស់ *អង្គការតម្លាភាពអន្តរជាតិ*។

ទោះជាយ៉ាងណាក៏ដោយ ក៏អំណះអំណាង របស់លោក *ពីនតូ-ឌូសឈីនស្គី (Pinto-Duschinsky)* ដែលបានលើកឡើងថា មានការជាប់ពាក់ព័ន្ធគ្នារវាងហិរញ្ញប្បទានសាធារណៈរបស់គណបក្សនយោបាយ និងប្រព័ន្ធបោះឆ្នោតត្រូវបានទទួលការគាំទ្រពីទិន្នន័យសាកលថ្មីៗមួយចំនួន។ មានប្រទេសតិចជាង១ភាគ៣ប៉ុណ្ណោះក្នុងចំណោមប្រទេសដែលប្រើប្រាស់ប្រព័ន្ធបោះឆ្នោតឯកត្តនាមដែលអនុវត្តប្រព័ន្ធហិរញ្ញប្បទានសាធារណៈ ខណៈដែលជិត៨៥%នៃប្រទេសដែលប្រើប្រាស់ប្រព័ន្ធបោះឆ្នោតសមាមាត្រអនុវត្តប្រព័ន្ធហិរញ្ញប្បទានសាធារណៈ។ ការពន្យល់បកស្រាយអំពីទំនាក់ទំនងនេះតម្រូវឲ្យមានការសិក្សាស្រាវជ្រាវថែមទៀត ក៏ប៉ុន្តែកត្តាដែលបង្កប់ខាងក្នុងនៃវប្បធម៌នយោបាយដែលជាប់ពាក់ព័ន្ធទៅនឹងសារៈសំខាន់ដែលគេបានផ្តល់ទៅឲ្យគណបក្សនយោបាយ ទំនងជាមានភាពចាំបាច់ជាពិសេសសម្រាប់ទាំងជម្រើសនៃប្រព័ន្ធបោះឆ្នោត និង ជម្រើសនៃទម្រង់ហិរញ្ញប្បទាន ។

តារាងខាងក្រោមនេះ បង្ហាញអំពីវិភាគទានហិរញ្ញប្បទានសាធារណៈរបស់ប្រទេសនានានៅក្នុងតំបន់ខុសៗគ្នា ដែលប្រើប្រាស់ហិរញ្ញប្បទានសាធារណៈដោយផ្ទាល់ ។

*តារាង ៣៖ ការប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈនៅក្នុងតំបន់ខុសៗគ្នា*

| តំបន់/ទ្វីប | វិភាគទានរបស់រដ្ឋដែលប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានដោយផ្ទាល់សម្រាប់គណបក្សនយោបាយ |
|---|---|
| អាមេរិក | 53% |
| អាហ្វ្រិក | 50% |
| អូស្ត្រា-អាស៊ី | 41% |
| អឺរ៉ុប | 89% |
| មជ្ឈឹមបូព៌ា | 38% |

## ទិដ្ឋភាពរួមស្ដីអំពីប្រព័ន្ធនៃការបែងចែកហិរញ្ញប្បទានសាធារណៈ

មានវិធីជាច្រើនក្នុងការបែងចែកហិរញ្ញប្បទានសាធារណៈ។ ការសិក្សានេះនឹងពិភាក្សាដោយសង្ខេបលើកត្តាចំនួន 7 ដែលគេត្រូវធ្វើការពិចារណា ដូចដែលគេបានបង្ហាញនៅក្នុងរូបភាពខាងក្រោមនេះ។




### 1. *អ្នកផ្ដល់មូលនិធិ*

ក្នុងប្រទេសជាច្រើន ការបែងចែក និង ការចាត់ចែងហិរញ្ញប្បទានសាធារណៈស្ថិតនៅក្រោមការគ្រប់គ្រងពីសំណាក់អង្គភាពគ្រប់គ្រងការបោះឆ្នោត។ តាមពិត ក្នុងប្រទេសមួយចំនួន (ដែលការគ្រប់គ្រងជាក់ស្ដែងទៅលើការបោះឆ្នោតគឺជាការទទួលខុសត្រូវយ៉ាងទូលំទូលាយរបស់ស្ថាប័ននៅតាមតំបន់) ការគ្រប់គ្រងបញ្ហាហិរញ្ញវត្ថុនយោបាយ គឺជាភារៈកិច្ចមួយក្នុងចំណោមភារកិច្ចម្យ៉ាងៗរបស់គណៈកម្មការបោះឆ្នោត (ដូចជាសហរដ្ឋអាមេរិកជាដើម)។ ក្នុងករណីដទៃទៀត ក្រសួងហិរញ្ញវត្ថុ ឬ ក្រសួងដែលទទួលបន្ទុកវិស័យរដ្ឋបាលជាអ្នកទទួលខុសត្រូវ ចំណែកឯ នៅប្រទេសស៊ុយអែតវិញ ក្រុមប្រឹក្សាពិសេសមួយនៃអង្គចៅក្រមដែលត្រូវបានតែងតាំងដោយរដ្ឋសភា គឺជាអ្នកចាត់ចែងការផ្ដល់ហិរញ្ញប្បទានសាធារណៈ។ នៅក្នុង ប្រទេសអាល្លឺម៉ង់ ការគណនាថវិកាដែលត្រូវបែងចែកឲ្យគណបក្សនយោបាយនីមួយៗ គឺជាការទទួលខុសត្រូវរបស់ប្រធានរដ្ឋសភា (សភា*ប៊ុនដេស្តាក*)។

ប្រសិនបើវិធានដែលកំណត់អំពីការផ្ដល់ហិរញ្ញប្បទានសាធារណៈឲ្យគណបក្សនយោបាយ និង/ឬ បេក្ខជនមានភាពច្បាស់លាស់ ការគ្រប់គ្រងប្រព័ន្ធហិរញ្ញប្បទានសាធារណៈគួរតែផ្ទុកផ្ដាក់ការទាមទារមួយចំនួនតូចប៉ុណ្ណោះទៅលើស្ថាប័នដែលត្រូវទទួលខុសត្រូវ។ កង្វល់ចំបងនោះគឺ កាលណាអ្នកនយោបាយត្រូវបានគេផ្ដល់សិទ្ធិអំណាចពិសេសក្នុងការធ្វើសេចក្ដីសម្រេចចិត្តទៅលើចំនួនទឹកប្រាក់ដែលត្រូវបែងចែកតាមបក្សនីមួយៗ ប្រព័ន្ធនោះនឹង "បើកចំហរឲ្យមានការគ្រប់គ្រងដោយមិនសុចរិតក្នុងរយៈពេលខ្លី និងការកើនឡើងយ៉ាងឆាប់រហ័ស"។ ផ្ទុយទៅវិញ ប្រសិនបើការបែងចែកហិរញ្ញប្បទានសាធារណៈទៅឲ្យគណបក្សនយោបាយ និង/ឬ យុទ្ធនាការឃោសនាបោះឆ្នោតត្រូវបានធ្វើឡើងដោយភ្ជាប់ជាមួយតម្រូវការបើកចំហរព័ត៌មាននិងដែនកំណត់ទៅលើការចំណាយឬការធ្វើវិភាគទាន វាក្លាយជាការចាំបាច់ដែលស្ថាប័នគ្រប់គ្រងហិរញ្ញប្បទានសាធារណៈមានទាំងសមត្ថភាព និងឯករាជ្យភាពពិតប្រាកដ ។

ដើម្បីភ្ជាប់ទៅនឹងការពិភាក្សាអំពីគោលបំនងខាងលើ ប្រសិនបើគោលបំណងនៃហិរញ្ញប្បទានសាធារណៈគឺដើម្បីពង្រឹងសមត្ថភាពរបស់គណបក្សនយោបាយ តាមរយៈការផ្ដល់ឲ្យពួកគេនូវមូលនិធិបន្ថែមទៀត ការគ្រប់គ្រងហិរញ្ញប្បទាននោះអាចធ្វើឡើងយ៉ាងសាមញ្ញ។ ផ្ទុយទៅវិញ ប្រសិនបើគោលបំណងនៃហិរញ្ញប្បទានសាធារណៈផ្ដោតទៅលើការកាត់បន្ថយអំពើពុករលួយក្នុងមជ្ឈដ្ឋាននយោបាយ នោះហិរញ្ញប្បទានសាធារណៈយ៉ាងហោច

ណាស់ចាំបាច់ត្រូវភ្ជាប់ជាមួយតម្រូវការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ពេលនោះហើយដែលបញ្ញត្តិករហិរញ្ញវត្ថុនយោបាយត្រូវធ្វើកិច្ចការច្រើនថែមទៀត។ ប្រសិនបើគោលបំនងហិរញ្ញប្បទានសាធារណៈគឺដើម្បីកាត់បន្ថយចំណាយជារូមសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ការធ្វើសេចក្តីសម្រេចចិត្តទៅលើចំនួនទឹកប្រាក់ដែលបែងចែកទៅឲ្យគណបក្សនយោបាយឬបេក្ខជន មិនគួរស្ថិតនៅក្រោមអ្នកនយោបាយឡើយ។

*តារាង ៤៖ ប្រភេទស្ថាប័នទទួលបន្ទុកបែងចែកហិរញ្ញប្បទានសាធារណៈ*

| ប្រភេទស្ថាប័ន | យោបល់ទៅលើប្រភេទស្ថាប័ន | ឧទាហរណ៍ |
|---|---|---|
| អង្គភាពគ្រប់គ្រងការបោះឆ្នោត | ទម្រង់នេះអាចបង្កើតបានជាផ្នែកទូទៅមួយនៃការគ្រប់គ្រងការបោះឆ្នោត ប៉ុន្តែវាក៏អាចខុសគ្នាទៅនឹងការរៀបចំការបោះឆ្នោតជាក់ស្តែងផងដែរ។ | ប្រទេសកេនយ៉ា សហរដ្ឋអាមេរិច |
| ស្ថាប័នសភា/ស្ថាប័នរដ្ឋបាល | ទម្រង់នេះប្រហែលជាអាចសមស្រប ប្រសិនបើជាការផ្តល់ហិរញ្ញប្បទានសាធារណៈដល់គណបក្សនយោបាយការងារដែលគេបានធ្វើជាយូរមកហើយ និង គ្មានភាពចម្រូងចម្រាស់។ | អាល្លឺម៉ង់ អាល់បានី និង កាម៉េរូន |

## 2. លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលហិរញ្ញប្បទានសាធារណៈ

ចម្ងល់មួយទៀតដែលគេត្រូវឆ្លើយគឺ តើគណបក្សនយោបាយ និង បេក្ខជនប្រភេទណាដែលសក្តិសមនឹងទទួលហិរញ្ញប្បទានសាធារណៈ។ ដំណោះស្រាយដែលស្មើភាពគ្នាបំផុតគឺ ការផ្តល់ហិរញ្ញប្បទានទៅឲ្យ គណបក្សទាំងអស់ដែលបានចុះបញ្ជី និង បេក្ខជនទាំងអស់ដែលឈរឈ្មោះបោះឆ្នោត ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើបែបនេះត្រូវការចំណាយច្រើនណាស់ (ជាឧទាហរណ៍ នៅចក្រភពអង់គ្លេស កាលពីឆ្នាំ 2009 គណបក្សដែលបានចុះបញ្ជីមានចំនួន 385 គណបក្ស)។

ករណីដូចខាងលើនេះក៏អាចជម្រុញឲ្យមានការបង្កើតគណបក្សនយោបាយថ្មីៗ ក្នុងគោលបំណងតែមួយគត់គឺដើម្បីទទួលបានហិរញ្ញប្បទានសាធារណៈដែរ ដែលមិនបានបង្កភាពងាយស្រួលសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិប - តេយ្យនោះទេ។ ឧទាហរណ៍ នៅឯ សន្និសិទជាតិឆ្នាំ 1990 ក្នុងប្រទេសហ្កាបុង គណៈប្រតិភូនានាត្រូវបានអញ្ជើញឲ្យចូលរួមបង្កើតគណបក្សនយោបាយ ដែលនឹងទទួលបានជំនួយពីរដ្ឋាភិបាល ។ គណបក្សចំនួន៧០ត្រូវបានបង្កើតឡើងដោយខ្លួនឯង។ គណបក្សនីមួយៗទទួលបានប្រាក់ប្រមាណជា ៣៨៧០០ ដុល្លារអាមេរិក និងរថយន្តប្រភេទទំនើបមួយគ្រឿងសម្រាប់ធ្វើយុទ្ធនាការឃោសនាបោះឆ្នោត។ ភាគច្រើននៃគណបក្សទាំងនោះបាត់មុខពីការបោះឆ្នោតបន្ទាប់ពីទទួលបានហិរញ្ញប្បទានពីរដ្ឋ ហើយគេមិនដែលឃើញគណបក្សទាំងនោះលេចមុខសាជាថ្មីទេ។

ហេតុដូច្នេះហើយ បានជា ប្រទេសភាគច្រើនដែលប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈ បានដាក់ចេញនូវលក្ខខណ្ឌអប្បរមាសម្រាប់គណបក្សក្នុងការទទួលហិរញ្ញប្បទានសាធារណៈ។ លក្ខខណ្ឌអប្បបរមានេះអាចនឹងផាត់ចេញនូវគណបក្សណាដែលគ្មានអាសនៈក្នុងសភា ឬគណបក្សណាដែលទទួលបានសម្លេងគាំទ្រតិចជាងចំនួនជាក់លាក់ណាមួយនៃអាសនៈដែលគេបានកំនត់ ។ ជម្រើសមួយទៀត (សម្រាប់ការផ្តល់ហិរញ្ញប្បទានដល់យុទ្ធនាការឃោសនា) គឺការតម្រូវឲ្យគណបក្សនយោបាយ ឬ បេក្ខជនត្រូវទទួលបានសម្លេងឆ្នោតក្នុងចំនួនជាក់លាក់ណាមួយ ឬបានដាក់ពង្រាយបេក្ខជនឈរឈ្មោះក្នុងចំនួនជាក់លាក់ណាមួយ។ បែបផែនពិសេសមួយត្រូវបានគេអនុវត្តនៅ

ចក្រភពអង់គ្លេស ដែលមានតែគណបក្សប្រឆាំងតែប៉ុណ្ណោះដែលត្រូវទទួលបាន "ថវិកាបន្ថែមក្នុងមុខងារជាតំណាងរាស្ត្រ (Short Money)" ដែលជាផ្នែកមួយនៃហិរញ្ញប្បទានសាធារណៈ។ ប្រទេសអាហ្វ្រិកខាងត្បូង ក៏បានអនុវត្តទម្រង់មួយខុសប្លែកពីគេដែរក្នុងការកំណត់លក្ខណៈសម្បត្តិដើម្បីទទួលបានហិរញ្ញប្បទានសាធារណៈមុនពេលបោះឆ្នោតដែលគេបានធ្វើក្នុងឆ្នាំ១៩៩៤ (ដែលជាការបោះឆ្នោតលើកដំបូងបំផុតក្រោយរបបប្រកាន់ពូជសាសន៍អាប៉ាថេត) ដែលតាមរយៈទម្រង់នោះ គណបក្សនយោបាយចាំបាច់ត្រូវបង្ហាញថា គេបានទទួលសម្លេងគាំទ្រយ៉ាងហោចណាស់២% នៅក្នុងការបោះឆ្នោតស្ទង់មតិមួយ "ដែលគេអាចជឿទុកចិត្តបាន" ឬ បានប្រមូលហត្ថលេខាគាំទ្រក្នុងចំនួនជាក់លាក់ណាមួយ។

*តារាង ៥៖ ប្រភេទលក្ខណៈវិនិច្ឆ័យដែលកំណត់អំពីលក្ខណៈសម្បត្តិសម្រាប់ទទួលហិរញ្ញប្បទានសាធារណៈ*

| ប្រភេទលក្ខណៈវិនិច្ឆ័យ | យោបល់ | ឧទាហរណ៍ |
|---|---|---|
| ភាគរយនៃសម្លេងឆ្នោតដែលបានទទួល | ក្នុងការបោះឆ្នោតពីលើកមុន ឬនៅក្នុងការបោះឆ្នោតដែលការផ្តល់ហិរញ្ញប្បទានត្រូវបានធ្វើ (ចំពោះទម្រង់ខាងក្រោយនេះ ការផ្តល់ហិរញ្ញប្បទានអាចធ្វើទៅបានតាមរបៀបទូទាត់ជាក្រោយ)។ | ប្រទេសទួគី ស៊ុយអែត និង អាល្លឺម៉ង់ |
| ចំនួនអសនៈដែលបានឈ្នះនៅក្នុងស្ថាប័នដែលកើតចេញពីការបោះឆ្នោត | ក្នុងការបោះឆ្នោតពីលើកមុន ឬនៅក្នុងការបោះឆ្នោតដែលការផ្តល់ហិរញ្ញប្បទានត្រូវបានធ្វើ (ចំពោះទម្រង់ខាងក្រោយនេះ ការផ្តល់ហិរញ្ញប្បទានអាចធ្វើទៅបានតាមរបៀបទូទាត់ជាក្រោយ)។ | ចក្រភពអង់គ្លេស ហ្វាំងឡង់ និង ហូឡង់ |

បញ្ហាមួយទៀតគឺថា តើគណបក្សនយោបាយគួរបន្តទទួលហិរញ្ញប្បទានសាធារណៈក្នុងរយៈពេលជាក់លាក់ទៀតឬទេបន្ទាប់ពីគណបក្សទាំងនោះលែងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួល (ជាពិសេស គឺ ក្រោយពីគណបក្សណាមួយបរាជ័យក្នុងការកាន់កាប់អសនៈមួយចំនួននៅក្នុងសភា)។ សម្រាប់ករណីនេះ គេគួរតែផ្តល់ឱកាសដល់គណបក្សទាំងនោះក្នុងការរៀបចំខ្លួនសាជាថ្មី និង ក្នុងការត្រឡប់ទៅកាន់សភាវិញ ប្រសិនបើគណបក្សនោះអាចបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឲ្យគាំទ្រខ្លួននៅពេលបោះឆ្នោតក្រោយៗទៀត។ នៅប្រទេសស៊ុយអែត គណបក្សនយោបាយ ដែលបានចាកចេញពីសភាតំណាងរាស្ត្រក្រោយពេលចាញ់ឆ្នោត នៅតែបន្តទទួលបានហិរញ្ញប្បទានសាធារណៈក្នុងមួយរយៈកាលទៀត។ ករណីនេះបានកើតឡើងចំពោះគណបក្សនយោបាយមួយចំនួនដូចជា៖ *គណបក្សគ្រីស្តសាសនិកប្រជាធិបតេយ្យ (The Christian Democrats) គណបក្សបៃតង (The Green Party) និង គណបក្សប្រជាធិបតេយ្យថ្មី (New Democracy)* ដែលបានចាកចេញពីសភាជាបន្តបន្ទាប់នៅឆ្នាំ១៩៨៨ ឆ្នាំ១៩៩១ និងឆ្នាំ១៩៩៤។ គណបក្សគ្រីស្តសាសនិកប្រជាធិបតេយ្យ និង គណបក្សបៃតង ជាបន្តបន្ទាប់បានចូលរួមក្នុងការបោះឆ្នោតលើកក្រោយៗទៀត ដោយទទួលបានសម្លេងគាំទ្រ៧% និង៥% ហើយបានបន្តវត្តមានរបស់ពួកគេនៅក្នុងសភាចាប់ពីពេលនោះមក។ ផ្ទុយទៅវិញ គណបក្សប្រជាធិបតេយ្យថ្មីដែលបានចាកចេញពីសភាតំណាងរាស្ត្រដោយហេតុតែបានទទួលសម្លេងឆ្នោតត្រឹមតែ១,២%ក្នុងការបោះឆ្នោតកាលពីឆ្នាំ១៩៩៤នោះ បានជួបបរាជ័យយ៉ាងដូចត់នៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៨ ដោយបានទទួលសម្លេងគាំទ្រមិនដល់០,២%ផង។

សំណួរ មួយដែលកម្រនឹងកើតមាននៅក្នុងប្រទេសដែលលទ្ធិប្រជាធិបតេយ្យមានភាពចាស់ទុំគឺ តើគេគួរធ្វើដូចម្តេចចំពោះហិរញ្ញប្បទានសាធារណៈដែលបានផ្តល់រួចហើយដល់គណបក្សនយោបាយណាមួយ ប្រសិនបើគណបក្សនយោបាយនោះសម្រេចដកខ្លួនពីការបោះឆ្នោតវិញ។ វាជាការសមហេតុផល ដែលហិរញ្ញប្បទាននោះត្រូវផ្តល់ត្រឡប់មកឲ្យរដ្ឋវិញ ហើយនោះគឺជាអ្វីដែលរដ្ឋាភិបាលបានស្នើយោបល់ឲ្យមានច្បាប់ថ្មីមួយដែលគេកំពុងតែពិចារណានៅក្នុងប្រទេសអេត្យូពី។ ទោះជាយ៉ាងនេះក្តី គណបក្សប្រឆាំងបានត្អូញត្អែរថា "តើឲ្យគណបក្សមួយប្រគល់ហិរញ្ញប្បទាននោះទៅឲ្យរដ្ឋវិញដូចម្តេចកើត បើគណបក្សនោះបានយកទៅប្រើប្រាស់ក្នុងយុទ្ធនាការឃោសនា និង ចំណាយផ្សេងៗអស់ទៅហើយ ប៉ុន្តែក្រោយមកគណបក្សនោះបានបង្ខំចិត្តដកខ្លួនចេញពីការបោះឆ្នោតវិញដោយសារការធ្វើទុកបុកម្នេញ និង ការគម្រាមកំហែងផ្នែកនយោបាយ? ... [លក្ខខណ្ឌនេះ] ត្រូវបានគេបង្កើតឡើង ដោយចេតនាដូច្នេះហើយគ្រប់គណបក្សនយោបាយទាំងអស់ដែលប្រឈមទៅនឹងការគម្រាមកំហែង និង ការធ្វើទុកបុកម្នេញយ៉ាងធ្ងន់ធ្ងរត្រូវបង្ខំចិត្តចូលរួមការបោះឆ្នោតគ្រាន់តែដើម្បីអមដំណើរគណបក្សកាន់អំណាចតែប៉ុណ្ណោះ"។

ការកំណត់លក្ខខណ្ឌអប្បបរមាមួយយ៉ាងតឹងតែងក្នុងការទទួលបានហិរញ្ញប្បទានសាធារណៈអាចលើកទឹកចិត្តឲ្យមានការរួមបញ្ចូលគ្នារវាងគណបក្សនយោបាយតូចៗ និង ការចងសម្ព័ន្ធភាពដើម្បីប្រកួតប្រជែងក្នុងការបោះឆ្នោត។ ការធ្វើបែបនេះអាចនឹងមានសារប្រយោជន៍សម្រាប់ការពង្រឹងសមត្ថភាព និង ស្ថាប័នភាវូបនីយកម្មរបស់គណបក្សនយោបាយ ហើយក៏នឹងជួយបង្កើនការប្រកួតប្រជែងនៅក្នុងការបោះឆ្នោត និង គុណភាពរបស់រដ្ឋាភិបាលផងដែរ។ ផ្ទុយទៅវិញ ការផាត់គណបក្សតូចៗចេញពីការបោះឆ្នោតអាចធ្វើឲ្យមានការកាត់បន្ថយចំនួនសម្លេងនៅក្នុងការពិភាក្សាដេញដោលផ្នែកនយោបាយ ហើយបម្រើជាប្រយោជន៍ក្នុងការរក្សាទុករបបរបស់គណបក្សកាន់អំណាច ។ នៅក្នុងករណីមួយចំនួន គណបក្សកាន់អំណាចបានធ្វើឲ្យប្រាកដថាលក្ខខណ្ឌអប្បរមាក្នុងការទទួលបានហិរញ្ញប្បទានសាធារណៈត្រូវបានគេដាក់ក្នុងកម្រិតមួយយ៉ាងខ្ពស់ដើម្បីផាត់គណបក្សប្រឆាំងចេញទាំងស្រុងពីការបោះឆ្នោត ។ នៅប្រទេសហ្ស៊ីមប៉ាវ៉េ (Zimbabwe) មានតែគណបក្សដែលទទួលបានសម្លេងឆ្នោតយ៉ាងតិច១៥អាសនៈតែប៉ុណ្ណោះ ទើបបំពេញបានគ្រប់លក្ខខណ្ឌដើម្បីបានទទួលហិរញ្ញប្បទានសាធារណៈ ដែលលក្ខខណ្ឌនេះមានតែគណបក្សគ្រប់គ្រងរដ្ឋ គឺគណបក្សហ្សានូ ភីអែហ្វ ( ZANU-PF) តែប៉ុណ្ណោះដែលអាចបំពេញបាននៅក្នុងការបោះឆ្នោតទាំងពីរលើកគឺការបោះឆ្នោតក្នុងឆ្នាំ១៩៩០ និង ១៩៩៥ មុនពេលតុលាការកំពូលបង្គាប់ឲ្យទម្លាក់លក្ខខណ្ឌអប្បរមាមកនៅត្រឹម៥%នៃសម្លេងឆ្នោតបានការសម្រាប់ការទទួលហិរញ្ញប្បទានសាធារណៈ។

ជាបន្តបន្ទាប់ គេមិនអាចកំណត់ថាតើអ្វីជាលក្ខខណ្ឌអប្បបរមាសមស្របសម្រាប់គណបក្សនយោបាយ ឬបេក្ខជនក្នុងការទទួលហិរញ្ញប្បទានសាធារណៈឡើយ។ ការធ្វើបែបនេះវាអាស្រ័យទៅលើគោលបំណងដែលគេព្យាយាមធ្វើឲ្យសម្រេចបាន។ បេក្ខជនឈរឈ្មោះបោះឆ្នោតនៅប្រទេសកូរ៉េខាងត្បូង ត្រូវតែទទួលបានសម្លេងឆ្នោត 10% ទើបមានសិទ្ធិទទួលបានហិរញ្ញប្បទានសាធារណៈ ខណៈដែលតុលាការធម្មនុញ្ញសហព័ន្ធអាល្លឺម៉ង់មោឃភាពចោលលក្ខខណ្ឌអប្បបរមា២,៥%នៃសម្លេងឆ្នោត ដោយបញ្ជាឲ្យទម្លាក់មកនៅត្រឹម០ ,៥%វិញ។ ជាទូទៅ លក្ខខណ្ឌអប្បរមាដែលកំណត់យ៉ាងទាបសម្រាប់ការទទួលបានហិរញ្ញប្បទានសាធារណៈនឹងបង្កឲ្យមានភាពជាពហុបក្ស និងអាចជួយធ្វើឲ្យទីលានប្រកួតប្រជែងមានសមភាព។ តែផ្ទុយទៅវិញ ការកំណត់លក្ខខណ្ឌអប្បរមាឲ្យនៅទាបបែបនេះក៏អាចរារាំងដំណើរការស្ថាប័នភាវូបនីយកម្មរបស់គណបក្សនយោបាយដែរ តាមរយៈការបង្កឲ្យមានការប្រេះឆានៅ

ក្នុងគណបក្សនយោបាយ ហើយថែមទាំងអាចនាំទៅរកការដាក់បេក្ខភាពគ្រាន់តែជាការលម្អ ឬ ការបង្កើតគណបក្សនយោបាយដែលមិនសូវមានភាពរឹងមាំទៀតផង។

ដំណោះស្រាយដ៏ប្រសើរបំផុតអាចថា "ក្នុងកម្រិតណាមួយ ការប្រុងប្រយ័ត្នជាមុនទល់នឹងបេក្ខជនដែលគ្រាន់តែឈរឈ្មោះដើម្បីលម្អអាចទទួលយកបាន លុះត្រាតែការធ្វើបែបនេះមិននាំឲ្យមានការរារាំងចលនានយោបាយដែលទើបនឹងបង្កើតថ្មីពីការចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងការប្រកួតប្រជែងផ្នែកនយោបាយ"។ ការដាក់ដែនកំណត់លើហិរញ្ញប្បទានសាធារណៈចំពោះគណបក្សនយោបាយដែលមានសម្លេងរួចហើយនៅក្នុងស្ថាប័នដែលត្រូវបានបង្កើតឡើងដោយការបោះឆ្នោតមានន័យជាការប្រថុយប្រថានដែលនាំទៅរកការផាត់ចេញនូវចលនានយោបាយថ្មីៗពីការប្រកួតប្រជែងនៅក្នុងការបោះឆ្នោត។

*តារាង ៦៖ លក្ខខណ្ឌអប្បបរមាសម្រាប់ហិរញ្ញប្បទានសាធារណៈ*

| ប្រទេស | សម្លេងឆ្នោត/ចំនួនអាសនៈត្រូវការសម្រាប់ទទួលហិរញ្ញប្បទាន |
|---|---|
| សាវតូម៉េនិងប្រាំងស៊ីប៉េ | គ្មាន |
| ដាណឺម៉ាក | ១,០០០ សម្លេង |
| អាល្លឺម៉ង់ | ០.៥% នៃសម្លេងឆ្នោតសរុប |
| ហ្វាំងឡង់ និង ហូឡង់ | ១ អាសនៈ (យ៉ាងតិចបំផុត ០.៦៧% នៃសម្លេងឆ្នោតសរុប) |
| ស្លូវ៉េនី អេស្តូនី និង ហុងគ្រី | ១% នៃសម្លេងឆ្នោតសរុប |
| អ៊ុយរុយហ្គាយ | ១.៥% នៃសម្លេងឆ្នោតសរុប |
| កាណាដា | ២% នៃសម្លេងឆ្នោតសរុប |
| អេស្ប៉ាញ លីទុយអានី ប៉ូឡូញ ស្លូវ៉ាក និង ឆែក | ៣% នៃសម្លេងឆ្នោតសរុប |
| កូស្តារីកា និង អ៊ីតាលី | ៤% នៃសម្លេងឆ្នោតសរុប |
| ហ្សកហ្ស៊ី ក្រូអាស៊ី និង តង់ហ្សានី | ៥% នៃសម្លេងឆ្នោតសរុប |
| ទួគី | ៧% នៃសម្លេងឆ្នោតសរុប |

## ៣. អ្នកទទួលហិរញ្ញប្បទាន

ខណៈដែលគណបក្សនយោបាយគឺជាតួអង្គមួយសមស្របក្នុងការទទួលហិរញ្ញប្បទានសាធារណៈជាហូរហែមក ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ក៏អាចត្រូវបានផ្តល់ទៅឲ្យបេក្ខជនឈរឈ្មោះបោះឆ្នោតផងដែរ។ ហិរញ្ញប្បទានសម្រាប់បេក្ខជនមានការប្រើប្រាស់ច្រើននៅក្នុងប្រព័ន្ធបោះឆ្នោតដែលផ្តោតទៅលើបេក្ខជនឈរឈ្មោះជាជាងផ្តោតសំខាន់ទៅលើគណបក្ស ហើយហិរញ្ញប្បទាននេះទៀតសោតក៏អាចបន្តកាត់បន្ថយតួនាទីរបស់គណបក្សនយោបាយនៅក្នុងការបោះឆ្នោតដែរ។ ហិរញ្ញប្បទានដែលផ្តល់ទៅឲ្យបេក្ខជនកើតមានតិចតួចជាងការផ្តល់ហិរញ្ញប្បទានទៅឲ្យគណបក្សនយោបាយ ក៏ប៉ុន្តែប្រព័ន្ធនេះត្រូវបានគេប្រើប្រាស់នៅ សហរដ្ឋអាមេរិក ម៉ុលដាវី ម៉ូហ្សាំប៊ិក និង កូរ៉េខាងត្បូងជាដើម។ ការបែងចែកឲ្យដាច់ស្រឡះពីគ្នារវាងតួអង្គទទួលហិរញ្ញប្បទានសាធារណៈមានសារៈសំខាន់ណាស់ ព្រោះថា "ប្រព័ន្ធហិរញ្ញប្បទាសាធារណៈដែលល្អប្រសើរសម្រាប់បេក្ខជន អាចនឹងមិនល្អសម្រាប់គណបក្សនយោបាយទេ"។ ខណៈដែលបេក្ខជនចង់បានថវិកាដើម្បីយកឈ្នះលើការប្រកួតប្រជែងរបស់ខ្លួន

(ជាពិសេសតាមរយៈការផ្តួលគូប្រជែងរបស់ខ្លួនឲ្យចាញ់យ៉ាងដំណំ) គណបក្សនយោបាយវិញចង់ឲ្យមានការបែងចែកហិរញ្ញប្បទាននៅក្នុងការប្រកួតប្រជែងមួយដែលមានភាពប្រកៀកប្រកិតគ្នាខ្លាំង។ របាយការណ៍មួយស្តីអំពីហិរញ្ញវត្ថុនយោបាយនៅប្រទេសបែលហ្សិកបានកត់សម្គាល់ថា ការហិរញ្ញប្បទានសាធារណៈក្នុងកម្រិតមួយយ៉ាងខ្ពស់ទៅឲ្យគណបក្សនយោបាយ និងអវត្តមានហិរញ្ញប្បទាននេះនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតមានលក្ខណៈគ្រប់គ្រាន់នៅក្នុងការពន្យល់បកស្រាយអំពី "ការកាន់កាប់ផ្តាច់មុខផ្នែកនយោបាយសម្រាប់គណបក្សនយោបាយ [នៅក្នុងការបោះឆ្នោត] ដែលបានក្លាយជាប្រភពហិរញ្ញវត្ថុមួយយ៉ាងសំខាន់សម្រាប់បេក្ខជន"។

ការផ្តល់ហិរញ្ញប្បទានសាធារណៈដោយផ្ទាល់ទៅឲ្យបេក្ខជន អាចជួយកាត់បន្ថយការពឹងផ្អែករបស់ពួកគេទៅលើការរៃអង្គាសមូលនិធិដែលធ្វើឡើងដោយបេក្ខជនផ្ទាល់ (ដែលអាចជួយលុបបំបាត់អំពើពុករលួយ) ហើយថែមទាំងអាចលើកទឹកចិត្តដល់បេក្ខជនដែលមិនសូវមានធនធាន (រាប់ទាំងបេក្ខជនស្ត្រីផង) ឲ្យបន្តជំហានរបស់ពួកគេ ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើបែបនេះក៏អាចនាំឲ្យមានការកាត់បន្ថយមុខងាររបស់គណបក្ស ដែលជាហេតុធ្វើឲ្យមានការគម្រាមកំហែងដល់លទ្ធភាពរបស់គណបក្សនយោបាយក្នុងការប្រមូលផ្តុំ និង នាំយកមតិយោបល់របស់អ្នកបោះឆ្នោត ដែលជាលទ្ធផលត្រឡប់មកវិញអាចនាំឲ្យមានការបាត់បង់ជំនឿទុកចិត្តនៅក្នុងប្រព័ន្ធគណបក្សទាំងមូល។

ប្រសិនបើប្រទេសមួយប្រើប្រាស់ប្រព័ន្ធបោះឆ្នោតសមាមាត្រ ដែលពុំផ្តល់ឱកាសឲ្យអ្នកបោះឆ្នោតធ្វើការផ្លាស់ប្តូរលំដាប់បេក្ខជន ភាគច្រើននៃការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតគឺធ្វើឡើងដោយគណបក្ស និង សម្រាប់គណបក្ស មិនមែនសម្រាប់បេក្ខជនម្នាក់ៗនោះទេ។ នៅក្នុងករណីទាំងនេះ ការផ្តល់ជំនួយឧបត្ថម្ភពីរដ្ឋទៅឲ្យបេក្ខជនមិនសូវជាមានន័យនោះទេ។ ផ្ទុយទៅវិញ ប្រសិនបើការបោះឆ្នោតផ្តោតជាសំខាន់ទៅលើបេក្ខជន ដូចជាការបោះឆ្នោតសភាកាលពីឆ្នាំ២០០៨ ដ៏ចម្រូងចម្រាស់មួយ នៅក្នុងប្រទេសបេឡារុស (Belarus) ដែល៩៩%នៃសមាជិកសភាដែលជាប់ឆ្នោត (យ៉ាង ហោចណាស់) ជាបេក្ខជនឯករាជ្យ នោះហិរញ្ញប្បទានសាធារណៈអាចនឹងមានន័យសម្រាប់តែការផ្តល់ទៅឲ្យបេក្ខជនតែប៉ុណ្ណោះ។

គេគួរធ្វើការបែងចែកឲ្យដាច់ពីគ្នារវាងការផ្តល់ហិរញ្ញប្បទានសាធារណៈទៅឲ្យទីស្នាក់ការកណ្តាលគណបក្សសាខានៅតាមតំបន់ និង សាខារបស់គណបក្សនៅតាមមូលដ្ឋាន ។ ការផ្តល់ហិរញ្ញប្បទានទៅឲ្យសាខាតំបន់ និងមូលដ្ឋានរបស់គណបក្សអាចជម្រុញឲ្យមានវិមជ្ឈការ និង ប្រហែលជាអាចនាំឲ្យមានលទ្ធិប្រជាធិបតេយ្យផ្ទៃក្នុងទៀតផង ក៏ប៉ុន្តែការធ្វើបែបនេះក៏អាចធ្វើឲ្យអន្តរាយដល់ការឯកភាពរបស់គណបក្សនយោបាយដែរ ។ ការសិក្សាមួយបានទាញសេចក្តីសន្និដ្ឋានថា ការផ្តល់ហិរញ្ញប្បទានសាធារណៈទៅឲ្យសាខាគណបក្សនយោបាយនៅតាមមូលដ្ឋានដែលគេបានធ្វើនៅក្នុងប្រទេសក្រូអាស៊ី (Croatia) បានធ្វើឲ្យសាខានៅតាមមូលដ្ឋានរបស់គណបក្សនយោបាយទាំងនោះ "មានស្វ័យភាពហិរញ្ញវត្ថុនៅក្នុងកម្រិតមួយយ៉ាងខ្ពស់"។

ការធ្វើហិរញ្ញប្បទានសាធារណៈនៅមានជម្រើសមួយចំនួនផ្សេងទៀត ។ ហិរញ្ញប្បទាន រួមទាំងប្រាក់បៀវត្សដែលគេបានផ្តល់ទៅឲ្យមន្ត្រីជាប់ឆ្នោត ក៏គេអាចចាត់ទុកថាជាហិរញ្ញប្បទានសាធារណៈដែរ ជាពិសេសក្នុងបណ្តាប្រទេសមួយចំនួនដែលមន្ត្រីជាប់ឆ្នោតទាំងនោះ ត្រូវបានគេតម្រូវ ឬត្រូវបានគេរំពឹងថានឹងផ្តល់វិភាគទានទៅឲ្យគណបក្សនយោបាយរបស់ពួកគេ។ ការឧបត្ថម្ភបែបនេះជារឿយៗក៏បានរួមបញ្ចូលទាំងបុគ្គលិកបម្រើការងាររដ្ឋបាល និង ការ ស្រាវជ្រាវ។ល។ ដែលធ្វើឡើងដោយក្រុមសមាជិកសភា ឬ ក្រុមដទៃទៀតដែលមានប្រយោជន៍ពាក់ព័ន្ធ ។

លើសពីនេះទៅទៀត ហិរញ្ញប្បទានសាធារណៈអាចត្រូវបានផ្តល់ទៅឲ្យក្រុមមួយចំនួនទៀតដែលស្ថិតនៅក្រោម ឬពាក់ព័ន្ធទៅនឹងគណបក្សនយោបាយ ដូចជា ចលនាស្ត្រី និង ចលនាយុវជនជាដើម ។ ហិរញ្ញប្បទានបែបនេះអាចជួយជម្រុញតួនាទីរបស់ក្រុមជនដែលមិនសូវមានសម្លេងទាំងនោះ ជាពិសេសប្រសិនបើគេបង្កើតវិធានការនានាដើម្បីធានាថា ហិរញ្ញប្បទានទាំងនោះត្រូវបានប្រើប្រាស់យ៉ាងពិតប្រាកដដោយក្រុមទាំងនោះ ។ ប្រទេសមួយចំនួនទៀតបានផ្តល់ហិរញ្ញប្បទានសាធារណៈទៅឲ្យអង្គការមនុស្សធម៌មួយចំនួនរបស់គណបក្សនយោបាយ ដើម្បីធ្វើការងារជួយគាំទ្រប្រព័ន្ធពហុបក្ស និង លទ្ធិប្រជាធិបតេយ្យនៅបរទេស ។ ការកំណត់ថាតើការជួយគាំទ្របៀបនេះអាចត្រូវបានចាត់ទុកជាផ្នែកមួយនៃហិរញ្ញប្បទានសាធារណៈឬអត់នោះគឺជាបញ្ហាមួយសម្រាប់ការពិភាក្សា។ ហិរញ្ញប្បទានបែបនេះកើតមាន ជាឧទាហរណ៍ នៅប្រទេសអាល្លឺម៉ង់ ន័រវេស្សន៍ ស៊ុយអែត និង ចក្រភពអង់គ្លេស។

ជាថ្មីម្តងទៀត តួអង្គដែលនឹងត្រូវជ្រើសរើសសម្រាប់ហិរញ្ញប្បទានសាធារណៈ មានការពាក់ព័ន្ធយ៉ាងជិតស្និទទៅនឹងគោលបំណងដែលគេចង់សម្រេចបាន។ ប្រសិនបើ វត្ថុបំណងសំខាន់គឺដើម្បីធ្វើឲ្យមានទីលានប្រកួតប្រជែងមួយស្មើភាពគ្នា ដែលការបោះឆ្នោតផ្តោតជាសំខាន់ទៅលើបេក្ខជនឈរឈ្មោះ ហិរញ្ញប្បទានគួរត្រូវបានផ្តល់ទៅឲ្យបេក្ខជនទាំងនោះដោយផ្ទាល់។ ប្រសិនបើបំណងប្រាថ្នានោះ គឺដើម្បីបង្កើនសមត្ថភាព និងដំណើរការស្ថាប័នភាវូបនីយកម្មរបស់គណបក្សនយោបាយជារួម ហិរញ្ញប្បទានគួរត្រូវបានផ្តល់ដោយផ្ទាល់ទៅឲ្យគណបក្សនយោបាយ (ចំណែកឯបញ្ហាដែលទាក់ទងទៅនឹងការជួយគាំទ្រចនាសម្ព័ន្ធថ្នាក់ក្រោមរបស់គណបក្សនយោបាយគួរតែយកមកដោះស្រាយ)។

*តារាង ៧៖ ប្រភេទតួអង្គដែលត្រូវទទួលហិរញ្ញប្បទានសាធារណៈ*

| ប្រភេទតួអង្គ | យោបល់ | ឧទាហរណ៍ |
|---|---|---|
| គណបក្សនយោបាយ | ជាតួអង្គទទួលហិរញ្ញប្បទានសាធារណៈដែលគេទទួលស្គាល់ជាទូទៅ។ | ប្រទេសអាល់បានី ហុងឌូរ៉ាស់ សាធារណរដ្ឋឆែក |
| បេក្ខជន | ជាធម្មតាយន្តការនេះប្រើសម្រាប់បេក្ខជនប្រធានាធិបតី និង/ឬ បេក្ខជនសភានៅក្នុងការបោះឆ្នោតនៅតាមមណ្ឌលដែលបេក្ខជនឈរឈ្មោះជាឯកត្តនាម។ | សហរដ្ឋអាមេរិក ម៉ូហ្សំប៊ិក កូរ៉េខាងត្បូង |
| អង្គការនានារបស់គណបក្សនយោបាយ | ដូចជាចលនាស្ត្រី និង ចលនាយុវជន ឬអង្គភាពទទួលបន្ទុកកិច្ចការស្រាវជ្រាវ ជាដើម។ | ប្រទេសស៊ុយអែត ចក្រភពអង់គ្លេស |

## ៤. សកម្មភាពដែលត្រូវទទួលហិរញ្ញប្បទានសាធារណៈ

ជាធម្មតា គេត្រូវធ្វើការបែងចែកឲ្យដាច់ពីគ្នារវាងហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនា និងសកម្មភាពជាបន្តរបស់គណបក្សនយោបាយ ដោយការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតផ្តោតទៅលើសមត្ថភាពរបស់គណបក្សនយោបាយក្នុងការបញ្ជូនសារនយោបាយរបស់ពួកគេឲ្យបានលឺទៅដល់អ្នកបោះឆ្នោត ចំណែកឯការផ្តល់ហិរញ្ញប្បទានសម្រាប់សកម្មភាពបន្តរបស់គណបក្សនយោបាយមានគោលបំណងជួយពង្រឹងដំណើរការស្ថាប័នភាវូបនីយកម្មរយៈពេលវែងរបស់គណបក្សនយោបាយ និង ជួយគាំទ្រការបំពេញមុខងាររបស់គណបក្សនយោបាយក្រៅពីការបោះឆ្នោត មានដូចជាការអប់រំសាធារណជន និង ការប្រមូលផ្តុំមតិយោបល់របស់ប្រជាពលរដ្ឋ។ ឧទាហរណ៍ នៅចក្រភពអង់គ្លេស ហិរញ្ញប្បទានសាធារណៈត្រូវបានគេផ្តល់ទៅឲ្យគណបក្ស

នយោបាយក្រោមទម្រង់ជា "ថវិកាជំនួយឥតសំណងសម្រាប់ការអភិវឌ្ឍគោលនយោបាយ" ដែលមានគោលដៅ "ជួយគាំទ្រនៅក្នុងការអភិវឌ្ឍគោលនយោបាយសម្រាប់ការដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយសម្រាប់ការបោះ - ឆ្នោត..."។ នៅខណៈដែលរដ្ឋនានាដែលមានប្រព័ន្ធហិរញ្ញប្បទានសាធារណៈធ្វើការប្រើប្រាស់ហិរញ្ញប្បទានទាំងពីរប្រភេទនោះ ការផ្តោតតែមួយមុខគត់ទៅលើការផ្តល់ហិរញ្ញប្បទានសម្រាប់សកម្មភាពនានាក្រៅពីការបោះឆ្នោតកម្រនឹងកើតមានណាស់។ មធ្យោបាយដែលគេប្រើប្រាស់ញឹកញាប់បំផុតក្នុងការកំណត់គោលដៅនៃហិរញ្ញប្បទានទាំងសម្រាប់ការបោះឆ្នោត និង ក្រៅពីការបោះឆ្នោតគឺតាមរយៈការកំណត់ពេលវេលាសម្រាប់ការផ្តល់ហិរញ្ញប្បទាន និងតាមរយៈការគូសបញ្ជាក់ថាតើហិរញ្ញប្បទាននោះនឹងត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច។ នៅសហរដ្ឋអាមេរិក ហិរញ្ញ-ប្បទានសាធារៈ (មូលនិធិផ្គូផ្គង) ក៏ត្រូវបានគេប្រើប្រាស់ផងដែរសម្រាប់ផ្តល់ទៅឲ្យបេក្ខជនប្រធានាធិបតីនៅក្នុងការបោះឆ្នោតបឋម រីឯគណបក្សនយោបាយចម្បងៗក៏មានលក្ខណៈសម្បត្តិក្នុងការទទួលបានហិរញ្ញប្បទានសាធារណៈសម្រាប់ការតែងតាំងមហាសន្និបាតរបស់បេក្ខជនប្រធានាធិបតីផងដែរ។

ការផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតមានការប្រើប្រាស់ច្រើន ហើយប្រព័ន្ធនេះក៏អាចជួយធ្វើឲ្យមានការប្រកួតប្រជែងកាន់តែខ្លាំង ព្រមទាំងកាត់បន្ថយអំណាចរបស់បេក្ខជនផុតអណត្តិទៀតផង។ ទោះជាយ៉ាងនេះក្តី ប្រព័ន្ធនេះមិនទំនងជាមានការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនោះទេនៅក្នុងស្ថានភាពជាច្រើន ប្រសិនបើគេមិនបានបង្កើតវិធានការដើម្បីប្រឆាំងទៅនឹងការប្រប្រាស់ធនធានរបស់រដ្ឋដោយមិនត្រឹមត្រូវ ឬដោយផ្ទុយច្បាប់ដោយគណបក្សផុតអណត្តិទេនោះ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើគោលបំណងនៃហិរញ្ញ-ប្បទានសាធារណៈធ្វើឡើងដើម្បីពង្រឹងអន្តរសកម្មភាពរវាងគណបក្សនយោបាយ និង អ្នកបោះឆ្នោត ឬ ដើម្បីលើកទឹកចិត្តឲ្យមានការពិភាក្សាដេញដោលអំពីគោលនយោបាយដោយរស់រវើក និងការកសាងទំនុកចិត្តរបស់សាធារណជនទៅលើគណបក្សនយោបាយ នោះការផ្តល់ហិរញ្ញប្បទានក្នុងអំឡុងពេលដែលពុំមានការបោះឆ្នោតអាចនឹងមានប្រយោជន៍។ ចំពោះករណីនេះ គេអាចនឹងលើកឡើងថាមានចំណុចសំខាន់តិចតួចប៉ុណ្ណោះក្នុងការគាំទ្រយុទ្ធនាការឃោសនាបោះឆ្នោតឲ្យមានភាពរស់រវើក ប្រសិនបើគណបក្សនយោបាយមិនបានចូលរួមជាមួយសាធារណជននៅក្នុងកិច្ចពិភាក្សាដេញដោលស្តីអំពីបំណងប្រាថ្នារបស់ពួកគេទេនោះ។

ផ្ទុយទៅវិញ ថវិកាតែមួយមុខនឹងមិនអាចជំរុញឲ្យគណបក្សនយោបាយចូលរួមក្នុងកិច្ចពិភាក្សាដេញដោលទៅលើគោលនយោបាយបាននោះទេ រីឯបទពិសោធន៍ដែលយើងទទួលបានពីបណ្តាប្រទេសដែលទើបនឹងមានលទ្ធិប្រជាធិបតេយ្យបានបង្ហាញថា គណបក្សនយោបាយភាគច្រើនមាននិន្នាការស្ងាត់ស្ងៀម ដោយពុំមានសកម្មភាពអ្វីប៉ុន្មានឡើយក្នុងចន្លោះពេលបោះឆ្នោត។ នៅក្នុងកាលៈទេសៈបែបនេះ ការដាក់ចេញឲ្យមានការអនុវត្តហិរញ្ញប្បទានសាធារណៈនឹងបង្កើនសារសំខាន់នៃតួនាទីហិរញ្ញវត្ថុនៅក្នុងនយោបាយរបស់គណបក្ស និង ការប្រើប្រាស់មូលនិធិនយោបាយដោយមិនត្រឹមត្រូវ។ ដូច្នេះ ការធ្វើកំណែទម្រង់គួរត្រូវបានភ្ជាប់ជាមួយការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ហើយវាអាចនឹងកាន់តែមានសារប្រយោជន៍ថែមទៀតប្រសិនបើមានការកំណត់ឲ្យបានច្បាស់ថា តើមូលនិធិទាំងនោះអាចអនុញ្ញាតឲ្យមានការចំណាយទៅលើអ្វីខ្លះ។ កង្វះខាតទិន្នន័យមានន័យថា យើងគួរមានការប្រុងប្រយ័ត្ននៅពេលទាញសេចក្តីសន្និដ្ឋានថា តើប្រព័ន្ធនីមួយៗមានការប្រើប្រាស់ច្រើនកម្រិតណានៅទូទាំងពិភពលោក ក៏ប៉ុន្តែព័ត៌មានដែលយើងអាចទទួលបានបានបង្ហាញប្រាប់យើងថា ប្រហែលជា២ភាគបីនៃប្រទេសទាំងអស់ដែលប្រើប្រាស់ប្រព័ន្ធហិរញ្ញប្បទានសាធារណៈបានផ្តល់ហិរញ្ញប្បទានសម្រាប់ទាំងសកម្មភាពដែលទាក់ទងនឹងការបោះឆ្នោត និង សកម្មភាព

ដែលមិនទាក់ទងនឹងការបោះឆ្នោត។ ក្រៅពីនេះ មានប្រទេសតិចតួចតែប៉ុណ្ណោះដែលបានផ្តល់ជំនួយសម្រាប់តែសកម្មភាពដែលមិនទាក់ទងនឹងការបោះឆ្នោត។

ចំពោះ សកម្មភាពណាមួយ ដែលគួរទទួលបានហិរញ្ញប្បទានសាធារណៈ វាអាស្រ័យទៅលើគោលបំណងដែលហិរញ្ញប្បទានសាធារណៈនោះចង់ឲ្យសម្រេចបាន។ ការទ្រទ្រង់យុទ្ធនាការឃោសនាបោះឆ្នោត អាចជួយធ្វើឲ្យមានភាពសមភាពក្នុងទីលានប្រកួតប្រជែងនយោបាយ ហើយក៏អាចជួយដល់អ្នកបោះឆ្នោតក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយការទទួលបានព័ត៌មានគ្រប់គ្រាន់ដែរ។ ការជួយគាំទ្រសកម្មភាពបន្តរបស់គណបក្សនយោបាយក៏អាចជាការជួយគាំទ្រដល់ដំណើរការស្ថាប័នភាវូបនីយកម្ម និង ការប្រមូលផ្តុំគំនិតយោបល់របស់អ្នកបោះឆ្នោតក្នុងរយៈពេលវែងផងដែរ។ វាអាចជាគំនិតល្អមួយដែលគេប្រើប្រាស់ប្រភេទទាំងពីរនៃហិរញ្ញប្បទានសាធារណៈ ក៏ប៉ុន្តែការធ្វើបែបនេះនឹងបង្កើនបន្ទុកថែមទៀតដល់ការចំណាយរបស់រដ្ឋ។ ការនេះធ្វើឲ្យយើងយល់បានថា មូលហេតុនេះហើយបានជាក្រុមប្រទេសមួយចំនួនដែលផ្តល់ជំនួយសម្រាប់តែយុទ្ធនាការឃោសនាបោះឆ្នោត ភាគច្រើនសុទ្ធតែក្រុមប្រទេសដែលទើបតែនឹងមានលទ្ធិប្រជាធិបតេយ្យ។

*តារាង ៨៖ ប្រភេទសកម្មភាពដែលអាចទទួលបានហិរញ្ញប្បទានសាធារណៈ*

| សកម្មភាព | យោបល់ | ឧទាហរណ៍ |
|---|---|---|
| យុទ្ធនាការឃោសនាបោះឆ្នោត | គឺជាទម្រង់ដែលមានការប្រើប្រាស់ច្រើនបំផុតនៅក្នុងប្រព័ន្ធហិរញ្ញប្បទានសាធារណៈ (អាច ឬ មិនអាចកំណត់ទម្រង់ជាក់លាក់នៃការចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតដែលត្រូវបានច្បាប់អនុញ្ញាត)។ | ប្រទេសអាល់បានី ហុងឌូរ៉ាស និង សាធារណរដ្ឋឆែក |
| សកម្មភាពបន្តរបស់គណបក្សនយោបាយ | សម្រាប់សកម្មភាពដែលមិនទាក់ទងនឹងការបោះឆ្នោត ដូចជារដ្ឋបាលរបស់គណបក្ស និង ការអប់រំពលរដ្ឋ | ប្រទេសហ្វាំងឡង់ សាម៉ាវ និង ស៊ុីស |
| សកម្មភាពជាក់លាក់របស់គណបក្ស | មូលនិធិនេះត្រូវបានគេអនុញ្ញាតឲ្យប្រើប្រាស់សម្រាប់តែសកម្មភាពមួយចំនួនដូចជា ការស្រាវជ្រាវ ឬ ការអភិវឌ្ឍអន្តរជាតិជាដើម។ | ប្រទេសស៊ុយអែត ហូឡង់ និង ម៉ិចស៊ិច។ |

## *៥. ប្រភេទមូលនិធិសាធារណៈ*

ការបែងចែកឲ្យដាច់ពីគ្នាយ៉ាងសំខាន់គឺ រវាងហិរញ្ញប្បទានដោយផ្ទាល់ និង ហិរញ្ញប្បទានដោយប្រយោល ។ ហិរញ្ញប្បទានដោយផ្ទាល់ គឺថវិកាដែលគេបានផ្តល់ដោយផ្ទាល់ទៅឲ្យគណបក្សនយោបាយ (ឬបេក្ខជន ដូចករណីខាងក្រោម)។ ហិរញ្ញប្បទាននេះផ្តល់សេរីភាពយ៉ាងទូលំទូលាយបំផុតដល់គណបក្សនយោបាយក្នុងគ្រប់គ្រងការប្រើប្រាស់មូលនិធិទាំងនោះ។ ជាបន្តបន្ទាប់ អ្នកផ្តល់ហិរញ្ញប្បទាន (រដ្ឋ) ពុំបានគ្រប់គ្រងទៅលើការប្រើប្រាស់ហិរញ្ញប្បទានដោយផ្ទាល់នោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់អាចត្រូវបានធ្វើឡើងតាមរយៈការដាក់ចេញឲ្យមានការអនុវត្តការរិតត្បិតទៅលើការចំណាយជាក់លាក់មួយចំនួន ។

ហិរញ្ញប្បទានបែបប្រយោល ជាទូទៅសំដៅទៅលើការដែលគណបក្សនយោបាយ (ឬបេក្ខជន) ត្រូវបានផ្តល់លទ្ធភាពក្នុងការប្រើប្រាស់សេវាផ្សេងៗដោយឥតគិតថ្លៃ ឬក្នុងតម្លៃមួយយ៉ាងទាប។ ទម្រង់នៃហិរញ្ញប្បទានបែប

ប្រយោលដែលមានការប្រើប្រាស់ច្រើនបំផុតគឺការឧបត្ថម្ភធនទៅលើការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ។ ជាធម្មតាទម្រង់នេះត្រូវបានរិតត្បិតសម្រាប់តែអំឡុងពេលបោះឆ្នោត និង ប្រព័ន្ធផ្សព្វផ្សាយសាធារណៈ។ គោលបំណងនៃការធ្វើហិរញ្ញប្បទានបែបនេះគឺដើម្បីបង្កើនឱកាសសម្រាប់គណបក្សនយោបាយក្នុងការទាក់ទាញអ្នកបោះឆ្នោត និងដែលជាហេតុបង្កើតឲ្យមានទីលានប្រកួតប្រជែងស្មើភាពគ្នា។ ទំរង់ដទៃទៀតនៃហិរញ្ញប្បទានសាធារណៈតាមបែបប្រយោលរួមមាន ការប្រើប្រាស់ធនធានរបស់រដ្ឋជាផ្លូវការ (ដូចជាមធ្យោបាយដឹកជញ្ជូន ការិយាល័យ ប្រព័ន្ធប្រៃសណីយ៍។ល។) សម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត ឬ សកម្មភាពបន្តនានារបស់គណបក្សនយោបាយ។ ទម្រង់មួយផ្សេងទៀតដែលគេមិនសូវឃើញមានការប្រើប្រាស់ក្រៅពីប្រទេស ដែលមានលទ្ធិប្រជាធិបតេយ្យចាស់ទុំ គឺការកាត់បន្ថយពន្ធទាំងសម្រាប់គណបក្សនយោបាយ និង សម្រាប់អ្នកធ្វើវិភាគទានឲ្យគណបក្សនយោបាយ។

ហិរញ្ញប្បទាន បែបប្រយោលសម្រាប់គណបក្សនយោបាយ អាចជាមធ្យោបាយដ៏ល្អមួយដើម្បីធានាថា ជំនួយឧបត្ថម្ភនេះត្រូវបានប្រើប្រាស់សម្រាប់គោលបំណងដែលគេបានកំណត់ទុក។ ហិរញ្ញប្បទានបែបនេះ ក៏នឹងជួយកាត់បន្ថយការប៉ុនប៉ងរបស់គណបក្សនយោបាយក្នុងការទទួលយកមូលនិធិឯកជន ដែលមានភ្ជាប់ទៅដោយលក្ខខណ្ឌ ហើយម្យ៉ាងទៀត វា ក៏អាចជួយធ្វើឲ្យមានសមភាពនៅក្នុងទីលានប្រកួតប្រជែងមានប្រសិទ្ធភាពជាងការផ្តល់ហិរញ្ញប្បទានបែបផ្ទាល់។ ប្រសិនបើមានគណបក្សតែមួយគត់គ្របដណ្តប់ទៅលើឆាកនយោបាយ ហិរញ្ញប្បទានតាមបែបប្រយោលប្រហែលជាមិនអាចធានាលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយបានឡើយ ប្រសិនបើប្រព័ន្ធផ្សព្វផ្សាយមិនបានបំពេញតួនាទីប្រកបដោយឯករាជ្យភាពទេនោះ។ ផ្ទុយទៅវិញ ប្រសិនបើគេផ្តល់ការផ្សព្វផ្សាយតាមរលកធាតុអាកាសដោយពុំគិតថ្លៃ បញ្ហានេះអាចនឹងត្រូវបានកាត់បន្ថយ។

*តារាង ៩៖ ប្រភេទផ្សេងៗនៃហិរញ្ញប្បទានសាធារណៈបែបប្រយោល*

| ប្រភេទនៃហិរញ្ញប្បទានបែបប្រយោល | ឧទាហរណ៍ |
|---|---|
| ការលើកលែងពន្ធ/ការផ្តល់អត្ថប្រយោជន៍ | អូស្ត្រាលី |
| ការឧបត្ថម្ភធន ឬ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយឥតគិតថ្លៃ | ញូហ្ស៊ីឡែន ឥណ្ឌា |
| ការឧបត្ថម្ភធន ឬ ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដោយឥតគិតថ្លៃ | ម៉ុលដាវី |
| ការបោះពុម្ព ឬ ការចែកចាយសម្ភារៈ | អេស្ប៉ាញ |
| ការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋដោយឥតគិតថ្លៃ | ហុងគ្រី |
| ការឧបត្ថម្ភធន ឬ ការប្រើប្រាស់ការិយាល័យសម្រាប់គណបក្សដោយឥតគិតថ្លៃ | អ៊ីតាលី |
| ការលើកលែងលើការតម្កល់ប្រាក់ធានារបស់បេក្ខជន | កាហ្សាក់ស្ថាន |
| ការឧបត្ថម្ភដល់សមាជិកសភា ឬ ក្រុមនានានៅក្នុងសភា | ចក្រភពអង់គ្លេស |

## ៦. យន្តការនៃការបែងចែកហិរញ្ញប្បទានសាធារណៈ

បញ្ហាដែលជារឿយៗទទួលបានការចាប់អារម្មណ៍ច្រើនជាងគេបំផុតនោះ គឺរបៀបបែងចែកហិរញ្ញប្បទានសាធារណៈ ឬ ចំនួននៃហិរញ្ញប្បទានដែលគួរផ្តល់ ទៅឲ្យគណបក្សនយោបាយនីមួយៗ ឬបេក្ខជនម្នាក់ៗ។ មានគោលការណ៍ទូទៅចំនួនពីរដែលគេគួរយល់ដឹង។ គោលការណ៍ទីមួយ គឺថារាល់អ្នកចូលរួមប្រកួតប្រជែងទាំងអស់គួរទទួលបានហិរញ្ញប្បទានស្មើៗគ្នា ដើម្បីធានាឲ្យមានទីលានប្រកួតប្រជែងស្មើភាពគ្នាមួយ។ យោងទៅតាម

សញ្ញាណនេះ អ្នកចូលរួមប្រកួតប្រជែងនីមួយៗគួរមានឱកាសដូចៗគ្នានៅក្នុងការប្រកួតប្រជែង ចំណែកឯ មូលនិធិដែលពួកគេបានទទួលក៏មិនត្រូវបែងចែកឲ្យមានភាពខុសគ្នាដែរ។ ប្រព័ន្ធបែងចែកហិរញ្ញប្បទានដែលផ្អែកទៅលើសមភាពពេញលេញជូនកាលត្រូវបានប្រើប្រាស់ច្រើនសម្រាប់បេក្ខជន តែមិនសូវមានការប្រើប្រាស់សម្រាប់គណបក្សនយោបាយទេ។ គោលការណ៍ទីពីរគឺថា ថវិកាដែលអ្នកចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតទទួលបាននោះ គឺអាស្រ័យទៅលើការគាំទ្រដែលអ្នកប្រកួតប្រជែងទទួលបានក្នុងចំណោមអ្នកបោះឆ្នោត។ ប្រព័ន្ធបែងចែកបែបនេះផ្អែកទៅលើសញ្ញាណមួយដែលយល់ថា ហិរញ្ញប្បទានសាធារណៈមិនគួរប៉ះពាល់ដល់ដំណើរការនយោបាយនៅក្នុងលក្ខណៈមួយដែលមិនស្របនឹងបំណងប្រាថ្នារបស់ពលរដ្ឋនោះទេ។ អ្វីដែលគេបានលើកឡើងជាក់ស្តែង គឺថាអ្នកចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត គួរទទួលបានចំណែកហិរញ្ញប្បទានសាធារណៈសមាមាត្រទៅនឹងការគាំទ្រដែលពួកគេបានទទួលពីអ្នកបោះឆ្នោត។ ការគាំទ្រនេះ ជាទូទៅ ត្រូវបានគេវាស់វែងតាមរយៈចំនួនសម្លេងឆ្នោតដែលបានទទួល ឬ តាមចំនួនអាសនៈដែលបានឈ្នះក្នុងការបោះឆ្នោតលើកមុន (សម្រាប់ការផ្តល់ហិរញ្ញប្បទានគាំទ្រសកម្មភាពបន្តរបស់គណបក្ស និង សម្រាប់ការផ្តល់ហិរញ្ញប្បទានគាំទ្រយុទ្ធនាការឃោសនាដែលត្រូវបានផ្តល់នៅមុនពេលបោះឆ្នោត) ឬ ក្នុងពេលដែលការបោះឆ្នោតបានចប់សព្វគ្រប់ (សម្រាប់ហិរញ្ញប្បទានដែលបានទទួលក្រោយពេលបោះឆ្នោត)។ ការគណនាសម្លេងគាំទ្រដោយផ្អែកលើចំនួនសន្លឹកឆ្នោត អាចចាត់ទុកថាជាអ្វីដែលគេចង់បានប្រសិនបើគេប្រើប្រាស់ប្រព័ន្ធមិនមែនសមាមាត្រ ដូចជាប្រព័ន្ធឯកត្តនាមជាដើមនៅក្នុងការបោះឆ្នោត ។ ការរិះគន់មួយដែលមានគោលដៅជំទាស់ទៅនឹងការបែងចែកហិរញ្ញប្បទានដោយផ្អែកទៅលើលទ្ធផលដែលទទួលបានពីពេលមុន គឺថា ការធ្វើបែបនេះនឹងមិននាំឲ្យមានការផ្លាស់ប្តូរអ្វីឡើយនៅក្នុងការឧបត្ថម្ភជាសាធារណៈក្នុងចន្លោះពេលបោះឆ្នោត ហើយជាពិសេសនោះ គឺសម្រាប់ការលេចឡើងនូវគណបក្សនយោបាយថ្មីៗ។ ឧទាហរណ៍ *ថាម (Tham)* បានបង្ហាញអំណះអំណាងថា នៅក្នុងករណីប្រទេសអូស្ត្រាលី ប្រព័ន្ធបែបនេះ "មានន័យដោយមិនអាចបដិសេធន៍បានថា គណបក្សនយោបាយដែលបានបង្កើតជាយូរមកហើយទទួលបានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើនជាងគណបក្សដែលទើបនឹងបង្កើតថ្មី"។

ការផ្តល់ថវិកាស្មើៗគ្នាដល់គ្រប់គណបក្សនយោបាយទាំងអស់ នឹងជួយកាត់បន្ថយលទ្ធភាពគ្រប់គ្រងរបស់គណបក្សធំៗនៅក្នុងឆាកនយោបាយ ហើយជាពិសេស វាកាន់តែមានសារៈសំខាន់ប្រសិនបើគណបក្សគ្រប់គ្រងអំណាចគ្របដណ្តប់ឥទ្ធិពលរបស់ខ្លួននៅក្នុងឆាកនយោបាយ (ដែលនៅក្នុងប្រទេសទាំងនោះ ការបែងចែកថវិកាទៅតាមសមាមាត្រពិតជានឹងអាចធ្វើឲ្យទីលានប្រកួតប្រជែងមិនសូវមានលក្ខណៈស្មើភាពគ្នា)។ ការប្រើប្រាស់យន្តការបែងចែកថវិកាបែបសមាមាត្រក៏បានទទួលរងការរិះគន់ផងដែរថា បានបង្កើតឲ្យមានច្រកចូលមួយយ៉ាងលំបាកសម្រាប់គណបក្សនយោបាយដែលទើបនឹងបង្កើតថ្មី។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធនេះក៏មានអត្ថប្រយោជន៍របស់វាដែរ។ យន្តការនេះបង្កប់អត្ថន័យមួយថា គណបក្សដែលមានអ្នកគាំទ្រច្រើននឹងទទួលបានថវិកាច្រើនដែរ (ក្នុងករណីនេះ ថវិកា ត្រូវបានគេចាត់ទុកថាមិនមែនជាសិទ្ធិរបស់គណបក្សសាមីនីមួយៗទេ ប៉ុន្តែវាជាអត្ថប្រយោជន៍ពិសេសមួយដែលគេត្រូវការស្វែងរក)។ ប្រព័ន្ធបែងចែកមូលនិធិមិនសមាមាត្រ ក៏អាចជម្រុញឲ្យមានការបង្កើតឡើងនូវគណបក្សនយោបាយក្នុងគោលបំណងតែមួយគត់គឺដើម្បីទាញយកប្រយោជន៍ពីហិរញ្ញប្បទានសាធារណៈ។

ប្រទេសភាគច្រើនប្រើប្រាស់យន្តការបែងចែកហិរញ្ញប្បទានបែបចម្រុះ ដែលនៅក្នុងនោះ គណបក្សទាំងអស់ត្រូវទទួលបានភាគនៃហិរញ្ញប្បទានសាធារណៈក្នុងចំនួនស្មើៗគ្នា ខណៈដែលភាគដែលនៅសល់នឹងត្រូវធ្វើការបែង

ចែកតាមបែបសមាមាត្រ។ ប្រទេសប្រមាណជា ៨០% លើពិភពលោក បានផ្តល់ហិរញ្ញប្បទានបែបផ្ទាល់ (យោងទៅតាមព័ត៌មានដែលយើងទទួលបាន) បានប្រើប្រាស់យន្តការនេះ ដែលជាទូទៅការបែងចែកហិរញ្ញប្បទានផ្អែកទៅលើលទ្ធផលដែលបានមកពីការបោះឆ្នោតកន្លងមក។ ដោយមានការរួមបញ្ចូលគ្នាបែបនេះ វាជាការចាំបាច់ណាស់ដែលគេត្រូវដឹងថា តើចំណែកណានៃហិរញ្ញប្បទានទាំងមូលដែលត្រូវយកមកគណនាទៅតាមសមមាត្រ ហើយយន្តការនេះទៀតសោតក៏មានលក្ខណៈខុសប្លែកគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតដែរ។ តារាង១០ខាងក្រោមនេះនឹងផ្តល់នូវឧទាហរណ៍មួយចំនួនអំពីរបៀបគណនាការបែងចែកហិរញ្ញប្បទានបែបចម្រុះនេះ។

*តារាង ១០៖ ការគណនាលើការបែងចែកហិរញ្ញប្បទានសាធារណៈនៅក្នុងប្រទេសខុសៗគ្នា*

| ប្រទេស | ភាគដែលគិតតាមសមាមាត្រ | ភាគដែលត្រូវចែកស្មើគ្នា |
|---|---|---|
| ឆាដ សហរដ្ឋអាមេរិក បារាំង កាណាដា | 0% | ១០០% |
| ឡេសូតូ | ៥០% (C) | ៥០% |
| បូស្នីនិងអ៊ែហ្សេហ្គូវីណា ម៉ាសេដូនី | ៧០% (S) | ៣០% |
| កូឡុំប៊ី ម៉ិចស៊ិច | ៩០% (V) | ១០% |
| ទុយនីស៊ី ដាណឺម៉ាក អ៊ីតាលី ម៉ារ៉ុក | ១០០% (V) | 0% |

"V" សំដៅទៅលើមូលនិធិសមាមាត្រទៅនឹងសម្លេងឆ្នោតដែលគណបក្សនយោបាយនីមួយៗបានទទួល។
"S" សំដៅទៅលើមូលនិធិសមាមាត្រទៅនឹងចំនួនអសនៈដែលកាន់កាប់ដោយគណបក្សនយោបាយនីមួយៗ។
"C" គឺជាចំនួនបេក្ខជនឈរឈ្មោះ។

នៅមានជម្រើសផ្សេងៗទៀតជាច្រើន។ នៅប្រទេសម៉ាល់ឌីវ គណបក្សនយោបាយទទួលហិរញ្ញប្បទានដោយយោងទៅតាមចំនួនសមាជិករបស់ពួកគេ។ ដោយសារការអនុវត្តបែបនេះបណ្តាលឲ្យមានស្ថានភាពខុសប្រក្រតីមួយចំនួន ពោលគឺគណបក្សកាន់អំណាចមិនមែនជាអ្នកទទួលហិរញ្ញប្បទានសាធារណៈធំជាងគេនោះទេ ដូច្នេះប្រព័ន្ធនេះអាចប្រឈមទៅនឹងការនាំទៅរកទម្រង់លើកទឹកចិត្តមិនសូវសមស្របមួយនៅក្នុងការជ្រើសរើសសមាជិកភាព។

ជម្រើសមួយទៀត គឺការផ្អែកការបែងចែកមូលនិធិទៅលើចំនួនថវិកាដែលគណបក្សនយោបាយ ឬបេក្ខជនមានលទ្ធភាពក្នុងការរៃអង្គាស ដែលជារឿយៗគេហៅថា *មូលនិធិផ្គូផ្គង* (Matching Funds) ដូចដែលគេបានប្រើប្រាស់នៅសហរដ្ឋអាមេរិក និង ប្រទេសអាល្លឺម៉ង់ជាដើម។ តាមរយៈប្រព័ន្ធនេះ រដ្ឋនឹងធ្វើការផ្គូផ្គងចំនួននីមួយៗនៃថវិកាដែលបេក្ខជន ឬ គណបក្សរៃអង្គាសបាន ជាមួយនឹងអត្រាជាភាគរយជាក់លាក់មួយ ឬរហូតដល់ចំនួនថវិកាកំណត់ណាមួយ (ឧទាហរណ៍ ២៥០ដុល្លារ នៅក្នុងការបោះឆ្នោតបឋមជ្រើសរើសប្រធានាធិបតីសហរដ្ឋអាមេរិច)។ អត្ថប្រយោជន៍នៃប្រព័ន្ធនេះគឺថា យន្តការនេះអនុញ្ញាតឲ្យមានការផ្តល់ហិរញ្ញប្បទានសាធារណៈដោយយោងទៅតាមការគាំទ្រផ្នែកហិរញ្ញវត្ថុពីសំណាក់សាធារណជនចំពោះអ្នកចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតនៅមុនពេលការបោះឆ្នោតផងដែរ ព្រមគ្នានេះ ប្រព័ន្ធ នេះក៏នឹងជួយលើកទឹកចិត្តអ្នកចូលរួមប្រកួតប្រជែងទាំងអស់ឲ្យរាយការណ៍អំពីវិភាគទានដែលខ្លួនបានទទួល ដែលការធ្វើដូច្នេះក៏នឹងជួយលើកកម្ពស់តម្លាភាពថែមទៀតផង។ ប្រសិនបើប្រព័ន្ធនេះមិនត្រូវបានប្រើប្រាស់ដោយភ្ជាប់ជាមួយការកំណត់កម្រិតអតិបរមាសម្រាប់ការធ្វើវិភាគទានឯកជនទេនោះ វាអាចជម្រុញឲ្យមានការរាយការណ៍ដោយមិនត្រឹមត្រូវអំពីវិភាគទានឯកជន ដែលជាហេតុនាំឲ្យមាន

ការលំបាកយ៉ាងខ្លាំងសម្រាប់បញ្ញត្តិករហិរញ្ញវត្ថុនយោបាយដែលមិនសូវមានសមត្ថភាពនៅក្នុងប្រទេសដែលទើបនឹងមានលទ្ធិប្រជាធិបតេយ្យក្នុងការធ្វើការអង្កេតរកការពិត។ ប្រទេសខ្លះទៀត បាន ផ្តល់ហិរញ្ញប្បទានសាធារណៈ ដោយផ្អែកទៅលើចំនួនបេក្ខជនដែលគណបក្សនយោបាយដាក់ឲ្យឈរឈ្មោះនៅក្នុងការបោះឆ្នោត។ ការធ្វើបែបនេះអាចត្រូវបានគេមើលឃើញថាជាកម្រិតវាស់វែងសមរម្យមួយទៅលើកម្រិតនៃការចូលរួមរបស់គណបក្សនយោបាយនៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោត។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធនេះមិនបានប្រាប់ឲ្យដឹងអំពីការឧបត្ថម្ភពីសំណាក់សាធារណជនដែលគណបក្សនយោបាយបានទទួលនោះទេ។

*តារាង ១១៖ មូលដ្ឋានគ្រឹះនៃរូបមន្តបែងចែកហិរញ្ញប្បទានសាធារណៈ*

| មូលដ្ឋានគ្រឹះ | យោបល់ | ឧទាហរណ៍ |
|---|---|---|
| ភាគរយនៃសម្លេងឆ្នោតដែលទទួលបាន | នៅក្នុងការបោះឆ្នោតពីលើកមុន ឬ នៅក្នុងការបោះឆ្នោតដែលហិរញ្ញប្បទានត្រូវបានផ្តល់ (ករណីនេះសម្រាប់តែហិរញ្ញប្បទានដែលនៅក្នុងទម្រង់ជាការទូទាត់ជាក្រោយ)។ | ប្រទេសអង់ដូរ៉ា អ៊ីតាលី កូស្តារីកា |
| អាសនៈដែលបានឈ្នះនៅក្នុងស្ថាប័នដែលកើតពីការបោះឆ្នោត | ប្រសិនបើផ្អែកទៅលើអសនៈដែលបានឈ្នះនៅក្នុងការបោះឆ្នោតលើកមុន គេមិនគួរគិតអំពីការផ្លាស់ប្តូរនៅក្នុងហិរញ្ញប្បទានសាធារណៈដែលធ្វើឡើងនៅក្នុងចន្លោះពេលបោះឆ្នោតទេ។ | ប្រទេសបេនីន ប៊ុលហ្គារី ហ្វាំងឡង់ |
| ចំនួនបេក្ខជនឈរឈ្មោះ | អាចផ្តល់ជាការលើកទឹកចិត្តសម្រាប់គណបក្សនយោបាយក្នុងការដាក់ពង្រាយបេក្ខជនដើម្បីទទួលបានមូលនិធិយ៉ាងសាមញ្ញ | កោះខេបវើត ប្រទេសបារាំង (ចម្រុះគ្នា) |
| ចំនួនសមាជិករបស់គណបក្សនយោបាយ | បញ្ជីសមាជិកភាពរបស់គណបក្សជារឿយៗមានការពិបាកក្នុងការជឿជាក់ណាស់ ករណីនេះមានដូចគ្នានៅក្នុងប្រទេសដែលទើបនឹងមានប្រជាធិបតេយ្យដែរ។ | ប្រទេសម៉ាល់ឌីវ អាល្លឺម៉ង់ (ចម្រុះគ្នា) |
| មូលនិធិផ្គូផ្គង | ចំនួនទឹកប្រាក់ដែលគណបក្សនីមួយទទួលបានអាស្រ័យទៅលើចំនួនដែលគណបក្សនោះរៃអង្គាសបានពីប្រភពឯកជន។ | សហរដ្ឋអាមេរិក កាណាដា |

## *កម្រិតនៃហិរញ្ញប្បទានសាធារណៈ*

បញ្ហាមួយទៀតពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាងសាធារណៈ និង ឯកជន ។ លោក*ណាសស្មាឈ័រ* (Nassmacher) បានកត់សម្គាល់ថា "ដោយសារគណបក្សនយោបាយមិនអាចក្លាយទៅជាទីភ្នាក់ងារសាធារណៈក៏ប៉ុន្តែនៅតែស្ថិតនៅក្នុងឋានៈជាស្ថាប័នឯកជន ដូចនេះ **ហិរញ្ញប្បទានសាធារណៈគួរតែគ្របដណ្តប់ទៅលើតែផ្នែកខ្លះនៃការចំណាយរបស់គណបក្សនយោបាយតែប៉ុណ្ណោះ**។ ភាពចាំបាច់ក្នុងការស្វះស្វែងឲ្យមានតុល្យភាពរវាងហិរញ្ញប្បទានសាធារណៈនិងមូលនិធិឯកជន មានលក្ខណៈជិតស្និទ្ធទៅនឹងការយល់ដឹងឲ្យកាន់តែទូលំទូលាយតាមដែលគេអាចធ្វើទៅបាននៅក្នុងការពិភាក្សាដេញដោលទៅលើប្រធានបទហិរញ្ញវត្ថុនយោបាយ ។ ការរួមបញ្ចូលគ្នារវាងហិរញ្ញប្បទានទាំងពីរប្រភេទនេះ គឺជាទម្រង់ដែលមានការប្រើប្រាស់ច្រើនបំផុតនៃប្រព័ន្ធហិរញ្ញប្បទាននយោបាយនៅទូទាំងពិភពលោកនាពេលបច្ចុប្បន្ននេះ។

ទោះជាយ៉ាងណាក៏ដោយ គេពុំមានការព្រមព្រៀងគ្នាជាឯកច្ឆន្ទថាតើ អ្វីគួរជាតុល្យភាពនៃហិរញ្ញប្បទាននោះទេ។ វាមិនមែនជារឿងងាយស្រួលឡើយក្នុងការប៉ាន់ប្រមាណចំណែកនៃចំណូលរបស់គណបក្សនយោបាយដែលបានទទួលពីប្រភពសាធារណៈ ព្រោះថារាល់ព័ត៌មានដែលយើងបានទទួលអាចជាព័ត៌មានដែលមិនអាចទុកចិត្តបាន ចំណែកទាំងចំណូលដែលបានមកពីប្រភពសាធារណៈ និង ឯកជនក៏អាចត្រូវបានគេកំណត់ក្នុងមធ្យោបាយខុសៗពីគ្នាផងដែរ។ ទោះជាយ៉ាងនេះក្ដី គណបក្សនយោបាយនៅក្នុងប្រទេសអេស្ប៉ាញ និង ម៉ិចស៊ិច ពឹងផ្អែកទៅលើហិរញ្ញប្បទានរបស់រដ្ឋប្រមាណ៩០% ខណៈដែលនៅក្នុងប្រទេសអេហ្ស៊ីបវិញ ចំនួនទឹកប្រាក់ដែលបានពីហិរញ្ញប្បទានសាធារណៈមានតិចតួចបំផុត ដែលគេមើលឃើញថា "គ្រាន់តែជានិមិត្តរូប" ប៉ុណ្ណោះ។ នៅពេលនោះ ហិរញ្ញប្បទានសាធារណៈ មានលក្ខណៈគ្រាន់តែជាល្បែងផ្តិនភ្នែកដើម្បីបង្ហាញអំពីទីលានប្រកួតប្រជែងស្មើភាពក្លែងក្លាយមួយតែប៉ុណ្ណោះ តែមិនមែនជាការកែទម្រង់មួយពិតប្រាកដឆ្ពោះទៅរកការធ្វើឲ្យមានសមភាពរបស់គណបក្សនយោបាយនោះទេ។ ការពឹងផ្អែកទៅលើហិរញ្ញប្បទានសាធារណៈ (យ៉ាងហោចណាស់នៅក្នុងទ្វីបអឺរ៉ុប) មានទំនោរទៅរកភាពខុសប្លែកគ្នាអាស្រ័យទៅលើប្រភេទ និង មនោគមវិជ្ជានៃគណបក្សនយោបាយ ថ្វីបើភាពការផ្លាស់ប្តូរដ៏គួរឲ្យកត់សម្គាល់ដែលបានកើតមានក្នុងរយៈកាលប៉ុន្មានទសវត្សចុងក្រោយនេះក៏ដោយ។ គណបក្សនយោបាយតូចៗមាននិន្នាការពឹងផ្អែកយ៉ាងខ្លាំងទៅលើហិរញ្ញប្បទានសាធារណៈជាងគណបក្សធំៗ។

*តារាង ១២៖ កម្រិតហិរញ្ញប្បទានសាធារណៈដែលប្រើប្រាស់នៅក្នុងប្រទេសខុសៗគ្នា*

| | |
|---|---|
| គ្មានហិរញ្ញប្បទានសាធារណៈ | អាហ្វហ្គានីស្ថាន បាហាម៉ា ហ្គាណា ញូហ្ស៊ីឡែន |
| ប្រព័ន្ធដែលមូលនិធិឯកជនគ្របដណ្ដប់ | ចក្រភពអង់គ្លេស សហរដ្ឋអាមេរិច អ៊ីតាលី អូស្ត្រាលី អេហ្ស៊ីប |
| ប្រព័ន្ធដែលហិរញ្ញប្បទានសាធារណៈ និង ឯកជនស្មើគ្នា | ដាណឺម៉ាក បារាំង ជប៉ុន |
| ប្រព័ន្ធដែលហិរញ្ញប្បទានសាធារណៈគ្របដណ្ដប់ | អូទ្រីស ស៊ុយអែត ហុងហ្គារី ម៉ិចស៊ិច ព័រទុយហ្គាល់ |
| មានតែហិរញ្ញប្បទានសាធារណៈ | អ៊ូសបេគីស្ថាន |

## *៧. ពេលវេលានៃការបែងចែកហិរញ្ញប្បទានសាធារណៈ*

ហិរញ្ញប្បទានដែលមានគោលដៅជួយឧបត្ថម្ភយុទ្ធនាការឃោសនាបោះឆ្នោត ត្រូវបានផ្ដល់មុន ពេល និង/ ឬក្រោយពេលបោះឆ្នោត។ ប្រសិនបើ ហិរញ្ញប្បទានទាំងនោះត្រូវបានផ្ដល់មុនពេលបោះឆ្នោត គេអាចប្រើប្រាស់វាដោយផ្ទាល់នៅក្នុងយុទ្ធនាការឃោសនា ក៏ប៉ុន្តែប្រសិនបើថវិកាសមាមាត្រត្រូវបានគេយកទៅប្រើប្រាស់ (តាមធម្មតា) ការធ្វើដូច្នេះត្រូវតែពឹងផ្អែកទៅលើសម្លេងគាំទ្រដែលគណបក្សនយោបាយទទួលបានពីពេលមុន ដែលការនេះអាចនឹងរារាំងដល់ការផ្លាស់ប្តូរគាំទ្រនៅក្នុងការឧបត្ថម្ភធនសាធារណៈសម្រាប់គណបក្សខុសៗគ្នា ពីការជះឥទ្ធិពលទាំងស្រុងដល់លទ្ធផលបោះឆ្នោត។ ការពន្យាពេលក្នុងការផ្តល់ ហិរញ្ញប្បទានសាធារណៈរហូតកៀកនឹងថ្ងៃបោះឆ្នោតត្រូវបានអនុវត្តក្នុងរបបដែលមិនសូវមានលទ្ធិប្រជាធិបតេយ្យក្នុងគោលបំណងរារាំងការប្រកួតប្រជែងដោយប្រសិទ្ធភាព ពីគណបក្សប្រឆាំង។ ម្យ៉ាងវិញទៀត ហិរញ្ញប្បទានអាចត្រូវបានគេផ្តល់ឲ្យនៅពេលក្រោយបន្ទាប់ពីការបោះឆ្នោត ។ ការអនុវត្តបែបនេះអនុញ្ញាតឲ្យគេកំណត់បាននូវចំនួនទឹកប្រាក់ដែលត្រូវផ្តល់ហិរញ្ញប្បទាន តាមរយៈលទ្ធផលដែលអ្នកប្រកួតប្រជែងនៅក្នុងការបោះឆ្នោតទទួលបានក្រោយពីការបោះឆ្នោតបានបញ្ចប់ ចំណែកឯមូលនិធិផ្តួងវិញអាចត្រូវបានគេប្រើប្រាស់ដើម្បីពង្រឹងចំណងទាក់ទងរវាងគណបក្សនយោបាយ និង ក្រុមអ្នកគាំទ្ររបស់ពួកគេ។

អត្ថប្រយោជន៍មួយផ្សេងទៀតគឺថា រដ្ឋអាចដកហូតថវិកានោះមកវិញ ប្រសិនបើគណបក្សនយោបាយ ឬ បេក្ខជនមិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវឲ្យមានការរបាយការណ៍ហិរញ្ញវត្ថុ។

ទោះជាយ៉ាងណាក៏ដោយ ការផ្តល់ ហិរញ្ញប្បទានសម្រាប់យុទ្ធនាការឃោសនានៅក្រោយពេលបោះឆ្នោតជារឿយៗមានន័យថាគណបក្សនយោបាយចាំបាច់ត្រូវការកម្ចីដើម្បីយកមកប្រើប្រាស់ក្នុងយុទ្ធនាការរបស់ពួកគេ។ ការនេះបង្កជាការលំបាកសម្រាប់គណបក្សណាដែលមិនអាចស្វែងរកមូលនិធិកម្ចីបាន ជាពិសេសនៅក្នុងស្ថានភាពដែលលទ្ធផលនៃការបោះឆ្នោតពិបាកនឹងទាយទុកជាមុន។ ក្នុងតំបន់ណាដែលវិស័យធនាគារមិនសូវមានការរីកចំរើនប្រព័ន្ធបែបនេះក៏អាចជាឧបសគ្គផងដែរសម្រាប់គណបក្សនយោបាយតូចៗ ដែលអាចជាហេតុនាំឲ្យគេរិតតែបង្កើនការពឹងអាស្រ័យថែមទៀតទៅលើក្រុមជនអ្នកមានទ្រព្យសម្បត្តិមួយក្រុមតូច។ ការធ្វើហិរញ្ញប្បទានតាមបែបប្រយោលដូចជា ការឧបត្ថម្ភធនផ្នែកប្រព័ន្ធផ្សព្វផ្សាយ ជាដើម អាចត្រូវបានផ្តល់នៅមុន ពេលបោះឆ្នោតដើម្បីជួយកាត់បន្ថយបញ្ហាខាងលើនេះ រីឯហិរញ្ញប្បទានដោយផ្ទាល់វិញ ជាការពិតណាស់ អាចត្រូវបានផ្តល់ទាំងមុន និង ក្រោយពេលបោះឆ្នោត។ ជា ធម្មតា ប្រព័ន្ធ មួយចំនួនអាចត្រូវបានគេបង្កើតឡើង ដែលផ្នែកខ្លះនៃហិរញ្ញប្បទានត្រូវបានផ្តល់មុនពេលបោះឆ្នោត និងផ្នែកខ្លះទៀតអាចត្រូវបានផ្តល់ក្រោយពេលបោះឆ្នោត។

ហិរញ្ញប្បទានដែលមានលក្ខណៈបន្ត តាមធម្មតាត្រូវបានផ្តល់ប្រចាំឆ្នាំ ឬ ញឹកញាប់ជាងនេះ (ដូចជាការផ្តល់ឲ្យជារៀងរាល់ត្រីមាស ដូចដែលគេបានអនុវត្តនៅក្នុងប្រទេសប៊ុលហ្គារី កាណាដា និងក្រូអា ស៊ី)។ លក្ខណៈវិនិច្ឆ័យសំខាន់ៗគឺថា ការផ្តល់ហិរញ្ញប្បទានបែបនេះគេអាចទស្សន៍ទាយបាន និង មានលក្ខណៈទៀងទាត់។ ជម្រើសមួយទៀតដែលមិនសូវសមស្របគឺការផ្តល់វិភាគទានដោយផ្អែកទៅលើមូលដ្ឋានបណ្តោះអាសន្ន ដូចដែលគេបានអនុវត្តនៅក្នុងប្រទេសប្រេស៊ីល ឆាត និង ហ្គាបុង។

*តារាង ១៣៖ ពេលវេលានៃការបែងចែកហិរញ្ញប្បទាន*

| ពេលវេលាដែលត្រូវផ្តល់ | ឃោបល់ | ឧទាហរណ៍ |
|---|---|---|
| មុនពេលបោះឆ្នោត | រូបមន្តនៃការបែងចែកជាធម្មតាត្រូវផ្អែកទៅលើលទ្ធផលបោះឆ្នោតពីលើកមុន | ប្រទេសអាហ្សង់ទីន<br>រុស្ស៊ី |
| ក្រោយពេលបោះឆ្នោត | អាចធ្វើឲ្យប៉ះពាល់គណបក្សនយោបាយ និង បេក្ខជនដែលជួបការលំបាកក្នុងការរៃអង្គាសមូលនិធិជាមុន។ | ប្រទេសកាណាដា កូឡុំប៊ី បារាំង |
| ចន្លោះពេលបោះឆ្នោត (ការផ្តល់ថវិកាជាបន្ត) | (ជាធម្មតា) ប្រើប្រាស់សម្រាប់ជួយដល់សកម្មភាពដែលមិនទាក់ទងនឹងការបោះឆ្នោតរបស់គណបក្ស។ | ប្រទេសអៀឡង់ ខេបវើត ព័រទុយហ្គាល់ |

## ការប្រើប្រាស់ហិរញ្ញប្បទានសាធារណៈដើម្បីជម្រុញការកែទម្រង់

ក្នុងខណៈដែលហិរញ្ញប្បទានសាធារណៈ ត្រូវបានគេដាក់ឲ្យប្រើប្រាស់យ៉ាងទូលំទូលាយបំផុតដើម្បីសម្រេចឲ្យបានគោលដៅដូចដែលយើងបានពិភាក្សារួចមកហើយក្នុងការសិក្សានេះ ជួលកាលហិរញ្ញប្បទាននេះត្រូវបានគេប្រើប្រាស់ដើម្បីសម្រេចបានគោលបំណងដទៃទៀតផងដែរ។ គោលបំណងដែលសាមញ្ញជាងគេបំផុតនោះ គឺដើម្បី

លើកកម្ពស់តម្លាភាព និងដើម្បីគ្រប់គ្រងចំណូល និង ចំណាយរបស់អ្នកប្រកួតប្រជែងក្នុងការបោះឆ្នោត។ ដើម្បី ទទួលបានហិរញ្ញប្បទានសាធារណៈ ជាទូទៅគណបក្សនយោបាយ និង បេក្ខជន (ទោះបីជាមានករណីលើកលែងចំពោះប្រទេសខ្លះដូចជា ហ្វាំងឡង់ ស៊ុយអែត និងណាមីប៊ីជាដើម) ត្រូវតែរាយការណ៍អំពីការប្រើប្រាស់ហិរញ្ញប្បទានសាធារណៈ។ នៅក្នុងប្រទេសមួយចំនួន ការតម្រូវចាំបាច់ក្នុងការធ្វើរបាយការណ៍ ក៏ត្រូវគ្របដណ្តប់ទៅលើថវិកាដែលបានមកពីប្រភពឯកជនផងដែរ។ ការគម្រាមដកហិរញ្ញប្បទានសាធារណៈចេញវិញអាចត្រូវបានគេចាត់ទុកថាជាឧបករណ៍មួយក្នុងចំណោមឧបករណ៍សំខាន់ៗឯទៀតដើម្បីធានាការអនុវត្តតាមលក្ខខណ្ឌតម្រូវឲ្យធ្វើរបាយការណ៍សម្រាប់គណបក្សនយោបាយ និង បេក្ខជន។

គោលដៅសាមញ្ញមួយទៀតនៃហិរញ្ញប្បទានសាធារណៈ គឺដើម្បីកាត់បន្ថយកម្រិតចំណាយ ពេលបោះឆ្នោតតាមរយៈការចងភ្ជាប់បញ្ញត្តិនៃហិរញ្ញប្បទាននេះទៅនឹងដែនកំណត់ចំណាយ។ យន្តការបែបនេះត្រូវបានគេប្រើប្រាស់សម្រាប់ការបោះឆ្នោតប្រធានាធិបតីនៅសហរដ្ឋអាមេរិក ។ លោកប្រធានាធិបតីបារ៉ាក់ អូបាម៉ា ( Barack Obama) គឺជាបេក្ខជនដំបូងគេបំផុតដែលបានបដិសេធការទទួលយកហិរញ្ញប្បទានសធារណៈ ដែលការនេះបានអនុញ្ញាតឲ្យគាត់ធ្វើការរៃអង្គាសប្រាក់ដោយស្របច្បាប់នៅក្នុងចំនួនមួយដែលគេមិនបានប្រាប់ឲ្យដឹងសម្រាប់យុទ្ធនាការរបស់គាត់។

នៅមានអត្ថប្រយោជន៍ផ្សេងៗទៀតដែលគេអាចទទួលបានពីហិរញ្ញប្បទានសាធារណៈ។ ប្រទេសបារាំងបានភ្ជាប់ផ្នែកខ្លះនៃហិរញ្ញប្បទានសាធារណៈទៅនឹងបញ្ហាសមភាពយេនឌ័រកាលពីឆ្នាំ១៩៨៨។ ប្រសិនបើគណបក្សនយោបាយណាមានវិសមភាពយេនឌ័រលើសពី ២% នៃបេក្ខជន សរុបរបស់ខ្លួន គណបក្សនោះនឹងត្រូវបាត់បង់ហិរញ្ញប្បទានសាធារណៈមួយភាគស្មើនឹងពាក់កណ្តាលនៃវិសមភាពយេនឌ័រនៅក្នុងគណបក្សនោះ។ លទ្ធផលចេញមកពីការធ្វើដូច្នោះពុំមានភាពច្បាស់លាស់ទាំងស្រុងនោះទេ។ ក្នុងខណៈដែល កូតានៃចំនួនស្ត្រីនៅក្នុងរដ្ឋសភាបារាំងបានកើនឡើងពីចំនួនតិចបំផុត ៥% ក្នុងឆ្នាំ ១៩៨០ រហូតដល់ ១៨% ក្នុងឆ្នាំ ២០០៩ នៅមានកត្តាផ្សេងៗទៀតដែលត្រូវការយកមកពន្យល់អំពីការផ្លាស់ប្តូរនេះ។ គណបក្សនយោបាយ ក៏មានការយឺតយ៉ាវខ្លះៗដែរក្នុងការសម្របខ្លួនទៅតាមវិធានទាំងនេះ ដែល ជាហេតុធ្វើឲ្យពួកគេបាត់បង់ថវិការួមគ្នាចំនួន ៧លានអឺរ៉ូ នៅក្នុងហិរញ្ញប្បទានសាធារណៈក្នុងចន្លោះពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៧។ អភិក្រមស្រដៀងគ្នានេះត្រូវបានប្រទេសក្រូអាស៊ី យកទៅអនុវត្តក្នុងឆ្នាំ១៩៩៣ ដោយមានការផ្តល់ហិរញ្ញប្បទានសាធារណៈចំនួន ១០% បន្ថែមទៀតដល់គណបក្សនយោបាយសម្រាប់បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតម្នាក់ៗនៃ "ក្រុមយេនឌ័រដែលខ្វះភាពជាតំណាង"។ ជាថ្មីម្តងទៀត លទ្ធផលនៃកំណែទម្រង់នេះអាចត្រូវបានលើកយកមកធ្វើការពិភាក្សាដេញដោល។ ខណៈដែល ភាពជាតំណាងរបស់ស្ត្រីបានកើនឡើងពី ៥% ទៅ ៨% និងបន្ទាប់មក ២៣% នៅឆ្នាំ ១៩៩២ ១៩៩៥ និង ២០០០ជាបន្តបន្ទាប់ មានកត្តាជាច្រើនដែលអាចយកមកពន្យល់ការផ្លាស់ប្តូរនេះ ដោយរួមទាំងកត្តាមួយដែលថា ការបោះឆ្នោតកាលពីឆ្នាំ១៩៩២ គឺជាការបោះឆ្នោតពហុបក្សលើកទីពីរនៅប្រទេសក្រូអាស៊ី ចាប់តាំងពី ពេលដែលប្រទេសនេះទទួលបានឯករាជ្យមក។ ក្រៅពីនោះ គេមិនឃើញមានការរីកចម្រើនបន្ថែមទៀតទេនៅក្នុងភាពជាតំណាងរបស់ស្ត្រីនៅក្នុងការបោះឆ្នោតពីរលើកចុងក្រោយនេះ។

## បញ្ហាជាសក្តានុពលនានា

## សេចក្តីផ្តើម

មកដល់ត្រឹមនេះ យើងបានពិភាក្សារួចហើយអំពី គោលបំណងនៃប្រព័ន្ធហិរញ្ញប្បទានសាធារណៈ ព្រមទាំងរបៀបដែលប្រព័ន្ធនេះអាចត្រូវបានបង្កើតឡើង។ គុណវិបត្តិដែលអាចកើតមានដោយសារហិរញ្ញប្បទាននេះក៏ត្រូវបានកំណត់រួចហើយដែរ ក៏ប៉ុន្តែពេលនេះ យើងចាំបាច់ត្រូវដោះស្រាយបញ្ហាជាសក្តានុពលនានាដោយផ្ទាល់ ដែលកើតឡើងពីហិរញ្ញប្បទានសាធារណៈ។ តាមរយៈគោលបំណងដែលយើងបានពិភាក្សារួចមកហើយ ចំណុចចាប់ផ្តើមដ៏មានសារៈសំខាន់មួយគឺ បញ្ហាមួយចំនួនដែលយើងបានកំណត់រួចហើយនៅក្នុងអត្ថបទដែលមានស្រាប់។

*តារាង១៤៖ បញ្ហាជាសក្តានុពលនានាដែលអាចកើតមាននៅពេលធ្វើហិរញ្ញប្បទានសាធារណៈ*

| | |
|---|---|
| **របាយការណ៍របស់នៀល** (Neill) | • អ្នកបង់ពន្ធមិនគួរត្រូវបានបង្ខិតបង្ខំឲ្យធ្វើវិភាគទានដើម្បីទ្រទ្រង់គណបក្សនយោបាយដែលពួកគេបានជំទាស់យ៉ាងខ្លាំងទៅនឹងបែបផែន និង គោលនយោបាយរបស់គណបក្សទាំងនោះឡើយ។<br>• វាអាចធ្វើឲ្យប្រព័ន្ធគណបក្សដែលមានស្រាប់... ពិបាកនឹងផ្លាស់ប្តូរជាមួយនឹងគណបក្សជាមួយនឹងគណបក្សនយោបាយដែលមានស្រាប់ដែលងាយស្រួលក្នុងការទទួលបានថវិកាពីរដ្ឋ ក៏ប៉ុន្តែជាមួយនឹងគណបក្សនយោបាយថ្មីៗដែលត្រូវតែពុះពារយ៉ាងលំបាកដើម្បីទទួលបានធនធានទាំងនោះ។<br>• ប្រសិនបើគណបក្សនយោបាយមានការពឹងផ្អែកទៅលើថវិការដ្ឋ ពួកគេអាចនឹងត្រូវបានបញ្ចុះបញ្ចូល...ឲ្យបោះបង់ចោលកិច្ចខិតខំប្រឹងប្រែងយ៉ាងមោះមុតរបស់ខ្លួន ដែលបច្ចុប្បន្ននេះមានគណបក្សមួយចំនួនធ្វើការអែអង្គាសប្រាក់នៅតាមមូលដ្ឋាន (តាមរយៈការចាប់ឆ្នោតផ្សងសំណាង ល្បែងភ្នាល់ ព្រឹត្តិការណ៍កំសាន្ត។ល។)<br>• [ហិរញ្ញប្បទានសាធារណៈប្រហែលជាអាច] ធ្វើឲ្យគណបក្សនយោបាយក្លាយជាផ្នែកមួយនៃរដ្ឋ។ ជំនួសឲ្យការធ្វើជាតំណាងរបស់ពលរដ្ឋទៅនឹងរដ្ឋ គណបក្សនយោបាយត្រូវបានជម្រុញឲ្យធ្វើជាតំណាងរបស់រដ្ឋទៅនឹងពលរដ្ឋវិញ។ |
| **លោក ណាម៉ាសឈ័រ** (Nassmacher) | • ឯករាជ្យភាពរបស់គណបក្សអាចត្រូវបានធ្វើឲ្យប៉ះពាល់ដោយសារការពឹងផ្អែករបស់ពួកគេទៅលើថវិការបស់រដ្ឋ។ នេះគឺជាបញ្ហាចម្បងមួយនៅក្នុងប្រទេសដែលស្ថិតនៅក្នុងដំណាក់កាលនៃការផ្លាស់ប្តូរ ដែលគណបក្សធំៗកំពុងកាន់អំណាច។<br>• ការសម្រេចចិត្តទៅលើចំនួន និង ការបែងចែកហិរញ្ញប្បទានសាធារណៈអាចមានភាពមិនយុត្តិធម៌ចំពោះគណបក្សប្រឆាំង។<br>• ការស្ទង់មតិនានាបានបង្ហាញថាឧបត្ថម្ភធនផ្នែកហិរញ្ញវត្ថុសម្រាប់គណបក្សនយោបាយអប្រជាប្រិយភាពយ៉ាងខ្លាំងក្នុងចំណោមពលរដ្ឋសាមញ្ញ។ |
| **លោកកាសា ហ្សាម៉ូរ៉ា** Casas-Zamora | • [ហិរញ្ញប្បទានសាធារណៈ] មិនអាចជំនួសឲ្យជំនួយឧបត្ថម្ភពីប្រភពឯកជនបានឡើយ ហើយប្រសិទ្ធភាពរបស់ហិរញ្ញប្បទានសាធារណៈនៅមានកម្រិតយ៉ាងខ្លាំងក្នុងការប្រឆាំងអំពើពុករលួយ។<br>• [ហិរញ្ញប្បទានសាធារណៈ] មានការរំខានទៅដល់ការប្រកួតប្រជែងក្នុងការបោះឆ្នោត និងធ្វើឲ្យប្រព័ន្ធគណបក្សមានការពិបាកនឹងផ្លាស់ប្តូរ។<br>• [ហិរញ្ញប្បទានសាធារណៈ] ផ្តល់ឲ្យគណបក្សនយោបាយនូវធនធានដែលធ្វើឲ្យអន្តរាយដល់សាមគ្គីភាពនៅក្នុងសង្គម លទ្ធិប្រជាធិបតេយ្យផ្ទៃក្នុង និង ស្វ័យភាព។ |
| **សភាជាតិអូស្រ្តាលី** | • ហិរញ្ញប្បទានសាធារណៈអាចប៉ះពាល់ដល់ឯករាជ្យភាពរបស់គណបក្ស និងធ្វើឲ្យគណបក្ស |

| | |
|---|---|
| **គណៈកម្មាធិការចម្រុះ** | ពឹងផ្អែកទៅលើរដ្ឋ។<br>• ហិរញ្ញប្បទានសាធារណៈអាចនាំឲ្យគណបក្សលែងយកចិត្តទុកដាក់ទៅលើសមាជិករបស់ពួកគេ និង ក្រុមសង្គមស៊ីវិលទូទៅ។<br>• ការសម្រេចចិត្តទៅលើចំនួន និងការបែងចែកថវិកាអាចមិនយុត្តិធម៌ចំពោះគណបក្សតូចៗ គណបក្សនយោបាយដែលទើបបង្កើតថ្មី និង/ឬ គណបក្សប្រឆាំង។<br>• ហិរញ្ញប្បទានសាធារណៈអាចជួយប្រមូលផ្តុំអំណាចរបស់គណបក្សធំៗ និង រារាំងការផ្លាស់ប្តូរប្រព័ន្ធគណបក្ស។<br>• ការស្ទង់មតិបានបង្ហាញថា ហិរញ្ញប្បទានសាធារណៈអប្រជាប្រិយភាពយ៉ាងខ្លាំងនៅក្នុងចំណោមប្រជាពលរដ្ឋសាមញ្ញដែលពួកគេអាចមើលឃើញថា វាជាអំណោយនយោបាយមិនស្មោះត្រង់។<br>• ប្រជាពលរដ្ឋអាចនឹងមិនយល់ស្របថា គណបក្សនយោបាយគឺជាអាទិភាពសម្រាប់ការប្រើប្រាស់ថវិការបស់រដ្ឋទេ។ |
| **សព្វវចនាធិប្បាយរបស់** ACE (ACE Encyclopedia) | • ហិរញ្ញប្បទានសាធារណៈធ្វើឲ្យមានគម្លាតកាន់តែខ្លាំងរវាងអ្នកនយោបាយ (មេដឹកនាំគណបក្ស បេក្ខជន) និងប្រជាពលរដ្ឋសាមញ្ញ (សមាជិកបក្ស អ្នកគាំទ្របក្ស អ្នកបោះឆ្នោត)។<br>• ហិរញ្ញប្បទានសាធារណៈអភិរក្សប្រព័ន្ធនយោបាយមួយដែលគ្មានការផ្លាស់ប្តូរដែលជួយរក្សាអំណាចរបស់គណបក្ស និង បេក្ខជនដែលបានចាក់គ្រឹះយ៉ាងរឹងមាំ។<br>• តាមរយៈហិរញ្ញប្បទានសាធារណៈ អ្នកបង់ពន្ធត្រូវបង្ខំចិត្តជួយឧបត្ថម្ភគណបក្សនិងបេក្ខជនដែលអ្នកបង់ពន្ធមានទស្សនៈមិនស្របជាមួយ។<br>• ហិរញ្ញប្បទានសាធារណៈដែលបានផ្តល់ទៅឲ្យគណបក្សយោបាយ និង បេក្ខជនបានដណ្តើមយកធនធានពីការអភិវឌ្ឍសាលារៀន និង មន្ទីរពេទ្យ យកទៅឲ្យពួកអ្នកនយោបាយដែលមានធនធានច្រើន។<br>• គណបក្សនយោបាយ និង បេក្ខជនគឺជាអ្នកអនុវត្តសេចក្តីសម្រេចចិត្ត និង ប្រមូលលុយ។<br>• គណបក្សនយោបាយប្រឈមទៅនឹងការប្រែក្លាយខ្លួនទៅជាអង្គការរបស់រដ្ឋជាជាងក្លាយទៅជាផ្នែកមួយរបស់សង្គមស៊ីវិល។ |

តាមរយៈតារាង១៤ខាងលើ គេអាចអះអាងបានថា មានបញ្ហាជាសក្តានុពលជាច្រើនដែលគេបានលើកឡើងជាទូទៅ ដែលពាក់ព័ន្ធទៅនឹងហិរញ្ញប្បទានសាធារណៈសម្រាប់គណបក្សនយោបាយ និង បេក្ខជន៖

- ការកាត់ផ្តាច់ (គណបក្សនយោបាយបាត់បង់ការទាក់ទងជាមួយនឹងប្រជាពលរដ្ឋ)
- ការរឹងត្អឹង/ការមិនអាចសម្របបាន (ប្រព័ន្ធគណបក្សមិនអាចសម្របខ្លួនទៅនឹងទំនោរថ្មីៗនៅក្នុងការជួយឧបត្ថម្ភ)។
- ការប្រើអំណាចគ្របដណ្តប់ (គណបក្សគ្រប់គ្រងអំណាចអាចប្រើប្រាស់ហិរញ្ញប្បទានសាធារណៈដើម្បីពង្រឹងអំណាចរបស់ខ្លួន)។
- អប្រជាប្រិយភាព (ហិរញ្ញប្បទានសាធារណៈសម្រាប់គណបក្សនយោបាយ និង បេក្ខជនជាធម្មតាមិនសូវមានប្រជាប្រិយភាពនោះទេ)។

ជាអកុសល ស្ទើរតែ គ្រប់ការសិក្សាទាំងអស់លើបញ្ហានានាដែលពាក់ព័ន្ធទៅនឹងហិរញ្ញប្បទានសាធារណៈធ្វើឡើងតែទៅលើប្រទេសដែលលទ្ធិប្រជាធិបតេយ្យមានភាពចាស់ទុំតែប៉ុណ្ណោះ ដូច្នេះហើយបានជាការយល់ដឹង

របស់យើងទៅលើឥទ្ធិពល និង បញ្ហាជាសក្តានុពលនានានៃហិរញ្ញប្បទានសាធារណៈនៅក្នុងផ្នែកដទៃទៀតនៃពិភព លោកនៅមានកម្រិតយ៉ាងខ្លាំង។

ប្រសិនបើគណបក្សនយោបាយទទួលបានថវិកាគ្រប់គ្រាន់ពីរដ្ឋ គេ មានការបារម្ភថាគណបក្សទាំងនោះនឹង មិនចាំបាច់ស្វះស្វែងរកជំនួយពីសមាជិករបស់ខ្លួនទៀតទេ ដែលជាហេតុធ្វើឲ្យគណបក្សទាំងនោះក៏ពុំសូវផ្តោតការ យកចិត្តទុកដាក់ទៅលើបំណងប្រាថ្នារបស់សមាជិកពួកគេប៉ុន្មានដែរ។ ជាយថាហេតុ គណបក្សទាំងនោះអាចគ្រាន់ តែជាអ្នកតំណាងរបស់រដ្ឋតែប៉ុណ្ណោះ តែមិនបានតំណាងឲ្យប្រជាពលរដ្ឋទូទៅទេ។ លោក*ហ្សែន កាយ៉ា* (Genckaya) បានលើកឡើងថា "នៅក្នុងប្រទេសទួគី ជំនួយដោយផ្ទាល់របស់រដ្ឋបានធ្វើឲ្យគណបក្សនយោបាយដែលមានលក្ខណៈ សម្បត្តិសមស្របមានការពឹងផ្អែកផ្នែកហិរញ្ញវត្ថុទៅលើប្រភពមូលនិធិបែបនេះ" ចំណែកឯលោកណាម៉ាសឈ័របាន ធ្វើការកត់សម្គាល់យ៉ាងដូច្នេះថា៖

*"ប្រសិនបើអន្តរកាលដំបូងឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យអំពាវនាវឲ្យមានការផ្តល់ជំនួយបន្ថែមទៀតយ៉ាង ច្រើនសន្ធឹកសន្ធាប់ទៅក្នុងកញ្ចប់ថវិការបស់គណបក្សនយោបាយ របបហិរញ្ញវត្ថុនយោបាយគួរកំណត់អំពីរយៈពេល ដែលត្រូវបញ្ចប់ ឬ កាត់បន្ថយការឧបត្ថម្ភធនរបៀបនេះ។ ប្រសិនបើគណបក្សនយោបាយមិនបានបង្កើតឲ្យមាននូវ បណ្តាញទំនាក់ទំនងជាអចិន្ត្រៃយ៍ជាមួយផ្នែកនានានៃសង្គមស៊ីវិលទេ គណបក្សនយោបាយទាំងនោះនឹងមិនបាន ចូលរួមក្នុងការធ្វើឲ្យមានលទ្ធិប្រជាធិបតេយ្យប្រកបដោយចិរភាពឡើយ។ ដូចគ្នានេះដែរ ប្រសិនបើបណ្តាញទំនាក់ ទំនងនោះមិនបង្កើតឲ្យមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុទេ បណ្តាញនោះក៏នឹងពុំអាចចាក់ឫសយ៉ាងជ្រៅនៅក្នុង រយៈពេលវែងបានដែរ"។*

ហិរញ្ញប្បទានសាធារណៈត្រូវបានប្រើប្រាស់នៅក្នុងប្រទេសជាច្រើនសម្រាប់រយៈពេលខ្លីដែលគេមិនទាន់អាច មើលឃើញលទ្ធផលនៅឡើយ។ នៅមានកត្តាជាច្រើនទៀតផងដែរ ដែលបានជះឥទ្ធិពលលើសកម្មភាពរបស់គណ បក្សនយោបាយ ដែលគេមានការលំបាកក្នុងការបង្កើតទំនាក់ទំនងសាមញ្ញៗមួយចំនួន (គេឃើញមានការចុះថមថយ យ៉ាងខ្លាំងនូវសមាជិកភាពរបស់គណបក្សនៅក្នុងប្រទេសដែលលទ្ធិប្រជាធិតេយ្យមានភាពចាស់ទុំ ដោយមិនពាក់ព័ន្ធ ទៅនឹងបទបញ្ញាហិរញ្ញវត្ថុនយោបាយរបស់ពួកគេនោះទេ)។ ការសិក្សាមួយបានបង្ហាញថា នៅក្នុងប្រទេសលោកខាង លិចដែលនិយមលទ្ធិប្រជាធិបតេយ្យ ការដាក់ចេញឲ្យមានការប្រើប្រាស់ហិរញ្ញប្បទានសាធារណៈហាក់ដូចជាពុំបាន ជះឥទ្ធិពលអ្វីដល់ការកើនឡើង ឬ ការថយចុះសមាជិកភាពរបស់គណបក្សនយោបាយនោះទេ ។ ដូចដែលយើង បានគូសបញ្ជាក់ពីខាងលើស្រាប់ របៀបដែលប្រព័ន្ធហិរញ្ញប្បទានសាធារណៈត្រូវបានបង្កើតឡើងអាចជះឥទ្ធិពល យ៉ាងច្រើនប្រសិនបើមានការផ្តល់ហិរញ្ញប្បទានសាធារណៈទោះតាមមធ្យោបាយណាក៏ដោយ។ ប្រសិនបើ ការផ្តាច់ ទំនាក់ទំនងរវាងគណបក្សនយោបាយ និង បេក្ខជន ពីសមាជិក និងអ្នកគាំទ្ររបស់ពួកគេគឺជាបញ្ហាមួយសំខាន់ នោះ ការប្រើប្រាស់មូលនិធិផ្គូផ្គង និងការផ្តល់ការអនុគ្រោះពន្ធសម្រាប់វិភាគទាន(តិចតួច) ដើម្បីលើកទឹកចិត្ត ឲ្យមានការ ចូលរួមពីសាធារណជននោះក៏អាចជាដំណោះស្រាយមួយដែរ។

## *ការទាត់ផ្ដាច់ពីសមាជិក និង ក្រុមអ្នកគាំទ្រ*

អំណះអំណាងដែលគេលើកឡើងជាទូទៅដើម្បីជំទាស់ទៅនឹង ហិរញ្ញប្បទានសាធារណៈគឺថា ហិរញ្ញប្បទាននេះអាចនឹងបិទខ្ទប់ប្រព័ន្ធគណបក្សពីការចូលរួមរបស់អ្នកថ្មី និង/ឬ នាំទៅរក "ការរាំងស្ទះ" ភាពខ្លាំងបង្គួររបស់គណបក្សនយោបាយនៅក្នុងសភា ដែលនាំទៅលើការមិនអាចប្រែប្រួលបាន ឬ ការមិនអាចសម្របបាននៃប្រព័ន្ធគណបក្ស។ អ្នកស្រាវជ្រាវម្នាក់បានលើកឡើងថា "ដោយសារការបែងចែកថវិកាតាមមធ្យោបាយណាមួយត្រូវផ្អែកទៅលើលទ្ធផលនៃការបោះឆ្នោតពីលើកមុន គណបក្សនយោបាយដែលគ្មានវត្តមាននៅក្នុងការបោះឆ្នោតនៅពេលនោះ ជាពិសេសគណបក្សដែលទើបនឹងបង្កើតថ្មីៗនិងមិនទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធនោះទេ។ ដូច្នេះការអនុវត្តប្រព័ន្ធ ឧបត្ថម្ភធនរបស់រដ្ឋគឺជាកត្តាមួយដែលផ្តល់ផលប្រយោជន៍ដល់គណបក្សធំៗច្រើនជាងគណបក្សតូចៗ"។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវថ្មីៗនេះទៅលើប្រទេសប្រជាធិបតេយ្យចំនួន២៥បានបង្ហាញថា "គ្មានប្រទេសណាមួយធ្វើឧបត្ថម្ភធនសាធារណៈដែលនាំទៅរកការបិទខ្ទប់ ឬ ការធ្វើឲ្យរាំងស្ទះ (ឧទាហរណ៍៖ ការមិនអាចសម្របបាន/ ការមិនអាចប្រែប្រួលបាន) របស់គណបក្សនយោបាយឡើយ"។ ក្នុងខណៈដែលបណ្តាប្រព័ន្ធគណបក្សនយោបាយនៅអឺរ៉ុបនៅតែ មានស្ថេរភាពគួរឲ្យកត់សម្គាល់នៅឡើយនៅក្នុងកំឡុងពេលបន្ទាប់ពីសង្គ្រាម ការមិនអាចប្រែប្រួលបាននេះបានចាប់ផ្តើមមុនពេលមានការអនុវត្តប្រព័ន្ធហិរញ្ញប្បទានសាធារណៈទៅទៀត។

## *ការពង្រឹងអំណាចរបស់គណបក្សផុតអណត្តិ*

អំណះអំណាងដែលពាក់ព័ន្ធគ្នាមួយគឺថា ការផ្តល់ហិរញ្ញប្បទានសាធារណៈអាចយកទៅប្រើសម្រាប់ពង្រឹងអំណាចគ្របដណ្តប់របស់គណបក្សនយោបាយមួយ មិនមែនតែនៅក្នុងប្រទេសប្រជាធិបតេយ្យថ្មីថ្មោងនោះទេ។ លោក*អាឡិចសាន់ឌ័រ* ( Alexander) បានកត់សម្គាល់ថា "ហិរញ្ញប្បទានសាធារណៈអាចបន្ថែមអំណាចថែមទៀតដល់រដ្ឋាភិបាល ប្រសិនបើគណបក្សកាន់អំណាចទទួលបានអំណាចត្រួតត្រាទៅលើមូលនិធិនៃគូប្រឆាំងរបស់ខ្លួន។ អត្ត-ដែលគណបក្សគ្រប់គ្រងអំណាចទទួលបានគ្របដណ្តប់រហូតដល់រូបមន្តដែលគេប្រើប្រាស់ដើម្បីកំណត់ថា តើអ្នកណាត្រូវទទួលហិរញ្ញប្បទានសាធារណៈ និង តើត្រូវទទួលក្រោមលក្ខខណ្ឌយ៉ាងដូចម្តេច"។ នៅក្នុងករណីដែលកើតមាននៅក្នុងប្រទេសតង់ហ្សានី គេបានអះអាងថា អំណាចគ្រប់ដណ្តប់របស់គណបក្សគ្រប់គ្រងរដ្ឋាភិបាលស៊ីស៊ីអឹម (CCM) "មានលក្ខណៈកាន់តែអាក្រក់ទៅៗនៅពេលដែលគណបក្សដែលមានតំណាងនៅក្នុងសភាក្នុងប្រទេសតង់ហ្សានី ត្រូវបានគេផ្តល់ឲ្យនូវហិរញ្ញប្បទានសាធារណៈ ... [ចំណែកឯគណបក្សគ្រប់គ្រងអំណាចស៊ីស៊ីអឹមបាន]ទទួលចំណែកមួយយ៉ាងធំនៅក្នុងចំណោមមូលនិធិទាំងនេះ"។ ករណីដែលគួរឲ្យចាប់អារម្មណ៍មួយទៀតគឺប្រទេសអាហ្វ្រិចខាងត្បូងដែលគេមានមន្ទិលថាតើ ហិរញ្ញប្បទានសាធារណៈត្រូវបានប្រើប្រាស់ដើម្បីលើកកម្ពស់ពហុភាពផ្នែកនយោបាយដែរឬទេក្នុងខណៈដែលគណបក្សគ្រប់គ្រងអំណាចអេអិនស៊ី (ANC) បានទទួលចំណែកជិត២ភាគ៣នៃហិរញ្ញប្បទានសាធារណៈដែលគេបានបែងចែក។

ជាការពិតណាស់ យើងមិនត្រូវបំផ្លើសឲ្យហួសពីការពិតអំពីការផ្តល់សារៈសំខាន់ទៅលើថវិកានៅក្នុងការយកឈ្នះនៅក្នុងការបោះឆ្នោតនោះទេ ទោះបីនៅក្នុង បណ្តាប្រទេសប្រជាធិបតេយ្យថ្មីថ្មោងក៏ដោយ។ តាមរយៈទិន្នន័យកាលពីឆ្នាំ២០០០ លោក *សាហ្វូ* (Saffu) បានកត់សម្គាល់ថា "វិសមភាពទាំងមូលនៃធនធានរវាងគណបក្សគ្រប់គ្រងអំណាចនិងគណបក្សប្រឆាំង ដែលបានបង្ហាញនៅក្នុងលទ្ធភាពរបស់គណបក្សកាន់អំណាចដើម្បីលុបលើចំណាយ

[illegible]បញ្ចូលគ្នាដោយមានកម្រិតវិសមភាព១៥:១ (ការចំណាយរបស់គណបក្សកាន់អំណាចតែមួយស្មើនឹងការចំណាយរបស់គណបក្សប្រឆាំងចំនួន១៥បូកបញ្ចូលគ្នា) ដូចដែលកើតមាននៅក្នុងប្រទេសហ្កាណា ហើយកម្រិតវិសមភាពនេះប្រហែលជាមានកាន់តែធំនៅក្នុងប្រទេសកេនយ៉ា និង ៣០ :១ នៅក្នុងប្រទេសសេណេហ្កាល់ ... បានធ្វើឲ្យប៉ះពាល់ដល់ភាពយុត្តិធម៌ ឬ សមភាពប្រជាធិបតេយ្យនៃការបោះឆ្នោត។ ប្រសិនបើផលវិបាកនេះកើតឡើងមែន គេក៏គួរតែកត់សម្គាល់ដែរថា ចាប់តាំងពីឆ្នាំ២០០០មក គណបក្សគ្រប់គ្រងអំណាចរបស់ប្រទេសទាំងនោះបានទទួលបរាជ័យជាបន្តបន្ទាប់នៅក្នុងការបោះឆ្នោត។

## *ហិរញ្ញប្បទានសាធារណៈអប្រជាប្រិយភាពយ៉ាងខ្លាំង*

បញ្ហាមួយទៀតដែលពាក់ព័ន្ធទៅនឹងហិរញ្ញប្បទានសាធារណៈគឺថា ហិរញ្ញប្បទានសាធារណៈស្ថិតនៅក្នុងទំនោរដែលគ្មានប្រជាប្រិយភាពទេនៅក្នុងចំណោមសាធារណជន ដែលមិនបានមើលឃើញថា តើហេតុអ្វីបានជាថវិកាដែលពួកគេបង់ពន្ធត្រូវបានយកទៅចំណាយសម្រាប់សកម្មភាពរបស់គណបក្សនយោបាយ ឬ បេក្ខជន ទៅវិញ។ នៅក្នុងបណ្តាប្រទេសប្រជាធិបតេយ្យថ្មីថ្មោង គេមានការលំបាកជាពិសេសក្នុងការបង្វែរថវិកាចេញពី វិស័យអប់រំ ការថែទាំសុខភាព ឬ ផលិតកម្មចំណីអាហារ ឲ្យធ្លាក់ចូលទៅក្នុងដៃរបស់អ្នកនយោបាយ និងគណបក្សនយោបាយរបស់ពួកគេ។ ការសិក្សាមួយបានកត់សម្គាល់ថា "គេក៏មានទស្សនៈមុតមាំមួយផងដែរថា ប្រទេសដូចជា ប៉ាគីស្ថានជាដើម ដែលមានប្រជាជនជាងពាក់កណ្តាលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ និងដែលធនធានហិរញ្ញវត្ថុមានកំណត់ គ្មានលទ្ធភាពនឹងធ្វើការចំណាយប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីយកទៅឧបត្ថម្ភដល់គណបក្សនយោបាយ និងបេក្ខជនបានឡើយ"។ ដូចដែលលោក *ពីនតូ ឌូសឈីនស្គី* (Pinto-Duschinsky) បានកត់ចំណាំថា "ក្នុងប្រទេសជាច្រើន ជំនួយឧបត្ថម្ភរបស់រដ្ឋមានប្រជាប្រិយភាពក្នុងចំណោមអ្នកនយោបាយ ក៏ប៉ុន្តែអប្រជាប្រិយភាពយ៉ាងខ្លាំងនៅក្នុងចំណោមអ្នកបោះឆ្នោត"។

ប្រហែលជាយើងអាចនិយាយបានថា បន្ទុកដែលមានកាន់តែតិចចាំបាច់ត្រូវភ្ជាប់ទៅនឹងទស្សនៈរបស់ពលរដ្ឋ ប្រសិនបើហិរញ្ញប្បទានសាធារណៈពិតជាបំពេញឲ្យបានតាមគោលបំណងដែលគេបានកំណត់ទុក។ ទោះជាយ៉ាងណាក៏ដោយ គ្មានការឯកភាពគ្នាជាឯកច្ឆ័ន្ទណាមួយ ថាតើនេះជាដំណោះស្រាយឬយ៉ាងណានោះទេ។ អ្នកស្រាវជ្រាវមានមុខមាត់ម្នាក់បានពោលអះអាងថា "បទពិសោធន៍នៅក្នុងប្រទេសជាច្រើនបានបង្ហាញថា ការធ្វើហិរញ្ញប្បទានសាធារណៈមិនមែនដើម្បីបំពេញបំណងប្រាថ្នារបស់មេដឹកនាំគណបក្សដែលចង់បានមូលនិធិឲ្យកាន់តែច្រើននោះទេ ហើយមានសូចនាករតិចតួចតែប៉ុណ្ណោះដែលបានបង្ហាញថា ហិរញ្ញប្បទាននេះជួយកាត់បន្ថយការលើកទឹកចិត្តឲ្យមានការធ្វើវិភាគទានពុករលួយ"។ ផ្ទុយពីការអះអាងនេះ របាយការណ៍ របស់លោក *នៀល* (Neill) បានបង្ហាញថា មានការគាំទ្រជាច្រើនចំពោះទស្សនៈដែលបានលើកឡើងថា "ទោះជាមានគុណវិបត្តិអ្វីក៏ដោយពីជំនួយឧបត្ថម្ភរបស់រដ្ឋ ការផ្តល់ហិរញ្ញប្បទានសាធារណៈបានជះឥទ្ធិពលនៅក្នុងប្រទេសនោះ ដោយធ្វើឲ្យដំណើរការនយោបាយកាន់តែមានភាពស្អាតស្អំគួរឲ្យកត់សម្គាល់ ជាងការដែលពុំមានការផ្តល់ហិរញ្ញប្បទានរបស់រដ្ឋ។ របាយការណ៍មួយទៀតស្តីអំពីប្រទេសម៉ូហ្សំប៊ិក ក៏បានរកឃើញដែរថា ការផ្តល់ "ថវិកាឲ្យបានគ្រប់គ្រាន់សម្រាប់គណបក្សនយោបាយឲ្យបានទាន់ពេលវេលា បានជួយទប់ស្កាត់ហានិភ័យលើការប្រឈមមុខដាក់គ្នាយ៉ាងហិង្សា និង បានជួយលុបបំបាត់ចោលដោយអន្លើនូវតម្រូវការរបស់អតីតអ្នកតស៊ូក្នុងការប្រើប្រាស់មធ្យោបាយចាស់ គម្រិលដើម្បីទទួលបានមូលនិធិតាមរយៈវិធីសាស្ត្រហិង្សានានា"។

ទោះជាយ៉ាងណាក៏ដោយ ក៏លោក *ណាស្មាឈ័រ* ( Nassmacher) បានអះអាងយ៉ាងត្រឹមត្រូវដោយគ្មានមន្ទិល នៅក្នុងរបាយការណ៍របស់គាត់ថា "ផលប៉ះពាល់នៃហិរញ្ញប្បទានសាធារណៈត្រូវបានគេលើកយកមកសិក្សាសម្រាប់ប្រទេសតែពីរបីតែប៉ុណ្ណោះ" ហេតុដូច្នេះគេត្រូវការ ការសិក្សាស្រាវជ្រាវបន្ថែមទៀតមុនពេលដែលផលប៉ះពាល់នៃប្រព័ន្ធហិរញ្ញប្បទានសាធារណៈលេចរូបរាងកាន់តែច្បាស់នៅក្នុងប្រទេសភាគច្រើន។

## *ការចំណាយលើយុទ្ធនាការឃោសនាដែលមានការកើនឡើង*

បើទោះជាគេពុំបានចាត់បញ្ចូលជាទូទៅនៅក្នុងបញ្ជីថាវាជាបញ្ហាមួយ ដែលពាក់ព័ន្ធទៅនឹងហិរញ្ញប្បទានសាធារណៈក៏ដោយ (ដោយសារថា វាស្ថិតនៅក្នុងការពិភាក្សា គុណសម្បត្តិដែលគេបានស្នើឡើង ជាជាងបញ្ហាដាច់ដោយឡែកមួយ ដូចដែលមានបញ្ជាក់នៅក្នុងតារាង២ពីខាងដើម) លទ្ធភាពដែល ហិរញ្ញប្បទានសាធារណៈក្នុងការជួយកាត់បន្ថយសារសំខាន់របស់ថវិកានៅក្នុងកិច្ចការនយោបាយគឺជាបញ្ហាមួយផ្សេងទៀត។ នៅក្នុងតំបន់មួយចំនួន មូលហេតុមួយដែលគេត្រូវធ្វើបទបញ្ញាដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនយោបាយ គឺការប៉ុនប៉ងកាត់បន្ថយ ការចំណាយលើយុទ្ធនាការឃោសនាបោះឆ្នោត។ ប្រសិនបើ មានការផ្តល់ហិរញ្ញប្បទានឲ្យបានគ្រប់គ្រាន់គួបផ្សំនឹងការកំណត់ដែនចំណាយយ៉ាងសមស្រប ការចំណាយទៅលើយុទ្ធនាការបោះឆ្នោតជាទូទៅនឹងមានការកាត់បន្ថយ។ ទោះជាយ៉ាង - ណាក៏ដោយ ការកំណ ត់ដែនចំណាយជារឿយៗគេពិបាកនឹងអនុវត្តណាស់។ ការសិក្សាថ្មីមួយបង្ហាញឲ្យឃើញថា ប្រទេសដែលមានកម្រិតហិរញ្ញប្បទានសាធារណៈខ្ពស់ ក៏ទំនងជាមានកម្រិតចំណាយទៅលើយុទ្ធនាការឃោសនាខ្ពស់ដែរ។ លោក *ពីនតូ ឌូសឈីនស្គី* (Pinto-Duschinsky) បានបន្ថែមទៀតថា "គណបក្ស ឬ បេក្ខជនដែលទទួលបានហិរញ្ញប្បទានសាធារណៈ ដោយបានដឹងយ៉ាងច្បាស់ថាថវិកាទាំងនោះនឹងត្រូវបានផ្តល់ស្មើៗគ្នាក្នុងចំណោមអ្នកចូលរួមប្រកួតប្រជែងទាំងអស់ នឹងច្បាស់ជាមិនបញ្ឈប់ការស្វះស្វែងរកថវិកាបន្ថែមទៀត ដែលជួយឲ្យគេយកទៅប្រើប្រាស់ដើម្បីលុបទៅលើការចំណាយ និង យកប្រៀបលើគូប្រជែងរបស់គេ"។

## អនុសាសន៍

យើងសូមធ្វើការបញ្ជាក់ឲ្យបានច្បាស់នៅត្រង់ចំនុចនេះថា ការសិក្សានេះនឹង មិនធ្វើការណែនាំឲ្យមានការប្រើប្រាស់ទ្រឹស្តី "ពុម្ពគម្រូមួយអាចប្រើបានគ្រប់ដំណោះស្រាយនោះទេ"។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីសន្និដ្ឋានមួយចំនួន អាចទាញយកនូ វបទពិសោធន៍ខ្លះៗដែលគួរចងចាំនៅពេលបង្កើត និង អនុវត្តប្រព័ន្ធហិរញ្ញប្បទានសាធារណៈដែលត្រូវផ្តល់ទៅឲ្យគណបក្សនយោបាយ និងយុទ្ធនាការឃោសនាបោះឆ្នោត។

- អ្នកតាក់តែងច្បាប់ដែលពិចារណាអំពីការអនុវត្តហិរញ្ញប្បទានសាធារណៈ ឬពិចារណាអំពី ការផ្លាស់ប្តូរប្រព័ន្ធដែលគេកំពុងប្រើប្រាស់គួរតែគិតគូរឲ្យបានហ្មត់ចត់ថា តើគោ លដៅអ្វីខ្លះដែលគេចង់សម្រេចឲ្យបានតាមរយៈការធ្វើកំណែទម្រង់ទាំងនេះ។ បទពិសោធន៍ ដែលបានមកពីប្រទេសដទៃទៀតអាចមានសារប្រយោជន៍ក្នុងការបង្កើតប្រព័ន្ធហិរញ្ញប្បទាន ក៏ប៉ុន្តែអ្នកតាក់តែងច្បាប់គួរដឹងយ៉ាងច្បាស់ថាប្រទេសផ្សេងៗទៀតអាចនឹងព្យាយាមកែលម្អបញ្ហាខុសៗគ្នាដែលពួកគេមើលឃើញ។

- ការពិភាក្សាដេញដោលយ៉ាងជិតស្និទ្ធមួយជាមួយភាគីពាក់ព័ន្ធដោយខ្លួនពួកគេផ្ទាល់ មានសារសំខាន់យ៉ាងខ្លាំងក្នុងការបង្ហាញអំពីដំណើរការ។ ដំបូន្មានគន្លឹះមួយគឺរួមគ្នាកំណត់បញ្ហានានា ដែលត្រូវដោះស្រាយ និងកំណត់អំពីមធ្យោបាយសម្រាប់អនុវត្តប្រព័ន្ធដែលបានបង្កើតឡើង។

- នៅពេលមានការកំណត់គោលបំណងរួចហើយ ការរៀបចំប្រព័ន្ធសម្រាប់អនុវត្តត្រូវពិចារណាអំពីលក្ខណៈពិសេសនៃរចនាសម្ព័ន្ធនយោបាយ រួមមានប្រព័ន្ធបោះឆ្នោត ទំនាក់ទំនងអំណាច និង ចរិតលក្ខណៈនៃប្រព័ន្ធគណបក្សនយោបាយ។

- មិនត្រូវរំពឹងថាហិរញ្ញប្បទានសាធារណៈអាចដោះស្រាយនូវរាល់បញ្ហាទាំងអស់តាមដែលយើងបានកំណត់នោះទេ ហើយសូមគិតថាដើម្បីវាត្រូវការចំណាយពេលវេលាច្រើនមុននឹងមានលទ្ធផលជាច្រើនកើតឡើង។ សូមមើលឲ្យបានគ្រប់ជ្រុងជ្រោយជុំវិញលទ្ធផលរំពឹងទុកនៃហិរញ្ញប្បទានសាធារណៈដែលត្រូវបានផ្តល់។

- ត្រៀមជាស្រេចក្នុងការផ្លាស់ប្តូរប្រព័ន្ធដែលបានបង្កើតរួចហើយនោះ ប្រសិនបើប្រព័ន្ធនោះផ្តល់ផលអវិជ្ជមាន គ្មានប្រសិទ្ធភាព ឬ លែងមានប្រជាប្រិយភាព។

- អ្នកនយោបាយចាំបាច់ត្រូវប្រើប្រាស់មូលនិធិដែលពួកគេទទួលបាន តាមរយៈការចូលរួមក្នុងវិស័យនយោ - បាយប្រកបដោយការទទួលខុសត្រូវ។ គេគួរគិតថាការទទួលបានហិរញ្ញប្បទានសាធារណៈជាអត្ថប្រយោជន៍ពិសេសមួយដែលគណបក្សនិងបេក្ខជន ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត (ទាំងមូល) បានទទួលតាមរយៈការលទ្ធផលគាំទ្រដែលពួកគេទទួលបាន តែមិនមែនជាអ្វីដែលពួកគេត្រូវបាននោះទេ។

- ដោយសារតែខ្ញុំមិនបានផ្តល់អនុសាសន៍ពីដំណោះស្រាយមួយទៅដំណោះស្រាយមួយទៀត វាអាចជាកំហុសធ្ងន់មួយក្នុងការដាក់ចេញឲ្យមានការប្រើប្រាស់ហិរញ្ញប្បទានសាធារណៈ ប្រសិនបើពុំមានការតម្រូវឲ្យគណ - បក្សនយោបាយ និង បេក្ខជនផ្តល់របាយការណ៍អំពីការប្រើប្រាស់មូលនិធិទាំងនោះ និង ប្រភពធនធានដទៃទៀតដែលពួកគេទទួលបាន។

- ជាទូទៅ ហិរញ្ញប្បទានសាធារណៈសម្រាប់គណបក្សនយោបាយ និង បេក្ខជនគួរត្រូវបានគេមើលឃើញថាជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ជាច្រើនទៀត ដែលគេអាចយកទៅប្រើប្រាស់រួមគ្នាដើម្បី ធ្វើឲ្យសម្រេចលទ្ធផលដែលគេចង់បាន រួមបញ្ចូលទាំងការដាក់ដែនកំណត់ទៅលើការចំណាយ និង ការធ្វើវិភាគទាន និងការហាមប្រាមមួយចំនួន។
- ជាចុងក្រោយ ខណៈដែលហិរញ្ញប្បទានសាធារណៈអាចជួយប្រយុទ្ធប្រឆាំងនឹងទិដ្ឋភាពអវិជ្ជមានមួយចំនួននៃការផ្តល់ជំនួយហិរញ្ញវត្ថុពីប្រភពឯកជនក្នុងនយោបាយ ការប្រើប្រាស់ហិរញ្ញប្បទានសាធារណៈមិនត្រូវឲ្យមាន

ការប៉ះពាល់ដល់សេរីភាពក្នុងការនិយាយស្តី ឬ ការចូលរួមរបស់អ្នកបោះឆ្នោតនៅក្នុងដំណើរការនយោបាយឡើយ។

## សេចក្តីសន្និដ្ឋាន

ក្នុងខណៈដែលហិរញ្ញវត្ថុគឺជាផ្នែកចាំបាច់មួយនៃដំណើរការនយោបាយ ហិរញ្ញវត្ថុក្នុងកិច្ចការនយោបាយមិនដែលថាមិនចេះបង្កបញ្ហានោះទេ រីឯយន្តការមួយចំនួនត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបទៅនឹងតួនាទីអវិជ្ជមាននានារបស់ហិរញ្ញវត្ថុក្នុងវិស័យនយោបាយ។ យន្តការទាំងនេះរួមមាន ការតម្រូវឲ្យបើកចំហរព័ត៌មាន ការដាក់ដែនកំណត់ទៅលើចំណូលនិងចំណាយ និង ការកំណត់រយៈពេលដែលអនុញ្ញាតឲ្យមានការចំណាយសម្រាប់យុទ្ធនាការឃោសនា។ ទោះជាយ៉ាងណាក៏ដោយ ក៏មានមធ្យោបាយមួយចំនួនអវិជ្ជមានក្នុងការធ្វើបទបញ្ញាគ្រប់គ្រងហិរញ្ញវត្ថុនយោបាយដែរ ហើយប្រសិនបើមធ្យោបាយទាំងនោះមិនត្រូវបានយកទៅប្រើប្រាស់ឲ្យបានត្រឹមត្រូវទេ វានឹងកាត់បន្ថយសមត្ថភាពរបស់គណបក្សនយោបាយ និង បេក្ខជនក្នុងការដើរតួនាទីនៅក្នុងសង្គមប្រជាធិបតេយ្យ។ ការដាក់ឲ្យមានការអនុវត្តហិរញ្ញវត្ថុនយោបាយបន្ថែមឲ្យមានអភិក្រមវិជ្ជមានមួយក្នុងការជួយលើកស្ទួយសមត្ថភាពរបស់អ្នកប្រកួតប្រជែងនយោបាយ ក្នុងខណៈដែលអភិក្រមនេះជួយទប់ស្កាត់ឥទ្ធិពលមិនល្អដែលអាចកើតមានពីហិរញ្ញប្បទានសាធារណៈក្នុងពេលជាមួយគ្នានោះ។

មានបទពិសោធន៍ជាច្រើនទាក់ទងទៅនឹងហិរញ្ញប្បទានសាធារណៈនៅក្នុងអំឡុងប៉ុន្មានទសវត្សចុងក្រោយនេះ ហើយការសិក្សានេះមានបំណងប្រមូលចងក្រងបទពិសោធន៍មួយចំនួនក្នុងចំណោមបទពិសោធន៍ទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថាហិរញ្ញប្បទានសាធារណៈគឺជារឿងមួយថ្មីដែរនៅក្នុងប្រទេសភាគច្រើន នៅមានចំនុចជាច្រើនទៀតដែលយើងមិនបានដឹងអំពីឥទ្ធិពលរបស់វា។ តាមរយៈការអះអាងរបស់លោក *ពីនតូ ឌូសឈីនស្គី* (Pinto-Duschinsky)៖

*"ឧបត្ថម្ភធនសាធារណៈសម្រាប់នយោបាយពាក់ព័ន្ធនឹងការបោះឆ្នោត មិនបានបង្កើតឲ្យមានទាំងអត្ថប្រយោជន៍ដែលបានសន្យាដោយក្រុមអ្នកគាំទ្រ ក៏ដូចជាគុណវិបត្តិដែលក្រុមអ្នករិះគន់មានការបារម្ភនោះទេ។ ម្យ៉ាងឧបត្ថម្ភធនសាធារណៈបរាជ័យដោយមិនអាចប្រកែកបានក្នុងការដោះស្រាយបញ្ហាពុករលួយទាក់ទិននឹងហិរញ្ញវត្ថុនយោបាយ...។ តែម្យ៉ាងទៀត ការភ័យខ្លាចរបស់អ្នករិះគន់មួយចំនួនដែលថា ហិរញ្ញប្បទានសាធារណៈនឹងនាំឲ្យគណបក្សនយោបាយមានការចុះខ្សោយដោយសារការកាត់បន្ថយគ្រឿងលើកទឹកចិត្តសម្រាប់ជ្រើសរើសសមាជិកថ្មីៗ និង សម្រាប់ការអែអង្គាសប្រាក់ពីប្រភពដែលមានស្រាប់ ហាក់ដូចជាមិនសូវសមហេតុផលទេ"។*

យើងគួរធ្វើការបញ្ចប់នៅត្រង់ចំណុចដែលយើងបានចាប់ផ្តើម ដោយការសង្កត់ធ្ងន់ថា របៀបដែលគេគួរបង្កើតប្រព័ន្ធហិរញ្ញប្បទានសាធារណៈអាស្រ័យលើគោលបំណងអ្វីខ្លះដែលគេចង់សម្រេចឲ្យបាន។ តារាងចុងក្រោយខាងក្រោមនេះមានបំណងបង្ហាញថា តើអ្នកតាក់តែងប្រព័ន្ធហិរញ្ញប្បទានសាធារណៈអាចនឹងប្រាថ្នាគ្រប់គ្រងទិដ្ឋភាពនីមួយៗក្នុងចំណោមទិដ្ឋភាពដែលយើងបានពិភាក្សារួចមកហើយនោះយ៉ាងដូចម្តេច ប្រសិនបើគេផ្តោតជាសំខាន់ទៅលើគោលបំណងនីមួយៗនៃគោលបំណងទាំង៦ដូចដែលមានការពិភាក្សានៅផ្នែកខាងដើមនៃការសិក្សានេះ។ តារាង

នេះពុំមានបំណងបង្ហាញអំពីដំណោះស្រាយចុងក្រោយបំផុតនោះទេ តែគ្រាន់តែជាចំណុចចាប់ផ្តើមសម្រាប់ការពិភាក្សាតែប៉ុណ្ណោះ។

*តារាង ១៥៖ ការពិចារណាទៅលើទិដ្ឋភាពនីមួយៗនៃហិរញ្ញប្បទានសាធារណៈតាមគោលបំណងដែលគេចង់បាន*

| គោលបំណង / ទិដ្ឋភាព | បង្កើនសមត្ថភាពក្នុងយុទ្ធនាការបោះឆ្នោត | ធ្វើឲ្យទីលានប្រកួតប្រជែងមានសមភាព | ស្ថាប័នភាវូបនីយកម្មគណបក្ស | កាត់បន្ថយអំពើពុករលួយនយោបាយ | កាត់បន្ថយតួនាទីរបស់ហិរញ្ញវត្ថុនៅក្នុងនយោបាយ/ការបោះឆ្នោត | ជម្រុញឲ្យមានការកែទម្រង់ |
|---|---|---|---|---|---|---|
| អ្នកផ្តល់ហិរញ្ញប្បទាន | ស្ថាប័នណាមួយដែលមានទំហំរដ្ឋបាលតូច | ទីភ្នាក់ងារដែលអាចដាក់ទណ្ឌកម្មទៅលើការរំលោភបំពានធនធានរដ្ឋ | ស្ថាប័នណាមួយដែលមានទំហំរដ្ឋបាលតូច | ស្ថាប័នមានសមត្ថកិច្ចដែលមានអំណាចធ្វើការស៊ើបអង្កេត | ស្ថាប័នដែលអាចអនុវត្តការកំណត់ដែនចំណាយ និងការធ្វើវិភាគទាន | ស្ថាប័នដែលអាចត្រួតពិនិត្យមើលការអនុលោមតាមរបៀបវារៈដែលបានកែទម្រង់ |
| លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលហិរញ្ញប្បទាន | អ្នកចូលរួមប្រកួតប្រជែងសំខាន់ៗត្រូវតែទទួលបានហិរញ្ញប្បទាន | ធ្វើឲ្យកាន់តែសេរីតាមដែលអាចធ្វើទៅបាន | ត្រូវមានភាពតឹងរ៉ឹងដើម្បីកុំឲ្យមានការបំបែកជាគណបក្សតូចៗ | អ្នកចូលរួមប្រកួតប្រជែងសំខាន់ៗត្រូវតែទទួលបានហិរញ្ញប្បទាន | អ្នកចូលរួមប្រកួតប្រជែងសំខាន់ៗត្រូវតែទទួលបានហិរញ្ញប្បទាន | យ៉ាងហោចណាស់ផ្នែកខ្លះនៃហិរញ្ញប្បទានសាធារណៈមានសម្រាប់តែអ្នកដែលចង់ធ្វើការកែទម្រង់តែប៉ុណ្ណោះ |
| អ្នកទទួលហិរញ្ញប្បទាន | គណបក្ស ឬបេក្ខជន ដោយអាស្រ័យទៅលើអ្នកណាដែលជាអ្នកធ្វើយុទ្ធនាការច្រើនជាងគេបំផុត | គណបក្ស ឬបេក្ខជនដោយអាស្រ័យទៅលើអ្នកណាដែលជាអ្នកធ្វើយុទ្ធនាការច្រើនជាងគេបំផុត | គណបក្សនយោបាយតែប៉ុណ្ណោះ | គណបក្សនយោបាយ ឬ បេក្ខជនដោយអាស្រ័យទៅលើអ្នកណាដែលទំនងជាពាក់ព័ន្ធនឹងអំពើពុករលួយជាងគេ | គណបក្ស ឬបេក្ខជន ដោយអាស្រ័យទៅលើអ្នកណាដែលជាអ្នកធ្វើយុទ្ធនាការចម្បង ព្រមទាំងគណបក្សនយោបាយនៅចន្លោះពេលបោះឆ្នោត | ក្រុមនានាដែលជម្រុញឲ្យមានការកែទម្រង់ (ចលនាយុវជន ស្ត្រី និង ជនភាគតិច) |
| សកម្មភាពដែលអាចទទួលបានហិរញ្ញប្បទាន | យុទ្ធនាការឃោសនា | យុទ្ធនាការឃោសនា | សកម្មភាពក្រៅពីការបោះឆ្នោត | យុទ្ធនាការឃោសនា និងសកម្មភាពដ៏សំខាន់ៗរបស់គណបក្ស | ទិដ្ឋភាពដែលត្រូវចំណាយច្រើនបំផុតនៃយុទ្ធនាការឃោសនា | ការពិភាក្សាដេញដោលផ្ទៃក្នុងរបស់ចលនាយុវជន និង ស្ត្រី |
| ប្រភេទនៃហិរញ្ញប្បទាន | ហិរញ្ញប្បទានតាមបែបផ្ទាល់ និងប្រយោលដោយផ្តោតទៅលើផ្នែកសំខាន់ៗនៃយុទ្ធនាការឃោសនា | ហិរញ្ញប្បទានតាមបែបផ្ទាល់ និងប្រយោលដោយផ្តោតទៅលើផ្នែកនានាដែលឥទ្ធិពលធំបំផុត | ការផ្តល់ជំនួយមិនផ្ទាល់សម្រាប់សកម្មភាពមិនមែនការបោះឆ្នោត តែហិរញ្ញប្បទាន | ហិរញ្ញប្បទានបែបផ្ទាល់/ប្រយោលដោយភ្ជាប់ជាមួយដែនកំណត់លើការធ្វើវិភាគទាន | ហិរញ្ញប្បទានបែបប្រយោលដោយភ្ជាប់ជាមួយដែនកំណត់យ៉ាងតឹងរ៉ឹងលើការចំណាយ | ហិរញ្ញប្បទានបែបប្រយោលដែលជម្រុញឲ្យមានការកែទម្រង់ (ឧ. ការផ្តល់ម៉ោងផ្សាយសម្រាប់ |

| | | | | | | |
|---|---|---|---|---|---|---|
| | | របស់អ្នកនយោបាយផុតអណត្តិ | ដោយផ្ទាល់ជាចម្បង | | | បេក្ខជនស្ត្រី) |
| យន្តការនៃការបែងចែកហិរញ្ញប្បទាន | បែងចែកស្មើៗគ្នា/ការបែងចែកតាមសមាមាត្ររួមគ្នា | បែងចែកស្មើៗគ្នា | បែងចែកដោយផ្អែកទៅលើចំនួនសមាជិកឬទៅតាមសមាមាត្រ | បែងចែកស្មើៗគ្នា/បែងចែកតាមសមាមាត្ររួមគ្នា | បែងចែកស្មើៗគ្នា/បែងចែកតាមសមាមាត្ររួមគ្នា | បែងចែកដោយផ្តល់ប្រយោជន៍ដល់គណបក្សដែលមានការកែទម្រង់ |
| ពេលវេលានៃការផ្តល់ហិរញ្ញប្បទាន | មុនបោះឆ្នោត | មុនបោះឆ្នោត | បន្តបន្ទាប់ | ក្រោយបោះឆ្នោត | មុនបោះឆ្នោត | នៅពេលការប្តេជ្ញាចិត្តក្នុងការកែទម្រង់ត្រូវបានបង្ហាញ |

# ជំពូក ៤

# ដំណោះស្រាយជាក់ស្តែងសម្រាប់ការអនុវត្តបទបញ្ញា ហិរញ្ញវត្ថុឥស្លាម និង ក្រុមត្រួតពិនិត្យ

ដោយ៖ ហានី ហ្សៃនូហៃ (Hani Zainulbhai)

## ៦៥ បរិបទ

"វិធានច្បាប់ល្អបំផុត ការអនុវត្តអាក្រក់បំផុត" សុភាសិតនេះ ដែលបានលើកឡើងដោយអ្នកជំនាញផ្នែកហិរញ្ញប្បទាននយោបាយគឺ បណ្ឌិត *ម៉ៃឃើល ពីនតូ ឌូឈីនស្គី* (Dr. Michael Pinto- Duschinsky) បានបង្ហាញអំពីការប្រឈមមួយក្នុងបញ្ហាប្រឈមធំៗបំផុតចំពោះការកែទម្រង់ហិរញ្ញវត្ថុនយោបាយ។ នៅក្នុងដំណើរការនៃការផ្តើមកំណែទម្រង់ ការអនុវត្តជារឿយៗគឺជាបញ្ហាមួយដែលគេតែងលើកយកមកនិយាយនៅពេលក្រោយ។ មាត្រា៧ (៣) នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយបានស្វះស្វែងលើកកម្ពស់តម្លាភាព តាមរយៈការជម្រុញឲ្យរដ្ឋជាភាគីទាំងអស់បង្កើតវិធានការរដ្ឋបាលនិងផ្លូវច្បាប់ ក្នុងគោលបំណងពង្រឹងតម្លាភាពក្នុងការផ្តល់ហិរញ្ញប្បទានដល់គណបក្សនយោបាយ និងបេក្ខជន។ ទោះជាយ៉ាងណាក៏ដោយ គោលបំណងនៃតម្លាភាព និងការទទួលខុសត្រូវខ្ពស់ ដែលមានការពាក់ព័ន្ធទៅនឹងហិរញ្ញវត្ថុនិងនយោបាយ អាស្រ័យលើប្រព័ន្ធនៃការអនុវត្តដែលមានដំណើរការល្អ។

ជំពូកដំបូងៗនៃសៀវភៅនេះបានពិនិត្យទៅលើឧបករណ៍គោលនយោបាយសំខាន់ៗចំនួនបី សម្រាប់បង្កើនតម្លាភាព និង ការទទួលខុសត្រូវខ្ពស់ ដូចជា៖ ការបង្ហាញព័ត៌មាន ហិរញ្ញប្បទានសាធារណៈ និងការកំណត់ដែនចំណាយ។ ពាក់ព័ន្ធទៅនឹងការបង្ហាញព័ត៌មាន អ្នកជំនាញផ្នែកហិរញ្ញប្បទាននយោបាយ លោកបណ្ឌិត *ខាល ហែនណា ស្មាឆើរ* (Dr.Karl Heinz-Nassmacher) ក៏បានកត់សម្គាល់ដែរថា បញ្ហាពិតប្រាកដនៅទីនេះ តាមពិតគឺកង្វះការអនុវត្ត។ កង្វះការអនុវត្តបទប្បញ្ញត្តិទាំងនេះ ឬការមិនអនុវត្តទាល់តែសោះទំនងជានាំទៅរកផលវិបាកដែលបង្កជាបញ្ហាកាន់តែច្រើនឡើងៗ ដូចជា ការមិនគោរពច្បាប់ជាទូទៅជាដើម ដែលជាហេតុបណ្តាលឲ្យមានបញ្ហានៃអំពើពុករលួយកាន់តែធំទៅៗ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការលើកកម្ពស់តម្លាភាព និង ការទទួលខុសត្រូវខ្ពស់ ការអនុវត្តគួរក្លាយជាឧបករណ៍ចម្បងមួយ។

ដោយទទួលស្គាល់ថា គេពុំមានគម្រូណាមួយនៃការអនុវត្តដែលល្អឥតខ្ចោះហើយថា កាលៈទេសៈពិសេសផ្នែកនយោបាយ សេដ្ឋកិច្ចនិងសង្គមនៃប្រទេសមួយជាក់លាក់ក៏បានដើរតួនាទីនៅក្នុងការអនុវត្តដែរ ទើបជំពូកនេះនឹងពិនិត្យទៅលើយន្តការនានានៃការអនុវត្ត ដោយហេតុថា យន្តការទាំងនោះជាប់ពាក់ព័ន្ធទៅនឹងឧបករណ៍គោលនយោបាយនីមួយៗនៃឧបករណ៍គោលនយោបាយទាំងនេះ និងស្ថិតនៅក្នុងបរិបទដ៏ទូលំទូលាយនៃកាតព្វកិច្ចអន្តរជាតិនិងតំបន់។ មាត្រា ៧(៣) បានលើកឡើងអំពីបញ្ហាតម្លាភាព ថាជាគោលដៅទូទៅដែលជាចំណុចស្នូលនៃបញ្ហាថវិកា និង នយោបាយ។ ក្នុងជំពូកនេះ យើងនឹងពិភាក្សាអំពីតម្លាភាពនិងគោលដៅជាប្រធានចំនួនពីរបន្ថែមទៀត ពោលគឺ ការលើកកម្ពស់ការប្រកួតប្រជែង និងការទប់ស្កាត់ឥទ្ធិពលអវិជ្ជមាន ដែលស្ថិតនៅក្នុងបរិបទនៃការអនុវត្ត។

ពេលខ្លះ យើងនឹងសង្កត់ធ្ងន់លើលក្ខណៈជាក់លាក់មួយចំនួន ដូចជាការកសាងសមត្ថភាពស្ថាប័ន ធនធាននយោបាយ និងការគោរពនីតិរដ្ឋជាដើម។ ជំពូកនេះនឹងចាប់ផ្តើមដោយពិនិត្យជាសង្ខេបទៅលើគោលបំណងជារួមនៃប្រព័ន្ធអនុវត្តន៍ បន្ទាប់មកយើងនឹងពិភាក្សាអំពីប្រភេទស្ថាប័នអនុវត្ត មុនពេលដែលយើងពិចារណាទិដ្ឋភាពទាំងនេះ

នៅក្នុងក្របខ័ណ្ឌនៃការអង្កេតរកការពិត ការបង្ការ និង ទណ្ឌកម្ម ។ ចុងក្រោយ ជំពូកនេះនឹងពិភាក្សាអំពីបញ្ហាប្រឈមចម្បងៗមួយចំនួនដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និង បទបញ្ញាស្តីអំពីហិរញ្ញវត្ថុនយោបាយ។

## គោលបំណងនៃប្រព័ន្ធអនុវត្តច្បាប់និងបទបញ្ញាហិរញ្ញវត្ថុនយោបាយ

រចនាសម្ព័ន្ធនៃប្រព័ន្ធការអនុវត្តខុសគ្នាពីប្រព័ន្ធនយោបាយមួយទៅប្រព័ន្ធនយោបាយមួយទៀត ប៉ុន្តែគោលបំណងជាមូលដ្ឋាននៃប្រព័ន្ធណាមួយដែលមានដំណើរការគួរតែដូចគ្នា ពោលគឺ៖ ការអង្កេតរកការពិត ការបង្ការ និងទណ្ឌកម្ម។ ប្រព័ន្ធអនុវត្តហិរញ្ញវត្ថុនយោបាយ គឺជាការរៀបចំបែបស្ថាប័នមានលក្ខណៈស្មុគស្មាញដែលរួមផ្សំដោយលិខិតុបករណ៍ និង តួអង្គខុសៗគ្នាជាច្រើន ។ កិច្ចសហប្រតិបត្តិការរវាងលិខិតុបករណ៍និងតួអង្គនយោបាយទាំងនោះមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការប៉ាន់ប្រមាណលើគោលដៅរួមសំខាន់ៗនៃការអង្កេតរកការពិត ការបង្ការ និងទណ្ឌកម្ម និងចុងក្រោយបំផុតគឺគោលដៅជាបទដ្ឋានទាំងបីដែលយើងចង់បាន ។ បិតុក្នុងក្របខណ្ឌជំពូកនេះក៏នឹងពិភាក្សាផងដែរអំពីការរបៀបដែលអាចធ្វើទៅបាននូវលិខិតុបករណ៍ និងតួអង្គទាំងនេះ ដោយពិចារណាទៅលើសំនួរជាមូលដ្ឋានមួយចំនួន។ ក្នុងនោះរួមមាន៖ តើច្បាប់និងបទបញ្ញាហិរញ្ញវត្ថុណាខ្លះដែលត្រូវអនុវត្ត? តើនរណាខ្លះគួរស្ថិតនៅក្រោមការត្រួតពិនិត្យដោយប្រព័ន្ធអនុវត្ត? តើការអនុវត្តគួរធ្វើឡើងនៅពេលណា? ត្រូវឧបករណ៍អ្វីខ្លះដែលអាចយកមកប្រើសម្រាប់ការអនុវត្ត? ទាំងនេះសុទ្ធសឹងតែជាសំនួរដែលនឹងត្រូវពិភាក្សានៅក្នុងជំពូកមួយនេះក្នុងបរិបទជាសកល។

ត្រឹមតែវត្តមាននៃឧបករណ៍ និងតួអង្គសំខាន់ៗ មិនអាចធានាឲ្យមានប្រព័ន្ធមួយដែលមានដំណើរការនោះទេ។ ការសហការក្នុងកម្រិតជាក់លាក់ណាមួយក្នុងចំណោមសមាសភាពទាំងនោះមានសារៈសំខាន់ណាស់ ។ នៅក្នុងដំណាក់កាលនៃការពិភាក្សា យើងនឹងបានឃើញឧបករណ៍ និង តួអង្គដូចខាងក្រោម៖

- ការត្រួតពិនិត្យផ្ទៃក្នុង (គោលការណ៍របស់ភ្នាក់ងារ បទដ្ឋានគណនេយ្យនិងប្រព័ន្ធធនាគារ)
- របាយការណ៍ហិរញ្ញវត្ថុនិងសវនកម្ម
- ការត្រួតពិនិត្យដោយភ្នាក់ងារពង្រឹងការអនុវត្តច្បាប់ ដែលគាំទ្រដោយយន្តការស៊ើបអង្កេត
- ការត្រួតពិនិត្យពីខាងក្រៅដោយស្ថាប័នខាងក្រៅ (សង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ គណបក្សដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត អ្នកបោះឆ្នោត) និង
- ការចាប់ពិរុទ្ធ និង ទណ្ឌកម្ម (ទណ្ឌកម្មផ្នែករដ្ឋបាល ព្រហ្មទណ្ឌ និង នយោបាយ)។

### ទំនាក់ទំនងរវាងសមាសធាតុនៃការត្រួតពិនិត្យ និង ដំណើរការអនុវត្ត




*(ប្រភព៖ ចេហ្វ៍រី ខាលសុន សព្វវចនាធិប្បាយអេស៊ីអ៊ី អំពីការអនុវត្តហិរញ្ញវត្ថុនយោបាយ)*

ក្នុងចំណោមតួអង្គពាក់ព័ន្ធទាំងអស់ ភ្នាក់ងារអនុវត្តបទបញ្ជា (ដែលគេហៅម្យ៉ាងទៀតថា បញ្ញត្តិករហិរញ្ញវត្ថុនយោបាយ) បានដើរតួនាទីយ៉ាងសំខាន់បំផុតនៅក្នុងប្រព័ន្ធដ៏ទូលំទូលាយនៃការអនុវត្ត ។ ខណៈដែលស្ថាប័នដទៃទៀតទទួលខុសត្រូវលើកិច្ចការធំៗមួយចំនួន ជារឿយៗបញ្ញត្តិករហិរញ្ញវត្ថុនយោបាយគឺជាអ្នកទទួលខុសត្រូវក្នុងការច្របាច់បញ្ចូលគ្នារវាងសមាសធាតុទាំងអស់ដែលពាក់ព័ន្ធនៅក្នុងការស៊ើបអង្កេតរកការពិត ការបង្ការ និងទណ្ឌកម្ម។ ដូចនេះ ការអនុវត្តច្បាប់ដោយប្រសិទ្ធភាពជារឿយៗកម្រកើតមានឡើងនៅក្នុងប្រទេសដែលពុំមានស្ថាប័នដែលទទួលខុសត្រូវក្នុងការអនុវត្តច្បាប់។ ដោយសារតួនាទីផ្តោតលើគន្លឹះរបស់ទីភ្នាក់ងារអនុវត្តមួយចំនួនពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតរការពិត ការបង្ការ និង ទណ្ឌកម្ម យើងនឹងពិនិត្យជាបឋមទៅលើស្ថាប័នទាំងនោះ ក្រៅពីបរិបទនៃគោលដៅដែលយើងបានលើកឡើងទាំងនេះ។

## ស្ថាប័នអនុវត្ត

អ្នកស្រាវជ្រាវនានាបានរកឃើញរួចមកហើយថា គេពុំមានប្រភេទស្ថាប័នណាមួយល្អឥតខ្ចោះសម្រាប់អនុវត្តបទបញ្ជាហិរញ្ញវត្ថុនយោបាយសម្រាប់ប្រទេសណាមួយទេ ដូច្នេះយើងនឹងមិនចាំបាច់ធ្វើការពិភាក្សាទៅលើបញ្ហានេះឡើងវិញទេ។ ជំនួសមកវិញ យើងនឹងពិចារណាថាតើចរិតលក្ខណៈអ្វីខ្លះដែលធ្វើឲ្យស្ថាប័នដែលទទួលបន្ទុកការអនុវត្តទទួលបានជោគជ័យ ដោយមិនគិតពីប្រព័ន្ធនយោបាយ ប្រវត្តិសាស្ត្រ និងបរិបទនយោបាយរបស់ប្រទេសនីមួយៗឡើយ។ ស្របពេល ជាមួយគ្នានេះដែរ យើងត្រូវតែ ទទួលស្គាល់ថា កត្តាទាំងនេះអាចជះឥទ្ធិពលដោយផ្ទាល់ដល់ទម្រង់ស្ថាប័នអនុវត្តដែលប្រទេសនីមួយៗមាន។ ឧទាហរណ៍ ប្រទេសជាច្រើនដែលធ្លាប់ស្ថិតនៅក្រោមអាណានិគមនិយមបារាំងរក្សាទុកស្ថាប័នមួយចំនួន ដែលបន្សល់ទុកដោយប្រព័ន្ធនយោបាយបារាំង។ ទាំងនៅក្នុងប្រទេសលីបង់ និងកូឌីវ័រ ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចមួយចំនួនទៅលើ បទបញ្ជាហិរញ្ញវត្ថុនយោបាយ និង ការអនុវត្តបទបញ្ជានេះ ។ នៅក្នុងប្រទេសអឺរ៉ុបខាងកើតមួយចំនួន នៅ ពេលដែលប្រទេសទាំងនោះ

ជាប់ជំពាក់ទៅនឹងមនោគមវិជ្ជានយោបាយដូចគ្នានោះ អ្នកជំនាញបានកត់សម្គាល់ទំនោរមួយដែលឆ្ពោះទៅរកការអនុវត្តដោយការិយាល័យសវនកម្មរបស់រដ្ឋ (State Audit Office)។

## *ប្រភេទនៃស្ថាប័នអនុវត្ត*

ស្ថាប័នមួយចំនួនអាចត្រូវបានផ្តល់ការទទួលខុសត្រូវក្នុងការអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយ ហើយនៅក្នុងប្រទេសជាច្រើន ស្ថាប័នខុសៗ គ្នាចូលរួមនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃដំណើរការអនុវត្ត។ នៅប្រទេសលីបង់ គណៈកម្មការត្រួតពិនិត្យយុទ្ធនាការបោះឆ្នោត(SCEC) រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងសាលាក្រុង និង គណៈកម្មការរដ្ឋធម្មនុញ្ញមានការទទួលខុសត្រូវតាមសមត្ថកិច្ចរៀងៗខ្លួនទៅលើបទបញ្ញាហិរញ្ញវត្ថុនយោបាយ និង ការអនុវត្ត ។ ជាទូទៅ បញ្ញត្តិករហិរញ្ញវត្ថុនយោបាយរួមបញ្ចូលទាំងអង្គភាពគ្រប់គ្រងការបោះឆ្នោត គណៈកម្មការប្រឆាំងអំពើពុករលួយ ស្ថាប័នឯករាជ្យ មួយចំនួន ស្ថាប័នតុលាការ និង ក្រសួងមួយចំនួនរបស់រដ្ឋ។ ស្ថាប័នបន្ថែមមួយចំនួន ទៀតដូចជា រដ្ឋសភា តុលាការធម្មនុញ្ញ ឬ តុលាការ ក៏អាចត្រូវបានផ្តល់ការទទួលខុសត្រូវក្នុងការអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយដែរ។

មានការព្រមព្រៀងជាឯកច្ឆ័ន្ទជាលក្ខណៈអន្តរជាតិដែលកាន់តែមានច្រើនឡើងៗ ស្តី អំពីចរិតលក្ខណៈមួយចំនួនដែលចាំបាច់សម្រាប់ភាពជោគជ័យរបស់ស្ថាប័នអនុវត្ត ដែលស្ថាប័ននេះត្រូវធ្វើទៅតាមកម្រិតនៃឯករាជ្យភាពរបស់ខ្លួន។ មានកត្តាចំនួនបីដែលរួមចំណែក ធ្វើឲ្យមានឯករាជ្យភាពរបស់ស្ថាប័នទាំងនោះ។ ទីមួយ រាល់ការតែងតាំងនានាសម្រាប់មុខដំណែងនៅក្នុងស្ថាប័ននោះគួរត្រូវធ្វើឡើងដោយឯករាជ្យពីរដ្ឋាភិបាលប្រសិនបើអាចធ្វើបាន។ ក្នុងករណីដែលការធ្វើដូច្នេះមិនអាចទៅរួចទេ ការត្រួតពិនិត្យឲ្យបានស៊ីជម្រៅគួរត្រូវបានយកមកអនុវត្ត។ យ៉ាងហោច-ណាស់ គេគួរជ្រើសរើសជម្រើសមួយដែលក្នុងនោះការតែងតាំងត្រូវបានធ្វើឡើងដោយសភាតំណាងរាស្ត្រ។ ប្រសិនបើការតែងតាំងសមាសភាពរបស់ស្ថាប័ននោះត្រូវបាន ធ្វើឡើងដោយរដ្ឋាភិបាល វាអាចនាំឲ្យមានការអនុវត្តដោយលំអៀង ឬដោយប្រកាន់បក្សពួក ដែល ធ្វើឲ្យគណបក្សប្រឆាំងត្រូវប្រឈមមុខនឹងការងសំពាធធ្ងន់ធ្ងរពីស្ថាប័នបញ្ញត្តិករហិរញ្ញវត្ថុនយោបាយ ឬភ្នាក់ងារអនុវត្តច្បាប់បើប្រៀប ធៀបទៅនឹងគណបក្សកាន់អំណាច ឬគណបក្សដែលគាំទ្ររដ្ឋាភិបាល។ ទីពីរ អ្នកដែលត្រូវបានតែងតាំងនៅក្នុងស្ថាប័ននោះគួរត្រូវបានផ្តល់ការធានាអំពីសន្តិសុខក្នុងមុខតំណែងរបស់ពួកគេ។ ចុងក្រោយ វាពិតជាមានសារសំខាន់ ណាស់ដែលស្ថាប័នោះត្រូវមានឯករាជ្យភាពយ៉ាងពិតប្រាកដពាក់ព័ន្ធនឹងថវិកាសម្រាប់ដំណើរការ ជាពិសេសស្ថាប័ននោះមិនគួរជាកម្មវត្ថុនៃការអន្តរាគមរបស់រដ្ឋា-ភិបាលទេ។ លក្ខ ខណ្ឌពីរចុងក្រោយសម្រាប់ធានាឯករាជ្យភាពនេះបានជួយធានាថាស្ថាប័ននោះ និងអ្នកដែលត្រូវបានគេតែងតាំងនឹងត្រូវបានដាក់ទណ្ឌកម្មដោយរដ្ឋាភិបាលទោះជាផ្នែកហិរញ្ញវត្ថុ ឬរូបកាយក៏ដោយ ចំពោះការចាត់វិធានការរបស់ពួកគេប្រឆាំងទៅនឹងជនណាដែលប្រព្រឹត្តល្មើសច្បាប់ និង បទបញ្ញាស្តីអំពីហិរញ្ញវត្ថុនយោបាយ។

ការប្រព្រឹត្តទៅនៃស្ថាប័នអនុវត្តអាចត្រូវបានរាំងស្ទះដោយកត្តាដទៃទៀត បើទោះជាស្ថាប័ននោះមានឯករាជ្យភាពសមល្មមហើយក្តី។ ការបែងចែក ការទទួលខុសត្រូវក្នុងចំណោមស្ថាប័ននានាដែលចូលរួមក្នុងការអនុវត្តគឺជាកត្តាមួយ។ កង្វះខាតកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ថាប័នផ្សេងៗនៅក្នុងប្រព័ន្ធ នៃការអនុវត្ត ជាញឹកញ យធ្វើឲ្យមានភាពខ្វះចន្លោះនៅក្នុងប្រព័ន្ធនោះនិងភាពច្របូកច្របល់លើការទទួលខុសត្រូវ ដែលជាហេតុធ្វើឲ្យដំណើរការអនុវត្តមានភាពស្មុគស្មាញ។ ការរិតត្បិតថែមទៀតទៅលើ លទ្ធភាពរបស់ស្ថាប័ននេះ ជា រឿយៗ គឺជាកង្វះខាតធនធាននិងអំណាចក្នុងការអនុវត្តទណ្ឌកម្មឲ្យបានពេញលេញ និងក្នុងការធ្វើការស៊ើបអង្កេត ។ ស្ថាប័ណភាគច្រើនត្រូវបាន

រំខានក្នុងកម្រិតណាមួយដោយសារកង្វះខាតធនធានទាំងនោះ។ បញ្ហាទាំ ងនេះរួមមាន ធនធានហិរញ្ញវត្ថុ និង ធនធានមនុស្ស ហើយពិតណាស់គឺពេលវេលាថែមទៀត។ នៅពេល គេជួបប្រទះកង្វះខាតផ្នែកធនធានមនុស្ស និងពេលវេលា ស្ទើរតែនៅគ្រប់ករណីទាំងអស់ ការធ្វើចំណាត់ថ្នាក់អាទិភាពគឺជារឿងចាំបាច់ ។ ផ្ទុយទៅវិញ កង្វះខាតផ្នែកថវិកាគឺជាបញ្ហាមួយធ្ងន់ធ្ងរដែលនាំទៅរកការខកខានទាំងស្រុងនៅក្នុងការអនុវត្ត។

ជុំវិញបញ្ហាកង្វះខាតថវិកានេះ ស្ថាប័នអនុវត្ត បទបញ្ញាគួរតែបង្កើតប្រព័ន្ធធ្វើចំណាត់ថ្នាក់អាទិភាពសម្រាប់ករណីនានាដែលគេត្រូវចាត់ការអនុវត្ត។ ដោយហេតុថាវាអាចនឹងមានភាពងាយស្រួលក្នុងការចាត់អាទិភាពករណីនានាដើម្បីប្រើប្រាស់ប្រកបដោយប្រសិទ្ធផលនូវធនធានដែលគេអាចរកបាន ការ បង្កើតប្រព័ន្ធធ្វើចំណាត់ថ្នាក់អាទិ-ភាពមួយប្រកបដោយប្រសិទ្ធភាព និង ការពិនិត្យប្រព័ន្ធនេះឡើងវិញជាទៀងទាត់ ពិតជាមានសារសំខាន់ចំពោះការបំពេញភារកិច្ចរបស់ស្ថាប័នអនុវត្ត។ បរាជ័យមួយក្នុងចំណោមបរាជ័យធំៗដែលកើតមានចំពោះស្ថាប័នអនុវត្តគឺកង្វះខាតធនធានរដ្ឋបាល និងធនធានមនុស្ស ដែលធ្វើឲ្យការគ្រប់គ្រងពេលវេលា និងធនធាន ទាំងអស់ប្រកបដោយភាពវៃឆ្លាតរិតតែមានភាពចាំបាច់។ នៅពេលគេពិចារណាអំពីប្រព័ន្ធធ្វើចំណាត់ថ្នាក់អាទិភាពដើម្បីឲ្យមានការប្រើប្រាស់ធនធានមានប្រសិទ្ធផល លក្ខខណៈវិនិច្ឆ័យក្នុងការចាត់អាទិភាព ជារឿយៗ គឺទំហំនៃករណីដែលត្រូវអនុវត្ត។

ឧទាហរណ៍ ៖ នៅសហរដ្ឋអាមេរិក គណៈកម្មការរៀបចំការបោះឆ្នោតសហព័ន្ធបាន បង្កើតប្រព័ន្ធមួយដើម្បីចាត់ចំណាត់ថ្នាក់លើករណីដែលត្រូវអនុវត្ត ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖

- លក្ខណៈធ្ងន់ធ្ងរនៃការរំលោភបំពានដែលត្រូវបានចោទប្រកាន់
- ផលប៉ះពាល់ជាក់ស្តែងដែលការរំលោភបំពានបានបង្កឡើងលើដំណើរការបោះឆ្នោត
- ទំនាក់ទំនងសកម្មភាព និង ការរៀបចំតាក់តែងច្បាប់ និង កម្មវត្ថុ។

ស្រដៀងគ្នាទៅនឹងបញ្ហាធនធាននេះដែរ ទាំងស្ថាប័ន អនុវត្តដែលមានភាពរឹងមាំ និងមិនសូវរឹងមាំ សុទ្ធតែត្រូវប្រឈមមុខទៅនឹងបញ្ហាដែលបណ្តាលមកពីកង្វះខាតអំណាចសម្រាប់ប្រតិបត្តិ។ នៅប្រទេស ប៊ុលហ្គារី ការិយាល័យសវនកម្មជាតិ គឺជាស្ថាប័នអនុវត្ត បទបញ្ញាហិរញ្ញវត្ថុនយោបាយដ៏ចម្បង បើទោះជាអំណាចដែលមានកម្រិតរបស់ស្ថាប័ននេះបានធ្វើឲ្យប៉ះពាល់ដល់ការប្រព្រឹត្តទៅរបស់ស្ថាប័ននេះក៏ដោយ ។ ការិយាល័យនេះមានអំណាចត្រឹមតែធ្វើសេចក្តីរាយការណ៍អំពីការរំលោភបំពាននានាតែប៉ុណ្ណោះ។ ក្នុងករណីដែ លគេជឿជាក់ថាមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ របាយការណ៍ពីការិយាល័យសវនកម្មជាតិ នឹងត្រូវបញ្ជូនទៅការិយាល័យរដ្ឋអជ្ញាក្រុងសូហ្វីយ៉ា (Sofia) ដើម្បីធ្វើការស៊ើបអង្កេត។ ពាក់ព័ន្ធទៅនឹងស្ថាប័នមួយដែលត្រូវបានបង្កើតឡើងយ៉ាងរឹងមាំ ទើបតែនៅឆ្នាំ ២០០៩ ប៉ុណ្ណោះដែលគណៈកម្មាការរៀបចំការបោះឆ្នោតរបស់ចក្រភពអង់គ្លេសត្រូវបានគេផ្តល់អំណាចថ្មីៗដើម្បីស៊ើបអង្កេតការប្រព្រឹត្តល្មើសនឹងច្បាប់គណបក្សនយោបាយនិងស្តីពីហិរញ្ញវត្ថុសម្រាប់ការបោះឆ្នោត និងដើម្បីដាក់ទណ្ឌកម្មផ្នែកស៊ីវិល តាមរយៈការអនុម័តច្បាប់ស្តីពីគណបក្សនយោបាយនិងការបោះឆ្នោត បន្ទាប់ពីមានការផ្ទុះរឿងអាស្រូវពាក់ព័ន្ធនឹងហិរញ្ញវត្ថុនយោបាយជាសាធារណៈមក។

*តារាង១ ៖ តើស្ថាប័នណាជាអ្នកទទួលខុសត្រូវទៅលើការគ្រប់គ្រង និង អនុវត្តបទបញ្ញា?*

| ស្ថាប័នជាតិគ្រប់គ្រងការបោះឆ្នោត | ស្ថាប័នអនុវត្តដែលបង្កើតឡើងពិសេសសម្រាប់គោលបំណងនេះ | ក្រសួងស្ថាប័នរបស់រដ្ឋាភិបាល | ផ្សេងៗ |
|---|---|---|---|
| ៤៥ ប្រទេស (៤៨%) | ៩ ប្រទេស (១០%) | ២០ ប្រទេស (២២%) | ១៩ ប្រទេស (២០%) |
| សរុប = ៩៣ ប្រទេស | | | |

តារាង១ បង្ហាញពី កម្រិតអត្ថិភាពនៃស្ថាប័នអនុវត្តខុសៗគ្នានៅជុំវិញពិភពលោក។ អង្គការអាយឌាអន្តរជាតិ (International IDEA) បានរាយការណ៍ផងដែរថា ក្នុងចំណោមប្រទេសចំនួន៩៣ មានប្រទេសចំនួន ២០ ដែលមានស្ថាប័នពីរឬច្រើនដែលគ្រប់គ្រង និងអនុវត្ត បទបញ្ញាហិរញ្ញវត្ថុនយោបាយ។ ទោះបីជា ការទទួលខុសត្រូវពាក់ព័ន្ធនឹងបទបញ្ញាហិរញ្ញវត្ថុនយោបាយ និងការអនុវត្តធ្លាក់ទៅលើស្ថាប័នមួយ ឬ ច្រើនក៏ដោយ ក៏កិច្ចការនៃប្រព័ន្ធហិរញ្ញវត្ថុនយោបាយនៅតែ នៅដូចគ្នាដដែល នោះគឺ ៖

- រៀបចំទម្រង់របាយការណ៍ និងនីតិវិធីក្នុងការរាយការណ៍
- ទទួលរបាយការណ៍ដែលបានធ្វើសវនកម្ម និង មិនបានធ្វើសវនកម្ម
- បោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍សវនករ
- ផ្តួចផ្តើមអធិការកិច្ច និងសំណួរសាធារណៈ និង
- ដាក់ទោសទណ្ឌកម្ម។

នៅក្នុងអត្ថបទវិភាគរបស់គាត់លើក្របខ័ណ្ឌហិរញ្ញវត្ថុនយោបាយនៃប្រទេសលីបង់ បណ្ឌិត *ម៉ាកណឹស អូមែន* បានបង្ហាញអំពីរបៀបដែលសមាសធាតុនៃភារកិច្ចនីមួយៗនៃភារកិច្ចទាំងនេះត្រូវបានបែងចែក រវាងស្ថាប័នធំៗចំនួនបីដែលជាប់ពាក់ព័ន្ធទៅនឹងបទបញ្ញាហិរញ្ញវត្ថុនយោបាយ និងការអនុវត្តនៅ ក្នុងប្រទេសលីបង់ (តារាងឯកសារយោងពាក់ព័ន្ធនឹងច្បាប់បោះឆ្នោតរបស់លីបង់)។

*តារាង២ ៖ សិទ្ធិអំណាចរបស់គណៈកម្មការត្រួតពិនិត្យយុទ្ធនាការបោះឆ្នោត(SCEC)*

| ការទទួលខុសត្រូវ | កាលបរិច្ឆេទកំណត់ | យោង |
|---|---|---|
| ការអនុលោមទៅតាមការបើក និង ការដំណើរការគណនីធនាគារសម្រាប់យុទ្ធនាការបោះឆ្នោត | បេក្ខជនត្រូវរាយការណ៍ទៅកាន់ SCEC | §55(1) |
| ការអនុលោមទៅតាមប្រភព និង ប្រភេទនៃមូលនិធិសម្រាប់ការឃោសនា និង ការធ្វើវិភាគទាន | តាមរយៈការវិភាគបន្តបន្ទាប់ និងការសិក្សាលើរបាយការណ៍ដែលទទួលបាន | §56 |
| ការអនុលោមទៅតាមកម្រិតអតិបរមានៃចំណាយ | តាមរយៈការវិភាគបន្តបន្ទាប់ និងការសិក្សាលើរបាយការណ៍ដែលទទួលបាន | §57 |
| ការអនុលោមទៅតាមមុខចំណាយលើយុទ្ធនាការឃោសនាដែលច្បាប់អនុញ្ញាត | តាមរយៈការវិភាគបន្តបន្ទាប់ និងការសិក្សាលើរបាយការណ៍ដែលទទួលបាន | §58-59 |
| ការអនុលោមទៅតាមការតម្រូវឲ្យធ្វើរបាយការណ៍ស្តីពីចំណាយក្នុងយុទ្ធនាការឃោសនា | SCEC អាចលើកយកករណីនៃការរំលោភបំពានទៅកាន់តុលាការ | §62(1) |

| | | |
|---|---|---|
| បង្ហៃរបាយការណ៍ទៅក្រុមប្រឹក្សាធម្មនុញ្ញ | របាយការណ៍របស់ SCEC ត្រូវភ្ជាប់ជាមួយទឡ្ហីករណ៍ផ្នែកច្បាប់ (ដោយបេក្ខជន) ប្រឆាំងទៅនឹងការការបោះឆ្នោតរបស់បេក្ខជនជាក់លាក់ណាមួយ | §62(2) |

## *តារាង៣ ៖ សិទ្ធិអំណាចរបស់គណៈរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រីមហាផ្ទៃនិងរដ្ឋបាលដែនដី*

| ការទទួលខុសត្រូវ | យោបល់ | យោង |
|---|---|---|
| ធ្វើការសម្រេចចិត្តលើដែនកំណត់ចំណាយសម្រាប់យុទ្ធនាការ | ការផ្តល់យោបល់ដែលធ្វើឡើងដោយរដ្ឋមន្ត្រី និង ចេញក្រិត្យដោយគណៈរដ្ឋមន្ត្រី | §57 |

## *តារាង៤ ៖ សិទ្ធិអំណាចក្រុមប្រឹក្សាធម្មនុញ្ញ*

| ភារកិច្ច | កាលបរិច្ឆេទកំណត់ | យោង |
|---|---|---|
| ធ្វើសេចក្តីសម្រេចចិត្តលើដែនកំណត់ចំណាយសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត | ទឡ្ហីករណ៍ដែលបានដាក់ដោយបេក្ខជនចាញ់ឆ្នោត | §62(2) |

ប្រភព៖ ម៉ាកណឹស អូមែន (២០០៩) "ក្របខ័ណ្ឌហិរញ្ញវត្ថុនយោបាយនៅក្នុងប្រទេសលីបង់" ទំព័រ ៣៤

## *៧. លវេលានៃការអនុវត្ត*

មិនថាស្ថាប័នប្រភេទណាជាអ្នកទទួលខុសត្រូវចុងក្រោយក្នុងការអនុវត្តហិរញ្ញវត្ថុនយោបាយនោះទេ ការអនុវត្តមានអត្ថន័យបំផុតនៅពេលដែលវាត្រូវបានធ្វើឡើងក្នុងអំឡុងពេលធ្វើយុទ្ធនាការឃោសនា ។ នៅពេលមានការអនុវត្តក្នុងពេលវេលាមួយសមស្រប អ៊ីនធ័រណែតត្រូវបានទទួលស្គាល់ថាជា ឧបករណ៍មួយដែលមានប្រសិទ្ធភាព និងកាន់តែមានការប្រើប្រាស់ច្រើនក្នុងខណៈដែលការបង្ហាញព័ត៌មានក្នុងរយៈពេលមួយពិតប្រាកដត្រូវបានធ្វើឡើងយ៉ាងទៀងទាត់។ ក្នុងពេលដែលមានកិច្ចខិតខំប្រឹងប្រែងប្រកបដោយភាពប្រយ័ត្នប្រយែងនៅជុំវិញពិភពលោកក្នុងការអនុវត្តច្បាប់និងបទបញ្ញាហិរញ្ញវត្ថុនយោបាយឲ្យទាន់ពេលវេលា ការអនុវត្តនេះទាមទារធនធានជាក់លាក់ មួយចំនួនដែលស្ថាប័នអនុវត្តខ្លះមិនអាចរកបានឡើយ។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធទិន្នន័យមូលដ្ឋានតាមបណ្តាញអ៊ីនធ័រណែត (Database Online) ត្រូវបានបង្កើតឡើងដោយស្ថាប័នអនុវត្តហិរញ្ញវត្ថុនយោបាយមួយចំនួន រួមមាន ៖ គណៈកម្មការកណ្តាលរៀបចំការបោះឆ្នោតនៅប៉ាឡេស្ទីន និងគណៈកម្មការ ជាតិរៀបចំការបោះឆ្នោតនៅប្រទេសអាហ្វហ្គានីស្ថានជាដើម។ ប្រទេសមួយចំនួន នៅក្នុងអតីតប្លុកសហភាពសូវៀត ដូចជា ឡាទ្វី (Latvia) និងលីទុយអានី (Lithuania) ក៏បានធ្វើឲ្យមានការជឿនលឿនផងដែរនៅក្នុងវិស័យនេះ ។ ប្រព័ន្ធ ទិន្នន័យមូលដ្ឋានតាមបណ្តាញអ៊ីនធ័រណែត (Database Online) ដែលមានលក្ខណៈទំនើប រួមមាន៖ គណៈកម្មការបោះឆ្នោតសហព័ន្ធសហរដ្ឋអាមេរិក (FEC) និងក្រុមប្រឹក្សាហិរញ្ញវត្ថុសម្រាប់យុទ្ធនាការ ឃោសនានៃបុរីញូវយ៉ក (NYCCFB) គណៈកម្មការ បោះឆ្នោតប្រទេសកាណាដា (Elections Canada) និងវិទ្យាស្ថានបោះឆ្នោតសហព័ន្ធនៃប្រទេសម៉ិ ចស៊ិច (IFE) ព្រមទាំងគណៈកម្មការរៀបចំការបោះឆ្នោតនៃចក្រភពអង់គ្លេស ដែល នឹងដាក់ឲ្យប្រើប្រាស់ប្រព័ន្ធនេះនៅឆ្នាំ២០១០។ ក្នុង -ករណីមួយចំនួន ដែលប្រព័ន្ធអ៊ីនធ័ រណែតត្រូវបានដាក់ឲ្យប្រើប្រាស់ជាឧបករណ៍សម្រាប់លើកកម្ពស់តម្លាភាពនៅក្នុងវិស័យអនុវត្ត និង បទបញ្ញា ការប្រើប្រាស់ ប្រព័ន្ធអ៊ីនធ័រណែតបានបង្ហាញភាពគ្មាននិរន្តរភាព ដែលញឹកញាប់ដោយសារកង្វះខាតថវិកា និងធនធានផ្សេងៗ។

ការទទួលបានរបាយការណ៍ទាំងនេះតាមរយៈបណ្តាញអ៊ីនធ័រណែត អនុញ្ញាតឲ្យសង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយមានឱកាសធ្វើការវិភាគ និងពិនិត្យព័ត៌មាន ព្រមទាំងអាចធ្វើការ ស៊ើបអង្កេតទៅលើភាពមិនប្រក្រតីនៃចំណូល ឬ ចំណាយ។

## ការស៊ើបអង្កេត

ការស៊ើបអង្កេតបានជួយលាតត្រដាងឲ្យឃើញពីភាពមិនប្រក្រតីទាក់ទងនឹងហិរញ្ញវត្ថុនយោបាយ និង ការរំលោភបំពាននានា តាមរយៈការធ្វើ សវនកម្មយ៉ាងទៀងទាត់ទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងពេលធ្វើយុទ្ធនាការឃោសនា ។ មានដំណើរការស្តង់ដារចំនួនបី ដែលតាមរយៈនោះ ការរំលោភបំពានច្បាប់ និង បទបញ្ញាពាក់ព័ន្ធនឹងហិរញ្ញវត្ថុនយោបាយត្រូវបានរាយការណ៍ ដំណើរការទាំងនោះមាន៖ ការតាមដាន បណ្តឹង និងការបញ្ជូនបណ្តឹង។

- ការតាមដាន៖ ការរំលោភបំពានរកឃើញតាមរយៈការពិនិត្យឡើងវិញលើរបាយការណ៍ហិរញ្ញវត្ថុ ឬការធ្វើសវនកម្ម។
- បណ្តឹង៖ បុគ្គល ឬអង្គភាពណាមួយអាចដាក់ពាក្យបណ្តឹង ធ្វើការចោទប្រកាន់ការរំលោភបំពាន និងពន្យល់ពីមូលដ្ឋានសម្រាប់ការចោទប្រកាន់។
- ការបញ្ជូនបណ្តឹង៖ ការរំលោភបំពានដែលអាចកើតមាន ដែលត្រូវបានរកឃើញដោយភ្នាក់ងារផ្សេងៗ (ឧទាហរណ៍ គណបក្សនយោបាយ) និង ដែលបានបញ្ជូនទៅកាន់ភ្នាក់ងារអនុវត្តហិរញ្ញវត្ថុនយោបាយចម្បងដើម្បីដោះស្រាយ។

សម្រាប់ដំណើរការនីមួយៗ មានវិធីសាស្រ្តនិងឧបករណ៍ជាក់លាក់ មួយចំនួនដែលគេបានទទួលយកមកប្រើប្រាស់។ វិធីសាស្រ្ត និង ឧបករណ៍ដែលប្រហែលជាមានការប្រើប្រាស់ច្រើនជាងគេបំផុតគឺ ការធ្វើសវនកម្ម ដែលជាឧបករណ៍តាមដានមួយត្រូវបានប្រើប្រាស់ដើម្បីធានាការគោរពច្បាប់ និងបទប ញ្ញាស្តីអំពីហិរញ្ញវត្ថុនយោបាយ។ យ៉ាងណាក៏ដោយ ដើម្បី ធ្វើសវនកម្ម គេចាំបាច់ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុនយោបាយមួយចំនួន។ ការធ្វើសវនកម្មអាចអនុញ្ញាតឲ្យកម្រិតតម្លាភាពមានការកើនឡើង នៅពេល ការធ្វើសវនកម្មនោះត្រូវបានធ្វើឡើងដោយដោយអង្គភាពណាមួយដែលមិនស្ថិតនៅក្នុងគណបក្សនយោបាយ ដូចជា បញ្ញត្តិករហិរញ្ញវត្ថុនយោបាយ អាជ្ញាធរពន្ធដារ ឬ អាជ្ញាធរឯករាជ្យណាមួយ។ វិធានដែលពាក់ព័ន្ធទៅនឹងការបង្ហាញព័ត៌មាន ជាទូទៅតម្រូវឲ្យយុទ្ធនាការឃោសនារាយការណ៍អំពីវិភាគទាន ការចំណាយ និងប្រតិបត្តិការហិរញ្ញវត្ថុដទៃទៀត រួមជាមួយនឹងកម្រងឯកសារពាក់ព័ន្ធសម្រាប់ធ្វើការផ្ទៀងផ្ទាត់របាយការណ៍។ ទោះជាយ៉ាងណាក៏ដោយ គ្មានអង្គភាពសវនកម្មណាមួយមានសមត្ថភាពត្រួតពិនិត្យមើលបរិមាណដ៏ច្រើននៃប្រតិបត្តិការហិរញ្ញវត្ថុ ដែលអាចនឹងត្រូវដាក់បង្ហាញនៅក្នុងពេលនៃដំណើរការបោះឆ្នោត។ ការអនុវត្តទូទៅក្នុងចំណោម ស្ថាប័នអនុវត្តនានាតាមរយៈសិទ្ធិអំណាចដែលគេត្រូវការជាចាំបាច់នោះ គឺការធ្វើសវនកម្មបែបគម្រូតាងទៅលើគណបក្សនយោបាយ និង/ឬ បេក្ខជនដោយសារតែកង្វះធនធាន។ ភ្នាក់ងារសវនកម្មអាចជ្រើសរើសធ្វើសវនកម្មគណបក្សនយោបាយនិងបេក្ខជន ដោយផ្អែកលើរបាយការណ៍មុនៗរបស់គណបក្សនយោបាយនិងបេក្ខជន។ គណបក្សនយោបាយ និង បេក្ខជននយោបាយ ដែលទទួលបានឧបត្ថម្ភធនសាធារណៈ ហើយនិងគណបក្សឬបេក្ខជន ដែលមានប្រវត្តិរំលោភបំពានច្បាប់និងបទបញ្ញាពាក់ព័ន្ធនឹងហិរញ្ញវត្ថុនយោបាយ ឬដែលធ្វើការចំណាយលើសពីចំនួនដែលច្បាប់កំណត់ទំនងជានឹងត្រូវបានធ្វើសវនកម្ម។ ការរកឃើញ

ភាពមិនប្រក្រតីធ្ងន់ធ្ងរ កំហុសឬការលួចបន្លំ ឬ ការរំលោភបំពានជាសក្តានុពលនានាតាមរយៈការធ្វើសវនកម្ម អាចនាំឲ្យមានការស៊ើបអង្កេតបន្ថែមទៀតដោយបញ្ញត្តិករហិរញ្ញវត្ថុនយោបាយ ប្រសិនបើគេមានសិទ្ធិអំណាចធ្វើដូច្នោះ។

ការត្រួតពិនិត្យគឺជាយន្តការដ៏មានតម្លៃមួយទៀតសម្រាប់ការស៊ើបអង្កេត ។ សង្គមស៊ីវិលនិង ប្រព័ន្ធផ្សព្វផ្សាយអាចមានឥទ្ធិពលជាពិសេសប្រសិនបើដំណើរការបណ្តឹងជាផ្លូវការកើតមាន។ ចាប់ពីប្រទេសអាហ្សង់ទីនដល់ហ្វីលីពីនឡាតវី និងប្រទេសដទៃទៀត   អង្គការសង្គមស៊ីវិលនិង   ប្រព័ន្ធផ្សព្វផ្សាយបានបង្ហាញថាពួកគេអាចជាកម្លាំងចលករដ៏សំខាន់។  ការត្រួតពិនិត្យហិរញ្ញវត្ថុយុទ្ធនាការឃោសនាអនុញ្ញាតឲ្យសង្គមស៊ីវិល និង  ប្រព័ន្ធផ្សព្វផ្សាយកំណត់បានអំពីចំណុចខ្វះខាតនៅក្នុងនីតិវិធីនៃបទបញ្ជា និងលើកឡើងអំពីដំណោះស្រាយនានា  ។  ការចូលរួមរបស់ពួកគេអាចមានសារៈសំខាន់ជាពិសេសក្នុងករណីដែលស្ថាប័នអនុវត្តដែលមានស្រាប់អាចនឹងមានភាពទន់ខ្សោយ ដើម្បីធានាថាបទបញ្ជា និង ការអនុវត្តហិរញ្ញវត្ថុយុទ្ធនាការឃោសនាមិនត្រូវបានបោះបង់ចោលទាំងស្រុង។ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយក៏មានតួនាទីផងដែរនៅក្នុងវិស័យដ៏សំខាន់នៃការបង្ការពីការរំលោភបំពាន  ហើយបញ្ហានេះនឹងត្រូវបានពិភាក្សាថែមទៀតនៅក្នុងផ្នែកបន្ទាប់នៃជំពូកនេះ។

## ការការពារពីការរំលោភបំពាន

ក្នុងវិស័យនៃការអនុវត្តហិរញ្ញវត្ថុនយោបាយ យើង          អាចយកសុភាសិតបុរាណដែលបានលើកឡើងថា "ការពារប្រសើរជាងព្យាបាល" យកមកអនុវត្ត ។ អ្នកជំនាញ ការ និងអ្ន កប្រតិបត្តិជាច្រើនបានទទួលស្គាល់ទស្សនៈនេះដោយពួកគេជ ឿ ក់ថា    គេច្បាស់ជាមិនអាចលុបបំបាត់ដំណើរការនយោបាយនៃគ្រប់ឥទ្ធិពលអវិជ្ជមានរបស់ថវិកានៅក្នុងបញ្ហានយោបាយបានទេ។   ទោះជាមានការទទួលស្គាល់យ៉ាងនេះក្តី   ក៏គេប ន្ផតើារស្រាវជ្រាវយ៉ាងតិចតួចបំផុតទាក់ទងទៅនឹងការធ្វើដូចម្តេចដើម្បីបង្ការការរំលោភបំពានបទបញ្ញាហិរញ្ញវត្ថុនយោបាយ  បើប្រៀបធៀបទៅនឹងការស្រាវជ្រាវទៅលើការធ្វើដូចម្តេចដើម្បីធ្វើការអង្កេត និង ចាត់វិធានការទៅលើប្រភេទនៃអំពើរំលោភបំពានទាំងនោះ។   តាមអ្វីដែលបានកើតឡើងពីអតីតកាល បទ  បញ្ញាហិរញ្ញវត្ថុនយោបាយនិងការអនុវត្តដែលគេឃើញមានការចាប់អារម្មណ៍ច្រើនជាញឹកញាប់បំផុតគឺដោយសារមានរឿងអាស្រូវលេចឡើង ។ ឧទាហរណ៍៖ នៅសហរដ្ឋអាមេរិកគណៈកម្មការរៀបចំការបោះឆ្នោតសហព័ន្ធ   ដែលជាស្ថាប័នច្បាប់ឯករាជ្យទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ហិរញ្ញវត្ថុយុទ្ធនាការឃោសនាបោះឆ្នោតរបស់ជាតិត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៧៥          ដែលជាលទ្ធផលកើតចេញពីរឿងអាស្រូវ*វ៉ាត់ធ័រហ្គេត* (Watergate)។ មុនពេល ផ្ទុះរឿងអាស្រូវនេះ  ការតម្រូវឲ្យមានការបង្ហាញព័ត៌មានដែលបង្កើតឡើងដោយច្បាប់ស្តីពីអំពើពុករលួយកាលពីឆ្នាំ ១៩១០ មិនត្រូវបានអនុវត្តទូលំទូលាយដោយសភាតំណាងរាស្ត្រឡើយ។ រឿងអាស្រូវ*វ៉ាត់ធ័រហ្គេត*   (Watergate)   បានបញ្ជាក់ពីតម្រូវការចាំបាច់ក្នុងការបង្កើតឲ្យមានស្ថាប័នឯករាជ្យមួយនៅសហរដ្ឋអាមេរិកដើម្បីអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការធ្វើយុទ្ធនាការឃោសនា បោះឆ្នោត។

រឿងអាស្រូវ *ហ្វ្លិច អាហ្វែរ* (Flick Affair) ដែលកើតមាននៅប្រទេសអាល្លឺម៉ង់បានផ្តល់ជា ឧទាហរណ៍មួយទៀតហើយនិងផលប៉ះពាល់របស់វាទៅលើបទបញ្ញាហិរញ្ញវត្ថុនយោបាយ និង ការអនុវត្តបទបញ្ញានេះ       ។ គណបក្សសហភាពប្រជាធិបតេយ្យនៃគ្រឹស្តសាសនិក (   CDU)    ជាយូរយារណាស់មកហើយតែងតែបានបញ្ជូនជំនួយឧបត្ថម្ភពីក្រុមហ៊ុនរបស់អាល្លឺម៉ង់ និង  ពីក្រុមតស៊ូមតិនានា តាមរយៈអង្គការសម្ងាត់   ដើម្បីគេចវេសពីការបង់ពន្ធដែលជាហេតុផលមួយក្នុងចំណោមហេតុផលផ្ទុយច្បាប់នានា។       នៅទីបំផុតការអនុវត្តរបស់គណបក្សសហភាពប្រជាធិបតេយ្យ

នៃគ្រឹស្តសាសនិក (CDU) ត្រូវបានលាតត្រដាងនៅក្នុងទសវត្សឆ្នាំ ១៩៨០ ដែលនាំទៅរកការដាក់ឲ្យប្រើប្រាស់ច្បាប់ថ្មីស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយ នៅក្នុងឆ្នាំ១៩៨៤។ គោលបំណងរួមនៃការបង្ការពីការរំលោភបំពានហិរញ្ញវត្ថុនយោបាយជាប់ពាក់ព័ន្ធទនឹងការលើកទឹកចិត្តឲ្យគណបក្សនយោបាយ និង បេក្ខជនធ្វើការផ្លាស់ប្តូរការអនុវត្តរបស់ពួកគេ ដើម្បីកុំឲ្យរឿងអាស្រូវដូចខាងលើកើតមានឡើង ។ បើនិយាយម្យ៉ាងទៀត ការផ្សព្វផ្សាយឲ្យសាធារណជនបានដឹងលឺអំពីការរំលោភបំពាននៅដំណាក់កាលនេះ និង នៃចំណែកតូចមួយអាចជាមធ្យោបាយមានប្រសិទ្ធភាពមួយក្នុងការលើកទឹកចិត្តគណបក្សនយោបាយ និង បេក្ខជនឲ្យគោរពតាមបទបញ្ញាពាក់ព័ន្ធនានាដែលមានជាធរមាន។

ជាថ្មីម្តងទៀត តួនាទីរបស់សង្គមស៊ីវិលនិងប្រព័ន្ធផ្សព្វផ្សាយមានសារសំខាន់យ៉ាងខ្លាំងទាក់ទងទៅនឹងការបង្ការពីការរំលោភបំពានបទបញ្ញាហិរញ្ញវត្ថុនយោបាយ ។ តាមរយៈការលាតត្រដាងឲ្យដឹងអំពីការរំលោភបំពានផ្នែកហិរញ្ញវត្ថុនយោបាយ និង ការធ្វើឲ្យអ្នករំលោភបំពានទាំងនោះអាម៉ាស់មុខ សង្គមស៊ីវិលនិងប្រព័ន្ធផ្សព្វផ្សាយអាចមានឥទ្ធិពលទៅលើសកម្មភាពនានារបស់គណបក្សនយោបាយ និង បេក្ខជនផ្សេងទៀត ។ ស្ថាប័នទទួលបន្ទុកអនុវត្តជាច្រើនត្រូវបានតម្រូវឲ្យផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុនៃយុទ្ធនាការឃោសនា ដើម្បីឲសាធារណៈជនបានដឹងចំណែកឯមធ្យោបាយដែលងាយស្រួលបំផុតក្នុងការធ្វើដូច្នេះគឺតាមរយៈប្រព័ន្ធអ៊ីនធ័រណែត។ យ៉ាងណាក៏ដោយប្រសិនបើការអនុវត្តវិធានការក្នុងការផ្សព្វផ្សាយរបាយការណ៍មានកម្រិតតិចតួច សង្គមស៊ីវិលនិងប្រព័ន្ធផ្សព្វផ្សាយអាចអនុវត្តការដាក់សំពាធតាមរយៈការទាមទារយករបាយការណ៍ទាំងនេះ។

ធាតុផ្សំដែលមានសារសំខាន់មួយផ្សេងទៀតសម្រាប់ការបង្ការពីការរំលោភបំពាន គឺការ ត្រួតពិនិត្យផ្ទៃក្នុងរបស់គណបក្សនយោបាយ។ នៅក្នុងគណបក្សនយោ បាយ ប្រព័ន្ធដែលមានរួមបញ្ចូល "គោលនយោបាយរបស់ស្ថាប័នអនុវត្ត" ដែលនៅក្នុងនោះភ្នាក់ងារ "ដែលគេបានចាត់តាំង" ជាអ្នកអនុញ្ញាតរាល់ការចំណាយទាំងអស់នៅក្នុងយុទ្ធនាការឃោសនា និងជាអ្នកពិនិត្យចំណូលដែលជាវិភាគទាននានាដើម្បីរកមើលករណីរំលោភបំពានលើវិធានពាក់ព័ន្ធនានា ជាទ្រឹស្តីប្រព័ន្ធនោះគួរតែមានរបាយការណ៍ល្អប្រសើរមួយដែលបង្ហាញអំពីការអនុវត្តតាមវិធានទាំងនោះ។ ប្រព័ន្ធនេះ ជួយធានាឲ្យបានថា ភ្នាក់ងារហិរញ្ញវត្ថុរបស់គណបក្សនយោបាយមាន ការទទួលខុសត្រូវមួយច្បាស់លាស់ក្នុងការគ្រប់គ្រងធនធានផ្នែកហិរញ្ញវត្ថុ។ កត្តាមួយចំនួនតូចអាចធ្វើឲ្យដំណើរការនៃការអនុវត្តតាមបទបញ្ញាមានភាពស្រពិចស្រពិលខ្លះៗ ហើយអាចធ្វើឲ្យរាំងស្ទះដល់សុឆន្ទៈក្នុងការបង្ការពីការរំលោភបំពាន។ កត្តាមួយក្នុងចំណោកត្តាទាំងនោះគឺ បទប្បបញ្ញត្តិនានាស្តីអំពីហិរញ្ញវត្ថុនយោបាយមិនត្រូវបានចែងឲ្យបានគ្រប់គ្រាន់នៅក្នុងច្បាប់តែមួយនោះទេ។ បទប្បបញ្ញត្តិទាំងនោះអាចមានចែងនៅក្នុងច្បាប់ខុសៗគ្នាជាច្រើន ដូចជាច្បាប់ហិរញ្ញវត្ថុគណបក្ស ឬហិរញ្ញវត្ថុសម្រាប់ការបោះឆ្នោត ច្បាប់បោះឆ្នោត ច្បាប់គណបក្សនយោបាយ ឬច្បាប់ប្រឆាំងអំពើពុករលួយជាដើម ដែលធ្វើឲ្យមានការលំបាកសម្រាប់គណបក្សនយោបាយ និង បេក្ខជនក្នុងការអនុវត្តតាមច្បាប់ និងបទបញ្ញាទាំងនោះ។ អ្វីដែលកាន់តែស្មុគស្មាញជាងនេះទៀតគឺថា បទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ផ្សេងៗគ្នាទាំងនោះអាចនឹងមិនស៊ីសង្វាក់គ្នា។

ជាចុងក្រោយ គោលគំនិត ពាក់ព័ន្ធនឹងការប៉ាន់ប្រមាណទៅលើហានិភ័យគួរតែយកមកអនុវត្តជាមធ្យោបាយសម្រាប់ទប់ស្កាត់ការរំលោភបំពានផងដែរ។ ស្ថាប័នទទួលបន្ទុកអនុវត្តហិរញ្ញវត្ថុនយោបាយអាចអនុម័តវិធីសាស្ត្រស្រដៀងគ្នាមួយសម្រាប់ប្រើប្រាស់ក្នុងការប៉ាន់ប្រមាណហានិភ័យក្នុងវិស័យដទៃៗទៀត ការរយៈការបង្កើតលក្ខណៈ

វិនិច្ឆ័យដើម្បីកំណត់អំពីគណបក្សនយោបាយនិងបេក្ខជន ដែលទំនងជាមិនសូវអនុវត្តតាមច្បាប់ និង បទបញ្ញាទាក់ទងទៅនឹងហិរញ្ញវត្ថុនយោបាយ។ គណបក្សនយោបាយនិងបេក្ខជនដែល ធ្លាប់បានរំលោភបំពានអាចនឹងត្រូវចាត់ទុកជាហានិភ័យខ្ពស់ជាងគណបក្សនិងបេក្ខជនដទៃ។ លក្ខណៈវិនិច្ឆ័យមួយចំនួនទៀតក៏ ចាំបាច់ត្រូវយកមកពិចារណាដែរ។ ប្រភេទនៃវិធីសាស្ត្រគោលដៅនេះគួរតែត្រូវបានអនុវត្តផងដែរនៅក្នុងការពិចារណាថា តើច្បាប់ និងបទបញ្ញាហិរញ្ញវត្ថុនយោបាយប្រភេទណាខ្លះដែលមានភាពចាំបាច់ជាងគេបំផុតសម្រាប់យកមកអនុវត្ត។

## *តើត្រូវអនុវត្តទៅលើអ្វីខ្លះ?*

តួនាទីរបស់បញ្ញត្តិករហិរញ្ញវត្ថុនយោបាយ គឺ ដើម្បីជួយកែលម្អការរំលោភបំពាន និងបញ្ឈប់គណបក្សនយោបាយនិងបេក្ខជនពីការរំលោភបំពាន តាមរយៈនៃការដាក់ទណ្ឌកម្ម។ យ៉ាងណាក៏ដោយ វា អាចជាការចាំបាច់ក្នុងការធ្វើការផ្លោះទៅរកការទប់ស្កាត់បញ្ហាជាក់លាក់ និងជាពិសេសដែលធ្វើឲ្យមានភាពទន់ខ្សោយនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុនយោបាយក្នុងទ្រង់ទ្រាយធំ។ បទបញ្ញាហិរញ្ញវត្ថុនយោបាយនីមួយៗអាចត្រូវបានផ្សារភ្ជាប់ទៅនឹងគោលដៅបទដ្ឋានជាក់លាក់មួយ។ ដើម្បីសម្រេចថា តើបទបញ្ញាអ្វីខ្លះដែលមានអាទិភាពក្នុងក្របខ័ណ្ឌនៃការយកមកអនុវត្តគេគួរពិចារណាទៅលើគោលដៅទាំងនេះ ដូចជា ៖ ការបង្កើនតម្លាភាព ការលើកកម្ពស់ការប្រកួតប្រជែង និងការទប់ស្កាត់ឥទ្ធិពលអវិជ្ជមានជាដើម ជាពិសេសក្នុងការអនុម័តប្រព័ន្ធនៃការចាត់ចំណាត់ថ្នាក់អាទិភាព។

ឧទាហរណ៍៖ បទបញ្ញាស្តីពីការបង្ហាញព័ត៌មានដែលមានការអនុវត្តប្រកបដោយប្រសិទ្ធភាព អាចនាំទៅរកប្រព័ន្ធហិរញ្ញវត្ថុនយោបាយមួយកាន់តែបើកចំហរដើម្បីធ្វើឲ្យអ្នកបោះឆ្នោតមានព័ត៌មានគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅពេលបោះឆ្នោត។ ការយល់ឃើញថា របាយការណ៍ហិរញ្ញវត្ថុដែលបញ្ញត្តិករហិរញ្ញវត្ថុនយោបាយទទួលបាននឹងត្រូវបានពិនិត្យយ៉ាងហ្មត់ចត់ អាច នឹងបញ្ឈប់គណបក្សនយោបាយ និងបេក្ខជនពីការ ជាប់ពាក់ព័ន្ធរបស់ពួកគេទៅនឹងសកម្មភាពហិរញ្ញវត្ថុមិនស្របច្បាប់ ឬមិនស្មោះត្រង់នានា ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើតម្រូវការចាំបាច់បំផុតគឺដើម្បីលើកកម្ពស់ការប្រកួតប្រជែង ដើម្បីធ្វើឲ្យទីលានប្រកួតប្រជែងមានភាពស្មើគ្នានៅក្នុងចំណោមបេក្ខជននិងគណបក្សនយោបាយ ដូចជាករណីដែលធ្លាប់កើតមាននៅក្នុងបណ្ដាប្រទេសអឺរ៉ុបខាងកើត ពេលនោះចំនុចអាទិភាពគួរតែផ្តោតទៅលើការអនុវត្តបទបញ្ញាស្តីអំពីហិរញ្ញប្បទានសាធារណៈ និងដែនកំណត់ចំណាយប្រសិនបើចាំបាច់។ ជាចុងក្រោយ ប្រសិនបើគោលដៅចម្បងនោះគឺដើម្បីទប់ស្កាត់ឥទ្ធិពលអវិជ្ជមាន និងការរំលោភបំពានធនធានរបស់រដ្ឋនោះស្ថាប័នដែលមានសមត្ថកិច្ចអនុវត្តគួរផ្តោតទៅលើការអនុវត្តបទបញ្ញានានាដែលពាក់ព័ន្ធទៅនឹងការធ្វើឧបត្ថម្ភធនផ្នែកសម្ភារៈ និង ការផ្សព្វផ្សាយសារនយោបាយតាមរលកធាតុអាកាសក្នុងចំណោមជម្រើសដទៃទៀត។

បទបញ្ញាស្តីពីហិរញ្ញប្បទានសាធារណៈ ដែនកំណត់ចំណាយ និងការបង្ហាញព័ត៌មានគួរតែជាផ្នែកតូចមួយនៃអ្វីដែលប្រព័ន្ធអនុវត្តគួរតែអនុវត្តប៉ុណ្ណោះ។ មានប្រភេទចម្បងៗបួននៃបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយ ដែលគេគួរយកមកពិចារណាប្រសិនបើគេចង់ឲ្យមានការអនុវត្តឲ្យបានត្រឹមត្រូវ។ ដូចគ្នាទៅនឹងបទបញ្ញានានាដែរ បទប្បញ្ញត្តិទាំងនេះរួមបញ្ចូលទាំងលក្ខខណ្ឌផ្នែកហិរញ្ញវត្ថុដែលទាក់ទងនឹងបេក្ខភាពសម្រាប់មុខតំណែងសាធារណៈ ឧបត្ថម្ភធន និង បម្រាមមួយចំនួន។ លក្ខខណ្ឌហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងបេក្ខភាពសំរាប់មុខតំណែងសាធារណៈ និងឧបត្ថម្ភ

ស្ថិតនៅក្នុងចំណោមប្រភេទបទប្បញ្ញត្តិដែលងាយស្រួលបំផុតក្នុងការអនុវត្ត ក្នុងខណៈដែលបម្រាម និង ប្រភេទដទៃទៀតនៃបទបញ្ជាបានបង្ហាញឲ្យឃើញនូវបញ្ហាប្រឈមមួយយ៉ាងធំ។

ប្រភេទទីមួយ ដែលជា លក្ខខណ្ឌពាក់ព័ន្ធទៅនឹងបក្ខភាព ជាទូទៅរាប់បញ្ចូលទាំងការប្រកាសទ្រព្យសម្បត្តិ និងប្រព័ន្ធដាក់ប្រាក់តម្កល់។ ការខកខានក្នុងការអនុវត្តបទបញ្ញត្តិច្បាប់ទាំងនេះ គឺជាមូលដ្ឋានក្នុងការហាមប្រាមគណបក្សនយោបាយ និង បេក្ខជន សម្រាប់ចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត ដែលបណ្តាលឲ្យមានការអនុវត្តបទប្បញ្ញត្តិទាំងនោះជាស្វ័យប្រវត្តិ។ ការធ្វើឧបត្ថម្ភធនផ្នែកនយោបាយក៏ងាយស្រួលក្នុងការត្រួតពិនិត្យដែរ ហើយឧបត្ថម្ភធនទាំងនេះរួមមានការផ្តល់ហិរញ្ញប្បទានដល់គណបក្សនយោបាយឬបេក្ខជន ការឧបត្ថម្ភ ឬ ការផ្តល់ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយឥតគិតថ្លៃដល់គណបក្សនយោបាយឬបេក្ខជន ការអនុគ្រោះពន្ធ និង ការឧបត្ថម្ភជាសម្ភារៈជាដើម។ គណបក្សនយោបាយនិងបេក្ខជនគឺជាអ្នកទី១ដែលត្រូវដឹងថា តើការផ្តល់ហិរញ្ញប្បទានសាធារណៈ និងការផ្សព្វផ្សាយតាមរយៈរលកធាតុអាកាសពិតជាត្រូវបានផ្តល់ឲ្យពួកគេដែរឬទេ។ ការបែងចែកទៅតាមជាក់ស្តែងនៃឧបត្ថម្ភធនទាំងនេះ ជាធម្មតាគឺជាការទទួលខុសត្រូវរបស់អង្គភាពគ្រប់គ្រងការបោះឆ្នោត ឬស្ថាប័នណាមួយរបស់រដ្ឋាភិបាល។ ដូចដែលបានកត់សម្គាល់នៅក្នុងជំពូក៣រួចមកហើយនោះ ៥៨%នៃរដ្ឋជាសមាជិកអង្គការសហប្រជាជាតិចំនួន១៧៤ប្រទេស ដែលមានប្រព័ន្ធនយោបាយបែបពហុបក្សមានបទបញ្ញត្តិជាផ្លូវការដែលចែងអំពីហិរញ្ញប្បទានសាធារណៈតាមបែបផ្ទាល់។ វត្តមានដ៏តិចតួចនៃបទប្បញ្ញត្តិទាំងនោះមិនធានាបានការអនុវត្តនោះទេ។ ឧទាហរណ៍ ប្រទេសអេត្យូពីបានផ្តើមអនុវត្តច្បាប់ស្តីពីហិរញ្ញប្បទានសាធារណៈសំរាប់បក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាំងពីយូរមកហើយ ពោលគឺចាប់ពីឆ្នាំ១៩៩៣មក ។ រហូតមកទល់សព្វថ្ងៃនេះ ពុំមានបក្សនយោបាយប្រឆាំងណាមួយបានទទួលហិរញ្ញប្បទានសាធារណៈឲ្យបានគ្រប់គ្រាន់ឡើយ។

ការហាមឃាត់ និង បទបញ្ជានានា (ដែលរួមបញ្ចូលទាំងបញ្ញត្តិស្តីពីចំណាយដែលយើងនឹងពិភាក្សានៅពេលក្រោយ) គឺស្ថិតក្នុងចំណោមបទប្បញ្ញត្តិហិរញ្ញវត្ថុនយោបាយដែលមានការលំបាកបំផុតក្នុងការអនុវត្ត។ ការហាមឃាត់អាចរួមបញ្ចូលទាំងអំពើពុករលួយ និង អំពើផ្ទុយច្បាប់នានា ដូចជាការរំលោភបំពានលើធនធានរបស់រដ្ឋ និងការទិញសន្លឹកឆ្នោតជាដើម ព្រមទាំងការផ្តល់វិភាគទាននានាដែលច្បាប់ហាមឃាត់ ដូចជាការផ្តល់វិភាគទានដែលមានប្រភពពីបរទេស និងវិភាគទានអនាមិក ហើយនិងវិភាគទានដែលធ្វើឡើងពីសំណាក់សាជីវកម្មពាណិជ្ជកម្មឬអ្នកម៉ៅការរបស់រដ្ឋាភិបាលជាដើម។ ការអនុវត្តដែលច្បាប់បានហាមឃាត់ទាំងនេះមានការលំបាកយ៉ាងខ្លាំងនៅក្នុងការអនុវត្តដោយហេតុថាអំពើទាំងនោះជារឿយៗកើតមានឡើងនៅគ្រប់កម្រិតទាំងអស់។

នៅកម្រិតទាប ការអនុវត្តពុករលួយ និង ការអនុវត្តផ្ទុយនឹងច្បាប់ អាចរាលដាលពាសពេញ និងដោយចំហរដែលធ្វើឲ្យមានការពិបាកក្រៃលែងក្នុងការទប់ស្កាត់។ នៅកៀកនឹងការបោះឆ្នោតនៅប្រទេសលីបង់កាលពីខែកក្កដា ឆ្នាំ២០០៩ កម្រិតដែលនៅក្នុងនោះ ការទិញសន្លឹកឆ្នោតបានក្លាយជារឿងមួយដែលគេអាចទទួលយកបាន ត្រូវបានគេមើលឃើញកាន់តែច្បាស់។ បើទោះជាការទិញសន្លឹកឆ្នោតជាអំពើដែលផ្ទុយនឹងច្បាប់នៅក្នុងប្រទេសលីបង់ក៏ដោយ ក៏កម្រិតនៃការទិញសន្លឹកឆ្នោតកើតមានយ៉ាងច្រើនសន្ធឹកសន្ធាប់នៅមុនការបោះឆ្នោត ដែលក្នុងករណីភាគច្រើនបំផុត គេបានចាត់វិធានការតិចតួចបំផុតទៅលើគណបក្សនយោបាយ និង បេក្ខជនក្នុងការលាក់បាំងសកម្មភាពរបស់ពួកគេ។ ការអនុវត្តដែលផ្ទុយនឹងច្បាប់យ៉ាងនេះក៏ត្រូវបានទទួលយកដោយទូលំទូលាយផងដែរដោយប្រជាពលរដ្ឋនៅតាមមណ្ឌលបោះឆ្នោត។ កាសែតញូយ៉កថាមស៍ (The New York Times) បានដកស្រង់សំដីរបស់អ្នកបោះឆ្នោត

ម្នាក់ ដែលបានអះអាង ថា "អ្នកដែលហ៊ានចំណាយច្រើនជាងគេនឹងទទួលបានសន្លឹកឆ្នោតរបស់ខ្ញុំ. ខ្ញុំនឹងមិនទទួលយកប្រាក់តិចជាង៨០០ដុល្លារឡើយ"។ នេះសបញ្ជាក់ឲ្យឃើញពីទង្វើផ្ទុយនឹងច្បាប់ដែលបានចាក់ឫសគល់យ៉ាងជ្រៅ ស្រដៀងគ្នានេះដែរ ប្រធានគណៈកម្មការបោះឆ្នោតនៅក្នុងប្រទេសថៃ លោកអាភិឆាត ស៊ុខាកកានុន (Apichart Sukhagganond) បានសំដែងចេញយ៉ាងចំហរថា ការទិញសន្លឹកឆ្នោតគឺមានពាសពេញនៅក្នុងប្រទេស ឯអ្នកនយោបាយទិញសន្លឹកឆ្នោតដោយចំហរ។

នៅក្នុងកម្រិតខ្ពស់ជាងនេះ អំពើ ពុករលួយនិងសកម្មភាពផ្ទុយនឹងច្បាប់ត្រូវបានអនុវត្តដោយប៉ិនប្រសប់ និងយ៉ាងសម្ងាត់ ដែលធ្វើឲ្យមានការលំបាកក្នុងការលាតត្រដាងអំពើទាំងនេះ។ នៅពេលអំពើទាំងនោះត្រូវបានគេរកឃើញ គេត្រូវការធនធានយ៉ាងច្រើនសន្ធឹកសន្ធាប់ដើម្បីផ្សព្វផ្សាយរំលោភបំពានទាំងនោះ។ ប្រសិនបើបទបញ្ញត្តិប្រឆាំងអំពើពុករលួយនិងអំពើផ្ទុយច្បាប់ទាំងនោះត្រូវបានអនុវត្ត និងមានការដាក់ទណ្ឌកម្មឲ្យបានគ្រប់គ្រាន់ អំពើទាំងនោះនឹងត្រូវបានកាត់បន្ថយប្រកបដោយប្រសិទ្ធភាព។

ចំនួនដ៏ច្រើននៃប្រភេទបទបញ្ញាហិរញ្ញវត្ថុនយោបាយធ្វើឲ្យការអនុវត្តបទបញ្ញាទាំងនោះមានការលំបាក។ បទបញ្ញាហិរញ្ញវត្ថុនយោបាយភាគច្រើនរួមបញ្ចូលវិធានមួយចំនួនដូចខាងក្រោម៖

១. វិធាននៃការបង្ហាញព័ត៌មាន
២. ដែនកំណត់នៃការចំណាយ
៣. ដែនកំណត់នៃការធ្វើវិភាគទាន
៤. វិធានការក្នុងការត្រួតពិនិត្យការប្រើប្រាស់ធនធានសាធារណៈសម្រាប់យុទ្ធនាការឃោសនា
៥. វិធានស្តីអំពីការប្រើប្រាស់ផ្ទាល់ខ្លួននូវមូលនិធិរបស់បេក្ខជន
៦. វិធានស្តីអំពីការប្រើប្រាស់មធ្យោបាយឃោសនាសម្រាប់យុទ្ធនាការបោះឆ្នោត
៧. វិធានពាក់ព័ន្ធទៅនឹងហិរញ្ញប្បទានសម្រាប់ការប្រកួតប្រជែងផ្ទៃក្នុងរបស់គណបក្ស
៨. វិធានពាក់ព័ន្ធទៅនឹងហិរញ្ញប្បទានសម្រាប់ការធ្វើប្រជាមតិ។

បទបញ្ញាមួយចំនួនក្នុងចំណោមបទបញ្ញាទាំងប៉ុន្មានខាងលើនេះ ស្ថិតនៅក្នុងប្រភេទទាំងនៅក្នុងដែនកំណត់ និង ការហាមប្រាម ។ ការហាមប្រាមលើការផ្តល់ហិរញ្ញវត្ថុពីបរទេសគេឃើញមានការប្រើប្រាស់យ៉ាងច្រើន ។ ប្រសិនបើមានករណីនេះ ការទទួលបានឬការទទួលយកមូលនិធិដែលមានប្រភពពីបរទេសដោយគណបក្សនយោបាយ ឬ បេក្ខជនគឺជាមូលហេតុសម្រាប់ការដាក់ទណ្ឌកម្ម។ គណបក្សនយោបាយក៏ដូចបេក្ខជនដែរបានទទួល ឬ ទទួលយកយកមូលនិធិពីបរទេសនិងបានបំពានលើច្បាប់ ឬពួកគេមិនបានធ្វើដូច្នោះ ។ ចំនួនទឹកប្រាក់នៅក្នុងករណីទាំងនេះគឺសម្រាប់ផ្នែកច្រើនបំផុតដែលមិនបានជាប់ពាក់ព័ន្ធ។ ផ្ទុយទៅវិញ ការអនុវត្តបទបញ្ញាពាក់ព័ន្ធនឹងដែនកំណត់តម្រូវឲ្យមានកិច្ចការ បន្ថែមទៀតនៅខាងអង្គភាពអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយ ឬស្ថាប័នសវនកម្ម ។ ប្រសិនបើមានការបំពានទៅលើដែនកំណត់ ស្ថាប័នអនុវត្តដែលមានសមត្ថកិច្ចត្រូវតែធ្វើការគណនា និង កំណត់ប្រតិបត្តិការហិរញ្ញវត្ថុមួយណាដែលគណបក្សនយោបាយ ឬ បេក្ខជនបានបំពានលើសពីដែនកំណត់ដើម្បីដាក់ទណ្ឌកម្ម។

## ទណ្ឌកម្ម

ទណ្ឌកម្មជាឧបករណ៍ដ៏ចម្បងដែលភ្នាក់ងារអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយអាចធ្វើបាន។ មានការព្រមព្រៀងជាឯកច្ឆ័ន្ទក្នុងចំណោមអង្គការនៅតាមតំបន់ និង អង្គការអន្តរជាតិមួយចំនួនថា ការដាក់ទណ្ឌកម្មមានភាពចាំបាច់ណាស់ក្នុងការអនុវត្តច្បាប់ហិរញ្ញវត្ថុនយោបាយឲ្យមានប្រសិទ្ធភាព។ កំរិតនៃការដាក់ទណ្ឌកម្មនៅក្នុងក្របខ័ណ្ឌច្បាប់នៃប្រទេសនានា បើទោះជារឿយៗមិនត្រូវបានអនុវត្តក៏ដោយ ក៏បានបង្ហាញអំពីការទទួលស្គាល់ជាសាកលថាជាឧបករណ៍ចាំបាច់មួយសម្រាប់បទបញ្ញា និងការអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយ។

*តារាង ៥៖ ការគាំទ្រដោយអន្តរជាតិ និងតំបន់ចំពោះការដាក់ទណ្ឌកម្ម*

| | |
|---|---|
| គណៈកម្មាធិការរដ្ឋមន្ត្រី<br>អនុសាសន៍លេខ៤ មាត្រា១៦ (២០០៣) | "រដ្ឋនានាគួរតែតម្រូវជាដាច់ខាតឲ្យការរំលោភទៅលើវិធានដែលពាក់ព័ន្ធទៅនឹងការផ្ដល់មូលនិធិដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោតក្លាយជាកម្មវត្ថុនៃការដាក់ទណ្ឌកម្មប្រកបដោយប្រសិទ្ធភាព សមស្របនិង លើកទឹកចិត្តមិនឲ្យមានការរំលោភបំពាន"។ |
| គណៈកម្មការទីក្រុងវេនីស(Venice)<br>គោលការណ៍ស្ដីពីការផ្ដល់ហិរញ្ញប្បទានដល់បក្សនយោបាយ<br>អនុម័តនៅថ្ងៃទី ៩-១០ មិនា ២០០១ (កថាខណ្ឌ ១៩) | "ភាពមិនប្រក្រតីណាមួយនៅក្នុងការផ្ដល់ហិរញ្ញប្បទានយុទ្ធនាការឃោសនាបោះឆ្នោតនានា ត្រូវទទួលទណ្ឌកម្ម សម្រាប់គណបក្សនយោបាយ ឬ បេក្ខជនដែលបាន ប្រព្រឹត្តកំហុស ឲ្យសមមាត្រទៅនឹងកំរិតនៃបទល្មើស។ ទណ្ឌកម្មនោះអាចរួមបញ្ចូលទាំងការហាមឃាត់ទាំងស្រុង ឬ មួយផ្នែកក្នុងការទទួលបានហិរញ្ញប្បទានសាធារណៈ ការដាកពិន័យ ឬ វិធានការផ្ទេកហិរញ្ញវត្ថុផ្សេងទៀត ឬ មោឃភាពលទ្ធផលនៃការបោះឆ្នោត"។ |
| មជ្ឈមណ្ឌលខាតផរ៖ សេចក្ដីថ្លែងការរបស់ក្រុមប្រឹក្សាប្រធានាធិបតី និង នាយករដ្ឋមន្ត្រីនៅទ្វីបអាមេរិច។<br>"ហិរញ្ញប្បទានប្រជាធិបតេយ្យ៖ គណបក្សនយោបាយ យុទ្ធនាការឃោសនា និង ការបោះឆ្នោត" ១៩ មិនា ២០០៣ ទំព័រ៣ | "ការអនុវត្តច្បាប់ និង បទបញ្ញាហិរញ្ញវត្ថុនយោបាយតម្រូវឲ្យមានអាជ្ញាធរត្រួតពិនិត្យឯករាជ្យមួយ និងប្រព័ន្ធដាក់ទណ្ឌកម្មមួយមានប្រសិទ្ធភាពដើម្បីបញ្ឈប់និទណ្ឌភាព"។ |
| អង្គការតម្លាភាពអន្តរជាតិ<br>ឯកសារគោលនយោបាយលេខ 2/2005 ទំព័រ ៣ | "ការរំលោភបំពានបទបញ្ញាហិរញ្ញវត្ថុគណបក្សត្រូវតែដាក់ទណ្ឌកម្មឲ្យមានប្រសិទ្ធភាព"។ |

នៅពេលការរំលោភបំពានត្រូវបានសិបើអង្កេត ការដាក់ទណ្ឌកម្មចាប់ពីកម្រិតស្រាលរហូតដល់កម្រិតធ្ងន់នឹងត្រូវអនុវត្តដោយស្ថាប័នមានសមត្ថកិច្ច។ ការដាក់ទណ្ឌកម្មមានសារសំខាន់ណាស់ ព្រោះទណ្ឌកម្មបានជួយដោះស្រាយការរំលោភបំពាន និងអាចអនុវត្តបានចាប់ពីការហាមប្រាមទៅលើការធ្វើវិភាគទានជាក់លាក់មួយចំនួន ឬក្នុងករណីធ្ងន់ធ្ងរ ការដាក់ទណ្ឌកម្មអាចឈានទៅដល់ការបណ្តេញចេញពីមុខតំណែងជាប់ឆ្នោត។ ដើម្បីធ្វើឲ្យមានប្រសិទ្ធភាព ទណ្ឌកម្មត្រូវតែសមាមាត្រទៅនឹងការទំហំនៃការរំលោភបំពាន។ ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរជ្រុលហួសហេតុពេកទៅលើគណបក្ស ឬបេក្ខជនដែលបានប្រព្រឹត្តកំហុស អាចនឹងបង្អាក់ការអនុវត្តច្បាប់ជាជាងការទប់ស្កាត់ការរំលោភបំពាន ជាពិសេសករណីអនុវត្តប្រឆាំងនឹងគណបក្សគ្រប់គ្រងអំណាច។ ប្រសិនបើយើងត្រឡប់ទៅនៅគោលដៅនៃបទដ្ឋានរបស់យើងវិញ ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរជ្រុលក៏អាចនាំឲ្យមានផលអវិជ្ជមានទៅលើគោលបំណងក្នុងការលើកកម្ពស់ការប្រកួតប្រជែងដែរ។ ជារឿយៗ គណបក្សដែលទើបនឹងបង្កើតថ្មី មិនសូវមានបទពិសោធន៍ គណបក្សតូចៗ ឬគណបក្សនៅមូលដ្ឋានច្រើនតែជួបប្រទះគុណវិបត្តិធ្ងន់ធ្ងរនៅពេលមានការអនុវត្តទណ្ឌកម្មជ្រុលហួសហេតុពេក។

ផ្ទុយទៅវិញ វិធានការព្រួសរលុងពេកក៏ជាបញ្ហាដែរ។ បេក្ខជននិងគណបក្សនយោបាយនឹងមើលឃើញថាការចំណាយក្នុងករណីមានការរំលោភបំពានទាបជាងការការអនុវត្តតាមច្បាប់ និង បទបញ្ញា ដែលជាហេតុនាំឲ្យមានការបង្អាក់ដល់ការអនុវត្ត។

**ការដាក់ទណ្ឌកម្មនៅអាមេរិកឡាទីន**

ទិន្នន័យពីបណ្តាប្រទេសចំនួន ៨ បានបង្ហាញថា ការដាក់ទណ្ឌកម្មមិនមែនជាប្រព័ន្ធដ៏កម្សោយបំផុតមួយ នៃប្រព័ន្ធហិរញ្ញវត្ថុនយោបាយតាមបណ្តាប្រទេសនានានៅអាមេរិកឡាទីននេះ ។ ការប្រើប្រាស់រង្វាស់ចង្អុលបង្ហាញ (សូចនាករ) ស្តីពីក្របខណ្ឌច្បាប់ និងការប្រកាន់ខ្ជាប់ខ្ជួនទៅនឹងការអនុវត្តច្បាប់ គួរសបញ្ជាក់បន្ថែមពីចំនុចសំខាន់ៗមួយចំនួន ។ ប្រភេទដ៏គួរសមញ្ញបំផុតមួយនៃការប្រើប្រាស់ប្រព័ន្ធដាក់ទណ្ឌកម្មក្នុងបណ្តាប្រទេសទាំង ៨ ខាងលើនេះគឺការកាត់ប្រាក់បំរុងដោយផ្ទាល់ ។ ការវាយតម្លៃលើក្របខណ្ឌច្បាប់ស្តីពីការដាក់ទណ្ឌកម្មនេះ ជាទូទៅវាមានការពាក់ព័ន្ធគ្នាបែបវិជ្ជមានពីមួយទៅមួយក្នុងប្រទេសមួយចំនួនដូចជា កូលុមបៀ កូស្តារីកា នីការ៉ាហ្គា និងប្រទេសប៉េរូជាដើម ។ លើកលែងតែប្រទេសកូលុមបៀមួយចេញ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តលើប្រព័ន្ធដាក់ទណ្ឌកម្មនេះគឺមានលក្ខណៈមិនខ្លាំងក្លាឡើយ ពោលគឺពាក់ព័ន្ធនឹងសំណុំបែបបទជាក់ស្តែងរបស់ច្បាប់ទាំងនោះតែម្តង ។ ជាជម្រើសមួយទៀត ខណៈដែលច្បាប់ទាំងឡាយខាងលើ មានសភាពមិនសូវជាទាមទារខ្លាំងក្លាប៉ុន្មាននោះ នោះការអនុវត្តច្បាប់ទាំងនោះក៏ពុំសូវជាមានសភាពខ្លាំងក្លាប៉ុន្មានឡើយ (ករណីប្រទេស អាហ្សង់ទីណា និងប៉ាណាម៉ាជាដើម)។ នេះមិនមែនជារឿងដែលតែងតែកើតមានឡើយ បន្ទាប់ពីបានជាទិន្នន័យនានា បានបង្ហាញថា ការអនុវត្តច្បាប់នៅមានការខ្វះចន្លោះ ដូចជានៅក្នុងប្រទេស ហ្គាតេម៉ាឡា (Guatemala) និងប្រទេសប៉ាណាម៉ា ដែលសុទ្ធសឹងតែជាប្រទេសដែលមិនមានការកំណត់បញ្ញត្តិឲ្យមានខ្លាំងក្លានោះឡើយ ។

ប្រភព៖ គម្រោងការងារ Crinis ក្នុងទំព័រទី ៣០-៣២

ប្រភេទទណ្ឌកម្មផ្សេងៗរួមមាន:

១. ការដាក់ទណ្ឌកម្មផ្នែកហិរញ្ញវត្ថុ ដែលរួមបញ្ចូលទាំងការផាកពិន័យរដ្ឋបាលតិចតួច
២. ការផាកពិន័យធ្ងន់ធ្ងរ សំរាប់កំហុសធ្ងន់ធ្ងរ
៣. ការដាក់ទណ្ឌកម្មផ្នែកព្រហ្មទណ្ឌចំពោះករណីធំៗ ដែលផ្ទើយប៉ះពាល់ដល់ភាពត្រឹមត្រូវនៃការបោះឆ្នោត
៤. ការខកខានក្នុងការទទួលបានសំណងមកវិញសម្រាប់ការចំណាយលើការបោះឆ្នោត ការដកហូតមកវិញនូវហិរញ្ញប្បទានសាធារណៈ និង ការផ្លោះសិទ្ធិក្នុងការទទួលបានហិរញ្ញប្បទានក្នុងពេលអនាគត

៥. អត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ដែលបានផ្តល់ឲ្យ ឬបានទទួលដោយគណបក្សនយោបាយដែលរំលោភបំពានទៅលើបញ្ញត្តិហាមប្រាមជាក់លាក់មួយចំនួនត្រូវបានរឹបអូសជាថវិការដ្ឋ
៦. ហាត់បង់អសនៈក្នុងសភា ត្រូវបានជម្រុះចេញពីការឈរឈ្មោះបោះឆ្នោតក្នុងពេលអនាគត និងហាត់បង់លក្ខណៈសម្បត្តិក្នុងការតែងតាំងជាមន្ត្រីសាធារណៈ
៧. ការរំលាយគណបក្ស
៨. មោឃភាពការបោះឆ្នោត។

ទណ្ឌកម្មមួយចំនួនក្នុងចំណោមទណ្ឌកម្មទាំងអស់ខាងលើនេះ (ឧទាហរណ៍ ទណ្ឌកម្មទី១ និងទី២ ) អាចត្រូវបានចាត់បញ្ចូលជាទណ្ឌកម្មផ្នែករដ្ឋបាល ដែលមានដំណើរការដូចជា "សំបុត្រផាកពិន័យ" ហើយគេអាចយកមកអនុវត្តទាំងចំពោះការរំលោភបំពានតូចតាចឬសាមញ្ញ និងទាំងការរំលោភបំពានធ្ងន់ធ្ងរជាងនេះ។ ក្នុងករណីដែលគេបានរកឃើញថាមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ស្ថាប័នដែលទទួលបន្ទុកអនុវត្តច្បាប់អាចសម្រេចដាក់ទណ្ឌកម្មព្រហ្មទណ្ឌដែលមានន័យថាជាការកាត់ទោស។ ក្នុងករណីជាច្រើន ស្ថាប័នដែលទទួលបន្ទុកអនុវត្តច្បាប់គ្មានអំណាចក្នុងការអនុវត្តការកាត់ទោសទេ។ បើទោះជាការកាត់ទោសត្រូវបានធ្វើឡើងដោយស្ថាប័នទទួលបន្ទុកអនុវត្តច្បាប់ ឬនីតិបុគ្គលមួយផ្សេងទៀតក៏ដោយ ក៏នីតិវិធីក្នុងការកាត់ទោសក្នុងរឿងព្រហ្មទណ្ឌអាចជាបន្ទុកមួយយ៉ាងធ្ងន់ធ្ងរ និងត្រូវការពេលវេលា។ ស្ថាប័នអនុវត្តបទបញ្ញត្តិអាចមានជម្រើសផងដែរក្នុងដាក់បណ្តឹងរដ្ឋប្បវេណីទៅកាន់តុលាការ។

## ឧបសគ្គសំខាន់ៗចំពោះការអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយ

### *ការផ្តល់ថវិកាដោយភាគីទីបី*

ការធ្វើវិភាគទាន និងចំណាយដែលធ្វើឡើងដោយភាគីទីបីបង្កើតបានជាចំណុចក៏ដធំមួយក្នុងបរិបទការត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយ និងបង្កជាឧបសគ្គធំមួយចំពោះបទបញ្ញាហិរញ្ញវត្ថុនយោបាយ។ វិភាគទាន និង ការចំណាយទាំងនោះរួមមាន ការចំណាយទៅលើទំនិញឬសេវា ឬការចំណាយប្រាក់ក្នុងនាមគណបក្សឬបេក្ខជននយោបាយដែលធ្វើឡើងដោយបុគ្គលផ្សេងទៀត។ កង្វះខាតបទបញ្ញា និងការអនុវត្តបទបញ្ញាទៅលើការផ្តល់ថវិកា ដែលធ្វើឡើងដោយភាគីទីបីបានគំរាមកំហែងដល់តម្លាភាពនៃហិរញ្ញវត្ថុនយោបាយ ដោយសារថា វិភាគទាននិងការចំណាយទាំងនេះជាញឹកញាប់ត្រូវបានកំណត់ថា ជាការឧបត្ថម្ភផ្នែកសម្ភារៈ និងមិនត្រូវបានកត់ត្រាចូលទៅក្នុងបញ្ជីឡើយ។ លើសពីនេះទៅទៀត ការដាក់ដែនកំណត់លើការចំណាយដែលមានគោលបំណងធានាឲ្យមានសមភាពនៅក្នុងទីលានប្រកួតប្រជែងតាមរយៈការកំណត់កម្រិតអតិបរមានៃការចំណាយ ក៏អាចនឹងត្រូវបានធ្វើប៉ះពាល់យ៉ាងធ្ងន់ធ្ងរផងដែរដោយការផ្តល់ថវិកាពីសំណាក់ភាគីទី៣។

មានមូលហេតុមួយចំនួនដែលបរិបទត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយរបស់ភាគីទីបីត្រូវបានគេមើលរំលង។ ទីមួយ គេមានការលំបាកក្នុងការធានាថា ច្បាប់ដែលភាគីពាក់ព័ន្ធសំខាន់ៗត្រូវតែគោរពត្រូវបានបន្តដល់ភាគីទី៣។ ទីពីរ សមាសធាតុរបស់គណបក្សជាញឹកញាប់ ប្រឈមទៅនឹងកង្វះខាតធនធានធ្ងន់ធ្ងរជាងទីស្នាក់ការកណ្តាលគណបក្សខ្លួន-ឯង។ នៅក្នុងជំពូក១ដែលនិយាយអំពីការបើកចំហរព័ត៌មានបានបង្ហាញឲ្យយើងឃើញអំពីអំពីអភិក្រមថ្មីមួយ ពាក់ព័ន្ធ

ទៅនឹងរបាយការណ៍ហិរញ្ញវត្ថុដែលផ្តល់ដោយភាគីទី៣នៅក្នុងប្រទេសលីបង់។ គណបក្សនយោបាយនិងបេក្ខជនត្រូវបានតម្រូវឲ្យយករបាយការណ៍អំពីការចំណាយទាំងឡាយណាដែលអាចនឹងផ្តល់ផលប្រយោជន៍ដល់យុទ្ធនាការរបស់ពួកគេ។ ក្នុងទិដ្ឋភាពជាក់ស្តែង មានតែអភិក្រមតិចតួចប៉ុណ្ណោះពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យថវិកាដែលផ្តល់ដោយភាគីទីបីបានទទួលជោគជ័យ។ ការលើកកម្ពស់ការត្រួតពិនិត្យផ្ទៃក្នុងរបស់គណបក្សតាមរយៈដោយការដាក់ឲ្យមានភ្នាក់ងារជំនាញផ្នែកហិរញ្ញវត្ថុដែលទទួលខុសត្រូវលើរាល់ចំណូល និង ចំណាយសម្រាប់យុទ្ធនាការឃោសនាពិតជាអាចជួយដោះស្រាយករណីនេះបាន។

## *ការអនុវត្តបទបញ្ជាដោយលំអៀង*

ការអនុវត្តដោយលំអៀងគឺជាបញ្ហាមួយធ្ងន់ធ្ងរដែលអាចធ្វើឲ្យប៉ះពាល់ដល់សមភាពរវាងបេក្ខជន និងរវាងគណបក្សនយោបាយដែលចូលរួមនៅក្នុងដំណើរការនយោបាយ ។ មានហេតុផលមួយចំនួន នៅពីក្រោយការ អនុវត្តបទបញ្ជាហិរញ្ញវត្ថុនយោបាយដោយលំអៀង ហើយដែលចម្បងជាងគេគឺទាក់ទិនទៅនឹងការរក្សាការពារខ្លួនឯង (*self-preservation)*។ ឧទាហរណ៍ បញ្ញត្តិករហិរញ្ញវត្ថុនយោបាយអាចមានអារម្មណ៍ថាគេទទួលរងសម្ពាធក្នុងការអនុវត្តការងារដែលជាហេតុធ្វើឲ្យគេត្រូវបំពេញកិច្ចការទៅតាមការចង់បានរបស់គណបក្សកាន់អំណាច ឬគណបក្សដែលគាំទ្ររដ្ឋាភិបាល ដោយសារតែពួកគេខ្លាចមានការសងសឹកប្រឆាំងនឹងពួកគេ ។ យ៉ាងណាក៏ដោយ កំរិតនៃការ អនុវត្តដោយលំអៀងអាចកើតមានលើសពីនោះទៅទៀត ជាហេតុធ្វើឲ្យគណបក្សប្រឆាំងឬបេក្ខជនប្រឆាំងអាចនឹងក្លាយជាកម្មវត្ថុនៃការរិតបន្តឹងការអនុវត្ត ដែលជួនកាលរួមបញ្ចូលទាំងការរំលោភបំពាននានាដែលច្បាប់ពុំបានចែងទៀតផង។ ឯករាជ្យភាពនៃស្ថាប័នអនុវត្តបទបញ្ជាពាក់ព័ន្ធទៅនឹងប្រភពមូលនិធិ ការធានាមុខតំណែងសម្រាប់ការបំពេញការងារ និង ដំណើរការនៃការតែងតាំងគឺជាគន្លឹះនៅក្នុងការបង្ការការប្រព្រឹត្តបែបនេះ។

## *ការកេងចំណេញទៅលើភាពខ្វះចន្លោះនៃច្បាប់*

ការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធហិរញ្ញវត្ថុនយោបាយ បានបណ្តាលឲ្យមានចំនួនដ៏ច្រើនលើសលប់នូវច្បាប់ និង បទបញ្ជានានាដែលមានលក្ខណៈប្រហាក់ប្រហែលស្តីអំពីបញ្ហានោះ ។ ប្រសិនបើប្រព័ន្ធហិរញ្ញវត្ថុនយោបាយមានការរីកចម្រើន គណបក្សនយោបាយ និង បេក្ខជនក៏មានទំនោរទៅតាមនោះដែរ ។ ទាំងនៅក្នុងកម្រិតទាបនិងខ្ពស់ គណបក្សនយោបាយ និងបេក្ខជនអាចមានលទ្ធភាពបត់បែនទៅតាមច្បាប់ស្តីពីហិរញ្ញវត្ថុគណបក្សនយោបាយ ដែលជាញឹកញាប់គឺដោយការកេងចំណេញលើភាពខ្វះចន្លោះនៃច្បាប់។ ប្រសិនបើស្ថាប័នអនុវត្តច្បាប់មានភាពទន់ខ្សោយ ការបត់បែនរបស់គណបក្សនយោបាយនិងបេក្ខជននឹងមិនសូវជាចាំបាច់ទេ ។ គណបក្សនយោបាយ និង បេក្ខជននយោបាយជារឿយៗនឹងមិនសូវយកចិត្តទុកដាក់ទៅលើច្បាប់និងបទបញ្ជា ដែលមិនសូវមានតម្លៃចំពោះពួកគេនោះទេ។

នៅក្នុងប្រព័ន្ធណាដែលស្ថាប័នមានភាពរឹងមាំ តួអង្គនយោបាយមានភាពស្ទាត់ជំនាញយ៉ាងពិសេសក្នុងការគេចវេសពីច្បាប់។ ការប្រើប្រាស់បច្ចេកទេសនានា ដូចជាប្រព័ន្ធគណនេយ្យត្រួត និងការពឹងផ្អែកទៅលើចំណាយឯករាជ្យត្រូវបានប្រើប្រាស់យ៉ាងច្រើន។ ក្នុងករណីមួយចំនួន ក្រុមមេធាវីអាចត្រូវបានគេប្រើឲ្យធ្វើការវិភាគទៅលើក្របខ័ណ្ឌច្បាប់ដើម្បីរកមើលចន្លោះប្រហោងណាដែលអាចមានប្រយោជន៍ដល់ពួកគេ។ នៅពេលដែលវិធាន និង បទ

បញ្ហាដែលពាក់ព័ន្ធមិនចាំបាច់មានការរំលោភបំពាន ប៉ុន្តែត្រូវបានគេចេរសេមិនព្រមគោរពតាម នោះទំនាក់ទំនងការអនុវត្តច្បាប់នឹងគ្មានអំណាចអ្វីធំដុំឡើយ។ នៅពេលបញ្ហាថ្មីៗត្រូវបានដាក់ចេញ ចន្លោះប្រហោងនានាក៏លេចចេញមកដែរ ហើយវដ្តនេះចេះតែបន្តកើតមានជាហូរហែរមក។

ដំណើរប្រទាក់ក្រឡាគ្នាចុះឡើងរវាងបទបញ្ញា និង ភាពចន្លោះប្រហោងនៃបទបញ្ញាបានបណ្តាលឲ្យមានច្បាប់ច្របូកច្របល់គ្នាយ៉ាងច្រើនពាក់ព័ន្ធទៅនឹងហិរញ្ញវត្ថុនយោបាយនៅសហរដ្ឋអាមេរិច ដែលអ្នកខ្លះនិយាយបំប៉ែកបំប្លែងថា មានអ្នកអនុវត្តច្បាប់មិនលើសពីមួយនាក់ទេឡើយនៅក្នុងពិភពលោកយើងនេះ ដែលបានយល់ច្បាស់អំពីច្បាប់ហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតរបស់សហរដ្ឋអាមេរិក។ កត្តាមួយចំនួនផ្សេងទៀតក៏បានរួមចំណែកផងដែរទៅលើចំនួនដ៏ច្រើននៃច្បាប់ហិរញ្ញវត្ថុនយោបាយនៅសហរដ្ឋអាមេរិក និងប្រព័ន្ធហិរញ្ញប្បទានរបស់ពួកគេ ដែលនៅក្នុងនោះ ហិរញ្ញប្បទានសាធារណៈសម្រាប់ការបោះឆ្នោតប្រធានាធិបតីបានក្លាយទៅជារឿងមិនធម្មតាមួយ ដែលខុសប្លែកយ៉ាងខ្លាំងពីប្រទេសដ៏ទៃទៀត។ បើទោះជាមានភាពខុសប្លែកគ្នានៅក្នុងចំណោមប្រព័ន្ធផ្តល់ហិរញ្ញប្បទាន និងដោយឡែកក្នុងចំណោមប្រព័ន្ធអនុវត្តច្បាប់ក៏ដោយ ការកេងយកចំណេញពីភាពខ្វះចន្លោះនៃច្បាប់គឺជាបញ្ហាជាសកលដែលកើតមាននៅក្នុងប្រទេសប្រជាធិបតេយ្យនិងមិនប្រជាធិបតេយ្យ។

សញ្ញាចុះសង្ខេបនៃបញ្ហាសំរាប់ប្រព័ន្ធដ៏ល្អមួយនៃបទបញ្ញា និងការអនុវត្ត ហាក់ដូចជាច្បាប់ហិរញ្ញវត្ថុនយោបាយមួយដែលមានភាពសាមញ្ញគ្រប់គ្រាន់- ច្បាស់លាស់ មិននាំឲ្យមានការបកស្រាយខុស ប្រកាន់និយម និងមានការធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់។ អត្ថន័យច្បាស់លាស់នៃពាក្យពេចន៍ហិរញ្ញវត្ថុនយោបាយជាក់លាក់ដែលប្រើប្រាស់នៅក្នុងច្បាប់មានសារសំខាន់យ៉ាងខ្លាំងក្នុងការបញ្ចៀសកុំឲ្យមានការភ័ន្តច្រឡំ ដែលអាចនាំមានការបកស្រាយខុស។

## *ការហាមឃាត់ការផ្តល់ប្រភពមូលនិធិពីបរទេសនិងពីក្រុមហ៊ុន*

ជារឿយៗ មូលនិធិពីបរទេសនិងពីក្រុមហ៊ុនដើរតួនាទីយ៉ាងធំក្នុងដំណើរការនយោបាយ ហើយនៅក្នុងករណីជាច្រើន មូលនិធិនេះមិនត្រូវបានគ្រប់គ្រងទាំងស្រុងដោយច្បាប់ឡើយ ។ ទិន្នន័យពីឆ្នាំ ២០០៣ បង្ហាញថា ក្នុងចំណោម ១១១ប្រទេស ៦៩%នៃប្រទេសទាំងនោះពុំមានបម្រាមលើការផ្តល់មូលនិធិពីបរទេសឡើយ។ ក្នុងខណៈនោះដែរ ៨០% នៃប្រទេសទាំងនោះពុំបានហាមឃាត់ការផ្តល់មូលនិធិពីក្រុមហ៊ុនទេ។ ប្រសិនបើមានការបម្រាមលើការផ្តល់មូលនិធិពីបរទេសនិងពីក្រុមហ៊ុន គឺរដ្ឋាភិបាលសម្អាតលុយកខ្វក់និងបច្ចេកទេសផ្សេងៗទៀតជាញឹកញាប់ត្រូវបានគេយកមកប្រើប្រាស់ដើម្បីគេចវេសពីបម្រាមទាំងនោះ។ នេះគឺជាបញ្ហាលំបាកយ៉ាងខ្លាំងសម្រាប់ស្ថាប័នអនុវត្តច្បាប់ ដោយហេតុថាមធ្យោបាយមួយចំនួនត្រូវបានបណ្តាបុគ្គលបរទេសដែលមានទ្រព្យធន ក្រុមហ៊ុន ឬ ក្រុមសហជីពយកមកប្រើប្រាស់ដើម្បីធ្វើវិភាគទានទៅឲ្យគណបក្សនយោបាយ ឬ បេក្ខជន ដោយតាមបែបបច្ចេកទេស ពួកគេមិនចាំបាច់រំលោភបំពានបញ្ញត្តិហាមឃាត់ដែលមានជាធរមានឡើយ។

មធ្យោបាយអសីលធម៌មួយចំនួនក្នុងការគេចវេសពីបម្រាមលើការផ្តល់មូលនិធិពីប្រទេស រួមមានការបង្កើតសាខាគណបក្សនយោបាយ ដោយលាក់ក្រោមឈ្មោះអង្គការដទៃៗទៀត ដូចជា ក្រុមបណ្តុំបញ្ញវន្ត ឬមូលនិធិរបស់គណបក្សជាដើម ដែលជួនកាលគេសំដៅទៅលើ "កោះឯនាយសមុទ្រ" របស់គណបក្សនយោបាយ។ ក្នុងករណីមួយចំនួនទៀត អ្នក ធ្វើវិភាគទានពីបរទេស និងគណបក្សនយោបាយឬបេក្ខជន អាចឆ្លៀតកេងយកចំណេញពីអត្ថន័យ

ទូលំទូលាយនៃពាក្យថា "បរទេស" នេះក្នុងបម្រាម ដែលមានចែងនៅក្នុងច្បាប់។ ស្រដៀងគ្នានេះ ដែរ មានមធ្យោបាយស្មុគស្មាញសម្រាប់អ្នកធ្វើអំណោយពីក្រុមហ៊ុនឯកជនក្នុងការគេចវេសពីបទប្បញ្ញត្តិដែលហាមឃាត់ការផ្តល់មូលនិធិពីក្រុមហ៊ុនឯកជន។ នៅក្នុងក្រុមហ៊ុន ទាំងនោះ អ្នកបរិច្ចាគនានាអាចធ្វើអំណោយដល់គណបក្សនយោបាយឬបេក្ខជនជាលក្ខណ:បុគ្គល ហើយបន្ទាប់ពីនោះមកក្រុមហ៊ុនជាអ្នកចេញលុយសងត្រឡប់ទៅពួកគេតាមរបៀបមិនផ្ទាល់វិញ។ ឥទ្ធិពលរបស់ក្រុមហ៊ុនឯកជនទៅលើដំណើរការនេះមានការលំបាកយ៉ាងខ្លាំងនៅក្នុងការទប់ស្កាត់សូម្បីតែនៅក្នុងប្រព័ន្ធនៃការអនុវត្តដែលមានភាពជឿនលឿនក៏ដោយ។

## សេចក្តីសន្និដ្ឋាន

ការអនុវត្ត និងបទបញ្ញាហិរញ្ញវត្ថុនយោបាយផ្សារភ្ជាប់គ្នាយ៉ាងស្អិតរមួត ហើយនៅក្នុងជំពូកនេះទាំងមូលយើងបានឃើញឧទាហរណ៍ជាច្រើននៃទំនាក់ទំនងដ៏ស្មុគស្មាញរវាងធាតុផ្សំនានានៃប្រព័ន្ធអនុវត្ត។ ខណ:ពេលដែលប្រព័ន្ធអនុវត្តជាធម្មតាមានលក្ខណ:ខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ការនិយមចូលចិត្តពិតជាកើតមានឡើង ហើយការអនុវត្តជាក់ស្តែងត្រូវបានអនុម័តក្នុងចំណោមរដ្ឋនានា ដោយ ពួកគេសង្ឃឹមថានឹងអាចទប់ស្កាត់បាននូវឥទ្ធិពលអវិជ្ជមាននៃថវិកានៅក្នុងវិស័យនយោបាយ។ អង្គការអន្តរជាតិនិងអង្គការតំបន់មួយចំនួនបានសម្រេចគាំទ្រនិងជម្រុញការអនុវត្តទាំងនេះដើម្បីបន្ថែមទម្ងន់ទៅលើបញ្ហានេះ។ ក្នុងចំណោមអង្គការទាំង នោះមានការឯកភាព គ្នាជាឯកច្ឆន្ទខ្លះលើបញ្ហាអនុវត្តជាមូលដ្ឋានមួយចំនួន ដូចជា ឯករាជ្យភាព នៃស្ថាប័នទទួលខុសត្រូវអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយ ភាពចាំបាច់នៃទណ្ឌកម្ម ការ ត្រួតពិនិត្យហិរញ្ញវត្ថុរបស់គណបក្សនិងយុទ្ធនាការឃោសនានិងក្របខណ្ឌច្បាប់ដែលមានចែងយ៉ាងច្បាស់ដើម្បីកំណត់បញ្ហាសំខាន់ៗមួយចំនួន។

អង្គការតំបន់និងអង្គការអន្តរជាតិដែលបានផ្តល់អនុសាសន៍ទៅលើបទបញ្ញាដើម្បីគ្រប់គ្រងទៅលើហិរញ្ញវត្ថុនយោបាយជួបប្រទះបញ្ហាដូចគ្នាទៅនឹងប្រទេសសាមីជាច្រើនដែលមានច្បាប់និងបទបញ្ញា ប៉ុន្តែគ្មានប្រព័ន្ធសម្រាប់អនុវត្តឲ្យទទួលបានជោគជ័យ។ លើសពីនេះទៅទៀត ក៏ដូចគ្នាទៅនឹងស្ថាប័នដទៃៗទៀតដែលត្រូវដោះស្រាយបញ្ហាហិរញ្ញវត្ថុនយោបាយដែរ អង្គការតំបន់និង អង្គការអន្តរជាតិទាំងនោះជួបប្រទះនឹងបញ្ហាមានអំណាចតិចតួចក្នុងការអនុវត្តអនុសាសន៍និងបទប្បញ្ញត្តិនានាឲ្យមានភាពសកម្ម។ ក្រុមប្រឹក្សា អឺរ៉ុបនៃក្រុមប្រទេសប្រឆាំងអំពើពុករលួយ (GRECO) បានកសាងនីតិវិធីអនុវត្តគួរឲ្យកត់សម្គាល់មួយ សម្រាប់ធ្វើការវាយតម្លៃទៅលើវិធានការនានាដែលបានចាត់តាំងដោយរដ្ឋជាសមាជិកដើម្បីអនុវត្តអនុសាសន៍របស់ខ្លួន ដែលមួយចំនួននៃអនុសាសន៍ ទាំងនោះជាប់ពាក់ព័ន្ធនឹងហិរញ្ញវត្ថុនយោបាយ។ របាយការណ៍ទូលំទូលាយស្តីពីរដ្ឋជាសមាជិកនីមួយៗ និងការរំលោភបំពាន ដែលអាចកើតមាននៅក្នុងរដ្ឋទាំងនោះ ទាក់ទងទៅនឹងអនុសាសន៍នីមួយៗដែលក្រុមប្រឹក្សានោះបានធ្វើ ត្រូវបានផ្សព្វផ្សាយជាសាធារណ:នៅលើគេហទំព័ររបស់ក្រុមប្រឹក្សានោះ។ ការវាយតម្លៃនៅជុំទីបីដែលបានបើកសម្ពោធកាលពីខែមករាឆ្នាំ២០០៧ ជាប់ទាក់ទងនឹងបញ្ហាចំនួនពីរ បញ្ហាមួយនៅក្នុងនោះគឺតម្លាភាពនៃហិរញ្ញប្បទានគណបក្សនយោបាយនិង ការផ្តោតទៅលើមាត្រា៧ (៣) នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយផងដែរ។

នៅខែវិច្ឆិកា ឆ្នាំ ២០០៩ វគ្គទីបី នៃសន្និបាតរបស់រដ្ឋជាភាគីនៃអនុសញ្ញាសហប្រជាជាតិប្រឆាំងអំពើពុករលួយនឹងរៀបចំឡើងនៅទីក្រុងដូហា (ប្រទេសកាតា) ។ ដោយមានការដាក់ចេញនូវអនុសាសន៍នៅក្នុងអនុសញ្ញានោះសន្និបាតនេះមានគោលបំណងពិនិត្យមើលឡើងវិញលើការអនុវត្តរបស់ខ្លួន ដែលជាជំហានមួយឆ្ពោះទៅ រកការត្រួតពិនិត្យដែលកាន់តែមានការកើនឡើងពីសំណាក់សមាជិកនៃសហគមន៍អន្តរជាតិ។

# ៦៥ ចរិតលក្ខណៈបរិសុទ្ធ

ដោយៈ បណ្ឌិត ម៉ាកណឹស អូមែន (Magnus Öhman)

ប្រហែលជា ២-៣ ម៉ោងមុននឹងខ្ញុំអង្គុយសរសេរ ចុះសេចក្តីសន្និដ្ឋានសម្រាប់សៀវភៅនេះ ដែលជាលទ្ធផលនៃការស្រាវជ្រាវអស់រយៈពេល២ឆ្នាំ សវនាការទៅលើអតីតនាយករដ្ឋមន្ត្រីអ៊ីស្រាអែលលោក *អេហ៊ូត អលមើត* (Ehud Olmert) បានចាប់ផ្តើម។ អតីតនាយករដ្ឋមន្ត្រីរូបនេះបានទទួលរងការចោទប្រកាន់ពីបទប្រើប្រាស់មុខតំណែងរបស់គាត់ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន និង តែងតាំងមនុស្សរបស់គណបក្សខ្លួនដោយមិនត្រឹមត្រូវឲ្យកាន់មុខងារនានារបស់រដ្ឋាភិបាល។ រឿងក្តីរបស់លោក*អលមើត* (ដែលគាត់បានបដិសេធន៍យ៉ាងដាច់អហង្ការចំពោះការចោទប្រកាន់នោះ) គឺជាករណីមួយប៉ុណ្ណោះនៃរឿងអាស្រូវរកើរកូសដ៏យូរលង់ទាក់ទងនឹងហិរញ្ញវត្ថុនៅក្នុងវិស័យនយោបាយដែលបានផ្ទុះឡើងនៅក្នុងរយៈពេល ២ឬ៣ឆ្នាំចុងក្រោយនេះ។

ទោះជាយ៉ាងនេះក្តី យើងគួរចងចាំថា រឿងអាស្រូវនីមួយៗបានបង្ហាញពីករណីរំលោភបំពានដែលត្រូវបានលាតត្រដាង និង ដែលក្នុងករណីខ្លះក៏អាចត្រូវទទួលទណ្ឌកម្មដែរ ។ នៅមានករណីជាច្រើនទៀតដែលមិនទាន់ត្រូវបានរកឃើញ ឬ ដាក់ទណ្ឌកម្មនៅឡើយ ដែលគួរតែជាកង្វល់របស់យើង ។ ដូច្នេះ វាពិតជាការចាំបាច់ណាស់ដែលប្រទេសទាំងអស់ត្រូវខំប្រឹងលើកកម្ពស់តម្លាភាពនៅក្នុងវិស័យហិរញ្ញវត្ថុនយោបាយ ដូចដែលត្រូវបានអំពាវនាវនៅក្នុងអនុសញ្ញាសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ។

វត្ថុបំណងនៃសៀវភៅនេះ គឺដើម្បីចែករំលែកបទពិសោធន៍នានានៅជុំវិញពិភពលោកក្នុងរយៈពេល ២ឬ៣ទសវត្សចុងក្រោយនេះដោយផ្តោតទៅលើវិស័យនៅក្នុងបញ្ហាហិរញ្ញវត្ថុនយោបាយ និងចង្អុលបង្ហាញអំពីការយល់ឃើញរួមគ្នា និង ចំណុចខ្វែងគំនិតគ្នានៅក្នុងបញ្ហានេះ ។ តួនាទីរបស់ភាគីពាក់ព័ន្ធខុសៗគ្នាក្នុងការធ្វើឲ្យហិរញ្ញប្បទានគណបក្សនយោបាយ និង បេក្ខជនកាន់តែមានតម្លាភាពក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ ដូចជា អ្នកតាក់តែងច្បាប់ អ្នកធ្វើបទបញ្ញា គណបក្សនយោបាយនិងបេក្ខជន ប្រព័ន្ធផ្សព្វផ្សាយ និងសង្គមស៊ីវិល។ ការយកចិត្តទុកដាក់ជាពិសេសត្រូវបានផ្តោតទៅលើ ការបើកចំហរព័ត៌មាន ការដាក់ដែនកំណត់លើចំណាយ ហិរញ្ញប្បទានសាធារណៈ និង ការអនុវត្តច្បាប់និងបទបញ្ញា ។ យើងសង្ឃឹមថា អ្នកដែលចង់ដឹងអំពីហិរញ្ញវត្ថុនៅក្នុងវិស័យនយោបាយ នឹងមានការចាប់អារម្មណ៍ទៅលើបញ្ហាខាងលើដូចដែលបានរៀបរាប់នៅក្នុងទំព័រនានាខាងដើមនៃសៀវភៅនេះ។

ដូចដែលបានលើកឡើងនៅក្នុងសេចក្តីផ្តើមនៃសៀវភៅនេះ សៀវភៅនេះត្រូវបានបំផុសឡើងដោយទស្សនាទានសំខាន់ចំនួន៥ ដែលបានលេចឡើងតាមរយៈបេសកកម្មរបស់អង្គការមូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោតនៅក្នុងប្រទេសជាង២០ ក៏ប៉ុន្តែក៏បានប្រសូតចេញពីបទពិសោធន៍នានាដែលយើងបានទទួល និង ទស្សនាទានសំខាន់ៗមួយចំនួនរបស់អង្គការដទៃៗទៀតដែលបាននិងកំពុងធ្វើការយ៉ាងសកម្មនៅក្នុងវិស័យនេះ។ ឥឡូវនេះគឺជាពេលដែលយើងត្រូវពិនិត្យមើលឡើងវិញនូវទស្សនាទានសំខាន់ៗទាំងនោះ និង មើលថាតើរបកគំហើញដែលមានរៀបរាប់នៅក្នុងជំពូកផ្សេងៗគ្នាទាំងនោះជាប់ទាក់ទងយ៉ាងដូចម្តេចទៅនឹងចំណុចនីមួយៗ។

## ១. ថវិកាមានភាពចាំបាច់ណាស់សម្រាប់នយោបាយប្រជាធិបតេយ្យ ហើយគណបក្សនយោបាយត្រូវតែមានលទ្ធភាពក្នុងការទទួលបានមូលនិធិដើម្បីចូលរួមក្នុងដំណើរការនយោបាយ។ បទបញ្ញាហិរញ្ញវត្ថុនយោបាយមិនត្រូវបង្កជាឧបសគ្គដល់ការប្រកួតប្រជែងដែលមានភាពស្វិតស្វាញទេ។

ក្នុងខណៈដែលអភិក្រមជាច្រើនក្នុងចំណោមអភិក្រមនានាដែលបានបង្ហាញនៅក្នុងសៀវភៅនេះ ត្រូវបានបង្កើតឡើងដើម្បីកាត់បន្ថយតួនាទីរបស់ហិរញ្ញវត្ថុនៅក្នុងវិស័យនយោបាយ និងដើម្បីដាក់កម្រិតលើទម្រង់ជាក់លាក់នៃចំណូលនិងចំណាយ ប៉ុន្តែគ្មានអភិក្រមណាមួយធ្វើឡើងដើម្បីដកហិរញ្ញប្បទានទាំងស្រុងចេញពីសកម្មភាពរបស់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោតនោះទេ ។ ហិរញ្ញវត្ថុមានសារសំខាន់ណាស់សម្រាប់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោតដើម្បីបំពេញតួនាទីរបស់ពួកគេនៅក្នុងសង្គមប្រជាធិប-តេយ្យ ចំណែកឯអ្នកបោះឆ្នោតគួរត្រូវបានបញ្ឈប់ផងដែរពីការបង្ហាញបំណងប្រាថ្នារបស់ពួកគេតាមរយៈការបូបលុយ។ ប្រសិនបើពុំមានហិរញ្ញវត្ថុគ្រប់គ្រាន់ទេ បេក្ខជននិងគណបក្សនយោបាយពុំអាចប្រាស្រ័យទាក់ទងជាមួយអ្នកបោះឆ្នោតបានទេ ហើយក៏មិនអាចដឹងពីបំណងប្រាថ្នារបស់ពួកគេ ឬ ពន្យល់គោលនយោបាយនិងទស្សនៈរបស់ពួកគេទៅឲ្យអ្នកបោះឆ្នោតបានដែរ។

សញ្ញាណនៃការបង្ហាញព័ត៌មាន និង តម្លាភាពក្នុងការផ្តល់មូលនិធិដល់គណបក្សនយោបាយ ត្រូវបានកសាងឡើងនៅលើការទទួលស្គាល់ជាមូលដ្ឋានមួយ ដែលថា ពេលដែលការផ្តល់មូលនិធិនោះចាំបាច់ត្រូវត្រួតពិនិត្យ និង ជួនកាលត្រូវការការគ្រប់គ្រង នៅពេលជាមួយគ្នានោះ វាគឺជាផ្នែកមួយយ៉ាងសំខាន់នៃដំណើរការនយោបាយ ។ ជាឧទាហរណ៍ ដែនកំណត់លើការចំណាយ បានត្រូវគេធ្វើឡើងដើម្បីកំណត់កម្រិតអតិបរមានៃការចំណាយ តែមិនមែនដើម្បីបញ្ឈប់ការចំណាយទេ។

ហិរញ្ញវត្ថុមិនមែនត្រឹមតែចាំបាច់នៅក្នុងដំណើរការនយោបាយទេ ប៉ុន្តែថែមទៀតមានសារសំខាន់សម្រាប់មូលនិធិឯកជនក្នុងការដើរតួនាទីយ៉ាងសំខាន់នៅក្នុងសកម្មភាពរបស់គណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោតផងដែរ។ ខណៈដែលហិរញ្ញប្បទានសាធារណៈគឺជាឧបករណ៍មួយដ៏មានប្រយោជន៍ក្នុងការកាត់បន្ថយការពឹងផ្អែករបស់តួអង្គនយោបាយទៅលើអ្នកធ្វើវិភាគទានដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ ហិរញ្ញប្បទានសាធារណៈមិនគួរយកមកជំនួសការផ្តល់មូលនិធិពីអ្នកដែលគាំទ្រគណបក្សនយោបាយ ឬ បេក្ខជនជាក់លាក់ណាមួយឡើយ ។ វាជាការសំខាន់ដែលយើងត្រូវចងចាំថា គណបក្សនយោបាយ និង បេក្ខជន ត្រូវធ្វើការប្រកួតប្រជែងគ្នាដើម្បីស្វែងរកការគាំទ្រពីអ្នកបោះឆ្នោត។ ការគ្រាន់តែអនុញ្ញាតឲ្យមានការប្រើប្រាស់តែហិរញ្ញប្បទានសាធារណៈ នឹងនាំឲ្យមានការចាត់ទុកគណបក្សនយោបាយថាជាស្ថាប័នសាធារណៈ ហើយអភិក្រមបែបនេះ "មិនត្រឹមតែនាំនយោបាយចេញពីនយោបាយប៉ុណ្ណោះទេ វាថែមទាំងផ្តល់ឲ្យរដ្ឋ (ជាពិសេស មន្ត្រីដែលគ្មានសីលធម៌)នូវអំណាចដ៏ច្រើនលើសលុបទៅលើគណបក្សកាន់អំណាច និង រឹតតែអាក្រក់ថែមទៀតសម្រាប់ក្រុមអ្នកប្រឆាំង។

## ២. លុយមិនមែនជាផ្នែកមួយដែលមិនមែនមិនចេះមានបញ្ហានៅក្នុងប្រព័ន្ធនយោបាយទេ ដូច្នេះគេត្រូវការបទបញ្ញាសម្រាប់គ្រប់គ្រងវា

ខណៈដែលហិរញ្ញវត្ថុ គឺជាគ្រឿងផ្សំដ៏ចាំបាច់មួយនៅក្នុងនយោបាយសម័យទំនើប ស្របពេលជាមួយគ្នានេះ តាមរយៈការពន្យល់នៅក្នុងជំពូកនានាខាងដើមនៃសៀវភៅនេះ វាគួរតែជាទឡ្ហីករណ៍ច្បាស់លាស់មួយដែលបង្ហាញថា ជារឿយៗហិរញ្ញវត្ថុតែបង្កឥទ្ធិពលដែលគេមិនចង់ឲ្យមានទៅលើប្រសិទ្ធភាព និង ការឆ្លើយតបនៃប្រព័ន្ធនយោ-បាយ។ អ្នកប្រកួតប្រជែងនយោបាយនៅជុំវិញពិភពលោកបានបង្ហាញឲ្យឃើញពីភាពបិនប្រសប់របស់ខ្លួនក្នុងការស្វែងរកមធ្យោបាយដើម្បីទិញនូវកំប៉ុងសកម្មភាពនយោបាយរបស់ខ្លួន ហើយពួកគេមិនមែនចេះតែដកខ្លួនចេញពីសកម្ម

ភាពទាំងឡាយណាដែលអាចនឹងមិនបម្រើប្រយោជន៍ដល់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ឬ ការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវនោះទេ។

លទ្ធភាពរបស់អ្នកធ្វើវិភាគទាននយោបាយដែលមានទ្រព្យស្តុកស្តម្ភ ក្នុងការទិញយកមុខតំណែង កិច្ចសន្យាក្នុងកិច្ចការសាធារណៈ និងគោលនយោបាយជាក់លាក់មួយចំនួន មិនត្រឹមតែធ្វើឲ្យបរាជ័យដល់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យប៉ុណ្ណោះទេ ថែមទាំងនាំឲ្យមានការខ្ជះខ្ជាយដ៏ធំធេងនូវមូលនិធិសាធារណៈដែលមានចំនួនដ៏តិចតួចស្តួចស្តើងផងដែរ។ មិនថា តើវាជាការចំណាយឲ្យសមាជិកសភាមកពីគណបក្សប្រឆាំងដើម្បីឲ្យគេផ្លាស់ប្តូរនិន្នាការនយោបាយ ដូចករណីប្រទេសប៉េរូ (Peru) ការសូកប៉ាន់នៅក្នុងប្រទេសប៉ូឡូញ ឬករណីដែលប្រធានាធិបតីមួយចំនួនលួចយកទ្រព្យសម្បត្តិរបស់រដ្ឋដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ (D.R. Congo) ល្បិចច្នៃប្រឌិតរបស់អ្នកនយោបាយជារឿយៗមានការភ្ញាក់ផ្អើលសឹងតែមិនគួរឲ្យជឿ។ ជំពូកនានានៅផ្នែកខាងដើមនៃសៀវភៅនេះក៏បានលើកយកមកពិភាក្សាផងដែរអំពីគណបក្សនយោបាយនិងបេក្ខជនដែលផ្តល់ការដោះដូរមុខតំណែង ធ្វើការផ្ទេរថវិកាតាមរយៈអង្គការលួចលាក់នានាដើម្បីគេចវេសពីការបង់ពន្ធ និងការពាក់ព័ន្ធរបស់ពួកគេនៅក្នុងសកម្មភាពផ្ទុយច្បាប់ ឬ សកម្មភាពអសីលធម៌មួយចំនួន ។ បែបផែននៃសកម្មភាពទាំងនេះមិនមែនជារឿងថ្មីនោះទេ។ រឿងអាស្រូវអំពីលុយជាថ្នូរនឹងតំណែង (ដែលអ្នកធ្វើវិភាគទាននយោបាយត្រូវបានគេផ្តល់ឲ្យនូវមុខតំណែងនៅក្នុងសភាជាន់ខ្ពស់ជារង្វាន់សម្រាប់ការធ្វើវិភាគទានរបស់ពួកគេ) ដែលបានផ្ទុះឡើងនៅចក្រភពអង់គ្លេសកាលពីឆ្នាំ២០០៦ ភាពជាន់ដាននៃព្រឹត្តិការណ៍នានាដែលបានទាញទម្លាក់រដ្ឋាភិបាលមួយរបស់ចក្រភពអង់គ្លេសកាលពីឆ្នាំ១៩២២។

នេះក៏ជាបញ្ហាមួយដែរដែលស្ថិតនៅពីក្រោយអនុសញ្ញាសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយដែលបានអំពាវនាវដល់រដ្ឋជាភាគីទាំងអស់លើកកម្ពស់តម្លាភាពក្នុងដំណើរការនយោបាយ ដើម្បីឲ្យគេអាចលាតត្រដាងការរំលោភបំពានច្បាប់នានា និង ធ្វើការផ្តន្ទាទោសអ្នកដែលប្រព្រឹត្តល្មើស ។ បើទោះជាគេអាចនិយាយបានថាលុយគឺជាសេរីភាពក្នុងការនិយាយស្តីក៏ដោយ ក៏វាមិនអាចជាសេរីភាពនៃការនិយាយស្តីនៅក្នុងភាពអាថ៌កំបាំងនោះដែរ។

ក្នុងបរិបទមួយចំនួន ការបង្ហាញព័ត៌មានអាចនឹងមិនមែនជាទម្រង់គ្រប់គ្រាន់នៃបទបញ្ញាទេ។ ប្រភេទជាក់លាក់ខ្លះនៃការធ្វើវិភាគទាន និង ការចំណាយអាចតម្រូវឲ្យមានការហាមឃាត់ជាចាំបាច់ ហើយប្រសិនបើគម្លាតរវាងតួអង្គប្រកួតប្រជែងនយោបាយមានទំហំធំពេក នោះការដាក់ដែនកំណត់លើការចំណាយ និង ការផ្តល់ថវិកាពីរដ្ឋអាចជារឿងមួយចាំបាច់ក្នុងការធានាឲ្យមានការបោះឆ្នោតមួយប្រកបដោយការប្រកួតប្រជែងយ៉ាងពិតប្រាកដ។

## ៣. បរិបទ និង វប្បធម៌នយោបាយត្រូវតែយកមកពិចារណានៅពេលគេបង្កើតយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុនៅក្នុងវិស័យនយោបាយ

វាបានក្លាយជាប្រធានបទសំខាន់មួយនៅក្នុងសៀវភៅនេះ ដែលប្រទេសនីមួយៗត្រូវតែពិចារណាលើអ្វីដែលគេព្យាយាមធ្វើឲ្យបានពាក់ព័ន្ធនឹងបទបញ្ញាហិរញ្ញវត្ថុនយោបាយ ហើយនិងថាតើគោលបំណងទាំងនេះត្រូវសម្រេចឲ្យបានដោយរបៀបណាឲ្យស្របទៅនឹងស្ថានភាពនយោបាយ និង បរិបទរួមរបស់ប្រទេសនោះ ក្នុងខណៈដែល

គេមានការយល់ឃើញជារួម និង បទពិសោធន៍ទាក់ទងទៅនឹងហិរញ្ញវត្ថុនៅក្នុងនយោបាយ តួនាទីរបស់វា និង ការធ្វើច្បាប់ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុក្នុងនយោបាយ។ កត្តាជាច្រើន ពាប់ចាប់តាំងពីទំនៀមទំលាប់នយោបាយ និង កម្រិតនៃការចូលរួមរបស់ពលរដ្ឋនៅក្នុងដំណើរការនយោបាយ រហូតដល់ប្រព័ន្ធបោះឆ្នោតនិងរចនាសម្ព័ន្ធគណៈ ការ និងវិធានគណនេយ្យដែលមានស្រាប់ជាដើម ត្រូវតែលើកយកមកពិចារណា ។ លទ្ធភាពរបស់គណបក្សនយោបាយ និង បេក្ខជន ក្នុងការបំពេញតាមតម្រូវការនៃការធ្វើរបាយការណ៍លម្អិតក៏ជាកត្តាមួយទៀត ដែលគេត្រូវគិតគូរផងដែរ ទោះជានៅក្នុងប្រទេសដែលទើបនឹងមានលទ្ធិប្រជាធិបតេយ្យថ្មីថ្មោងដែលមានកម្រិតនៃការអប់រំទាបក៏ដោយ។ ការវិភាគទៅលើរបាយការណ៍គណនីធនាគារ អាចជាមធ្យោបាយដ៏ល្អមួយក្នុងការត្រួតពិនិត្យប្រតិបត្តិការហិរញ្ញវត្ថុក្នុងពេលធ្វើយុទ្ធនាការឃោសនា ប៉ុន្តែគេអាចធ្វើបែបនេះបានលុះត្រាតែនៅក្នុងប្រទេសនោះមានប្រព័ន្ធធនាគារល្អ។

យើងត្រូវតែយល់ផងដែរថា ការពារភាពខុសប្លែកគ្នានៃសង្គមជាតិដែលយើងកំពុងរស់នៅគឺនៅជាមួយនឹងភាពខុសប្លែកគ្នាផ្សេងៗទៀតផងដែរនៅក្នុងរបៀបដែលយើងចង់ឲ្យសង្គមទាំងនោះមានដំណើរការយ៉ាងដូចម្តេច។ ការនេះជាទឡ្ហីករណ៍មួយដែលបង្ហាញប្រាប់យើងនៅក្នុងរបៀបយ៉ាងដូចម្តេច ដែលយើងមើលឃើញតួនាទីរបស់គណបក្សនយោបាយនៅក្នុងប្រព័ន្ធនយោបាយ។ នៅប្រទេសមួយចំនួន គណបក្សនយោបាយត្រូវបានគេមើលឃើញថាមានតួនាទីក្នុងការគៀងគរប្រជាពលរដ្ឋ និង ប្រមូលផ្តុំគំនិតយោបល់របស់ពួកគេផងដែរនៅក្នុងចន្លោះពេលបោះឆ្នោត។ ក្នុងប្រទេសផ្សេងទៀត ការយកចិត្តទុកដាក់ភាគច្រើនផ្តោតទៅលើបេក្ខជន ចំណែកឯគណបក្សនយោបាយត្រូវបានគេមើលឃើញថាមានតួនាទីតិចតួចប៉ុណ្ណោះនៅក្នុងកិច្ចការនយោបាយ។

ជាផលវិបាក មាន គ្រោះថ្នាក់យ៉ាងពិតប្រាកដដែលនឹងកើតមានឡើង ប្រសិនបើគេទទួលយកប្រព័ន្ធនៃបទបញ្ញាហិរញ្ញវត្ថុនយោបាយពីប្រទេសដទៃទៀតមកអនុវត្តដោយពុំបានសិក្សាឲ្យបានដិតដល់។ តាមមតិរបស់លោក *ណាស្មាឈើរ* (Nassmacher) ដែលយើងបានដកស្រង់ចេញពីសេចក្តីផ្តើមនៃសៀវភៅនេះ "ការប៉ុនប៉ងណាមួយក្នុងការផ្ទេរបទពិសោធន៍ ត្រូវតែចាប់ផ្តើមចេញពីការទទួលស្គាល់ភាពខុសគ្នា"។ នេះមិនមែនមានន័យថា ពុំមានភាពស្រដៀងគ្នាគួរឲ្យកត់សម្គាល់ ឬ បទពិសោធន៍ណាមួយ ដែលយើងមិនអាចរៀនសូត្រតាមបាននោះទេ (ប្រសិនបើវាដូច្នោះមែន អ្វីដែលបានចងក្រងនៅក្នុងសៀវភៅនេះពិតជាមិនសមហេតុផលទេ )។ ក៏ប៉ុន្តែអ្វីដែលគេត្រូវចង់និយាយគឺថា អ្នកធ្វើច្បាប់ អ្នកធ្វើបទបញ្ញា និង តួអង្គមិនមែនរដ្ឋាភិបាលត្រូវតែពិចារណាយ៉ាងហ្មត់ចត់អំពីគោលបំណង និងស្ថានភាពរបស់ពួកគេផ្ទាល់ នៅពេលពួកគេសម្រេចថាតើបទពិសោធន៍មួយណាពីប្រទេសផ្សេងដែលពួកគេគួរយកមកប្រើប្រាស់។

## ៤. បទបញ្ញា និង ការបង្ហាញព័ត៌មានប្រកបដោយប្រសិទ្ធភាពអាចជួយទប់ស្កាត់ឥទ្ធិពលមិនល្អរបស់ហិរញ្ញវត្ថុនៅក្នុងនយោបាយ ប៉ុន្តែលុះត្រាតែបទបញ្ញានោះត្រូវបានតាក់តែង និង អនុវត្តយ៉ាងល្អ

ផ្នែកសំខាន់មួយដែលមានចងក្រងនៅក្នុងសៀវភៅនេះ ត្រូវបានឧទ្ទិសទៅដល់ការបង្ហាញអំពីជម្រើសបទ-បញ្ញាផ្សេងៗគ្នា ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនយោបាយ និងបង្ការ រកមើលការរំលោភបំពាន និងដាក់ទណ្ឌកម្មលើការប្រព្រឹត្តដែលផ្ទុយនឹងច្បាប់ និង ការប្រព្រឹត្តដែលមិនត្រឹមត្រូវ ។ សកម្មភាពទាំងនេះពិតជាមានប្រយោជន៍ ហើយថែមទាំងបានជួយបង្ហាញឲ្យឃើញនូវប្រតិបត្តិការហិរញ្ញវត្ថុស្រមោល និងកំណត់នូវរបៀបដែលគណបក្សនយោបាយ និង

បញ្ហានេះបានកើតឡើងនៅក្នុងប្រទេសជាច្រើន។ ដូចដែល *ខាយ៉ាម ហ្សេវ ប៉ាល់ត្យែល* (Khayyam zev Paltiel) បានពោលអះអាងថា "ការតម្រូវជាដាច់ខាតក្នុងការធ្វើរបាយការណ៍ និង ការបង្ហាញព័ត៌មានអំពីចំណូល និង ចំណាយ មានឥទ្ធិ - ពលក្នុងការបំបាត់ភាពមិនត្រឹមត្រូវ" ទៅលើគណបក្សនយោបាយ និង ការបោះឆ្នោតនៅក្នុងបណ្តាប្រទេសលោកខាងលិចដែលប្រកាន់លទ្ធិប្រជាធិបតេយ្យ។

ទោះជាយ៉ាងណាក៏ដោយ ដូចដែលយើងបានឃើញម្តងហើយម្តងទៀតនៅក្នុងបណ្តាប្រទេសជាច្រើន ការគ្រាន់តែដាក់ចេញយ៉ាងសាមញ្ញនូវច្បាប់មួយដែលមានខ្លឹមសារនិងគួរឲ្យចាប់អារម្មណ៍ នឹងមិននាំឲ្យយើងអាចសម្រេចគោលដៅបានទេ។ បទបញ្ញា និង ការតម្រូវជាចាំបាច់ក្នុងការបង្ហាញព័ត៌មានមិនមែនគ្រាន់តែពិចារណាតែទៅលើបរិបទក្នុងស្រុកនោះទេ តែគេត្រូវពិចារណាផងដែរអំពីភាពអនុវត្តបានរបស់បទបញ្ញា និង ការតម្រូវទាំងនោះ ។ ជាញឹកញាប់ លោក *ពីនតូ ឌូសឈីនស្គី* (Pinto-Duschinsky) បានក្រើនរំលឹកដដែលៗថា ហិរញ្ញប្បទាននយោបាយទទួលរងការខូចខាតដោយសារតែ "មានច្បាប់ច្រើនហួសប្រមាណ តែមានការអនុវត្តតិចតួចបំផុត"។

ជំពូកមួយដែលនិយាយអំពីការអនុវត្ត បានផ្តល់ឲ្យយើងនូវឧទាហរណ៍មួយចំនួន ទាក់ទងទៅនឹងហេតុដូចម្តេចបានជា បទបញ្ញាដែលមានខ្លឹមសារយ៉ាងល្អបែរជាបរាជ័យក្នុងការបង្កើតឥទ្ធិពល ហើយថែមទាំងផ្តល់លទ្ធផលផ្ទុយពីគោលបំណងដែលគេចង់បាន។ ការអនុវត្តនូវការបង្ហាញព័ត៌មានប្រកបដោយប្រសិទ្ធភាពជាញឹកញាប់ត្រូវបានរាំងស្ទះដោយសារភាពខ្វះចន្លោះនានាដែលគេអាចមើលឃើញ និង ប្រើប្រាស់បានយ៉ាងស្រួលដោយអ្នកប្រកួតប្រជែងនយោបាយ។

ឧទាហរណ៍ដ៏ប្រសើរមួយទៀតនៃភាពចាំបាច់ក្នុងការបង្កើត និងអនុវត្តយ៉ាងហ្មត់ចត់នូវបទបញ្ញាហិរញ្ញប្បទាននយោបាយ គឺការដាក់កម្រិតដែលកំណត់ថាតើគណបក្សនយោបាយ និង យុទ្ធនាការឃោសនាបោះឆ្នោតអាចធ្វើការចំណាយបានត្រឹមចំនួនប៉ុន្មាន។ ដូចដែលយើងបានឃើញរួចមកហើយនៅក្នុងជំពូកមួយដែលនិយាយពីប្រធានបទនេះ ការដាក់ដែនកំណត់លើការចំណាយគឺជាមធ្យោបាយដ៏មានប្រជាប្រិយភាពមួយក្នុងការកាត់បន្ថយចំណាយលើការបោះឆ្នោតនិងធ្វើឲ្យទីលានប្រកួតប្រជែងមានសមភាព។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលជំពូកដដែលនេះបានបង្ហាញ ដែនកំណត់ចំណាយទាំងនេះជារឿយៗច្រើនតែមានការបំពានជាជាងមានការគោរព។ ជាពិសេសប្រសិនបើគេពុំបានអនុវត្តបទបញ្ញាអំពីការបង្ហាញព័ត៌មានឲ្យមានប្រសិទ្ធភាពទេ ច្បាស់ជាគ្មានអ្នកណាដឹងថាតើបេក្ខជន និង គណបក្សនយោបាយបានអនុវត្តតាមបទប្បញ្ញត្តិស្តីអំពីដែនកំណត់លើការចំណាយឬយ៉ាងនោះទេ ហេតុដូច្នេះការរំលោភបំពានមិនអាចត្រូវបានគេដាក់ទណ្ឌកម្មនោះទេ។

អ្វីដែលកាន់តែសំខាន់ជាងនេះទៅទៀត ជួនកាលការអនុវត្តបទបញ្ញាហិរញ្ញប្បទាននយោបាយត្រូវបានធ្វើឡើងក្នុងលក្ខណៈមួយ ដែលផ្តល់ប្រយោជន៍ច្រើនលើសលុបដល់គណបក្សនយោបាយ និង បេក្ខជនមួយចំនួន លើគណបក្ស និង បេក្ខជនផ្សេងទៀត ។ ជំពូកនានានៅក្នុងសៀវភៅនេះ ក៏បានបង្ហាញផងដែរអំពីរដ្ឋាភិបាលដែលប្រើប្រាស់ដោយមិនត្រឹមត្រូវនូវបទបញ្ញាអំពីការបង្ហាញព័ត៌មាន និង ហិរញ្ញប្បទានសាធារណៈដើម្បីធ្វើទុក្ខបុកម្នេញ ឬបំបាក់ក្រុមប្រឆាំង។ យើងក៏បានឃើញរួចមកហើយផងដែរថា សូម្បីតែបទប្បញ្ញត្តិនៃហិរញ្ញប្បទានសាធារណៈ ដែលជាធម្មតាត្រូវបានគេមើលឃើញថាជាមធ្យោបាយមួយក្នុងការបង្កើនសមត្ថភាពរបស់គណបក្សនយោបាយ និងយុទ្ធនាការឃោសនាទាំងអស់ និង ដើម្បីកាត់បន្ថយគម្លាតខុសគ្នានៅក្នុងមូលនិធិរបស់គណបក្សនយោបាយក៏ដោយ ក៏បទ -

ប្បញ្ញត្តិនោះត្រូវបានគេប្រើប្រាស់ដើម្បីធ្វើឲ្យក្រុមប្រឆាំងទន់ខ្សោយ តាមរយៈការធ្វើឲ្យក្រុមប្រឆាំងទាំងនោះពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានហិរញ្ញប្បទានសាធារណៈ ឬ តាមរយៈការប្រើប្រាស់ប្រព័ន្ធណាមួយដែលជម្រុញឲ្យក្រុមប្រឆាំងមានការបែកខ្ញែកជាក្រុមតូចៗ។

## ៥. ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពអាស្រ័យទៅលើសកម្មភាពនៃអន្តរអំពើរវាងភាគីដែលពាក់ព័ន្ធនានា (ដូចជា បញ្ញត្តិករហិរញ្ញវត្ថុនយោបាយ សង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយ) និង ត្រូវផ្អែកទៅលើតម្លាភាព។

ដូចដែលបានបង្ហាញរួចមកហើយក្នុងជំពូកស្តីពីការអនុវត្ត បើគ្មានស្ថាប័នអនុវត្តបទបញ្ញារបស់រដ្ឋមួយដែលមានសមត្ថភាព និងឯករាជ្យភាពទេនោះ វានឹងមានការលំបាកយ៉ាងខ្លាំងក្នុងការបង្កើតឲ្យមានប្រព័ន្ធត្រួតពិនិត្យមួយប្រកបដោយប្រសិទ្ធភាព ដើម្បីពិនិត្យមើលថា តើគណបក្សនយោបាយ និងយុទ្ធនាការឃោសនា ប្រមូលមូលនិធិ និងប្រើប្រាស់មូលនិធិនោះដោយរបៀបណា។ ពេលដែលបទបញ្ញាសំខាន់ៗទាំងឡាយមានជាធរមានហើយនោះ ស្ថាប័នទាំងឡាយទាំងនេះមានសិទ្ធិអំណាចទាមទារឲ្យមានការដាក់ជូនរបាយការណ៍ហិរញ្ញវត្ថុ ហើយ(ប្រសិនបើស្ថាប័នទាំងនោះមានសមត្ថភាពគ្រប់គ្រាន់) គេក៏អាចអនុវត្តការស៊ើបអង្កេតដោយមិនចាំបាច់ជូនដំណឹងជាមុនទៅលើគណនីរបស់គណបក្សនយោបាយ និង បេក្ខជន។

យ៉ាងណាក៏ដោយ បទពិសោធន៍ដែលទទួលបានពីប្រទេសមួយចំនួនធំ បានបង្ហាញថា អត្ថិភាពនៃស្ថាប័នអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយដែលសកម្មក្នុងការត្រួតពិនិត្យ មានភាពឯករាជ្យ និង មានសមត្ថភាពនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេសម្រាប់ឲ្យការត្រួតពិនិត្យមានប្រសិទ្ធភាព និង បានបង្ហាញផងដែរថាភាគីពាក់ព័ន្ធទាំងអស់មានការពឹងផ្អែកគ្នាទៅវិញទៅមក។ ក្រុមសង្គមស៊ីវិលអាចមានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យសកម្មភាពជាក់ស្តែងរបស់តួអង្គនយោបាយ។ ក្នុងករណីជាច្រើន សមត្ថភាពធនធានមនុស្សរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមានច្រើនលើសពីសមត្ថភាពរបស់ស្ថាប័នអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយរបស់រដ្ឋទៅទៀត ហើយកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់អង្គការទាំងនោះបានជួយបើកកកាយរឿងអាស្រូវនៅក្នុងប្រទេសជាច្រើន ។ ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពទំនងជាមិនអាចទៅរួចទេ លុះត្រាអ្នកកាសែតជួយធ្វើឲ្យពលរដ្ឋបានដឹងអំពីសារ -សំខាន់នៃហិរញ្ញវត្ថុនៅក្នុងនយោបាយ ហើយលុះត្រាតែពួកគេជួយធ្វើការស៊ើបអង្កេត និង បង្ហាញករណីនានានៃការលួចបន្លំផ្នែកនយោបាយ និង ការរំលោភបំពានធនធានរបស់រដ្ឋ ។ ដូចដែលយើងបានលើកឡើងរួចមកហើយជាទូទៅរឿងអាស្រូវនានាបានបង្ហាញឲ្យយើងឃើញថាជាកំលាំងចលករយ៉ាងមានប្រសិទ្ធភាពសម្រាប់ជម្រុញឲ្យមានកំណែទម្រង់ហិរញ្ញវត្ថុនយោបាយ។ គេបានសង្កេតឃើញថា រឿងអាស្រូវ *វ៉ាត់ធ័រ ហ្គេត* (Watergate) បាននាំទៅរកការបង្កើតគណៈកម្មការបោះឆ្នោតសហព័ន្ធ (The Federal Electoral Commission) នៅសហរដ្ឋអាមេរិច។

ដោយសារតែអ្នកធ្វើកំណែទម្រង់ និងបញ្ញត្តិករហិរញ្ញវត្ថុនយោបាយ អាចទទួលបានអត្ថប្រយោជន៍ពីការជួយគាំទ្ររបស់ក្រុមសង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយ នៅក្នុងការជម្រុញតាមរយៈកំណែទម្រង់ក្របខណ្ឌបទបញ្ញាថ្មីៗដូច្នេះព័ត៌មានដែលបានបង្ហាញនៅក្នុងរបាយការណ៍ជាផ្លូវការក៏មានប្រយោជន៍យ៉ាងធំធេងសម្រាប់តួអង្គមិនមែនរដ្ឋាភិបាលដែរ។ ប្រសិនបើគ្មានអ្វីផ្សេងទៀតទេ របាយការណ៍ដែលតួអង្គនយោបាយបានបង្ហាញនឹងបង្កើតបានជា

ឯកសារផ្លូវការមួយដែលមានព័ត៌មានទាក់ទងទៅនឹងប្រតិបត្តិការហិរញ្ញវត្ថុរបស់គណបក្សនយោបាយ និង បេក្ខជន ដែលគេអាចយកមកប្រៀបធៀបបានជាមួយនឹងព័ត៌មានដែលអ្នកកាសែត និង ក្រុមសង្គមស៊ីវិលបានទទួល។

ជាចុងក្រោយ គណបក្សនយោបាយ បេក្ខជន និងមន្ត្រីជាប់ឆ្នោត ដើរតួនាទីយ៉ាងសំខាន់។ អំពើទាំងនេះ ប្រាកដជាជំទាស់ទៅនឹងការប៉ុនប៉ងក្នុងការទទួលយកជំនួយខុសច្បាប់ ឬមូលនិធិផ្សេងៗពីអ្នកផ្តើមគំនិតដែលចង់ឲ្យអ្នកនយោបាយធ្វើតាមបំណងរបស់ពួកគេក្រោយពេលជាប់ឆ្នោត។ តួអង្គនយោបាយទាំងនោះត្រូវតែស្ថិតនៅឲ្យឆ្ងាយពីការទិញសន្លឹកឆ្នោត និង ការរំលោភបំពានធនធានរបស់រដ្ឋ ។ ខណៈដែលវាជាការលំបាកសម្រាប់គណបក្សនយោបាយសាមីនីមួយៗ និង បេក្ខជនធ្វើខ្លួនឲ្យស្អាតស្អំ ប្រសិនបើប្រព័ន្ធនោះត្រូវបានគេបំពាន នោះការប្រព្រឹត្តបែបពុករលួយនានានឹងកើតមានជាយថាហេតុ ដែលជាហេតុធ្វើឲ្យមុខតំណែងដែលតួអង្គនយោបាយទាំងនោះកំពុងតែពុះពារឈោងចាប់យកមិនមានតម្លៃសម្រាប់ការចង់បានរបស់ពួកគេនោះទេ។

## មតិចុងក្រោយ

យើងសង្ឃឹមថា សៀវភៅនេះនឹងមានប្រយោជន៍ចំពោះអ្នកទាំងឡាយណាដែលមានចំណាប់អារម្មណ៍លើបញ្ហានានាពាក់ព័ន្ធនឹងតួនាទីរបស់ហិរញ្ញវត្ថុនៅក្នុងវិស័យនយោបាយ និងបញ្ហាថាតើតួនាទីនេះនឹងត្រូវបានគ្រប់គ្រងយ៉ាងដូចម្តេច។ បើទោះបីជាមានបទពិសោធន៍ច្រើនដែលយើងបានរៀនសូត្រក្នុងរយៈពេលពីបីទសវត្សចុងក្រោយនេះក៏ដោយ ក៏វានៅតែចាំបាច់សម្រាប់យើងធ្វើការស្រាវជ្រាវ និង ចែករំលែកអ្វីដែលយើងបានរកឃើញឲ្យគ្នាទៅវិញទៅមក ។ លើសពីនេះទៅទៀត ស្ថាប័ននានាដែលធ្វើការងារខាងការត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយ (ទាំងស្ថាប័នរដ្ឋាភិបាល និង មិនមែនរដ្ឋាភិបាល ) នៅក្នុងតំបន់ផ្សេងៗគ្នានៅមានបទពិសោធន៍ជាច្រើនដែលត្រូវសិក្សាពីគ្នាទៅវិញទៅមក ហើយពួកគេគួរតែរកមធ្យោបាយនានាដើម្បីធ្វើការចែករំលែកអ្វីដែលពួកគេបានធ្វើកន្លងមក។ បទពិសោធន៍ទាំងនោះចាំបាច់ណាស់សម្រាប់បញ្ញត្តិករហិរញ្ញវត្ថុនយោបាយនៅទ្វីបអាហ្វ្រិក អ្នកកាសែតនៅអាមេរិចឡាទីន ក្រុមសង្គមស៊ីវិលនៅទ្វីបអាស៊ី និង អ្នកតាក់តែងច្បាប់នៅទ្វីបអឺរ៉ុបជាដើម។ រដ្ឋាភិបាលនានាគួរធ្វើការសហការគ្នាដើម្បីបង្កើនលទ្ធភាពរបស់ពួកគេក្នុងការគោរពទៅតាមការប្តេជ្ញាចិត្តរបស់ពួកគេចំពោះតម្លាភាពហិរញ្ញវត្ថុនយោបាយ ដូចមានចែងនៅក្នុងអនុសញ្ញាសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ។ ជាជំហានដំបូង រដ្ឋទាំងឡាយណាដែលពុំទាន់បានបង្កើតវិធានបង្ហាញព័ត៌មានសម្រាប់ឲ្យបេក្ខជន និង គណបក្សនយោបាយអនុវត្តគួរតែសិក្សាពីប្រទេសទាំងឡាយដែលបានបង្កើតវិធានទាំងនោះរួចហើយ។

គ្មានឡើយទីបញ្ចប់នៃការសិក្សានិង ចែករំលែកបទពិសោធន៍ទាំងនោះ។ បទពិសោធន៍ពីប្រទេសមួយចំនួនដែលបាននិងកំពុងធ្វើការងារលើការត្រួតពិនិត្យហិរញ្ញវត្ថុនយោបាយអស់រយៈពេលជាយូរមកហើយមិនមែនត្រឹមតែបង្ហាញថា ការសម្រេចបានការត្រួតពិនិត្យក្នុងកម្រិតមួយដែលអាចទទួលយកបានត្រូវការចំណាយពេលវេលាប៉ុណ្ណោះទេ តែថែមទាំងបានបង្ហាញថែមទៀតថា កិច្ចការក្នុងការធ្វើឲ្យប្រសើរឡើងនូវវិធីសាស្ត្រក្នុងការរកមើលការរំលោភបំពានត្រូវតែបន្តដោយពុំមានការកំណត់។ ទោះជាយ៉ាងណាក៏ដោយ ការនេះមិនមែនជាការបង្អាក់ទឹកចិត្តរបស់អ្នកណាម្នាក់ឡើយ។ ក្នុងន័យនេះ ការខិតខំប្រឹងប្រែងដោះស្រាយបញ្ហាហិរញ្ញវត្ថុនយោបាយ គ្មានអ្វីខុសប្លែកពីការតស៊ូតតឈប់ឈរដើម្បីការពារ និង លើកកំពស់លទ្ធិប្រជាធិបតេយ្យនៅក្នុងសង្គមរបស់យើងឡើយ។

មូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) រំពឹងទុកថានឹងបន្តធ្វើការងារដើម្បីលើកកម្ពស់ការប្រើប្រាស់ហិរញ្ញ - វត្ថុនៅក្នុងវិស័យនយោបាយប្រកបដោយតម្លាភាព និង ការទទួលខុសត្រូវ ដោយសហការជាមួយបណ្ដាដៃគូដែលមានស្រាប់ និង ដៃគូថ្មីៗដទៃទៀតនៅជុំវិញពិភពលោក។

## *តារាង១៖ រដ្ឋជាភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ ដែលមានប្រព័ន្ធបង្ហាញព័ត៌មានដូចដែលបានគូសបញ្ជាក់នៅក្នុងមាត្រា ៧ (៣)*

| រដ្ឋជាភាគី | គណបក្ស | បេក្ខជន | រដ្ឋជាភាគី | គណបក្ស | បេក្ខជន | រដ្ឋជាភាគី | គណបក្ស | បេក្ខជន |
|---|---|---|---|---|---|---|---|---|
| អាហ្វហ្គានីស្ថាន | មាន | មាន | ហ្សកហ្ស៊ី | មាន | មាន | ន័រវេស្សន៍ | មាន | គ្មាន |
| អាល់បានី | មាន | គ្មាន | ហ្គាណា | មាន | មាន | ប៉ាគីស្ថាន | មាន | គ្មាន |
| អាល់ហ្សេរី | គ្មាន | មាន | ក្រិច | មាន | មាន | ប៉ាឡាវ | គ្មាន | មិនដឹង |
| អង់ហ្គោឡា | គ្មាន | មាន | ហ្គាតាមេឡា | មាន | គ្មាន | ប៉ាណាម៉ា | មាន | មាន |
| អង់ទីហ្គានិងបាប៊ូដា | គ្មាន | មាន | ហ្គីណេប៊ីស្សូ | គ្មាន | គ្មាន | ប៉ាពួញូហ្គេនេ | មាន | មិនដឹង |
| អាហ្សង់ទីន | មាន | មាន | ហ្គុយយ៉ាន | គ្មាន | មាន | ប៉ារ៉ាហ្គាយ | មាន | គ្មាន |
| អាមេនី | មាន | មាន | ហុងឌូរ៉ាស | មាន | គ្មាន | ប៉េរូ | មាន | គ្មាន |
| អូស្ត្រាលី | មាន | មាន | ហុងហ្គារី | មាន | គ្មាន | ហ្វីលីពីន | មាន | មាន |
| អូទ្រីស | មាន | គ្មាន | ឥណ្ឌូនេស៊ី | មាន | គ្មាន | ប៉ូឡូញ | មាន | មាន |
| អាហ្សែបៃហ្សង់ | មាន | មាន | អៀរ៉ង់ | មិនដឹង | មិនដឹង | ព័រទុយហ្គាល់ | មាន | មាន |
| បាហាម៉ា | គ្មាន | គ្មាន | អៀរ៉ាក់ | មិនដឹង | មិនដឹង | កាតា | មិនដឹង | មិនដឹង |
| បង់ក្លាដេស | គ្មាន | គ្មាន | អ៊ីស្រាអែល | មាន | មាន | រ៉ូម៉ានី | មាន | គ្មាន |
| បែលឡារុស | មាន | មាន | ហ្សាម៉ៃកា | គ្មាន | មាន | រុស្ស៊ី | មាន | មាន |
| បែលហ្ស៊ិច | មាន | គ្មាន | ហ្សកដានី | មិនដឹង | មិនដឹង | រ្វ៉ាន់ដា | មាន | គ្មាន |
| បេនីន | មាន | មាន | កាហ្សាក់ស្ថាន | មាន | មាន | សាវតូម៉េនិងប្រាំងស៊ីប៉េ | មាន | មិនដឹង |
| បូលីវី | មាន | គ្មាន | កេនយ៉ា | មាន | គ្មាន | សេណេហ្គាល់ | គ្មាន | គ្មាន |
| បូស្នី អែហ្ស៊ីហ្គូវីណា | មាន | គ្មាន | កូរ៉េខាងត្បូង | មាន | មាន | សែប៊ី | មាន | គ្មាន |
| ប្រេស៊ីល | មាន | មាន | គុយវ៉ែត | មិនដឹង | មិនដឹង | ស៊ីសឈែល | មាន | មិនដឹង |
| ប្រ៊ុយណេ | គ្មាន | គ្មាន | គៀហ្ស៊ីសស្ថាន | គ្មាន | មាន | សៀរ៉ាលេអូន | មាន | គ្មាន |
| ប៊ុលហ្គារី | មាន | គ្មាន | ឡាទ្វី | មាន | គ្មាន | ស្លូវ៉ាក | មាន | មាន |
| បើគីណា ហ្វាសូ | គ្មាន | គ្មាន | លីបង់ | គ្មាន | មាន | ស្លូវេនី | មាន | មាន |
| ប៊ូរ៉ុងឌី | គ្មាន | គ្មាន | ឡេសូថូ | មាន | មិនដឹង | អាហ្វ្រិចខាងត្បូង | មាន | គ្មាន |
| កម្ពុជា | មាន | គ្មាន | លីបេរីយ៉ា | មាន | មាន | អេស្ប៉ាញ | មាន | មាន |
| កាមេរូន | គ្មាន | គ្មាន | លីប៊ី | មិនដឹង | មិនដឹង | ស្រីលង្កា | មិនដឹង | មាន |
| កាណាដា | មាន | មាន | លីទុយអានី | មាន | គ្មាន | ស៊ុយអែត | គ្មាន | គ្មាន |
| ខេបវើត | មាន | មាន | លុចហ្សំបួរ | មាន | គ្មាន | តាហ្ស៊ីគីស្ថាន | មាន | មាន |
| អាហ្វ្រិចកណ្ដាល | គ្មាន | មិនដឹង | ម៉ាសេដូនី | មាន | គ្មាន | តង់ហ្សានី | គ្មាន | គ្មាន |
| ឈីលី | មាន | មាន | ម៉ាដាហ្គាស្កា | គ្មាន | មិនដឹង | ទីម័រខាងកើត | មាន | មិនដឹង |
| ចិន | គ្មាន | គ្មាន | ម៉ាឡាវី | គ្មាន | គ្មាន | តូហ្គោ | មិនដឹង | មិនដឹង |
| កូឡុំប៊ី | មាន | មាន | ម៉ាឡេស៊ី | គ្មាន | មិនដឹង | ទ្រីនីដាត និង តូបាហ្គោ | គ្មាន | មាន |
| សាធារណរដ្ឋកុងហ្គោ | គ្មាន | គ្មាន | ម៉ាល់ឌីវ | មិនដឹង | មិនដឹង | ទុយនីស៊ី | មិនដឹង | មិនដឹង |
| កូស្តារីកា | មាន | គ្មាន | ម៉ាលី | មាន | មិនដឹង | ទួគី | មាន | គ្មាន |
| ក្រូអាស៊ី | មាន | មិនដឹង | ម៉ាល់តា | គ្មាន | មាន | ទួកមេនីសស្ថាន | មិនដឹង | មិនដឹង |
| គុយបា | គ្មាន | គ្មាន | ម៉ុលដាវ៉ា | មាន | គ្មាន | អ៊ូហ្គាន់ដា | មាន | គ្មាន |
| ស៊ីព្រ | គ្មាន | គ្មាន | ម៉ូរីតានី | មិនដឹង | មិនដឹង | អារ៉ាប់រួមអេមីរ៉ាត | មិនដឹង | មិនដឹង |
| ដាណឺម៉ាក | គ្មាន | គ្មាន | ម៉ូរីទៀស | គ្មាន | មិនដឹង | ចក្រភពអង់គ្លេស | មាន | មាន |
| ហ្ស៊ីប៊ូទី | គ្មាន | គ្មាន | ម៉ិចស៊ិច | មាន | គ្មាន | សហរដ្ឋអាមេរិច | មាន | មាន |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| សាធារណរដ្ឋដូមេនិចកែន | មាន | គ្មាន | ម៉ុងហ្គោលី | មិនដឹង | មិនដឹង | អ៊ុយរុយហ្គាយ | គ្មាន | គ្មាន |
| អេក្វាឌ័រ | គ្មាន | គ្មាន | ម៉ុងតេនេក្រូ | មាន | គ្មាន | អ៊ូសបេគីស្ថាន | មាន | មិនដឹង |
| អេហ្ស៊ីប | មិនដឹង | មាន | ម៉ារ៉ុក | មាន | គ្មាន | វេណេហ្ស៊ុយអេឡា | មាន | គ្មាន |
| អែលសាល់វ៉ាឌ័រ | មាន | គ្មាន | ម៉ូហ្សម្ប៊ិច | មាន | មាន | វៀតណាម | មិនដឹង | មិនដឹង |
| អេត្យូពី | គ្មាន | គ្មាន | ណាមីប៊ី | គ្មាន | មិនដឹង | យេមែន | មាន | មាន |
| ហ្វីជី | គ្មាន | គ្មាន | ហូឡង់ | មាន | គ្មាន | ហ្សមប៊ី | គ្មាន | គ្មាន |
| ហ្វាំងឡង់ | គ្មាន | មាន | នីការ៉ាហ្គ័រ | មាន | គ្មាន | ហ្ស៊ីមបាវេ | មាន | មាន |
| បារាំង | មាន | មាន | នីហ្សេ | មាន | មិនដឹង | | | |
| ហ្គាបុង | គ្មាន | គ្មាន | នីហ្សេរីយ៉ា | មាន | គ្មាន | | | |

*កំណត់សម្គាល់៖ តារាងខាងលើនេះត្រូវបានរៀបចំឡើងដោយ ចាក សានទូស៊្សី ដែលបង្ហាញថាតើ រដ្ឋជាភាគីណាខ្លះនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយបានដាក់ចេញនូវបទប្បញ្ញត្តិស្តីពីការតម្រូវឲ្យមានការបង្ហាញព័ត៌មានហិរញ្ញវត្ថុសម្រាប់គណបក្សនយោបាយ (ក្រឡោនទី១) និង សម្រាប់បេក្ខជន (ក្រឡោនទី២)។ ប្រទេសនីមួយៗត្រូវបានកត់សម្គាល់ថា "មាន" ប្រសិនបើប្រទេសនោះមានការតម្រូវឲ្យមានការបង្ហាញព័ត៌មានសម្រាប់ក្រុមនីមួយៗ។ ចូរកត់សម្គាល់ថា ការតម្រូវទាំងនេះអាចមិនត្រូវបានគេអនុវត្តទេ។ "មិនដឹង" សំដៅទៅលើការខ្វះខាតព័ត៌មាន ឬ ក្នុងករណីខ្លះដែលគណបក្សនយោបាយមិនត្រូវបានគេអនុញ្ញាតឲ្យបង្កើត។*

*ប្រភពសំខាន់ៗ៖ របាយការណ៍តាមប្រទេស ដែលរៀបចំដោយ GRECO (សូមមើលនៅក្នុង www.coe.int/t/dghl/monitoring/greco)។ "ការផ្តល់ហិរញ្ញប្បទានដល់គណបក្សនយោបាយ និង យុទ្ធនាការឃោសនានៅទ្វីបអាមេរិច" របស់ IDEA/OAS និពន្ធដោយហ្គ្រីន័រ ស្ទីវិន និង ហ្សូវ៉ាតូ ដានីញ៉ែល (២០០៥)។*

*គម្រោង ACE ទិន្នន័យជាមូលដ្ឋានរបស់អង្គការអោយខាអន្តរជាតិស្តីពីហិរញ្ញវត្ថុនយោបាយ (សូមមើលនៅក្នុង www.idea.int) ច្បាប់ជាតិ។*

# សទ្ទានុក្រមហិរញ្ញវត្ថុនយោបាយ

## ធនធានរដ្ឋបាល (Administrative Resources)

ពាក្យប្រយោលដែលគេបានប្រើប្រាស់នៅក្នុងប្រទេសមួយចំនួន (ជាពិសេសនៅក្នុងអតីតសហភាពសូវៀត) ដើម្បីពិពណ៌នាអំពីការបំពានទៅលើធនធានរបស់រដ្ឋ។

## សវនកម្ម(Audit)

ការត្រួតពិនិត្យទៅលើរបាយការណ៍ហិរញ្ញវត្ថុ កំណត់ត្រាហិរញ្ញវត្ថុ និងព័ត៌មានធនាគារ របស់អង្គភាពមួយ ដែលបានរៀបចំឡើងដោយភ្នាក់ងារហិរញ្ញវត្ថុរបស់អង្គភាពនោះ សម្រាប់ភាគីដែលមានប្រយោជន៍ពាក់ព័ន្ធដទៃទៀត ក្រៅពីអង្គភាពនោះ និង ជាតឹកតាងដែលគាំទ្រព័ត៌មានដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនោះ។

## ចំណាយលើយុទ្ធនាការឃោសនាបោះឆ្នោត(Campaign Expenditure)

ការចំណាយដែលធ្វើឡើងដោយ ឬ ក្នុងនាមគណបក្សនយោបាយ និង បេក្ខជនដែលបានចុះបញ្ជីត្រឹមត្រូវ ដើម្បីផ្សព្វផ្សាយអំពីគណបក្សនយោបាយ ឬ បេក្ខជននោះនៅក្នុងអំឡុងពេលនៃការបោះឆ្នោត ឬ ដែលទាក់ទងទៅនឹងការបោះឆ្នោតនៅពេលអនាគត ដោយរួមបញ្ចូលទាំងការចំណាយដែលមានគោលបំណងបំផ្លិចបំផ្លាញឱកាសជោគជ័យរបស់គណបក្ស ឬ បេក្ខជនមួយទៀត។

## ហិរញ្ញវត្ថុសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត(Campaign Finance)

សំដៅទៅលើប្រតិបត្តិការហិរញ្ញវត្ថុនានា ដែលជាប់ពាក់ព័ន្ធទៅនឹងយុទ្ធនាការឃោសនាបោះឆ្នោត។ ប្រតិបត្តិការទាំងនោះអាចរួមបញ្ចូលទាំងការឧបត្ថម្ភជាផ្លូវការ ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ឬ ការចំណាយនានា។

## ចំណូលសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត(Campaign Income)

ចំណូលដែលប្រមូលគៀងគរដោយ ឬ ក្នុងនាមគណបក្សនយោបាយ ឬ បេក្ខជនដែលបានចុះបញ្ជី ដើម្បីឧបត្ថម្ភយុទ្ធនាការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ឬ បេក្ខជន។

## ដែនកំណត់លើការចំណាយក្នុងយុទ្ធនាការឃោសនាបោះឆ្នោត(Campaign Spending Limit)

ចំនួនទឹកប្រាក់អតិបរមា ដែលយុទ្ធនាការឃោសនារបស់បេក្ខជនម្នាក់អាចធ្វើការចំណាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត។

## ដែនកំណត់លើចំណាយរបស់បេក្ខជន (Candidate Spending Limit)

ចំនួនទឹកប្រាក់អតិបរមាដែលបេក្ខជនម្នាក់អាចផ្តល់ឲ្យ ឬ ផ្តល់កម្ចីដល់យុទ្ធនាការឃោសនារបស់គេផ្ទាល់។

### ហិរញ្ញប្បទានដែលទាក់ទងនឹងយុទ្ធនាការឃោសនាបោះឆ្នោត(Campaign-related Funding)

ការបែងចែកធនធានដែលទទួលបាន និង ដែលត្រូវបានចំណាយដោយបេក្ខជនឈរឈ្មោះ និង គណបក្សនយោបាយក្នុងអំឡុងពេលបោះឆ្នោត។

### កម្រិតកំណត់អតិបរមា (Ceilling)

កម្រិតកំណត់ខ្ពស់បំផុតទៅលើការចំណាយសម្រាប់យុទ្ធនាការឃោសនា។ ជួនកាលពាក្យនេះសំដៅទៅលើកម្រិតកំណត់ខ្ពស់បំផុតទៅលើអ្វីដែលបុគ្គលម្នាក់ៗ និង គណបក្សនយោបាយអាចធ្វើវិភាគទានបាន។

### ជម្លោះផលប្រយោជន៍ (Conflict of Interest)

ស្ថានភាពមួយដែលបុគ្គលណាម្នាក់មានផលប្រយោជន៍ត្រួតគ្នាដែលជាហេតុធ្វើឲ្យគេមិនអាចបំពេញការងារបានត្រឹមត្រូវ។ ឧទាហរណ៍៖ នៅពេលដែលមន្ត្រីរបស់រដ្ឋាភិបាលទទួលយកវិភាគទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតពីមនុស្សដែលនៅក្នុងផលប្រយោជន៍សេដ្ឋកិច្ចរបស់ខ្លួនទទួលឥទ្ធិពលពីការធ្វើគោលនយោបាយរបស់រដ្ឋាភិបាល។

### ដែនកំណត់ទៅលើការធ្វើវិភាគទាន (Contribution Limit)

ចំនួនទឹកប្រាក់អតិបរមា ដែលបុគ្គលម្នាក់ ឬ គណបក្សនយោបាយមួយ អាចធ្វើវិភាគទានដល់យុទ្ធនាការឃោសនាបោះឆ្នោតរបស់បេក្ខជន ឬ គណបក្សនយោបាយមួយ។

### វិភាគទាន (Contributions)

លុយ ឬ អ្វីផ្សេងទៀត ដែលមានតម្លៃ(ដូចជា បញ្ជីឈ្មោះ និង អាសយដ្ឋានរួមនៃអ្នកទទួលសារ ទូរស័ព្ទ និង ផ្ទាំងប៉ាណូសម្រាប់ផ្សព្វផ្សាយជាដើម) ដែលបានផ្តល់សម្រាប់យុទ្ធនាការឃោសនារបស់បេក្ខជន ឬ គណបក្សនយោ - បាយដោយបុគ្គល ឬ អង្គការណាមួយ។

### អ្នកនយោបាយឈ្នាន់ (Co-opted Politician)

សំដៅទៅលើមន្ត្រីជាប់ឆ្នោតណាម្នាក់ ដែលទទួលជំនួយហិរញ្ញប្បទានយ៉ាងច្រើនសន្ធឹកសន្ធាប់ពីម្ចាស់ជំនួយសម្បូរទ្រព្យធន ដែលជាលទ្ធផល ម្ចាស់ជំនួយទាំងនោះបានប្រើឥទ្ធិពលរបស់ខ្លួនឲ្យមន្ត្រីជាប់ឆ្នោតនោះធ្វើគោលនយោបាយជាក់លាក់ណាមួយទៅតាមបំណងរបស់ពួកគេ។

### ចំណាយពុករលួយ (Cost of Corruption)

ចំនួនទឹកប្រាក់ដែលបាត់បង់ដោយសារការបង្វែ ឬ ការដកហូតដោយមិនត្រឹមត្រូវលើមូលនិធិសាធារណៈ។

## ការបោះឆ្នោតដោយផ្តល់ហិរញ្ញវត្ថុតាមបែបប្រជាធិបតេយ្យ(Democratically Financed Elections)

ប្រព័ន្ធបោះឆ្នោតមួយដែលនៅក្នុងនោះ យុទ្ធនាការរបស់បេក្ខជនត្រូវបានផ្តល់ថវិកាតាមរយៈធនធានដែលបានមកពីប្រជាពលរដ្ឋទាំងមូល តែមិនមែនបានមកពីអភិជនមួយក្រុមតូចទេ។

## ហិរញ្ញប្បទានសាធារណៈផ្ទាល់ (Direct Public Funding)

ថវិកាដែលរដ្ឋាភិបាលបានផ្តល់ទៅឲ្យគណបក្សនយោបាយ ឬ បេក្ខជន នៅក្នុងអំឡុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត ឬ សម្រាប់ឧបត្ថម្ភសកម្មភាពជាបន្តរបស់គណបក្សនយោបាយ។ ជាធម្មតាហិរញ្ញប្បទានបែបនេះមានទម្រង់ជាទឹកប្រាក់ដែលផ្ទេរតាមធនាគារ ជូនកាលទៀតជាសាច់ប្រាក់សុទ្ធ ឬជាមូលប្បទានប័ត្រ។

## ការបង្ហាញព័ត៌មាន (Disclosure)

ការតម្រូវជាដាច់ខាតឲ្យបេក្ខជន និង គណបក្សនយោបាយ ធ្វើរបាយការណ៍អំពីចំនួន និង ប្រភពចំណូលសម្រាប់ធ្វើយុទ្ធនាការឃោសនា ដាក់ជូនអង្គភាពគ្រប់គ្រងការបោះឆ្នោត ស្ថាប័នសវនកម្មរបស់រដ្ឋាភិបាល ឬ ទី - ភ្នាក់ងារអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងការបោះឆ្នោត។ ការបង្ហាញព័ត៌មានប្រកបដោយប្រសិទ្ធភាពអាចកើតមានប្រសិនបើគណនីទាំងនោះត្រូវបានគេធ្វើឡើងយ៉ាងលំអិត និង អាចឲ្យសាធារណជនពិនិត្យមើលបាន។

## ការឧបត្ថម្ភ(Donations)

សូមអានចំនុច *វិភាគទាន (Contributions)* ខាងលើ។

## ទីលានប្រកួតប្រជែងសមាមាត្រ(Equitable Playing Field)

ការប្រកួតប្រជែងក្នុងការបោះឆ្នោត ដែលនៅក្នុងនោះបេក្ខជនដែលចូលរួមប្រកួតប្រជែងមានធនធានដែលសមាមាត្រទៅនឹងលទ្ធភាពរបស់ពួកគេក្នុងការរៃអង្គាសមូលនិធិ និង ទទួលវិភាគទានសម្រាប់ធ្វើយុទ្ធនាការឃោសនាបោះឆ្នោត។

## វិភាគទានក្រៅប្រទេស (External Contribution)

ថវិកាដែលត្រូវបានផ្តល់ជូនយុទ្ធនាការឃោសនារបស់បេក្ខជន ឬ គណបក្សនយោបាយដោយបុគ្គលណាម្នាក់ដែលមានទីលំនៅស្ថិតនៅក្នុងខាងក្រៅប្រទេសដែលកំពុងរៀបចំធ្វើការបោះឆ្នោត។

## ហិរញ្ញប្បទាននយោបាយអប្បរមា(Floor)

ថវិកាអប្បរមា ឬ កញ្ចប់ហិរញ្ញវត្ថុ ឬ ធនធានសាធារណៈដទៃទៀត (ឧទាហរណ៍៖ ប្រព័ន្ធផ្សព្វផ្សាយ ឬ សេវាប្រៃសណីយ៍ដោយមិនគិតថ្លៃ) ដែលគេចាត់ចែងសម្រាប់បេក្ខជនដែលមានសិទ្ធិទទួលធនធានទាំងនោះនៅក្នុងប្រព័ន្ធហិរញ្ញប្បទានសាធារណៈ។

## ប្រតិបត្តិការផ្លូវការ (Formal Transactions)

ការឧបត្ថម្ភ និង ការចំណាយដែលកើតមានក្រោមវិសាលភាពនៃច្បាប់ និង ដែលអាចត្រូវបានបង្កើតចំនួនតាមរយៈការផ្តល់ហិរញ្ញប្បទានសាធារណៈសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោត។

## ការឃោសនាដោយលាក់កំបាំង (Hidden Advertising)

ព័ត៌មានដែលលេចឡើងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងទម្រង់ជារបាយការណ៍ និង ការវិភាគ ប៉ុន្តែតាមការពិតត្រូវបានធ្វើឡើងដើម្បីជួយផ្សព្វផ្សាយលើកតម្កើងបេក្ខជន ឬ គណបក្សណាមួយ ឬ ដើម្បីបង្ខូចមុខមាត់បេក្ខជន ឬ គណបក្សដទៃ។

## ប្រព័ន្ធផ្តល់ហិរញ្ញប្បទានក្នុងទម្រង់ភ្នកាត់ (Hybrid Funding System)

ប្រព័ន្ធមួយនៃការផ្តល់ហិរញ្ញប្បទានដល់ការបោះឆ្នោត និង សកម្មភាពរបស់គណបក្សនយោបាយ ដែលមួយផ្នែកនៃមូលនិធិសម្រាប់ប្រើក្នុងពេលឃោសនាបោះឆ្នោត ដែលត្រូវយកទៅប្រើប្រាស់ដោយបេក្ខជនបានមកពីរដ្ឋាភិ - បាល ហើយដែលធម្មតាបានទទួលក្នុងទម្រង់ជាជំនួយគ្មានសំណង ដែលគេយកទៅផ្គូរផ្គងជាមួយថវិកាឯកជនដែលគណបក្សនយោបាយ ឬ បេក្ខជនរៃអង្គាសបាន។

## វិភាគទានមិនមែនហិរញ្ញវត្ថុ (In-Kind Contribution)

ការផ្តល់វិភាគទានក្នុងទម្រង់ជាទំនិញ សេវា ឬទ្រព្យសម្បត្តិដោយឥតគិតថ្លៃ ឬផ្តល់ឲ្យក្នុងតម្លៃដែលទាបជាងទីផ្សារ។

## ចំណាយឯករាជ្យ (Independent Expenditure)

ការចំណាយថវិកាសម្រាប់ធ្វើការឃោសនា ឬ សកម្មភាពទំនាក់ទំនងដទៃទៀតដែលបញ្ជាក់ពីការគាំទ្រ ឬ កាច់បំបាក់បេក្ខជនណាម្នាក់ ហើយការចំណាយនេះធ្វើឡើងដាច់ដោយឡែកពីបេក្ខជនណាមួយ ឬ គណៈកម្មាធិការទទួលបន្ទុកយុទ្ធនាការឃោសនារបស់បេក្ខជនណាម្នាក់។

## ហិរញ្ញប្បទានសាធារណៈបែបប្រយោល (Indirect Public Funding)

ធនធាននានាដែលមានតម្លៃជាប្រាក់ដែលរដ្ឋបានផ្តល់ឲ្យទៅគណបក្សនយោបាយ ឬ បេក្ខជនសម្រាប់ធ្វើយុទ្ធនាការ ឃោសនាបោះឆ្នោត ឬ សម្រាប់ឧបត្ថម្ភសកម្មភាពរបស់គណបក្សនយោបាយ ដូចជាការផ្តល់មធ្យោបាយដឹកជញ្ជូន ឬ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដោយឥតគិតថ្លៃ។

## វិភាគទានជាលក្ខណៈបុគ្គល (Individual Contribution)

ថវិកាដែលបុគ្គលម្នាក់ៗធ្វើវិភាគទានឲ្យទៅគណៈកម្មាធិការរៀបចំយុទ្ធនាការឃោសនារបស់បេក្ខជន ឬ គណបក្សនយោបាយ (ឬវិភាគទានដែលធ្វើឡើងដោយបុគ្គលច្រើនជាងមួយនាក់ ក្រោមមូលប្បទានប័ត្រទោល១)។

## ប្រតិបត្តិការមិនផ្លូវការ (Informal Transactions)

ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ និង ការចំណាយដែលធ្វើឡើងនៅក្រៅក្របខ័ណ្ឌច្បាប់។ ប្រតិបត្តិការទាំងនោះរាប់តាំងពីការទិញសន្លឹកឆ្នោត ចំណូលឬចំណាយដែលគេមិនកត់ត្រាចូលក្នុងគណនី ការផ្តល់ជំនួយមិនមែនហិរញ្ញវត្ថុដែលធ្វើឡើងដោយសហគ្រាសសាធារណៈ និង ឯកជន រហូតដល់ការបំពានទៅលើធនធានរបស់រដ្ឋ។

## ទីលានប្រកួតប្រជែងដែលមានសមភាព(Level Playing Field)

ការប្រកួតប្រជែងនៅក្នុងការបោះឆ្នោត ដែលនៅក្នុងនោះបេក្ខជនដែលចូលរួមប្រកួតប្រជែងមានធនធានស្មើៗគ្នាក្នុងការធ្វើយុទ្ធនាការឃោសនា។

## ភាពចន្លោះប្រហោង (Loophole)

មធ្យោបាយនៃការគេចវេស ឬ ពង្វាងច្បាប់ ដែលជាធម្មតាកើតមានដោយសារភាពមិនគ្រប់គ្រាន់ ឬភាពស្រពិចស្រពិលនៅក្នុងច្បាប់នោះផ្ទាល់។

## មូលនិធិផ្គូផ្គង (Matching Funds)

ថវិកាសាធារណៈដែលគេផ្តល់ក្នុងចំនួនមួយជាក់លាក់ឲ្យទៅបេក្ខជនដែលទទួលជោគជ័យក្នុងការរៃអង្គាសថវិកាពីប្រភពឯកជនក្នុងចំនួនដែលច្បាប់បានកំណត់ក្នុងវិភាគទានដែលធ្វើឡើងជាលក្ខណៈបុគ្គល នៃទំហំជាក់លាក់មួយ។ ប្រព័ន្ធនេះគេឃើញមានការប្រើប្រាស់យ៉ាងទូលំទូលាយនៅសហរដ្ឋអាមេរិច។

## ការប្រើប្រាស់ធនធានរដ្ឋបាលដោយមិនត្រឹមត្រូវ

ការប្រើប្រាស់អំណាចសាធារណៈ និង ធនធានរបស់រដ្ឋ (រួមមាន អំណាចក្នុងការគាបសង្កត់ ធនធានមនុស្ស ហិរញ្ញវត្ថុ សម្ភារៈ និង ធនធានដទៃផ្សេងទៀត ដោយអ្នកនយោបាយ ឬ គណបក្សនយោបាយផុតអណត្តិដើម្បីពង្រីកឱកាសរបស់ខ្លួនក្នុងការដណ្តើមយកជ័យជម្នះលើការបោះឆ្នោត ដោយបំពានទៅលើវិធានផ្នែកច្បាប់ និង /ឬ បទដ្ឋានដទៃទៀត និង បំពានទៅលើតួនាទីភារកិច្ចក្នុងការគ្រប់គ្រងការប្រើប្រាស់អំណាចសាធារណៈ។

## ការលាងលុយ (Money Laundering)

ការធ្វើវិភាគទានសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតឲ្យទៅមន្ត្រីជាប់ឆ្នោតណាម្នាក់ (ឬគណបក្សនយោបាយណាមួយ) តាមរយៈភាគីទីបីម្នាក់ ឬ ច្រើននាក់ ដែលដើរតួជារនាំងសម្រាប់បិទបាំងប្រភពវិភាគទាន និង ដើម្បីគេចវេសពីដែនកំណត់លើការធ្វើវិភាគទាន។

## លំហូរថវិកា (Money Trail)

លំហូរនៃការផ្តល់មូលនិធិសម្រាប់យុទ្ធនាការឃោសនា និង គណបក្សនយោបាយដែលមានលក្ខណៈទៀងទាត់តាមរយៈប្រព័ន្ធនយោបាយ។ ការតាមដានទៅលើលំហូរថវិកាគឺជាវិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រនានាដែលអ្នកកាសែត និង អង្គភាពអនុវត្តបទបញ្ញាហិរញ្ញវត្ថុនយោបាយប្រើប្រាស់ដើម្បីតាមដានវិភាគទាន និង ចំណាយដែលធ្វើឡើងដោយផ្ទុយច្បាប់។

## ការត្រួតពិនិត្យ

ការអង្កេតជាលក្ខណៈប្រព័ន្ធ និង ដោយឯករាជ្យ និង ការចងក្រងដំណើរការជាក់លាក់ក្នុងអំឡុងពេលមួយ។

## ចំណាយដើម្បីទទួលបានប្រយោជន៍ (Pay to Play)

សំដៅទៅលើភាពអាចិកំបាំងនៃចរិកានៅក្នុងនយោបាយ។ ដើម្បីធានាឲ្យមានលទ្ធភាព និង ឥទ្ធិពលទៅលើមន្ត្រីជាប់ឆ្នោត មនុស្សម្នាក់ឬក្រុមណាមួយត្រូវធ្វើវិភាគទានច្រើនសន្ធឹកសន្ធាប់សម្រាប់ឧបត្ថម្ភដល់យុទ្ធនាការឃោសនារបស់មន្ត្រីទាំងនោះដើម្បីឲ្យពួកគេបានជាប់ឆ្នោតជាថ្មី។

## អត្ថប្រយោជន៍ត្រឡប់ (Payoff)

ការផ្តល់ប្រយោជន៍ជាថ្នូរទៅនឹងការជួយឧបត្ថម្ភដល់យុទ្ធនាការឃោសនា ដែលធ្វើឡើងដោយអ្នកធ្វើវិភាគទានណាម្នាក់ដែលផលប្រយោជន៍ខ្លួនមានការពាក់ព័ន្ធ ជាពិសេសការផ្តល់ប្រយោជន៍ទាំងនោះធ្វើឡើងក្រោមរូបភាពជាការតែងតាំង (ដូចជា ក្នុងមុខតំណែងជារដ្ឋមន្ត្រីណាមួយ) ការមិនបង់ពន្ធ ឧបត្ថម្ភធន ការផ្តល់ការអនុគ្រោះផ្សេងៗ ឬ ការទទួលបានគម្រោងនានារបស់រដ្ឋាភិបាលដោយមិនចាំបាច់ធ្វើការដេញថ្លៃ។

## ធនិកាធិបតេយ្យ (Plutocracy)

ក្រុមអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភដែលមានឥទ្ធិពលលើកិច្ចការនយោបាយ ដោយសារការពឹងផ្អែករបស់មន្ត្រីសាធារណៈទៅលើការធ្វើវិភាគទានរបស់ក្រុមអ្នកមានទ្រព្យទាំងនោះដល់យុទ្ធនាការឃោសនារបស់អ្នកនយោបាយ ឬ ដោយសារក្រុមអ្នកមានទ្រព្យទាំងនោះប្រើប្រាស់លុយរបស់ពួកគេដើម្បីយកដណ្តើមយកមុខតំណែងសាធារណៈដោយខ្លួនពួកគេផ្ទាល់។

## អំពើពុករលួយផ្នែកនយោបាយ

ការរំលោភអំណាចដែលធ្វើឡើងដោយអ្នកដឹកនាំនយោបាយដើម្បីទាញយកផលប្រយោជន៍ឯកជន ឬ ផលប្រយោជន៍សម្រាប់បក្សពួកខ្លួន ឬ ដើម្បីរក្សាអំណាចរបស់ខ្លួន។

## ហិរញ្ញវត្ថុនយោបាយ

ចំណូល និង ចំណាយរបស់បេក្ខជន និង គណបក្សនយោបាយ ដែលមានទម្រង់ជាផ្លូវការ និង មិនផ្លូវការ ជាហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុ។ ប្រតិបត្តិការទាំងនេះអាចកើតមានក្នុងកំឡុងពេលឃោសនា ឬ ក្រៅកំឡុងពេលឃោសនា ឬ អាចមិនជាប់ទាក់ទងដោយផ្ទាល់ជាមួយយុទ្ធនាការឃោសនាទេ។

## បញ្ញត្តិករហិរញ្ញវត្ថុនយោបាយ (Political Finance Regulator)

*(គេអាចហៅម្យ៉ាងទៀតថា អង្គភាពអនុវត្ត ឬ ស្ថាប័នអនុវត្ត )* ជាស្ថាប័ន ឬ ទីភ្នាក់ងាររបស់រដ្ឋដែលមានភារកិច្ចត្រួតពិនិត្យ និង គ្រប់គ្រងលំហូរនៃប្រព័ន្ធហិរញ្ញវត្ថុនយោបាយរបស់ប្រទេសមួយ។ ស្ថាប័ននេះត្រូវធានាថា គណបក្សនយោបាយ គណៈកម្មាធិការ និង បេក្ខជន បានគោរពទៅតាមបទប្បញ្ញត្តិទាក់ទងទៅនឹងដែនកំណត់លើ

ការធ្វើវិភាគទាននិងចំណាយ ការហាមឃាត់ និង ការតម្រូវជាដាច់ខាតឲ្យធ្វើការបង្ហាញព័ត៌មាន ឬ ធ្វើរបាយការណ៍។ ទីភ្នាក់ងារនេះមានភារកិច្ចពង្រឹងការអនុវត្តកាតព្វកិច្ចនានាដែលបានដាក់ចេញដោយបទបញ្ញាហិរញ្ញវត្ថុនយោបាយ។

## ចំណាយរបស់គណបក្សនយោបាយ

នៅក្នុងរបបប្រធានាធិបតីនិយម គេសំដៅទៅលើថវិកា ដែលប្រើប្រាស់ដោយគណបក្សនយោបាយក្នុងនាម បេក្ខជនប្រធានាធិបតី ឬ បេក្ខជនសភានៅក្នុងការបោះឆ្នោតសកល ។ នៅក្នុងរបបសភានិយម គេសំដៅលើថវិកា ដែលប្រើប្រាស់ដោយគណបក្សនយោបាយក្នុងអំឡុងយុទ្ធនាការឃោសនាបោះឆ្នោត។

## ហិរញ្ញវត្ថុរបស់គណបក្សនយោបាយ (Political Party Finance)

ជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ឬ សម្ភារៈមិនមែនសម្រាប់យុទ្ធនាការឃោសនាដែលគេផ្តល់ទៅឲ្យគណបក្ស អង្គការ ឬ សមាគមនយោបាយ និង ចំណាយនានាដែលធ្វើឡើងដោយក្រុមទាំងនេះ។ គណបក្សនយោបាយអាច ទទួលបានហិរញ្ញប្បទានសាធារណៈ ដែលជារឿយៗគឺជាលទ្ធផលនៃការទទួលបានសម្លេងឆ្នោតគាំទ្រក្នុងកម្រិតជា ភាគរយណាមួយ នៅក្នុងការបោះឆ្នោត។

## ប្រព័ន្ធហិរញ្ញប្បទានឯកជន (Private Funding System)

ប្រព័ន្ធនៃការផ្តល់ថវិកាសម្រាប់ការបោះឆ្នោត និង សកម្មភាពរបស់គណបក្សនយោបាយ ដែលភាគច្រើន ចំណូល និង ចំណាយរបស់បេក្ខជន និង គណបក្សនយោបាយបានទទួលមូលនិធិពីប្រភពឯកជន។

## ហិរញ្ញប្បទានសាធារណៈ (Public Financing/funding)

មូលនិធិសម្រាប់យុទ្ធនាការឃោសនា ឬ មូលនិធិសម្រាប់គណបក្សនយោបាយ ដែលឧបត្ថម្ភដោយរដ្ឋាភិ-បាលចំពោះបេក្ខជន ឬ គណបក្សនយោបាយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានមូលនិធិទាំងនោះ។

## តម្លៃតបស្នង (Quid Pro Quo)

ជាពាក្យដែលមានដើមកំណើតពីភាសាឡាតាំង ដែលមានន័យថា "អ្វីមួយជាថ្នូរសម្រាប់អ្វីមួយ"។ ពាក្យនេះ សំដៅទៅលើផលប្រយោជន៍ដែលអ្នកធ្វើវិភាគទានដល់យុទ្ធនាការឃោសនាបោះឆ្នោតបានទទួលពីមន្ត្រីជាប់ឆ្នោត ដោយសារការជួយគាំទ្រផ្នែកហិរញ្ញវត្ថុដ៏ច្រើនក្រាស់ក្រែលរបស់អ្នកធ្វើវិភាគទានទាំងនោះ។ ផលប្រយោជន៍ទាំងនោះ រួមមាន៖ ការមិនបង់ពន្ធ ឧបត្ថម្ភធន ការផ្តល់មុខតំណែង ការផ្តល់ការអនុគ្រោះផ្សេងៗ ឬ ការទទួលបានគម្រោងនានា របស់រដ្ឋាភិបាលដោយមិនចាំបាច់ធ្វើការដេញថ្លៃ។

## មូលនិធិសម្រាប់សកម្មភាពធម្មតារបស់គណបក្សនយោបាយ(Regular Party Funding)

ហិរញ្ញវត្ថុដែលមិនជាប់ពាក់ព័ន្ធនឹងយុទ្ធនាការឃោសនាបោះឆ្នោត រួមមានអំណោយ និង ចំណាយរបស់ គណបក្ស អង្គការ និង សមាគមរបស់គណបក្សនយោបាយ ដែលប្រើប្រាស់ប្រចាំឆ្នាំដើម្បីគាំទ្រការប្រតិបត្តិជាធម្មតា របស់គណបក្សនយោបាយ។

## វិភាគទាន និងចំណាយដែលធ្វើឡើងដោយភាគីទីបី (Third-Party Contributions & Expenditures)

ទំនិញ ឬ សេវាដែលត្រូវបានចំណាយ ឬ ការចំណាយនានាដែលធ្វើឡើងក្នុងនាមបេក្ខជន ឬ គណបក្សនយោបាយ ដោយបុគ្គលណាមួយដែលមិនជាប់ពាក់ព័ន្ធនឹងបេក្ខជន ឬ គណបក្សនយោបាយ។

## នយោបាយដែលទទួលរងការបំផ្លាញ(Tainted Politics)

ប្រព័ន្ធនយោបាយបែបពុករលួយ ដែលទទួលរងឥទ្ធិពលយ៉ាងធ្ងន់ធ្ងរពីសំណាក់លុយកខ្វក់ ឬ លុយដែលបានមកពីអំពើខុសច្បាប់ និង ដែលបានបង្អាក់ដល់ដំណើរការនីតិរដ្ឋ។

## តម្លាភាព (Transparency)

កម្រិតដែលហិរញ្ញវត្ថុ គោលនយោបាយ វិធីសាស្ត្រ និង ការអនុវត្តការងាររបស់ស្ថាប័នណាមួយត្រូវបានផ្សព្វផ្សាយឲ្យបានដឹងលឺដល់សាធារណជន។

## វិសមភាពក្នុងការទទួលបានមុខតំណែង(Unequal Access to Office)

កង្វល់ដែលក្រុមសេដ្ឋកិច្ច -សង្គមមួយចំនួន មានការខ្វះខាតធនធានហិរញ្ញវត្ថុអប្បបរមាដើម្បីដំណើរការយុទ្ធនាការឃោសនា ឬទទួលបានភាពជាតំណាងប្រកបដោយអត្ថន័យ។

## ទីលានប្រកួតប្រជែងគ្មានសមភាព(Uneven Playing Field)

កង្វល់ដែលចំនួនទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់អាចផ្តល់ប្រយោជន៍ដោយមិនយុត្តិធម៌ដល់បេក្ខជន និង /ឬ គណបក្សនយោបាយជាក់លាក់ណាមួយ ដែលជាហេតុធ្វើឲ្យការប្រកួតប្រជែងមានភាពទន់ខ្សោយ។

## ការទិញសន្លឹកឆ្នោត(Vote-buying)

ទម្រង់នៃការប្រព្រឹត្តផ្នែកនយោបាយដោយមិនស្មោះត្រង់ ដើម្បីបង្កើនចំនួនសន្លឹកឆ្នោតដែលបេក្ខជន ឬ គណបក្សនយោបាយទទួលបាននៅក្នុងការបោះឆ្នោតមួយ តាមរយៈការផ្តល់ជាលុយ ឬ អត្ថប្រយោជន៍ផ្សេងៗទៅឲ្យអ្នកបោះឆ្នោតដើម្បីប្តូរយកសន្លឹកឆ្នោត។

## សក្ខីប័ណ្ណ (Vouchers)

ទម្រង់នៃការផ្តល់ជំនួយពីរដ្ឋដែលមិនមែនហិរញ្ញវត្ថុ ដែលបេក្ខជន និង /ឬ គណបក្សនយោបាយបានទទួលលិខិតបញ្ជាក់ដែលផ្តល់ឲ្យពួកគេនូវធនធានមួយចំនួនដែលមានការបញ្ជាក់ច្បាស់សម្រាប់ប្រើប្រាស់ក្នុងយុទ្ធនាការឃោសនា ដូចជា ការប្រើប្រាស់ប្រព័ន្ធប្រៃសណីយ៍ ឬ ម៉ោងផ្សាយដោយឥតគិតថ្លៃជាដើម។

**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ (មាត្រា៧ (៣))៖**

រដ្ឋជាភាគីនីមួយៗក៏ត្រូវពិចារណាផងដែរអំពីវិធានការរដ្ឋបាល និងវិធានការផ្លូវច្បាប់សមស្របមួយចំនួន ដែលស្របទៅនឹងគោលបំណងនៃអនុសញ្ញានេះ និង គោលការជាមូលដ្ឋាននៃច្បាប់ផ្ទៃក្នុងរបស់ខ្លួន ដើម្បីលើកកម្ពស់តម្លាភាពនៅក្នុងការផ្តល់ហិរញ្ញប្បទានដល់បេក្ខជនសម្រាប់មុខតំណែងសាធារណៈដែលកើតចេញពីការបោះឆ្នោត និង នៅក្នុងការផ្តល់ហិរញ្ញប្បទានដល់គណបក្សនយោបាយប្រសិនបើអាចធ្វើទៅបាន។

**United Nations Convention Against Corruption, Article 7(3)**

Each State Party shall also consider taking appropriate legislative and administrative measures, consistent with the objectives of this Convention and in accordance with the fundamental principles of its domestic law, to enhance transparency in the funding of candidatures for elected public office and, where applicable, the funding of political parties.